មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ចិន គីមថុន ភេទប្រុស អាយុ៦៤ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ប្រធានសារទូរលេខនៅរតនគិរី(៨០១)**

**ស្រុកកំណើតនៅភូមិទួលរកា ឃុំពាមស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម**

**រស់នៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០៣:៤៣:២៩និង០២:០២:០៤**

**១២៨ទំព័រ**

ដានីៈ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំពេញ ។

គីមថុនៈ ចង់ឈ្មោះខ្ញុំពេញ?

ដានីៈ បាទ!

គីមថុនៈ រាល់ថ្ងៃខ្ញុំឈ្មោះ ជិន គីមថុន ។

ដានីៈ អ៊ំសព្វថ្ងៃអាយុប៉ុន្មានហើយ?

គីមថុនៈ ខ្ញុំរាល់ថ្ងៃនេះ៦៤ហើយ ឆ្នាំថោះ ។

ដានីៈ អ៊ំស្រុកកំណើតនៅភូមិអី ឃុំអីដែរ?

គីមថុនៈ អត្តសញ្ញាណរបស់ខ្ញុំ ដាក់ក្នុងបញ្ជីជាតិឥឡូវ ខ្ញុំដាក់ភូមិទួលរកា ឃុំពាមស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

ដានីៈ ឪពុកអ៊ំគាត់ឈ្មោះអីដែរ?

គីមថុនៈ ជិន ខេង ស្លាប់ហើយ ។

ដានីៈ គាត់ខូចតាំងពីអង្កាល់?

គីមថុនៈ គាត់ស្លាប់ដូចជាឆ្នាំ គាត់ស្លាប់ដូចមុនសមាហរណកម្ម ខ្ញុំអត់ចាំដែរ ។

ដានីៈ ក្នុងឆ្នាំកៅ?

គីមថុនៈ ខ្ទង់កៅ បែប៩៦-៩៧ ។

ដានីៈ គាត់នៅជាមួយអ៊ំ ឬគាត់នៅស្រុកកំណើត?

គីមថុនៈ អត់ទេ គាត់ស្លាប់នៅទួលរការ ។

ដានីៈ ចុះម្តាយ?

គីមថុនៈ មុំ គាន ។

ដានីៈ សព្វថ្ងៃគាត់នៅ?

គីមចុង: ស្លាប់ដែរ ។

ដានី: ស្លាប់តាំងពីអង្កាល់?

គីមចុង: ស្លាប់មុនពុកខ្ញុំ ដូច៧៥ ឬ៩៥ ឬប៉ុន្មានខ្ញុំអត់ចាំ ក្រោយបោះឆ្នោត៩៣ ។

ដានី: អ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ?

គីមចុង: ខ្ញុំបងប្អូន៦នាក់ ប្រុស៣ ស្រី៣ ។

ដានី: ទី១ឈ្មោះអីទៅ?

គីមចុង: បងគេបង្អស់ឈ្មោះ ជិន សុខ ។

ដានី: គាត់នៅណាដែរ?

គីមចុង: នៅភូមិទួលរការ ។

ដានី: ស្រីឬប្រុសគាត់?

គីមចុង: ប្រុស ។

ដានី: គាត់នៅទួលរការ?

គីមចុង: បាទ!

ដានី: ហើយទី២?

គីមចុង: ឈ្មោះ ជិន យ៉ាន (ស្រី) នៅខ្ពកតាង៉ួន ។

ដានី: ជិន យ៉ាន (ស្រី) នៅភូមិខ្ពកតាង៉ួន?

គីមចុង: បាទ! ទី៣ខ្ញុំ ។

ដានី: ទី៣អ៊ំ?

គីមចុង: បាទ! ទី៤ឈ្មោះ ជិន សាប នៅភូមិទួលរការ ។ ស្រី ។

ដានី: ទី៥?

គីមចុង: ទី៥ ឈ្មោះ ជិន មន្ថា នៅសំរោងនេះ ឧត្តរមានជ័យ (ស្រី) ។

ដានី: ទី៦?

គីមចុង: ទី៦ ជិន សារិន នៅត្រពាំងប្រាសាទហ្នឹងដែរ ។

ដានី: ប្រុស ឬស្រី?

គីមចុង: ប្រុស ធ្វើទាហានចូលនិវត្តន៍ហើយ ។

ដានី: ចំណោមពួកគាត់ទាំងអស់ចូលបំរើក្នុងជួរជួចអ៊ំដែរមានប៉ុន្មាននាក់?

គីមចុង: មានតែខ្ញុំមួយទេ ហើយប្អូនមួយ ជិន សារិន ធ្វើទាហាន ឥឡូវចូលនិវត្តន៍ ។

ដានី: គ្រួសារអ៊ំគាត់ឈ្មោះអីដែរ?

គឹមចុង: ខៀប ភាព ។

ជានី: គាត់អាយុប៉ុន្មានហើយ?

គឹមចុង: គាត់ប្រហែលជាសែសជាង ឆ្នាំ១៩៦៣ ស្រុកកំណើតគាត់នៅខេត្តតាកែវ ។

ជានី: ខេត្តតាកែវ នៅខាងណា?

គឹមចុង: នៅខាងគិរីវង្ស ។

ជានី: នៅភូមិអីដែរខាងគិរីវង្ស?

គឹមចុង: នៅភូមិព្រៃជើង ។

ជានី: ឃុំ?

គឹមចុង: ឃុំគោកព្រេច ។

ជានី: ស្រុកគិរីវង្ស?

គឹមចុង: ស្រុកគិរីវង្ស ។

ជានី: ជិតព្រំដែន!

គឹមចុង: ជិត ។

ជានី: អ៊ំរៀបការជាមួយគាត់តាំងពីអង្កាល់?

គឹមចុង: ខ្ញុំការដូចជាខែ៣ ១៩៧៧ សម័យខ្មែរក្រហម ។

ជានី: ខែ៣ ១៩៧៧ គាត់អាយុទើបតែ១០ឆ្នាំជាងអីចឹង?

គឹមចុង: អត់ទេ ។

ជានី: គាត់កើតឆ្នាំ១៩៦៣ ទើប១៤ឆ្នាំ ។

គឹមចុង: អត់ទេ អាយុគាត់ច្រើនដែរ ។

ជានី: គាត់កើតឆ្នាំអីឆ្នាំខ្មែរយើង?

គឹមចុង: ខ្ញុំអត់ដឹងថាគាត់កើតឆ្នាំអីទេ តែក្នុងបញ្ជីជាតិដែលដាក់រាល់ថ្ងៃ១៩៦៣ ហើយគាត់ចូលតស៊ូដែរហ្នឹងកងទ័ពនារីដែលហ្នឹង ហើយអត់ដឹងប្រវត្តិទេដោយសារម្ដាយគាត់ស្លាប់ ពុកគាត់ស្លាប់ ហើយគាត់ចូលតស៊ូដូចក្មេងកំព្រាអីចឹង ។

បូលី: ប្រហែលជាគាត់កើតហាជាងអីតាមមើល ។ ពីព្រោះបើគាត់កើត៦៣ ។

គឹមចុង: បើគិតគាត់ប្អូនខ្ញុំ១២ឆ្នាំ ។

ជានី: អីចឹងគាត់អាយុ៥២ឥឡូវ ។

គឹមចុង: បាទ!

ជានី: ១២ឆ្នាំ គាត់ឆ្នាំថោះដែរ?

គឹមចុង៖ ប្រហែល តែគាត់ដាក់រាល់ថ្ងៃ គាត់ដាក់១៩៦៣ អត់ច្បាស់លាស់ទេគ្រួសារខ្ញុំនិយាយពីអាយុគាត់ មិនដឹងគាត់ឆ្នាំអី ។

ដានី៖ អ៊ីការឆ្នាំ៧៧?

គឹមចុង៖ ១៩៧៧ ។

ដានី៖ ការនៅណាទៅ?

គឹមចុង៖ នៅរតនគិរី ។

ដានី៖ អ៊ីមានកូនចៅប៉ុន្មាននាក់ដែរ?

គឹមចុង៖ រាល់ថ្ងៃនៅសល់៤ តែកូននេះ៥ ស្លាប់មួយ ស្លាប់នៅស្រុក ទៅរៀន ។

ដានី៖ ទាំងអស់៥ តែស្លាប់មួយ ។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គឹមចុង៖ ស្រីតែ១ទេកូនខ្ញុំ ។

ដានី៖ ទី១ឈ្មោះអីទៅ?

គឹមចុង៖ ខេង ពិសី(ស្រី) ។

ដានី៖ សព្វថ្ងៃគាត់នៅរៀន ឬ?

គឹមចុង៖ ពីមុនគាត់ជាមន្ត្រី ដល់ពេលគាត់ទៅជាប់IBMខាងកសិកម្ម ប្រធានមន្ទីរខេត្តរមានជ័យយកឈ្មោះទៅលក់ ដល់គវ៉ាទៅវាលុបឈ្មោះចោលទៅជាមន្ត្រីអសកម្ម ដល់ក្រោយមកគាត់ធ្វើការអង្គការយូរឆ្នាំដែរ ឥឡូវឈប់សំរាក ត្រឹមខែ៩មកសំរាក មើលកូន ។

ដានី៖ គាត់មានកូនហើយ?

គឹមចុង៖ បាទ! មានកូនមួយ ។

ដានី៖ គាត់នៅក្នុងបន្ទុកជាមួយអ៊ីដែរ?

គឹមចុង៖ អត់ទេ មានគ្រួសារនៅសៀមរាបរាល់ថ្ងៃ ។

ដានី៖ ឥឡូវនៅសៀមរាប?

គឹមចុង៖ ប្ដីធ្វើការដែរ ប្ដីនៅក្រសួងកសិកម្មដែរ តែធ្វើការអង្គការយូរហើយ ។

ដានី៖ ទី២ឈ្មោះអីទៅ?

គឹមចុង៖ ទី២ដែលស្លាប់នៅស្រុកហ្នឹង មិនបាច់ដាក់ទេ ។

ដានី៖ ស្លាប់នៅ?

គឹមចុង៖ នៅទួលរការហ្នឹង ។

ដានី៖ ឆ្នាំណាទៅ?

គឹមចុង៖ ស្លាប់ដូចជា១៩៩៧-៩៨ ។

ដានីៈ ស្រី ឬប្រុស?

គឹមថុង៖ ប្រុស ទៅរៀនទៅពាម ។

បូលីៈ ម៉េចបានស្លាប់?

គឹមថុង៖ មូលហេតុស្លាប់ខ្ញុំសួរក្រោយមក វាដឹកថ្នាំជក្នុវ ទៅនៅផ្ទះបងសុខ បងខ្ញុំហ្នឹង ទៅនៅរៀននៅសាលាពាមហ្នឹង ដល់បងជីដូនមួយវាបាត់លុយចោទថាកូនខ្ញុំយក កូនខ្ញុំនៅជាមួយខ្ញុំមិនដែលយកអីទេ ដល់យកទៅស្តីឲ្យនៅសាលារៀន ស្តីឲ្យ១-២ វាខឹងគេមកវិញ ទិញថ្នាំជក្នុវមកលាយជឹកទៅ ប្រហែលស្មានហ្នឹងខ្ញុំដឹងព័ត៌មាន ហើយខ្ញុំទៅគេដុតអស់ ។ ទៅដល់ដុតនៅតែឆ្អឹងស្តាយកូនដែរ ។

ដានីៈ ទី៣?

គឹមថុង៖ ទី៣ ឈ្មោះ ខេង ម៉ៅ ។

ដានីៈ គាត់ស្រី ប្រុស?

គឹមថុង៖ ប្រុស ។

ដានីៈ សព្វថ្ងៃគាត់នៅណាទៅ?

គឹមថុង៖ និស្សិតឆ្នាំទី៤នៅមហាវិទ្យាល័យអាយធីរៀននៅនីម ។

បូលីៈ សាលាខ្ញុំ ។

គឹមថុង៖ នីមដែរ?

បូលីៈ ខ្ញុំនីមដែរ ។

គឹមថុង៖ រៀនជំនាញអាយធី ។

ដានីៈ ខាងជំនាញអាយធី?

គឹមថុង៖ ឥឡូវវាយកnetwork ។

ដានីៈ សព្វថ្ងៃគាត់នៅភ្នំពេញ?

គឹមថុង៖ បាទ! នៅភ្នំពេញនៅក្រោយក្រសួងការពារជាតិ ផ្ទះជាប់ក្រសួងការពារជាតិ ។

ដានីៈ ផ្ទះអ៊ី?

គឹមថុង៖ អត់ទេ ជួលគេ ។

ដានីៈ ជួលគេនៅខាងក្រោយក្រសួងការពារជាតិ?

គឹមថុង៖ បាទ! ខាងក្រោយក្រសួងការពារជាតិ ។

ដានីៈ ខាងដេអិន?

គឹមថុង៖ ដេអិន នៅខាងក្រោយសណ្ឋាគារA1 ម៉ូតូមិនដែលចាក់សោរកទេ ។

ដានី៖ គាត់ទៅប៉ុន្មានឆ្នាំហើយ?

គឹមចុង៖ ឆ្នាំទី៤ឆ្នាំហ្នឹងហើយ ។

ដានី៖ ៤ឆ្នាំហើយអីចឹង?

គឹមចុង៖ បាទ! ឆ្នាំទី៤ ដល់ពេលសរសេរសារណាហើយ ។

ដានី៖ ចុះទី៤អ៊ី?

គឹមចុង៖ ទី៤ឈ្មោះ ខេង ប៊ុនចិន ។

ដានី៖ ស្រី ឬប្រុស?

គឹមចុង៖ ប្រុស ។

ដានី៖ ហើយសព្វថ្ងៃគាត់រៀន?

គឹមចុង៖ រៀននៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង ឆ្នាំទី៣ហើយ ។

ដានី៖ ទី៣នៅចំការដូង?

គឹមចុង៖ បាទ!

បូលី៖ ជំនាញអីអ៊ី?

គឹមចុង៖ ខាងពេទ្យសត្វ ខាងវិទ្យាសាស្រ្តសត្វ ។

ដានី៖ ស្នាក់នៅជាមួយគ្នា?

គឹមចុង៖ បាទ! នៅជិតហ្នឹងហើយជិះម៉ូតូទៅ បើអាបងជិះពីហ្នឹងទៅនឹមជិត ហើយនេះ១០គីឡូ ទាំងទៅទាំងមក២០គីឡូជាង ។

ដានី៖ ឆ្ងាយដែរ?

គឹមចុង៖ បាទ!

ដានី៖ អ៊ំឧស្សាហ៍ទៅលេងកូនដែរ?

គឹមចុង៖ ខ្ញុំអត់ដែលទៅទេ តែតាមរយៈទូរស័ព្ទ តែខ្ញុំតាមដានរាល់ពេលដែរ ។

ដានី៖ អ៊ំស្រីក៏អត់ដែលទៅលេងដែរ?

គឹមចុង៖ អត់ដែលទៅទេ ទៅម្ដងកាលអានៅចំការដូងគ្រោះថ្នាក់ចរាចរណ៍ឆ្នាំទៅនេះ សន្លប់ប៉ុន្មានថ្ងៃ ឥឡូវចូលរៀនវិញអត់អី ។

ដានី៖ កូនៗអ៊ំឧស្សាហ៍មកលេងស្រុកដែរ?

គឹមចុង៖ មករាល់ពេលបុណ្យ ពេលបុណ្យជាតិឈប់៣-៤ថ្ងៃមកហើយ ហើយឥឡូវហ្នឹងខ្ញុំអត់សូវឲ្យមក មកខាតតែពេល ។

ដានី៖ ចុះកូនពៅទី៥?

គឹមថុង៖ កូនទី៥ ខេង វុទ្ធី ។

ដានី៖ គាត់នៅណាដែលឥឡូវ?

គឹមថុង៖ នៅក្នុងបន្ទុក រៀនក៏អត់រៀនដែរ ដូចជាពិការខួរក្បាល ពីក្មេងឆ្លាតតែចាប់ពីអាយុ១៦ មកដូចជាម៉ឹងមាំងអត់ដឹងអី រាល់ថ្ងៃលេបថ្នាំខ្ញុំយកទៅមើលដុកទ័រនៅ ខ្ញុំមើលច្រើនកន្លែងដែរ ទៅមើលទៅនៅថៃ នៅសុរិន្ទ ទៅស្ពានខួរក្បាលមើលអត់មានអីទេ ទៅស្កេនម៉ាស៊ីនធំនៅសៀមរាបក៏គេថាអត់មានអីដែរ ។ តែយើងជារូបភាពដូចមនុស្សឆ្កួត តែវាដឹងអីទាំងអស់ រាល់ថ្ងៃនៅក្នុងបន្ទុកខ្ញុំហ្នឹង មើលដែរហ្នឹងជាដុំថ្មមួយក្តៅនៅលើផ្ទះខ្ញុំ ដោយសារកូន ។

ដានី៖ ស្រីឬប្រុស?

គឹមថុង៖ ប្រុស ពៅគេ ។

ដានី៖ អាយុប៉ុន្មានហើយ?

គឹមថុង៖ ដែលគេមកម៉ិញវាហ្នឹងហើយ ដែលកាន់ទូរស័ព្ទហើយគេមក ដឹង១លេខទូរស័ព្ទខ្ញុំដឹងទាំងអស់ តែដូចជាមើលយ៉ាប់មើល បើអ្នកដែលអត់ដឹងចូលទៅថាគេឆ្កួតហើយ បើនៅជាមួយវារាល់ថ្ងៃដឹងថាវាដឹង ។ លុយកាក់យកអីចឹងទៅ ឲ្យអីចឹងវាអត់ចាយទេទុកម្តុំ ទុកមួយកន្លែង ហើយដឹងថាបាត់ ស្គាល់លុយ៥០០៛ ពេលខ្លះក៏ស្គាល់៥០០០៛ ពេលខ្លះមិនដឹងលុយ២ម៉ឺនខ្មែរយើង គេថាលុយថៃ ។

ដានី៖ ហ្នឹងឯកឯងឬមានខបន្ទុវហេតុអីកើតឡើងចំពោះគាត់?

គឹមថុង៖ អត់មានឈឺអីសោះ ថាក្តៅសន្ធំអីអត់ទេ វាទៅអីចឹង ឥឡូវខ្ញុំយកទៅមើលគ្រូខ្មែរ តែលេបថ្នាំឌុកទ័រហ្នឹងគាត់ជំនាញខាងវិកលសាស្ត្រ គេមើលតាមបែបរបស់គេទៅ ហើយមកមើលគ្រូខ្មែរវាមានបែបរបស់គ្រូខ្មែរទៅ ។

ដានី៖ អីចឹងអ៊ំនៅក្នុងបន្ទុកគ្រួសារឥឡូវហ្នឹងមានប៉ុន្មាននាក់?

គឹមថុង៖ តែមួយហ្នឹង កូនមួយ ហើយកូនរៀន២ហ្នឹងជាបន្ទុក ។

ដានី៖ នៅផ្ទះនៅនេះមានតែ៣នាក់ ។

គឹមថុង៖ ៣នាក់ម៉ែ ពីមុនមានចៅមួយ ចិញ្ចឹមចៅកូនធ្វើការយកចៅមកផ្ញើតាំងពី៣ខែ ចិញ្ចឹមទឹកដោះគោ ឥឡូវយកទៅរៀន ដល់អាយុចូលរៀន នៅសៀមរាប ។

ដានី៖ សព្វថ្ងៃអ៊ំរស់នៅក្នុងភូមិ ឃុំ ស្រុកអីដែរ?

គឹមថុង៖ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

ដានី៖ ភូមិត្រពាំងប្រាសាទ ឃុំក៏ត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទទៀត?

គឹម ថុង៖ ត្រពាំងប្រាសាទទាំងអស់ ថែមតែខត្តរមានជ័យ ។

ដានី៖ អ៊ំសព្វថ្ងៃរបរអ៊ំធ្វើអីខ្លះទៅ?

គឹម ថុង៖ ខ្ញុំជាមន្ត្រីនៅសាលាស្រុក ខ្ញុំជានាយករដ្ឋបាល ហើយក្រៅពីហ្នឹងខ្ញុំធ្វើស្រែ ធ្វើចំការរួមផ្សំ បើកាលពីក្រោយពេលសមាហរណកម្មហើយខ្ញុំជាមន្ត្រីសាលាស្រុក កាលហ្នឹងខ្ញុំនៅប្រធានអនុប្រធានរដ្ឋបាលសាលាស្រុកហ្នឹង ហើយកាលហ្នឹងយូនេសេសគេមានគម្រោងគេហៅសិទ្ធិកុមារ គេមកដើរវាស់ ថ្លឹងក្មេង គេមានអាហារូបត្ថម្ភក្មេងខ្លះអី ។ ហើយឆ្នាំ ២០០០ខ្ញុំទៅធ្វើតេស្តគេជ្រើសរើសមន្ត្រីសម្របសម្រួលតាមខេត្ត របស់កម្មវិធីសីលាខ្ញុំជាប់ជាមន្ត្រីសម្របសម្រួលតាមខេត្ត ខ្ញុំធ្វើ២អាណត្តិឃុំ ហើយតួនាទីពេលហ្នឹងខ្ញុំជាអ្នកពង្រឹងសមត្ថភាពឃុំ ។ ទី១ពង្រឹងខាងទាក់ទងនឹងអភិបាលកិច្ចល្អ ទី២ការរៀបចំផែនការព្រោះក្រុមប្រឹក្សាឃុំនៅពេលបោះឆ្នោត ឆ្នាំ២០១២ហ្នឹងគាត់មួយអាណត្តិរបស់គាត់ត្រូវធ្វើផែនការ៥ឆ្នាំរបស់គាត់ ។ ចាប់ផ្តើមភ្ជាម៣រំកិលផែនការវិនិយោគ ក្រោយមករាជរដ្ឋាភិបាលគាត់កែ រំកិលមួយៗ ១ឆ្នាំម្តង ខ្ញុំធ្វើ២អាណត្តិ អាណត្តិទី១ និងទី២ ។ ខែ៦ ២០០៩ ខ្ញុំឈប់លាចេញពីមុខដំណែងហ្នឹងមក ខ្ញុំមកទទួលជានាយករដ្ឋបាលក្រោយពេលសមាហរណកម្ម ផ្ទេរសិទ្ធិរបស់មន្ត្រីរាជការចូលទៅក្នុងរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលថ្មី ក្រោយការបោះឆ្នោតក្រុមប្រឹក្សាស្រុក ។ ឥឡូវខ្ញុំនៅជានាយករដ្ឋបាលរហូត ហើយរវល់ដែរ ។

ដានី៖ ហើយអ៊ំស្រីគាត់ធ្វើអីដែរ?

គឹម ថុង៖ នៅផ្ទះ ។

ដានី៖ ស្រែចំការអ៊ំម៉េចដែរ? យើងធ្វើមួយឆ្នាំៗផល ហើយធ្វើអីខ្លះ?

គឹម ថុង៖ ស្រែខ្ញុំធ្វើសំរាប់ហូប ខ្ញុំអត់មានធ្វើលក់ បាន២តោនទុកហូបទៅ អត់ដែលលក់ស្រូវទេ និយាយរួមខ្ញុំនៅពឹងផ្អែកលើប្រាក់ខែទាំងស្រុង ចិញ្ចឹមកូនរៀននៅមហាវិទ្យាល័យ ហើយមានគោ ខ្ញុំមានគោដែរ ចិញ្ចឹមគោក៏ពេលកូនត្រូវការទៅលក់គោ ដូចជារាល់ថ្ងៃកូនខ្ញុំ២នាក់មានម៉ូតូជិះគ្រប់គ្នា កុំព្យូទ័រមានគ្រប់គ្នា ធូន់ដែរសំរាប់ជីវភាព ឃើញលុយតែភ្លេតក្រោយពីខ្ញុំឈប់ជាអ្នកសម្របសម្រួលតាមខេត្ត ខ្ញុំទៅស៊ីឈ្នួលគេ កាន់គណនេយ្យប្រេងកន្លែងការាស់ទល់មុខវត្តធំមូល ការាស់សូគីមេច គេឲ្យមួយខែ១០០ គ្រាន់តែធ្វើបញ្ជីឲ្យគេទេ បូកសរុបប្រេងចូល និងប្រេងចេញ ទូទាត់លុយឲ្យគេ គេឲ្យ១០០ ហ្នឹងហើយសំរាប់ប្រាក់ខែកូនខ្ញុំ ថ្លៃរៀន ចាយវាយហើយរួមផ្សំកិច្ចការមួយចំនួនទៀត ហើយខ្ញុំរកបាន ។

ដានី៖ អ៊ំយល់ឃើញយ៉ាងម៉េចដែរ ទាក់ទងនឹងការអប់រំ ការសិក្សា ឃើញអ៊ំដូចជាលះបង់ធំមែនទែន ទាក់ទងរឿងកូនចំណាយ អ៊ំយល់ឃើញយ៉ាងម៉េច?

គីមថុង៖ ការសិក្សាទាក់ទងនឹងធនធានមនុស្ស ព្រោះខ្ញុំកើតមក ខ្ញុំបានជាប់ឥទ្ធិពលក្នុងការសិក្សាជំនាន់សម្តេច ខ្ញុំរៀនដល់ថ្នាក់ទី៣ពីសង្គមចាស់ ហើយខ្ញុំស្រឡាញ់ណាស់ ។ ក្រោយមកយើងមានសង្គ្រាម សង្គ្រាមទៅធនធានមនុស្សបាត់ បាត់ស្ទើរទាំងស្រុង បញ្ញាជននៅក្នុងស្រុកខ្មែរយើងអស់រលីង ហើយបញ្ញាជនមួយចំនួនដែលគេចផុតពីសង្គ្រាមទៅរស់នៅបារាំង និយាយរួមប្រទេសខាងលិច អីចឹងបាត់បង់អស់រលីង ។ ហើយជាគំនិតរបស់ខ្ញុំចង់រុញឲ្យកូនមានឧត្តមគតិថា បើសិនមានឱកាស ឱកាសមានច្រើនយ៉ាង ១ឱកាសផ្ទាល់ខ្លួន ១ឱកាសរបស់កូន បើសិនជាឱកាសរបស់កូនរៀនយកបាន រុញ ហើយឱកាសរបស់ក្រុមគ្រួសារខ្ញុំយកបានរុញទៀត អីចឹង២ហ្នឹងជុំគ្នាទៅដើម្បីឈានទៅរក ហើយខ្ញុំមិននឹកស្មានថាកូនខ្ញុំបានរៀនទៅដល់ឧត្តមសិក្សាទេ គិតពីជីវភាពខ្ញុំតាំងពីសង្គ្រាមរហូតដល់ឥឡូវ ។ ខ្ញុំមកដល់ដីបូងនេះខ្ញុំនៅត្រង់នេះ ខ្ទមខ្ញុំ ធ្វើខ្ទម ចុះពីជំរំមក ជំរំចុងក្រោយរបស់តាម៉ុក ។

បូលី៖ ជំរំអីគេអ៊ំ?

គីមថុង៖ ហៅជំរំភូណយ ។ ជំរំភូណយហ្នឹង ពួកខ្ញុំត្រូវពួកតាម៉ុករុញឲ្យឡើង ការពិតខ្ញុំអត់ចង់ទេ ខ្ញុំថាសង្គ្រាមដូចជីស្រុកខ្មែររត់ចង់អស់ហើយ ឥឡូវចប់ហើយ តែដោយសារពួកសន្តិសុខរបស់តាម៉ុក មកបង្ខំឲ្យឡើងភ្នំ អីចឹងខ្លាចស្លាប់ ការពិតសំរាប់តែយើង២នាក់ប្តីប្រពន្ធអត់ខ្លាចទេងាប់ក៏ងាប់ទៅ តែកូន នៅពេលដែលយើងស្លាប់ទៅអ្នកណាជាអ្នករងគ្រោះ កូន ។ នៅពេលដែលអត់ឪពុក អត់ម្តាយ ទី១អត់សាលារៀន អត់បេះទេ ទី២ជីវភាពរស់នៅប្រចាំថ្ងៃ ដល់អីចឹងជីវិតរបស់គាត់នៅក្នុងសង្គមរាល់ថ្ងៃ គាត់ធ្លាក់ចូលហើយ ចូលទៅស្អីផ្សេងៗ ។

ដានី៖ ដូចកូនរបស់អ៊ំទៅរៀនដល់ថ្នាក់ឧត្តម អ៊ំមានបំណងចង់ឲ្យកូនរៀនបន្តទៀត ឬក៏សង្ឃឹមយ៉ាងម៉េចដែលពីកូនមកវិញ?

គីមថុង៖ រាល់ថ្ងៃខ្ញុំអត់ទាន់មានសង្ឃឹម១០០ភាគរយទេ សំរាប់កូនខ្ញុំរៀនចប់ ថាតើអនាគតវាយ៉ាងម៉េច? ប៉ុន្តែខ្ញុំចម្លងដល់កន្លែងវាអាចរកការងារធ្វើបាន នេះជាគោលដៅដែលខ្ញុំបានចម្លងទៅដល់ អីចឹងបានរាល់ឯកសារខ្ញុំទូទាត់លុយខ្ញុំទុកចងក្រងរហូត ហើយខ្ញុំមានសរសេរជាប្រវត្តិផ្ទាល់ខ្លួនខ្ញុំ តិចទៀតខ្ញុំសរសេរពីប្រវត្តិកូន ដែលកូនមកពីរៀនដាក់ក្នុង Flashមួយ ឬខ្ញុំអាចប្រើប្រាស់កុំព្យូទ័របានតិចតួច ហើយខ្ញុំសរសេរទៅ ដល់កូនរៀនចប់

នេះទឹកចិត្តពុកនិងម៉ែ ហើយសំរាប់កូនឯងតទៅមុនទៀត វាជារឿងកូនឯង ។ ឧទាហរណ៍ ឥឡូវកំពុងក្បាច់គុណ ដល់ពេលបានខ្សែក្រវ៉ាត់ហើយឡើងវេញបែកមុខសន្ទប់លើខ្លួនឯង ទេ ។ អីចឹងដូចអូនឯងអីចឹង ពេលហ្នឹងខ្លួនឯងហើយ លែងនៅក្នុងបន្ទុកឪពុកម្តាយហើយ ហើយខ្ញុំឲ្យរៀនរាល់ថ្ងៃខ្ញុំអត់មានប្រាថ្នាឲ្យកូនធ្វើមន្ត្រីអត់ ជាគំនិតរបស់ខ្ញុំ ខ្ញុំប្រាប់ថា គំនិតរបស់ពុកអត់មានចង់ឲ្យកូនអនាគតធ្វើជាអ្នកនេះ អ្នកនោះអីសំរាប់មន្ត្រីអីទេ ប៉ុន្តែ ការជ្រើសរើសផ្លូវដើររបស់កូនឯង នៅពេលដែលកូនឯងរៀនចប់ ដើរទៅ ដើរផ្លូវណា ប៉ុន្តែកុំឲ្យដើរថយក្រោយ ។ ដើរថយក្រោយចង់និយាយថាវាដើរបញ្រាសសង្គម ។

ដានី: អ៊ុំខ្ញុំចង់សុំបកត្រឡប់ក្រោយតិច ទាក់ទងពីប្រវត្តិរបស់អ៊ុំ ដូចថាតាំងពីក្មេង អ៊ុំចាប់ផ្តើម តស៊ូពីឆាកជីវិតយ៉ាងម៉េចខ្លះ ហើយដំបូងខ្ញុំចង់ដឹងពីឈ្មោះអ៊ុំ អ៊ុំមានប្រសាសន៍ថាឈ្មោះ ដើម ជិន គឹមថុង ។

គឹមថុង: ឈ្មោះដើម ឈ្មោះពីកំណើត ។ ជិន សំអាត ខ្ញុំទៅស្រុកគេហៅតែឈ្មោះហ្នឹង ។

ដានី: ហើយដល់ពេលឈ្មោះបដិវត្តន៍មានទៀតដែលអត់?

គឹមថុង: ហ្នឹង ឈ្មោះហ្នឹង ។

ដានី: ជិន សំអាត ។

គឹមថុង: ក្រោយមកខ្ញុំដាក់ ជិន ថុង១ ដល់សម័យអ៊ុនគាក់ខ្ញុំនៅប្រធានគេនៅប៉ៃលិន ខ្ញុំដាក់ ជិន គឹមថុន កាលហ្នឹងមានរឿងរ៉ាវវែងឆ្ងាយ លោកស៊ុន ទៅព្រំដែន ខ្ញុំអត់ឲ្យទៅព្រំដែនកាល កងទ័ពដាច់ចូលមក ។

ដានី: សុំឲ្យអ៊ុំជួយរៀបរាប់ទាក់ទងពីជីវិត ដំណាក់កាលតាំងពីក្មេង អ៊ុំចាប់ផ្តើមចូលរៀនពីឆ្នាំណា

គឹមថុង: ខ្ញុំភ្លេចឆ្នាំ ។

ដានី: អ៊ីដែលអ៊ុំចាំ អ៊ុំអាចរៀបរាប់ ។

គឹមថុង: ខ្ញុំពីដើមខ្ញុំនៅរៀនជាមួយឪពុកមាពីតូច ខ្ញុំនៅកាលហ្នឹងជិតទួលស្វាយព្រៃ ក្បែរទូតចិន ពីដើមគេហៅចំការចិន ខ្ញុំនៅជាមួយឪពុកមា ឪពុកមាដែលខ្ញុំនិយាយថាស្លាប់ក្រោយ ៧៥ គេចេញទៅគាត់ឈឺស្លាប់ ឥឡូវនៅប្អូនជីដូនមួយនៅជិតផ្សារដើមថ្កូវ គេធ្វើប៉ូលីស

ដានី: ឆ្នាំណាដែលអ៊ុំចាប់ផ្តើមចូលរៀន ដែលមកនៅជាមួយឪពុកមានៅទួលស្វាយព្រៃ?

គឹមថុង: ខ្ញុំនៅរៀនជាមួយឪពុកមាដូចជាអាយុ៧-៨ឆ្នាំទេ នៅតូចដែរ ខ្ញុំដូចជាមិនចាំឆ្នាំទេ តែខ្ញុំ ចាំកាលហ្នឹងដូចជាគេធ្វើបុណ្យពាក់កណ្តាលសាសនា នៅមុខវាំង ខ្ញុំចាំព្រឹត្តិការណ៍ធំៗ ដែលខ្ញុំចាំ តែឆ្នាំខ្ញុំអត់ចាំ ។

ដានី: ពាក់កណ្តាលសាសនាបានន័យថាឆ្នាំ២៥០០?

គឹម ថុង៖ បាទ! ហើយនៅហ្នឹងគេចាប់សម សារី, ដាប ឈួន។ សម សារី ក្បាលមនុស្សខ្ទួនឆ្អែទាក់ក គេដើរបិទតាមដើមអំពិលមុំវាំង ហើយដាប ឈួន គេបាញ់ស្លាប់ មិនដឹងបាញ់នៅណាទេ ដល់ក្រោយបានខ្ញុំដឹងថា ខ្ញុំមើលឯកសារប្រវត្តិសាស្ត្រខ្លះ គេបាញ់នៅសៀមរាប ហ្នឹងមួយជំនាន់ហ្នឹង ដូចជាហាជាង ឬក៏ជិតហុក។ ក្រោយមកខ្ញុំឈប់ទៅខ្ញុំមករៀននៅស្រុក មករៀននៅបឋមសិក្សានៅស្រុក។

ដានី៖ ខាងទួលរការ?

គឹម ថុង៖ អត់ទេ រៀននៅខ្ពបតាងួន ក្រោយមកបានខ្ញុំបួស បួសរៀនដល់ថ្នាក់ទី៣ មធ្យមសិក្សារបស់លោក។

ដានី៖ បួសបានប៉ុន្មានវស្សាដែរ?

គឹម ថុង៖ បួសដូច១៩៦៨ខ្ញុំបួស ឆ្នាំរដ្ឋប្រហារលន់ នល់ខ្ញុំសឹក នៅពេលដែលរដ្ឋប្រហារគេទៅលាន់ខ្ញុំអត់ទៅទេ។

ដានី៖ បួសនៅវត្តខ្ពបតាងួនហ្នឹងតែម្តង គេហៅវត្តអីទៅ?

គឹម ថុង៖ ខ្ញុំបួសនៅវត្ត គេហៅវត្តទួលស្វាយ វត្តពោធិ៍សារព្រឹក្សគេហ្នឹង។ កាលហ្នឹងខ្ញុំឈប់ទៅព្រោះម្តាយខ្ញុំជាប់សាច់សារលោហិតរបស់លោកតា ហ៊ុន តាំង នៅក្រូចឆ្មារ ហើយគាត់ជិះឡានមកដល់ពាមហ្នឹង ជួបអ៊ំ វ៉ន ខ្ញុំហ្នឹងហើយខ្ញុំចេញពីហ្នឹងទៅ គាត់សួរថាកូនពីណាគេ គាត់ប្រាប់។ គាត់ថាឯងពួនៗទៅប្រយ័ត្នគេចាប់ទាហាន ខ្ញុំនៅសំងំអីស្រែជិតអារក្សត្នោត អត់បានធ្វើទាហានទេ ដល់ក្រោយមកមានកងទ័ពរំដោះពួកខោអាវខ្មៅ ពីដើមខ្ញុំខ្លាចដែរ ខ្លាចពួកហ្នឹងឃើញមកចាប់មនុស្សវៃចោលស្រស់ៗដែរ ខ្សែអគ្រឹងមូលៗដាក់ចង្កេះហ្នឹង នៅក្រោយផ្ទះខ្ញុំមាន១-២នាក់ដែរ បន្តិចមក... កាលហ្នឹងពួកយៀកកុង យួនមកហើយមានខ្មែរពួកខាងជើង មកហើយនិយាយខ្មែរ ខ្ញុំចូលទៅសួរនិយាយគេឃោសនាពីរឿងតស៊ូវណ្ណៈបដិវត្តន៍ កាលហ្នឹងនៅឈាមរាវដែរ ហើយត្រូវនឹងខ្ញុំនិយាយសន្ទនាគ្នាលេងមុនថាមានចុះធ្វើត្រី មានកងទ័ពខាងកងទ័ពរបស់ខ្មែរក្រហម ពីដើមគេហៅកងរំដោះមកធ្វើត្រី មានចំណង់ចំណូលចិត្តចូល ដោយសារខ្ញុំអត់ចូលចិត្តជាមួយពួកកាន់អំណាចនៅថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់តំបន់ ហើយកាលហ្នឹងមានតែគណៈតំបន់ហ្នឹងហើយចេះតែសំឡុតចេះតែគំរាមកំហែងប្រជាពលរដ្ឋ ដល់ហើយមានចំណង់ចំណូលចិត្តស្រឡាញ់ពួកកាន់អាវុធគេនិយាយដូចត្រូវ វាសមនឹងយើងដឹង ហើយចង់ចូល។ ចូលទៅពួកស្រុកហ្នឹងតាមខ្ញុំរហូតដល់លើភ្នំ ម៉ោង៨ខ្ញុំដើបឡើងជិះកង់ឡើងលើភ្នំព្រៃសង្កែ ហើយជិះម៉ូតូតាមខ្ញុំគេចចូលព្រៃកោស៊ូ មិនដឹងតាមធ្វើអី មានគំនិតធ្វើអីខ្ញុំមិនដឹង ខ្ញុំមកចូលនៅភូមិ គេហៅភូមិ

ចារក្បែរស្រុកបារាយណ៍ម្តុំកន្ធា កាលហ្នឹងក្រោយចេនឡាទី២ហើយ ប្រតិបត្តិការចេនឡាទី២របស់លន់ នល់ បាក់នៅខេត្តកំពង់ធំហ្នឹងហើយ ពីបារាយណ៍មករហូតភ្នំសន្ទុកហ្នឹង ខ្ញុំចូលនៅទ័ពហ្នឹង ។

ដានី: អ៊ំចូលឆ្នាំណា ដែលចាប់ផ្តើមចូល?

គឹមថុង: ឆ្នាំ៧១ ខែ១០ ថ្ងៃ២៥ ។

ដានី: ចូលហ្នឹងចូលជាមួយខាង?

គឹមថុង: កងហ្នឹងពីដើមហៅកង៣៩ កងហ្នឹងគេហៅកងមជ្ឈិម ។

ដានី: កង៣៩របស់ខាងកងទ័ពរំដោះ?

គឹមថុង: បាទ! អត់មានកងទ័ពភូមិភាគទេ ភូមិភាគតាពក ហើយនិងស៊ីមេភូមិភាគ ខ្ញុំភ្លេចឈ្មោះ ។

ដានី: កុយ ធួន ហៅធុច?

គឹមថុង: នេះ ។

ដានី: ភូមិភាគ៣០៤?

គឹមថុង: បាទ! ភូមិភាគ៣០៤ កុយ ធួន ។ ឥឡូវភ្លេចច្រើន ។

ដានី: អ៊ីចឹងឆ្នាំ៧១?

គឹមថុង: ខ្ញុំចូលហើយ ចូលជាកងទ័ព ។

ដានី: គេហៅកងទ័ព?

គឹមថុង: ទ័ព៣៩ ។

ដានី: កាលហ្នឹងជាវៀតកុង?

គឹមថុង: ភាគខាងដើងដឹកនាំ អង្គភាពហ្នឹងអ្នកដែលមកពីហាណូយ ទើបក្រោយមកបានខ្ញុំដឹង យុវជនដែលក្រោយពីបញ្ចប់សង្គ្រាមឆ្នាំ១៩៥៤ យកទៅជាមួយវៀតណាមទៅរៀននៅហាណូយ ពួកហ្នឹងរៀននៅសូវៀតខ្ញុំអត់ដឹងទេ ។ តែចេះតែលឺតៗគ្នា ដល់ខ្ញុំយកមកមើលឯកសារច្រើន ភ្ជាប់ទៅត្រូវមែន ។

ដានី: កាលហ្នឹងចូលជាមួយកង?

គឹមថុង: ៣៩ហ្នឹង ។

ដានី: ពីណាគេអ្នកដឹកនាំ៣៩ហ្នឹង?

គឹមថុង: ដូចជាមានឈ្មោះរិទ្ធិមួយ កាលហ្នឹងមិនដឹងជាប្រធានក្រុម ប្រធានផ្នែកដែលមកដេកធ្វើត្រីប្រហុក ឆ្អើរត្រីនៅទួលរការហ្នឹង ។ វាថាល្មមចូលហើយមិត្តអើយ គេហៅមិត្តៗ ចូលទៅចូលអង្គភាពខ្ញុំ ហើយនៅតាមតំបន់ពិបាកដែរ កាលហ្នឹងមានការវ៉ៃប្រហារគ្នាវាងអ្នក

តំបន់ហើយនិងកងទ័ព ពីព្រោះកងទ័ពគេមកវាប្លែក ប្លែកត្រង់ប្រជាពលរដ្ឋខ្លាចរញ្ញើតអ្នកកាន់អំណាចនៅតាមភូមិ ។

ដានី: កាលហ្នឹងនៅព្រែកសង្កែគេបង្កើតជាស្រុកមួយដែលឬអត់ទេ?

គឹមចុង: ស្រុកស្អីងត្រង់ តែមានតំបន់មួយ ឈ្មោះពល មេតំបន់ហ្នឹងគាត់គ្រូបង្រៀន ។

ដានី: កាលជំនាន់ហ្នឹងគេហៅតំបន់លេខប៉ុន្មានទៅ?

គឹមចុង: ខ្ញុំអត់ចាំទេ ខ្ញុំចេញពីហ្នឹងដូចបាត់ឈឹង ចេញផុតអត់បានគិតគូរពីអ្នកនៅក្រោយ ខ្ញុំដឹងនៅអគ្គភាពទ័ព កាលហ្នឹងគេឲ្យបើកកាណូតដឹកគ្រាប់ ពីកំពង់ថ្មមកកំពង់ស្ដេច ។

ដានី: អ៊ីកាលហ្នឹងចូលតែម្នាក់ឯងទេ អត់មាន?

គឹមចុង: ទៅពីរនាក់ មានមិត្តភក្តិខ្ញុំម្នាក់ទៀតនៅជាប់ផ្ទះខ្ញុំ ឈ្មោះ អ៊ីម ។

ដានី: ឈ្មោះ អ៊ីម?

គឹមចុង: បាទ! ទៅពីរនាក់ហ្នឹង ឥឡូវស្លាប់ហើយ គាត់ស្លាប់នៅចាប់ព្រាយ ភ្នំប្រសិទ្ធ ។

ដានី: ស្លាប់ពេលវៃចូលភ្នំពេញ!

គឹមចុង: មុន៧៥ ថ្ងៃរំដោះ៧៥ គាត់ស្លាប់ពេលហ្នឹង ។

ដានី: អ៊ីចឹងពេលដែលអ៊ំឡើងភ្នំទៅយ៉ាងម៉េចទៀតទៅ?

គឹមចុង: ខ្ញុំទៅរហូតដល់ភូមិចារ ជិះកង់ទៅរហូតព្រលប់ៗដល់ មានគេជូនទៅ ជិះកង់គេស្គាល់ភូមិចារខ្ញុំអត់ស្គាល់ គេនាំទៅគេដាក់នៅ អ្នកគ្រប់គ្រងឈ្មោះតារុំៗ មកពីភាគខាងជើង គាត់កាន់ភស្តុភាររបស់ភូមិភាគ៣៩ហ្នឹង ។ ទៅដល់គេជដែកក្នាមកពីទន្លេ? មកទន្លេឲ្យបើកកាណូតតាហ្នឹងប្រាប់អ៊ីចឹង ថានៅទន្លេជិនាញហើយកាណូត ។

ដានី: ប៉ុន្មានឆ្នាំទៅបើកកាណូត?

គឹមចុង: ខ្ញុំដូចជាមិនយូរទេ កាលហ្នឹងខ្ញុំដេកនៅវត្តបារាយណ៍បណ្ដែត ដល់លឺសូរគេដាក់ក្បាលខ្មោចនៅហ្នឹង ដើរទៅប្រមូលហើយបន្ទាប់ពីរត់កាណូតហ្នឹងកន្លះខែ ឲ្យខ្ញុំមករត់សំបុត្រពីកំពង់ថ្ម ទៅតាំងក្រសាំង ជិះកង់ទេ ។ រត់សំបុត្រពីអគ្គភាពមួយទៅអគ្គភាពមួយ ហើយនៅតាំងក្រសាំងជាកងទ័ពនៅមុខគេរបស់កងទ័ព៣៩ ខ្ញុំទៅ ។

ដានី: ៣៩ជាវរៈ ឬជាកងពល ឬយ៉ាងម៉េច?

គឹមចុង: មិនមែនជាកងពលទេ ជាវរសេនាធំមួយឯករាជ្យ ដែលគ្រប់គ្រងដោយកម្មាភិបាលមកពីភាគខាងជើង ។

ដានី: ឈ្មោះ?

គឹមចុង: អត់មាន ។

ដានី:	ឈ្មោះ រុំ?

គឹមចុង:	ក្រោមឥទ្ធិពលរបស់ភូមិភាគទេ កាលហ្នឹងមានទ័ពភូមិភាគ មានទ័ពតំបន់ ហើយបានមានកង៣៩ជាអង្គភាពមួយឯករាជ្យ ហៅកងមជ្ឈិម ។

ដានី:	ពេលហ្នឹងអុំរត់សំបុត្រពីកង៣៩ទៅអង្គភាពទាហានក្នាងឯង ឬក៏ទៅ?

គឹមចុង:	ទាហានក្នុងអង្គភាពហ្នឹង ក្នុងអង្គភាព៣៩ មានអនុសេនាធំ អនុសេនាតូច រាយនៅខាងមុខហ្នឹង ។

ដានី:	ពេលហ្នឹងចប់ចេនឡាហើយ?

គឹមចុង:	ចប់ហើយ នៅចេនឡាទី២ ខ្ចាត់ខ្ចាយ នៅកើង នៅត្រឹមភូមិ នៅរាល់ថ្ងៃ ភូមិហ្នឹងហួសបញ្ញាជីទៅ ។

ដានី:	បញ្ញាជីជិតភ្នំសន្ទុក ។

គឹមចុង:	ហួសបញ្ញាជី ហៅកំពង់យុគ ទាហានលន់ នល់ នៅទីតាំងបន្ទាយ ។ ពួកខ្ញុំដាក់ខ្សែត្រៀមនៅហ្នឹង ដល់ក្រោយពីរត់សំបុត្រហើយគេឲ្យឡើងទៅរៀនហាត់ហ៊ើនហ៊ឺន បាញ់យោធាទៅហាត់យោធានៅភូមិស្មោរខាងកើតភូមិខ្វែង ។ ដោយសារការរៀនសូត្ររបស់ខ្ញុំឆ្លាតជាងគេ បាញ់ស៊ីបល្អជាងគេ គេឲ្យកាន់អនុសេនាតូច តាំងពីហ្នឹងមកចេញពីសាលាយើងទៅរៀនសាលាទាហាន ក្រោយមកគេជ្រើសរើសឲ្យកាន់ មានសក្តិដូចទាហានពីដើម

ដានី:	អនុសេនាតូច ឆ្នាំណាអុំ?

គឹមចុង:	ខ្ញុំដូចជាឆ្នាំ៧២ ឬ៧៣ ។ ៧៣ព្រោះកាលហ្នឹងមានការចរចារឈប់បាញ់ រវាងលន់ នល់និងកងយួន រឿងប៉ុណ្ណឹងឈប់បាញ់ ចរចារគ្នាមួយកន្ទាក់ ។

ដានី:	ឈប់ទម្លាក់គ្រាប់បែកឆ្នាំ៧៣?

គឹមចុង:	ឈប់ទម្លាក់គ្រាប់បែក ពេលហ្នឹងអាមេរិកតម្លើងសង្គ្រាម បង្កើនកាំភ្លើងធំឲ្យមកលន់ នល់ជំនាន់ហ្នឹងខ្ញុំនៅ ក្រោយមកខ្ញុំឈប់នៅអង្គភាពកងទ័ពហើយ គេឲ្យខ្ញុំមកកាន់វិទ្យុទាក់ទងតាំងពីហ្នឹងរហូត ។

ដានី:	អីចឹងឆ្នាំ៧៣ ដែលអុំធ្វើជាប្រធានអនុសេនាតូច យើងចេញពីកង៣៩ហ្នឹងហើយ?

គឹមចុង:	អត់ចេញទេ នៅក្នុងហ្នឹងដែរ តែមកទទួលការងារ ។

ដានី:	ខាងវិទ្យុទាក់ទង?

គឹមចុង:	បាទ! វិទ្យុទាក់ទង អត់មានប្រធានក្រុមទេ នៅក្រោមការគ្រប់គ្រងរបស់គេ គេមានប្រធានគេមួយ នៅដូចយុទ្ធជនធម្មតា ។

ដានី:	ហ្នឹងគ្រប់គ្រងក្រោមភូមិភាគ?

គឹមថុង៖ អត់ទេ នៅក្នុងអគ្គភាព៣៩ នៅក្នុងអគ្គភាពកសុភាដែលខ្ញុំថាតាវុំៗ ។

ដានី៖ ហើយយ៉ាងម៉េចទៀតទៅ?

គឹមថុង៖ ចប់ពីហ្នឹងមក កង៣៩ហ្នឹងត្រូវចល័តចេញពីខេត្តកំពង់ធំ ទៅវ៉ៃរំដោះព្រៃគ្រី កាលហ្នឹងប្រហែលក្រោយមកបានខ្ញុំដឹង ការពិតខ្មែរក្រហមចង់បើកព្រៃគ្រីឲ្យបាន ដើម្បីដឹកគ្រាប់ទៅរំដោះភ្នំពេញ ពីព្រោះមានទីតាំងមួយដែលស្ទះ ចេញពីតំបន់រំដោះដូចជាផ្លូវ, ស្គន់ ចេញមកមានចន្លោះហ្នឹងស្ទះព្រៃគ្រីហ្នឹង អីចឹងត្រូវរំដោះព្រៃគ្រី ។

ដានី៖ ឆ្លងទឹកទៅ?

គឹមថុង៖ បាទ! ឆ្លងទឹកកាត់ទៅស្រុកកំពង់ត្រឡាច កាត់ហ្នឹងវាឆាប់ ។ អីចឹងបានទៅនៅកងទ័ព៣៩ ដឹកនាំដោយតាសានៗ ដែលគេចំណាំនៅអន្លង់វែង ប្រហែលជាដឹងហើយតាម៉ុកចាប់ដាក់គុក ។

បូលី៖ សាន!

គឹមថុង៖ សាន នៅស្រុកកំណើតនៅចំបក់ ស្លាប់ហើយ ។

ដានី៖ អ៊ំស្គាល់ឈ្មោះដើមគាត់ទេ?

គឹមថុង៖ យន ជាប់សាច់ឈាមបងប្អូនខ្ញុំដែលហ្នឹង ។

ដានី៖ គេនៅភូមិគេហៅ យន?

គឹមថុង៖ បាទ! យន ។

បូលី៖ "យ" និង "ម" ។

គឹមថុង៖ យ នឹងបងគាត់នៅសំភោ គ្រូបង្រៀន គេហៅអាយមៗ ។

ដានី៖ គាត់មានទៅរៀននៅសាលាដាក់ឈ្មោះ មៀច សារី អីដែលអត់?

គឹមថុង៖ ប្រហែលជាក្រោយមកគាត់ដូរ គាត់រៀននៅក្រចេះ ខ្ញុំអត់ដឹងដែរ ។

ដានី៖ គាត់រៀនជំនាន់ជាមួយគណៈតំបន់ក្រចេះ យី គួន ។

គឹមថុង៖ ហ្នឹងហើយជាមួយ គួន គាត់រៀនៗ ហើយគាត់ទៅបញ្ជាវ៉ៃនៅហ្នឹង នៅព្រៃគ្រី ហើយខ្ញុំកាលហ្នឹង យូរៗទៅគិតរឿងស្លាប់ ព្រោះស្លាប់ច្រើនពេក ខ្ញុំសុំមួយសារហ្នឹង ខ្ញុំថាបងខ្ញុំឈប់វ៉ៃហើយ ខ្ញុំទៅផ្ទះហើយ គាត់ថាអត់ឲ្យទៅទេ នៅជាមួយអញ អត់ដឹងថាជាប់បងប្អូនទេ ដល់ក្រោយមកបានដឹង នៅជាមួយអញ ក៏នៅជាមួយគាត់ទៅ ។

ដានី៖ កាលហ្នឹងគាត់ធ្វើអីគេទៅ?

គឹមថុង៖ មេវរៈៗ ។

ដានី៖ វរសេនាតូចទេ?

គីមថុង: វរសេនាតូច កាលហ្នឹងគ្រាប់បែកអាអេស១១១ ធ្លាក់ខ្លាំងដែរ ។

ដានី: វរៈរបស់គាត់ក្រោមពីណាទៅ?

គីមថុង: ក្រោមគាត់ហ្នឹង នៅក្នុងអង្គភាព៣៩ហ្នឹង តែដឹងបញ្ជាដោយសុន សេន ផ្ទាល់ កងហ្នឹង ។ បានវៃរំដោះព្រៃត្រីហើយបានឲ្យខ្ញុំនៅជាមួយមន្ទីររបស់វរៈហ្នឹង នៅចាំបាញ់អាមារីននៅតួចាឡៃ ក្បាលកំពង់ជិតស្រុកកំពង់លែង ខាងនេះទីរួមខេត្តកំពង់ឆ្នាំង ទៅដេកហ្នឹងកប៉ាល់ដេញបាញ់ចង់ផាប់ហើយ នៅក្នុងកំប្លោកទេខ្ញុំ រួចខ្លួនបានគេរៀបចំដឹកទ័ពមកវៃរំដោះភ្នំពេញ ។

ដានី: ឆ្នាំណាហ្នឹង?

គីមថុង: ខ្ញុំអត់ចាំទេ ដូចជា៧៤ ចុង៧៣ ដើម៧៤ ខែវស្សា ខ្ញុំចាំខែវស្សា ។

ដានី: ៧៤ដែលគេដឹកទ័ពមក គេរៀបជាកងពលហើយនៅ?

គីមថុង: រៀបជាវរៈទេ តែវរៈហ្នឹងមួយទេ ចំរាញ់ចេញរបួស ពិការ នៅច្រើនកងទ័ពប្រហែល ៣០០-៤០០នាក់ទេ ដឹកនាំដោយសាន ហ្នឹង ។ បានទៅ ទៅដល់ភូមិមួយខ្ញុំអត់ចាំទេ ខ្ញុំទៅពុលក្រសាំង ហើយទៅបញ្ចូលជាមួយកងតំបន់នៅភូមិភាគពិសេស ក្រោមការគ្រប់គ្រងរបស់ចេង អន ប្រធានតំបន់នៅហ្នឹង ។

ដានី: តំបន់១៥?

គីមថុង: បាទ! តំបន់១៥ ក្រោយមកខ្ញុំជា បងសាន ហ្នឹងទទួលរួមដូចជាវរសេនាធំ តែគេបែងចែកជាវរៈ ដូចជាអត់ទាន់ទៅជាវរៈទេ នៅជាអនុសេនាធំនៅឡើយទេ ក្រោមបញ្ជារបស់តាឌួង ។ ឌួង ហ្នឹងពួកម៉ាក់សាន នៅភូមិសោមខាងលើក្រចេះ ។

បូលី: កោះទ្រង់?

គីមថុង: បាទ! កោះទ្រង់ គាត់នៅហ្នឹង នៅជាមួយតាឌួង ។ តាឌួង ហ្នឹងខ្ញុំថាគាត់ខុះកម្មាភិបាលខុះមេទ័ព ឲ្យខ្ញុំចេញពីគាត់ទៅកាន់អនុសេនាតូច កងទ័ពផ្ទាល់ ប្រយុទ្ធនៅសមរភូមិ ។ ដល់នៅមួយរយៈទៀត អាងតែស្គាល់ ខ្ញុំថាខ្ញុំឈប់ធ្វើទ័ព ធ្វើមេអី ទៅនៅមន្ទីរ សុំទៅនៅមន្ទី ។ គាត់ថានៅមន្ទីរក៏នៅ កាន់គេអូរហូតទៅ គេអូវិទ្យុទាក់ទងសេ២៥ នៅខ្សែត្រៀម ដល់ក្រោយមកគេរៀបចំកងពល ដោយសារកំលាំងមកពីខាងត្បូងផ្លូវជាតិលេខ ៤ មកពីហ្នឹងមកសន្សំគ្នានៅវៃហ្នឹង វៃប្រតិបត្តិការដេប៉ារូជ័យ ហើយនិងប្រតិបត្តិការបញ្ជាដោយ សុះ ម៉ាត់ ដែលនៅតាមទីបញ្ជាការនៅវត្តពាមសេដ្ឋា តាមផ្លូវជាតិលេខ៥

ដានី: ផ្លូវពីខាងស្ពានសេដ្ឋា ពីភ្នំខត្តុងមកចេញមកយើងមានស្ពាន ។

គឹមចុង: ទៅពេលហ្នឹងខ្ញុំជិះឡានខ្ញុំខស្សាប់ប្រាប់កូន កាលខ្ញុំនាំកូនទៅភ្នំពេញ នេះកន្លែងពុកវេទនា ជិតស្លាប់ ជិតរស់ ។

ដានី: ពេលអ៊ំមានប្រសាសន៍មិញតាសាន ដឹកនាំមួយវរៈទៅ ។

គឹមចុង: ទៅបន្ទីក្នានៅកង១៥ ជាមួយចេង អន ។

ដានី: បន្ទីហ្នឹង កាលគេដឹកនាំទ័ពពីនេះទៅ ពីណាគេអ្នកដឹកនាំទៅ ។

គឹមចុង: សាន ហ្នឹង ។

ដានី: សាន គាត់ដឹកពីនេះទៅ ចុះខាងត្បូងផ្លូវជាតិលេខ៨មក?

គឹមចុង: ត្បូងផ្លូវជាតិលេខ៨ តាសារឿន(០៥) ដែលមកជាមួយកែវ សារឿន មកបន្ទីក្នា ជាមួយហ្នឹង មកស្លាប់ច្រើននៅម្ដុំពាមសេដ្ឋា ដោយសារកាលហ្នឹងហៅប្រតិបត្តិការមេបារូមជ័យ បញ្ជាដោយសត្តិ៥ទេ សុះ ម៉ាត់ ។

ដានី: សុះ ម៉ាត់ អ្នកចំរៀងហ្នឹង?

គឹមចុង: សុះ ម៉ាត់ អ្នកចំរៀងហ្នឹង មេបញ្ជាការនៅហ្នឹង ។

ដានី: នៅកន្លែងពាមសេដ្ឋា?

គឹមចុង: នៅហួសវត្តពាមសេដ្ឋាទៅមានវត្តមួយគេហៅវត្តដងទង់ ។

ដានី: អ៊ីចឹងគាត់ប្រសព្វក្នាបានជាកងពល គេហៅកងពល?

គឹមចុង: កងពលលេខ១៨ ។

ដានី: ប្រធានពីណាគេកាលហ្នឹង?

គឹមចុង: ប្រធានហ្នឹងតាសារឿន (០៥) គាត់អនុ ។

ដានី: តាសាន អនុ?

គឹមចុង: បាទ! ហើយខ្ញុំកាន់ ខ្ញុំនិយាយដូចហួសបន្តិច ដល់គេបញ្ចូលទៅនៅក្នុងកងពលហ្នឹង មានឈ្មោះ១៨ ហើយខ្ញុំនៅកាន់កន្លែងបងវ៉ែន រាល់ថ្ងៃក្រុមប្រឹក្សាស្រុករាល់ថ្ងៃ គាត់ហ្នឹងនៅវរៈ ក្រោយមកគេរៀបចំជាវរសេនាធំហើយ វរសេនាធំមាន គាត់នៅវរៈនៅឡើយ ទេបងវ៉ែនហ្នឹង ហើយបងសាន ហ្នឹងវរសេនាធំហើយ ។

ដានី: ឆ្នាំណាដែលគេបង្កើតចេញជាវរសេនាធំ?

គឹមចុង: ដូចជាមុនរំដោះភ្នំពេញ ៧៥ ប្រហែលជាខែ១-២អីហ្នឹង ។ តែមុននឹងដល់អាហ្នឹងគេហៅបើកសមរភូមិមួយ គេហៅសមរភូមិ កាលហ្នឹងទៅជិតពោធិ៍ចិនតុង ខ្ញុំភ្លេចឈ្មោះសមរភូមិ ៩៩០ មិនដឹងប៉ុន្មានទេខ្ញុំអត់ចាំទេ វ៉ៃម្ដងនៅកៀក នៅម្ដុំឈូកវ៉ា ។

ដានី: វត្តឈូកវ៉ា!

គឹមចុង: ខ្មែរក្រៀមខ្ញុំនៅឈូករ៉ា កាលហ្នឹងតាជុំ ជាតិ គាត់នៅជាវរៈទេ ។

ដានី: តាជុំ ជាតិ?

គឹមចុង: បាទ! គាត់នៅជាវរៈ កាលហ្នឹងកងគាត់ស្លាប់ច្រើនណាស់ជាមួយកងនារី ប្រពន្ធបងសាន យាយរី ស្លាប់ច្រើនណាស់ ត្រូវគ្រាប់បាញ់នៅវាលខាងលិច ។

ដានី: បើតាមអ៊ំចាំពិតប្រាកដទៅកងពល១៨កើតក្នុង?

គឹមចុង: នៅតំបន់១៥ ។

ដានី: តំបន់១៥ ក្នុងឆ្នាំ៧៤ ឬឆ្នាំ៧៥?

គឹមចុង: ៧៥ ។

ដានី: ប្រហែលជាខែប៉ុន្មានទៅ?

គឹមចុង: កាលហ្នឹងក្រោយវៃប្រតិបត្តិការមេបុ៉រួមជ័យហ្នឹងហើយ ដូចជាខែ មិនទាន់បន្សុីគ្នាទេ នៅដាច់ដោយឡែកវៃកាលហ្នឹង នៅមេបុ៉រួមជ័យខាងតារឿន វៃផ្សេង សានហ្នឹងវៃផ្សេង ហើយខ្ញុំគិតថាដូចជាមុនចុង៧៣ ព្រោះ៧៤ ថ្ងៃ១៧ មេសា ខ្មែរក្រហមចូលកាន់ភ្នំពេញ ។

ដានី: ម៉េចបានគេដាក់ឈ្មោះកងពល១៨អីចឹង?

គឹមចុង: ខ្ញុំអត់ដឹងប្រវត្តិហេតុអីបានដាក់១៨ ។

ដានី: កាលហ្នឹងតាសារឿន គាត់ប្រធាន, តាសាន អនុ?

គឹមចុង: បាទ!

ដានី: មានសមាជិកទេ?

គឹមចុង: ដូចកាលហ្នឹងមានតែប្រធាននយោបាយ និងយោធាទេ ហើយច្រើនតែទៅប្រជុំជាមួយបេង អន ។

ដានី: វរសេនាធំមានប៉ុន្មានវរសេនាធំទៅ?

គឹមចុង: កាលហ្នឹងនៅក្នុង១៨មានកង៨២, ១១០ជាកងរបស់ភូមិភាគនិរតីពីដើម តាំងពីជំនាន់ប្រធានគាត់ឈ្មោះតាចេង ១១០ ក្រោយមកបានដាក់២០១០ ។ ហើយមានកងមកពីខាងខ្ញុំ មកពីព្រៃត្រឹមកបញ្ចូលគ្នានៅហ្នឹង ហើយមានកងមួយទៀត៨៣ ជាកងតំបន់មួយដែលរំលែកចេញពីតាអន មកកើតជាវរសេនាធំមួយដែលមាន៣វរៈ ហើយមានយោធាកង១៩មួយមកពីខាងត្បូងភ្នំពេញមក ដឹកនាំដោយតាម៉ន ។

ដានី: ៨២ ចេញមកពីណា?

គីមថុង: ៨២ កងហ្នឹង កងតាសាន ទៅពីខត្តរ ទៅពីព្រៃគ្រី៨២, ដល់មក៨៣កងនៅនឹងតំបន់ បេង អន, ២១០កងរបស់នីរតីពីដើម តាជុំ ជាតិ នៅ២១០ ។

ដានី: ជុំ ជាតិ ឬក៏ជាតិ ជុំ ឈ្មោះគាត់?

គីមថុង: ពីដើមឈ្មោះ ហុង ហោ, ហ៊ន ហុងហោ ក្រោយមកគេដាក់ជាតិ ជុំ ដល់មកសម្តេច ជុំ ជាតិ សមាហរណកម្មហើយ ជុំ ជាតិ ។

ដានី: សមាហរណកម្មហើយ ជុំ ជាតិ វិញ កាលពីមុន ជាតិ ជុំ ទេ?

គីមថុង: ក្រោយមកសម្តេចថាដាក់ ជុំ ជាតិ តែម្តងទៅ មកជុំគ្នាហើយ ជុំ ជាតិ ។

ដានី: កាលហ្នឹងអត់មានកង៨១ទេ?

គីមថុង: ៨១ក្រោយមកទៀត ទៅដល់រតនគិរីបានមាន៨១, ៨២, ៨៣, ៨៤ ។

ដានី: អីចឹងកង៨២ ជាកងអតីតរបស់កងតាសាន ដែលមកពីខាងភូមិភាគខត្តរ?

គីមថុង: ភូមិភាគខត្តរដែលឆ្លងកាត់ព្រៃគ្រីទៅ ។

ដានី: កាលហ្នឹងប្រធានវរៈពីណាគេទៅ?

គីមថុង: ៨២ដូចជា តាឌួង ដែលខ្ញុំថាស្លាប់នៅក្នុងគ្រង់សេគ្រូវគ្រាប់១០៥ ។

ដានី: ឆ្នាំណាទៅ?

គីមថុង: ខែវស្សា កាលហ្នឹងដូច៧៨ នៅជិតគេហៅវត្តនៅត្នោតពង ផ្លូវលេខ២៦ ក្លោចវត្តហ្នឹង ខាងនេះវត្តឈូកឧត្តម ។

ដានី: ដល់ពេលគាត់ស្លាប់ពីណាឡើងជំនួសគាត់?

គីមថុង: ស្លាប់តាឌួង ហើយ ហ្នឹងដូចជាវង្វេងបន្តិចខ្ញុំ ក្រោយពីតាឌួង មិនដឹងពីណា ។ ដូចមាន តាស៊ុង នៅកង១៩ដែលមកពីត្បូង ហើយហ៊ន ឈ្មោះ ហ៊ន ។

ដានី: មានឈ្មោះស៊ុង ឈ្មោះ ហ៊ន!

គីមថុង: បាទ! ប្រហែលជាអូនឯងទៅស្រាវជ្រាវនៅស្រុកត្រពាំងប្រាសាទ ហ្នឹងចេញអាហ្នឹង ព្រោះគេច្រើនអ្នកនៅហ្នឹង នៅទំនប់ដាច់ យកមកជុំគ្នាទៅរៀនបានហើយ ។

ដានី: ១១០ អីចឹងពីណាគេទៅ?

គីមថុង: ១១០ពីដើមតាចេក សួរតាជុំ ដឹងប្រវត្តិកង១១០ ខ្ញុំគិតថាបើសួរគាត់នៅបរិវេណកង ១៨ សួរតាជុំដឹងច្បាស់ ព្រោះគាត់នៅដូចជាម្ចាស់ស្រុកនៅហ្នឹង ។ ម្ចាស់ស្រុកចង់ និយាយថាគាត់វិលនៅតែកៀនៗ ខាងលិចភ្នំប្រសិទ្ធិ កងគាត់ តាជុំ ហើយនិងបងវ៉ែន ដឹងច្បាស់តែម្តងប្រវត្តិកងហ្នឹង ។

ដានី: តាវ៉ែន គាត់នៅក្នុងកង?

គឹមថុង:	នៅក្នុងចង្កោមហ្នឹង ចង្កោមកង១៤ សួរគាត់ដឹងហើយ ។

ដានី:	តែពីដំនាន់ហ្នឹង តាជុំ, តាវ៉ែន គាត់មិនមែនជា គណៈវរសេនាធំទេ?

គឹមថុង:	ក្រោយពីស្លាប់តាឌួន ហើយមានការរៀបចំជាកង៨០១ចេញពី ក្រោយរំដោះ១៧ ទៅមានគេរៀបចំជាខ្សែសង្វាក់ មានវរសេនាធំថែមទៀត ។

ដានី:	ចុះ៨៣?

គឹមថុង:	៨៣កាលហ្នឹងដូចជាក្រោមការគ្រប់គ្រងរបស់ ខ្ញុំដូចជាវ៉ាក់ដែលត្រង់ហ្នឹង ៨៣រៀបចំមក ក្រោយទេ ៨៣ដូចជាបញ្ចូលជាកងតំបន់មកពីក្រចេះមក បន្ថែមមកទៀត មានឈ្មោះ ប្រ៉, តាលើ ។

ដានី:	ចុះតាធិន?

គឹមថុង:	ហ្នឹងកងតាធិន ស្លាប់ហើយតាធិន ។

ដានី:	នៅ៨៣ដែរ?

គឹមថុង:	បាទ! នៅ៨៣ កងជនជាតិ ។

ដានី:	បាទ!

គឹមថុង:	មកមានតាលើ, តាធិន ហើយបានថែមកងតំបន់មកពីក្រចេះ មកចូលក្នុងហ្នឹង ជិតវ៉ៃ រំដោះភ្នំពេញហើយ គេហៅកង១១០ ក្រោមការគ្រប់គ្រងរបស់ កាលហ្នឹងគ្រួសារគាត់ នេះនៅរាល់ថ្ងៃ ។

ដានី:	ពីណាគេ?

គឹមថុង:	ឈ្មោះ ស្លាប់អស់ហើយពួកហ្នឹង ខ្ញុំចាំតែភាព ដឹកនាំកំលាំងមកដែលពីក្រចេះ ។

ដានី:	ភាព?

គឹមថុង:	ភាព ខ្មៅ ។

ដានី:	ភាព ក្រោយមកគាត់នៅកងពល ។

គឹមថុង:	នៅតាំភ្លើងធំជាមួយចិន, ចិនហ្នឹងនៅក្រូចឆ្មារស្រុកកំណើត ភាពហ្នឹងនៅក្រចេះ ។

ដានី:	ភាព ក្រោយមកនៅកងពល៨០០?

គឹមថុង:	(អត់ឆ្លើយ) ។

ដានី:	កែវ សារឿន គាត់នៅធ្វើអី?

គឹមថុង:	កែវ សារឿន នៅក្នុងចង្កោមកងពល ពីមុនគាត់កាន់វរៈ៨១ មកពីនោះមក៨១ហ្នឹង កែវ សារឿន ។

ដានី:	អ៊ីចឹងទិសដៅកងពល១៤ពេលដែលយើងវ៉ៃចូលភ្នំពេញ វ៉ៃនៅម្តុំណាទៅ?

គឹមចុង៖ វ៉ៃបុកចេញពីភ្នំប្រសិទ្ធិ គេហៅភូមិតាំងក្រសាំង បុកឆ្ងាយពីហ្នឹង ។ ភ្នំពេញកងពល ៨០១ ដែលវ៉ៃឆ្ងាយមុនគេ ។

ដានី៖ ភ្នំប្រសិទ្ធិទៅតាំងក្រសាំង?

គឹមចុង៖ តាំងក្រសាំងចេញមកម្តុំរ៉ាសំរោង ហើយមេបញ្ជាការរថក្រោះកាលហ្នឹងខ្ញុំកាន់តេអូខ្ញុំចាំឈ្មោះ យៃ ស៊ុនឌី មេបញ្ជាការរថក្រោះខាងលន់ នល់ ។

ដានី៖ ឈ្មោះអីគេ?

គឹមចុង៖ យៃ ស៊ុនឌី មេបញ្ជារថក្រោះនៅសំរោង ថ្ងៃវ៉ៃឆ្ងាយហ្នឹងស្រែកនៅអូរបែកក្អម លើកទង់ស ។

ដានី៖ អ៊ីកាន់តេអូរបស់កងពល?

គឹមចុង៖ ខ្ញុំកាន់តេអូរបស់កងវរៈ ។

ដានី៖ របស់វរៈណាទៅ?

គឹមចុង៖ វរសេនាធំរបស់តាវ៉ែន ខ្ញុំនៅជាមួយគាត់ ហើយបងសាន នៅជាមួយតារឿន ហ្នឹងហើយ ។ គេដូចជាបំបែកហើយ ខ្ញុំនៅវរៈជាមួយតាវ៉ែន ។

ដានី៖ វរៈលេខប៉ុន្មានហ្នឹង?

គឹមចុង៖ ដូចជា៨២កាលហ្នឹង ។ ៨២ហ្នឹងក្លាយចេញពីអនុសេនាធំមួយ គេហៅអនុសេនាធំ៨២ ខ្ញុំនៅជាមួយបងវ៉ែន ហ្នឹងរហូតដល់ចូលភ្នំពេញ ម៉ោង៦-៧ខ្ញុំទៅដល់ពោធិ៍ចិនតុង ។

ដានី៖ អ៊ីខ្ញុំដូចជាមានការអត់ច្បាស់មួយ ទាក់ទងនឹងកងពល១៨ ហើយនិងកងពលខាងភូមិភាគឧត្តរ ភូមិភាគ៣០៤ ។ ទិសដៅវាដូចជាជាន់គ្នា ឬក៏ច្របូកច្របល់ជាមួយគ្នា ។

គឹមចុង៖ ច្របូកច្របល់យ៉ាងម៉េច?

ដានី៖ ដូចថាកាលហ្នឹងមានកងពលទី១ កងពលទី២ កងពលទី៣ របស់ភូមិភាគឧត្តរ ។ មានកងរបស់តាអឿន, កងពលរបស់សួង, ជិន កាលហ្នឹងគេវ៉ៃពីខាងភ្នំប្រសិទ្ធិមកពាមសេដ្ឋាដែរ

គឹមចុង៖ ខ្ញុំគូរផែនទីឲ្យមើល មានក្រដាស ។ នេះជាផ្លូវជាតិលេខ៥ នេះស្ពានតាម៉ូម នេះភ្នំប្រសិទ្ធិ ពួកហ្នឹងវ៉ៃចេញពីនេះ វ៉ៃតាមផ្លូវជាតិលេខ៥មកចេញអីចឹងនេះស្ពានតាម៉ូម នេះទីតាំងនេះភ្នំប្រសិទ្ធិ ។ ភ្នំប្រសិទ្ធិពួកកងពល១៨ហ្នឹងអ្នកវ៉ៃ ហើយវ៉ៃធ្លាក់ភ្នំប្រសិទ្ធិហើយបានវ៉ៃចេះ មុខព្រួញចេញចេះ ហើយពួកនេះសៀលតាមនេះមករំដោះគីឡូលេខ៦ ម្តុំគីឡូលេខ៦ហើយស្ពឹមួយទៀតគេហៅ ពល់ថ្ងៃមានស្ពានរបស់ ។

បូលី៖ លី យ៉ុងផាត់?

គឹមចុង៖ បាទ! ស្ពានលីយ៉ុងផាត់ ។

ដានី:		ព្រែកព្នៅ?

គីមថុង:		បាទ! ព្រែកព្នៅ ហ្នឹងកងតាអឿនវ៉ៃហ្នឹង ហើយវ៉ៃសសៀលមកអីចឹង នេះជាផ្លូវជាតិលេខ៤ នេះភ្នំពេញ នេះពោធិ៍ចិនតុង កង៨០១វ៉ៃទៅហ្នឹង ហើយកងនេះវ៉ៃបេះស្ពាប ហើយនីរតីវ៉ៃបេះ កងស៊ូ ម៉េត វ៉ៃអមមកតាមផ្លូវជាតិលេខ៤ និងខាងនេះ ហើយកងមួយទៀតវ៉ៃមកចំការដូង វ៉ៃបេះ នេះពោធិ៍ចិនតុង ។ រំដោះពោធិ៍ចិនតុងទាំងអស់បែមុខមកបេះ ។

បូលី:		នេះ៨០១?

គីមថុង:		បាទ!៨០១, ១៤ វ៉ៃភ្នំប្រសិទ្ធិហើយបានបែមុខមកបេះ ទិសដៅពោធិ៍ចិនតុង ។

បូលី:		ភ្នំប្រសិទ្ធិ នេះផ្លូវជាតិលេខ៥, នេះផ្លូវជាតិលេខ៤, នេះភ្នំពេញ ។

គីមថុង:		នេះកងនីរតី ។

ដានី:		នេះរបស់ស៊ូ ម៉េត, កងរបស់តាសឿង ។

គីមថុង:		កងរបស់តាសឿង វ-១, វ-២, វ-៣ កងនីរតីរបស់តាសេង ចាប់ដៃជាប់ជាមួយកងហ្នឹង សេង ហើយតាម៉េត ។

បូលី:		នេះខត្តរអ្នកវ៉ៃមក ។

គីមថុង:		បាទ! ខត្តរឈ្មោះអីទេ អឿន ហើយសួង វ៉ៃមួយជួរហ្នឹង វ៉ៃសរសៀលម្តុំបឹងប្រយ៉ាបក្តួញ មុខព្រួញគាត់ហើយ ។ នេះពួក៨០១ក្រោយពីរំដោះហ្នឹងហើយវ៉ៃបុកសំដៅមកនេះ ហើយគើងនៅជាមួយកងពលលេខ២៨នេះ ។

ដានី:		២៨របស់លន់ នល់?

គីមថុង:		បាទ! ២៨របស់លន់ នល់ គើងគ្នានៅហ្នឹង ។

បូលី:		ម្តុំណានេះអ៊ំ គើង?

គីមថុង:		គើងនៅភូមិអីទេ ខ្ញុំភ្លេចហើយ ឈ្មោះឥន្ទ្រីខ្មៅ ហ្នឹងគើងនៅហ្នឹងហើយវ៉ៃពិសេសកង៨០១វ៉ៃពិសេសរំដោះហ្នឹងហើយ បានបែកបាក់គ្នាហើយវ៉ៃវាងមកកាត់នេះ ពួកហ្នឹងអត់នេះ រត់ចេញមកបេះ មកចូលមកនេះគេហៅវ៉ាសំរោង ជិតចប់ហើយ ។

ដានី:		វ៉ាសំរោង?

គីមថុង:		បាទ!

ដានី:		ហួសពីពោធិ៍ចិនតុងទៅ ។

គីមថុង:		ហួសមកនេះ ។

ដានី:		ហួសមកខាងកំពង់ស្ពឺ?

គឹមចុង: បាទ! ហួសមកខាងកំពង់ស្ពឺ ។

បូលី: ចុះនេះខាងណាវ៉ៃ?

គឹមចុង: ហ្នឹងកងពលតាណាត, តាណាត, តាទាញ ។

បូលី: ៧០៣!

គឹមចុង: តាណាត វ៉ៃពីហ្នឹងមក ហើយតាទាញ កងដែលមកផ្គុំគ្នាជាមួយ១៨ហ្នឹង បំបែកចេញពីតាទាញ ហើយ ។

បូលី: តាទេញ?

ដានី: ស៊ុន ទី ហៅទាញ, តាទាញ, តាសោម?

គឹមចុង: បាទ! ហើយមកចូលហ្នឹង ។

ដានី: អីចឹងគេយកកំលាំងមួយចំនួនចេញពីនេះមកបង្កើតកងពល១៨?

គឹមចុង: មកវ៉ៃនៅម្តុំនេះ វ៉ៃនៅប្រតិបត្តិការមេបារួមជ័យ នេះមិនព្រែកក្តាមមកវ៉ៃនៅហ្នឹង ក្រោយមកបានរំលាយអាហ្នឹងមកចូលនេះ ហ្នឹងប្រតិបត្តិការមេបារួមជ័យវ៉ៃនៅម្តុំពាមសេដ្ឋា នេះព្រែកក្តាម ផ្លូវមកនេះ ។

ដានី: អ៊ឹមានប្រសាសន៍ថានេះមួយកងពលដែរ នេះកងពលមួយទៀត?

គឹមចុង: វរៈ គេហៅវ-១, វ-២ ។ "វ"ហ្នឹងគឺវរៈហើយ របស់តាម៉េត, របស់តាសេង ។

ដានី: តាបិទ អត់ទេ?

គឹមចុង: តាបិទ ដូចនៅខាងលើហើយ ។ មានកងតាបិទ ដូរហ្នឹងតែខ្ញុំអត់ដឹងច្បាស់ ។

ដានី: តារិន?

គឹមចុង: តែខ្ញុំអត់ដឹងច្បាស់ទេប្រវត្តិខាងនេះ ។

ដានី: ចុះខាងបូព៌ាគេវ៉ៃខាងណាវិញ?

គឹមចុង: បាទ?

ដានី: ខាងកងបូព៌ា ខាងចាន់ ចក្រី?

គឹមចុង: បូព៌ានេះ បូព៌ាអរិយក្សត្រ ទល់មុខកងចក្រី តែគេវ៉ៃនេះភ្នំពេញ នេះជ្រោយចង្វា វ៉ៃមួយជិនារជ្រោយចង្វា ម្តុំបាក់ខែង លីតែតាមគេអូ ហ្នឹងចក្រី ។

ដានី: អ៊ឹសរសេរដែនទីមើលទៅស្រួលមើលច្បាស់ ។

គឹមចុង: ពួកនេះវ៉ៃបុកចូលរណ្តៅទៅនេះដែរ ហើយមុខព្រួញដែលវ៉ៃធ្លាយមុនគេនេះ កង៨០១ ហើយមេបញ្ជាការដែលចូលវ៉ៃដល់នេះគឺតាឡូញ ហ្នឹងហើយគឺកងពិសេសរបស់៨០១ កង១៨ ។

ដានី៖ គាឡូញ?

គឹមថុង៖ ឡូញ ។

ដានី៖ ឥឡូវគាត់នៅទេ?

គឹមថុង៖ ស្លាប់ហើយ ។ វៀចូលទៅដល់ពោធិ៍ចិនតុងហ្នឹងមុនគេ គេអូទៅខ្ញុំសួរថាបងឯងដល់ណា ហើយ អញនៅឈរក្រោមគេ២៨ហ្នឹង អាហ្នឹងយន្តហោះរបស់លន់ នល់ ហៅគេ២៨ ។

ដានី៖ ពេលដែលយើងវៀចូលដល់ទីក្រុងភ្នំពេញហើយ យ៉ាងម៉េចទៀតទៅអ៊ី? ពេលដែល យើងចូលទៅដល់ ថ្ងៃ១៧ មេសា ចូលដល់ទីក្រុងភ្នំពេញតែម្តង ឬកងពលចូលមុន ហ្នឹង?

គឹមថុង៖ មុននឹងដល់ភ្នំពេញនៅប្រទូស្តប្រត្រាស់គ្នានៅពោធិ៍ចិនតុង តែប្រហែលជាស្ពានហ្នឹងនីរតី វៀហ៊ុមព័ទ្ធក្រុងកំពង់ស្ពឺ ហើយនេះចេះតែវៀ ហើយកងទ័ពមួយចំនួនចាប់ផ្តើមលើកទង់ស ពួកនេះនៅក្រាញនៅឡើយទេ តែលឺថាកំពង់ស្ពឺលើកទង់ស ម្តុំនេះចាប់ផ្តើមហែរៗ លើក ហើយត្រង់ហ្នឹងខ្ញុំដូចជាអត់ចាំគ្រប់គ្រាន់ទេព័ត៌មាន ខ្ញុំដឹងតែម៉ោងប្រហែល៦ និយាយរួម មើលគ្នាឃើញ ម៉ោងប្រហែល៧គាឡូញ រាយការណ៍ថាគាត់មកដល់ពោធិ៍ចិនតុង ។ មកដល់ពោធិ៍ចិនតុងព្រឹកឡើងមានការលើកទង់សព្រោងព្រាត ។

ដានី៖ កាលហ្នឹងទាំងអស់ហ្នឹងក្រោមបញ្ជាការរបស់ពីណាគេ? គ្រប់កងពលទាំងអស់?

គឹមថុង៖ ប្រហែលជា សុន សេន ។ មិនប្រហែលទេ សុន សេន មកបញ្ជានៅតំបន់១៥ ជាមួយ ចេង អន ។ នៅទីតាំងកន្លែងបញ្ជានៅជាមួយ ចេង អន ហើយកាលហ្នឹងមានឈ្មោះ ដុះៗ កាន់គេអូនៅហ្នឹង ឥឡូវលឺថាស្លាប់ហើយ អ្នកកាន់គេអូជាមួយខ្ញុំ នៅវៀម្តុំទេព ប្រណម្យ ក្រោយមកគេឡើងទៅកាន់គេអូហ្នឹង ឃើញនិយាយពីហ្នឹងមក ។

ដានី៖ វង់ៗសុន សេន ទៀតពីណាទៀតដែរ?

គឹមថុង៖ ខ្ញុំគិតថាប្រហែលទេ សមាជិកគេមានចេង អន នៅក្នុងតំបន់ហ្នឹង តែសុន សេន ជាអ្នក មកបញ្ជានៅហ្នឹងផ្ទាល់តែម្តង ព្រោះពេលខ្លះខ្ញុំលឺគេអូនិយាយ ពិសេសវៀថ្ងៃពួកខ្ញុំកំពុងវៀ នេះ សភាពការណ៍សួរច្រើនជាងគេមកពួកខ្ញុំ សួរមកវរៈបងវ៉ែន ហ្នឹងវៀមុខសញ្ញាចូល ។

ដានី៖ ដល់ពេលយើងវៀរំដោះបានទីក្រុងភ្នំពេញហើយ កងពល១៨ឈរនៅណាទៅ?

គឹមថុង៖ កងពលនៅស្តាត ។

ដានី៖ នៅក្នុងស្តាតហ្នឹងតែម្តង?

គឹមថុង៖ បាទ! កន្លែងបងរឿន, សាន នៅលើស្តាត កន្លែងខ្ញុំដេកជញ្ជាំងមួយគេដាក់រាងស្តាតមាន ប៉ាណូមួយ ហ្នឹងកន្លែងខ្ញុំដាក់ជោអ៊ីដេក ។

ដានី: ពេលចូលបានយើងទៅនៅហ្នឹងតែម្ដង?

គីមថុង: បាទ! មុនដំបូងខ្ញុំអត់ទាន់មកនៅកន្លែងកងពលទេ ខ្ញុំនៅជាមួយបងរ៉ែន មកនៅផ្ទះសាក់សុសាខន ក្រោយបុរីកីឡា ។ ខ្ញុំមកនៅផ្ទះឧត្ដមសេនីយ៍ សាក់ សុសាខន ផ្ទះវីឡាគាត់មួយសំបូរដើមជម្ពូ ខ្ញុំទៅបេះស៊ីតែហ្នឹង ហើយក្មេងៗដើររើ ខ្ញុំថាប្រយ័ត្នវៀយ ប្រយ័ត្នខ្សែភ្លើងឆក់ ។

ដានី: តែកូនកងទ័ពនៅក្នុងស្ដាតហ្នឹង ឬនៅខាងក្រៅ?

គីមថុង: កងទ័ពរាយ កាលហ្នឹងដូចជាកង៨២នៅម្ដុំនេះ កង៨១នៅកន្លែងដីឥដ្ឋរាល់ថ្ងៃ ៨៣នៅម្ដុំសាលាសន្ទរម៉ុក, ៨២នៅម្ដុំផ្សារខាងជើងស្ដាត សព្វថ្ងៃគេហៅផ្សារដេប៉ូ?

ដានី: បាទ!

គីមថុង: នៅមួយជួរហ្នឹង ហើយកងនារីនៅក្នុងស្ដាត កាលហ្នឹងក្រោយរំដោះភ្លាមនិរតីឲ្យនារីមួយវរៈមកចូលជាមួយកងពល១៨ ។

ដានី: នារីពីណាគ្រប់គ្រង?

គីមថុង: មកពីនិរតី ឈ្មោះយាយខាង រាល់ថ្ងៃនៅស្រែកណ្ដាល ប្រធានគេ ប្រពន្ធខ្ញុំនៅកងហ្នឹង ។

ដានី: យាយខា?

គីមថុង: យាយខា ប្រពន្ធតាភាព ឥឡូវនៅស្រែកណ្ដាល កាល៧៩គាត់រត់ចេញមកគេកាប់នៅមោង ។

ដានី: ឈ្មោះយាយខា?

គីមថុង: ហ្នឹងប្រធានវរៈកងនារី ។

ដានី: ឥឡូវគាត់ធ្វើអីដែលយាយខា?

គីមថុង: ឥឡូវនៅប្រជាជានធម្មតា ។

ដានី: នៅភូមិស្រែកណ្ដាល?

គីមថុង: បាទ! ភូមិស្រែកណ្ដាល ហ្នឹងដើមកំណើតកងហ្នឹង កងនារី ។

ដានី: ស្រែកណ្ដាល ឃុំអី?

គីមថុង: ឃុំត្រពាំងប្រាសាទដែរ ។

ដានី: អ៊ំស្នាក់នៅប៉ុន្មានទៅបានគេចាប់ផ្ដើមប្រកាស ប្ដូរឈ្មោះកងពលពី១៨មក៨០១?

គីមថុង: ខ្ញុំនៅរហូតរំដោះខែ៨ ហើយក្រោយមកមន្ទីរខ្ញុំហ្នឹងកន្លែងខ្ញុំឈប់នៅស្ដាតហើយ ០៥ ឲ្យខ្ញុំមកនៅកន្លែងវិហារយ៉េស៊ូ ផ្លូវទៅក្ដួញបឹងប្រយ៉ាប ឥឡូវគេហៅតំបន់ភ្នំពេញថ្មី ចុះពីរោងចក្រតម្បាញនៅខាងនេះបុរី១០០ខ្នង ។

បូលីៈ	មិនមែនកាត់តាមផ្លូវសំរោងអណ្តែតទេ?

គឹមចុងៈ	បាទ! ជិតសំរោងអណ្តែត ខាងកើតសំរោងអណ្តែត ខ្ញុំទៅនៅជាប់វិហារយ៉េស៊ូមួយ ទៅនៅចំការចេក ខ្ញុំទៅមើលថែចេក ។

ដានីៈ	អ៊ីកាលជំនាន់ហ្នឹងអ៊ីមានដែលឃើញវិហារយ៉េស៊ូមួយជិតសាលានីមទេ?

គឹមចុងៈ	អត់ទេ អត់ដែលដឹង ។

ដានីៈ	សាលានីមចេះ ដល់យើងឆ្លងផ្លូវមកមានវិទ្យាល័យពេទ្យ ។

គឹមចុងៈ	សាលាក្រហមរាល់ថ្ងៃ?

ដានីៈ	ជាប់សាលាក្រហមមក មកខាងសាលាក្រុង មកជាប់សាលាក្រុងមានវិហារគ្រិស្តមួយធំ!

គឹមចុងៈ	ខ្ញុំដូចជាមិនចាំអស់ទេ ពីព្រោះខ្ញុំរំដោះភ្នំពេញហើយបានប្រហែល១អាទិត្យ បានគេឲ្យខ្ញុំទៅកាន់វិទ្យុទាក់ទងនៅស្តាត នៅកន្លែងកងពល ។ ទៅខ្ញុំអត់ដែលដើរទេ និយាយរួមអត់ដែលទេ នៅភ្នំពេញគេរាល់គ្នាគេដើររើ ហើយខ្ញុំខោអាវមួយសំពាត ហើយស្រឡាញ់ដែរ ស្រឡាញ់សាក់កាដូរបស់អាមេរិក មីឡូយកមកគេថាឲ្យក្រវ៉ាត់ចោលដាក់តែមួយសំពាតហ្នឹង ហើយមានគេអូមួយ នៅជាមួយ០៥នៅលើស្តាតហ្នឹង ។ មកនៅបានបន្តិចគេចាប់ផ្តើមរៀបចំក្រុងហើយ កាលហ្នឹងមានពាណិជ្ជកម្មក្រុង ពាណិជ្ជកម្មភូមិភាគ ខ្ញុំទៅនៅកន្លែងវិហារយ៉េស៊ូមានដើមស្រល់ មិត្តភក្តិខ្ញុំម្នាក់នៅភ្នំពេញរាល់ថ្ងៃនៅកងទ័ពឥឡូវនាំខ្ញុំទៅមើលកន្លែងនេះបងឯងបាញ់ផ្អែ កន្លែងបងឯងកាប់ចេក ប្រាប់ខ្ញុំ តែសុទ្ធតែផ្ទះថ្មឥឡូវ ខ្ញុំថាខ្ញុំអត់ចាំទេ ពីព្រោះប្រែប្រួលអស់ហើយ ។

ដានីៈ	តែវិហារយ៉េស៊ូកាលជំនាន់ហ្នឹង?

គឹមចុងៈ	តូចទេ ជាសាខា ។

ដានីៈ	យើងទុកជាវិហារ ឬក៏យើងរើចោលយកទៅធ្វើស្រែ?

គឹមចុងៈ	មិនមែនទេ ធ្វើពីឈើ ។ ឥឡូវដើមស្រល់នៅ កាលមិត្តភក្តិខ្ញុំនាំទៅហ្នឹង ដើមស្រល់នៅ ។ ហើយខ្ញុំមកនៅហ្នឹងដែលគេរៀបចំចងក្រងឲ្យទៅជាកងពល៨០១ ខ្ញុំមកនៅកន្លែងយ៉េស៊ូហ្នឹងហើយខ្ញុំទៅភ្នំពេញខ្ញុំបើកឡានពេទ្យ ឡានពេទ្យកាលហ្នឹងគេធ្វើស្រែនៅកន្លែងខ្ទញប្រយ៉ាបហ្នឹង កងទ័ពឈឺដឹកយកមកដាក់ពេទ្យលោកសង្ឃ ។

ដានីៈ	ពេទ្យលោកសង្ឃកាលហ្នឹងគេហៅ“ព”ប៉ុន្មានទៅ?

គឹមចុងៈ	ព-៥ ហើយខ្ញុំដឹកអ្នកជំងឺ ពីដើមមានឡានកាត់សង់កាត់ អាកន្ទុយពិតពីក្រោយដូចឡង់គ្រីស័រយើងឥឡូវតែតូច ខ្ញុំបើកអាហ្នឹង ។

ដានីៈ	ចុះព-១ ពេទ្យនៅណា?

គឹមចុង: ព-១ ខ្ញុំអត់ដឹងទេ ដូចជានៅពេទ្យប្ញស្សីកែវដឹង ព-១ អត់នៅក្រោមការគ្រប់គ្រងរបស់កងពល៨០១ទេ ព-៥ដែលនៅក្រោមការគ្រប់គ្រងរបស់កងពល៨០១ អតីតពីដើមនៅពេទ្យលោកសង្ឃ មានឈ្មោះសិទ្ធី គ្រប់គ្រងនៅហ្នឹងពេទ្យ ។

ដានី: អីចឹងពេទ្យព-៥ នៅក្រោមការគ្រប់គ្រងរបស់កងពល៨០១?

គឹមចុង: បាទ! កងពល៨០១ ក្រោយមកគេដាក់ព-៥ ។

ដានី: ព-២ អត់ដឹងនៅណា?

គឹមចុង: អត់ដឹងទេ ព-១, ព-២ ។

ដានី: ព-៣?

គឹមចុង: អត់ ។

ដានី: ដឹងតែពេទ្យលោកសង្ឃព-៥?

គឹមចុង: បាទ! ពេទ្យលោកសង្ឃព-៥ ។

ដានី: អ៊ំគេបង្កើតជាកងពល៨០១ ដឹងក្នុងខែប៉ុន្មានដែរ?

គឹមចុង: ខ្ញុំមើលឡើងទៅជិះកាណូតពាណិជ្ជកម្មរបស់ភូមិភាគ៤ ដឹកទៅក្រចេះជិះកប៉ាល់ ជិះទៅខែ ១១ ខែវស្សា ។

ដានី: អីចឹងគេបង្កើតកងពលមុនខែ១១?

គឹមចុង: បាទ! មុន ខ្ញុំគិតថាប្រហែលជារៀបចំតាំងពីខែ៨ ខែ៩ រៀបចំបង្កើតកងពល៨០១ហ្នឹង មានវរសេនាធំ៨១, ៨២, ៨៣ ។

ដានី: ចាប់ពីគេរៀបចំកងពល៨០១ហើយ វរសេនាធំ១១០, ២១០ហ្នឹងគេលែងឲ្យមានទៀតហើយ?

គឹមចុង: លែងមានហើយ ចូលក្នុង៨២ ចូលក្នុងវរៈ៨២ ។

ដានី: ៨០១វាមានវរៈ៨១ ។

គឹមចុង: ៨១ ហ្នឹងកែវ សារឿន ។

ដានី: ៨២?

គឹមចុង: ហើយ៨៣ ។

ដានី: ដល់ពេល៨១ កែវ សារឿន!

គឹមចុង: ហើយនិងតាម៉ៅ ។ ម៉ៅ ឥឡូវនៅលិចនេះនៅភូមិភាគ៥ ។

ដានី: ឈ្មោះអីម៉ៅ?

គឹមចុង: អត់ដឹងឈ្មោះអី ។

ដានី៖ សព្វថ្ងៃនៅយុទ្ធភូមិភាគ៥?

គឹមថុង៖ បាទ! នៅមុំមោងនេះ ហើយ៨២ ពីដើមក្រោមការគ្រប់គ្រងរបស់បងរ៉ែន កាលទៅរតនគិរី អ៊ុង រ៉ែន ប្រធានវរសេនាធំ បន្ទាប់មកមាន តាស៊ុង មិនដឹងស្អីស៊ុង។ ហើយ៨៣បងធិន បងឡឹ សុទ្ធតែជនជាតិគ្នាគាត់ ទីតាំងគាត់ទៅបោះនៅអូរដំបូក។ ហើយ៨២នៅតាវ៉ែ្ល រតនគិរី។ ៨១ នៅបរកែវ ហើយទីតាំងកងពលដំបូងបំផុតនៅបាងឡុង តែស្លាប់ឈឺច្រើនពេកមកនៅវ៉ើងសៃ។

ដានី៖ ឆ្នាំណាដែលដូរពីបាងឡុងមកវ៉ើងសៃ?

គឹមថុង៖ ៧៦អីហ្នឹង មុនដំបូងប្រុងទៅនៅលំផាត់ ទីរួមរតនគិរីពីដើមមានដំណាក់ស្ដេច ដល់ផាទឹកលិចច្រើនពេកមកនៅវ៉ើងសៃ ជ្រើសរើសនៅវ៉ើងសៃ។

ដានី៖ កាលហ្នឹងគណៈកងពលមានតែ២នាក់ទេ មានតា០៥ និង០៦?

គឹមថុង៖ ០៦។

ដានី៖ តែពីរនាក់ហ្នឹងទេ?

គឹមថុង៖ ក្រោយមកបងធិន កន្លែងហ្នឹងក្រោយមកគេដកបងសាន ឲ្យទៅនៅ៩២០។

ដានី៖ មណ្ឌលគិរី?

គឹមថុង៖ បាទ! មណ្ឌលគិរី។

ដានី៖ អ៊ឹ០៥, ០៦ ចាប់ឈឺឈ្មោះហៅ០៥, ០៦ តាំងពីពេលណាមក?

គឹមថុង៖ ០៥, ០៦ តាំងពីនៅវ៉ៃរំដោះភ្នំពេញ។

ដានី៖ អីចឹងហៅឈ្មោះគាត់តាំងពីវ៉ៃរំដោះភ្នំពេញមក?

គឹមថុង៖ កាលពិត ច-៥ ហ្នឹងលេខសំងាត់នៅក្នុងសៀវភៅបកប្រែឈ្មោះច-៥, ច-៦ សានហ្នឹងហើយក្រោយមកគេហៅ០៥, ០៦ មិនមែនហៅ“ច”ទេ បើពួកខ្ញុំនិយាយ“ច” តែក្រោយៗមក០៥ៗ ក៏ទំលាប់០៥, ០៦ហ្នឹងទៅ សំលេង នៅក្នុងឈ្មោះសំងាត់ក្នុងតេអូ ច-៥, ច-៦ហ្នឹងហើយ ខ្ញុំចាំ។

បូលី៖ ម៉េចបានជ្រើសរើសយកលេខ០៥, ០៦អ៊ឹ?

គឹមថុង៖ ខ្លួនគាត់ហៅ០៥។

ដានី៖ ខ្លួនគាត់ ខ្លួនឯង គាត់ជ្រើសរើសយកលេខហ្នឹង?

គឹមថុង៖ បាទ! ហៅលេខហ្នឹង០៥។

ដានី៖ អ៊ឹកាលទៅរតនគិរីអ៊ឹនៅតែកាន់តេអូដដែល?

គឹមថុង: បាទ! កាន់តេអូ ខ្ញុំទៅមុនគេ ខ្ញុំទៅជាមួយបងសាន ទៅមុនគេ ។ គាត់ជិះម៉ូតូបងសាន តាមផ្លូវស្រុកយើង ហើយបានគាត់ទៅដល់ឆ្លងនៅសោម គាត់ជិះម៉ូតូ ហើយទៅដល់ក្រចេះក៏គាត់ជិះម៉ូតូដែរ ហើយខ្ញុំមានឥវ៉ាន់ មានឡង់រ៉ូវើមួយដឹកឥវ៉ាន់ កាលហ្នឹងតេអូមាន C៤៦មួយ និងម៉ាស៊ីនកូឡាំងរបស់អាមេរិក ដឹកទៅដល់ខ្ញុំដំកើងនៅភូមិបុស្សីចារ ខ្ញុំទៅមុនគេ ។

ដានី: កាលហ្នឹងគាត់ការនៅតាសាន?

គឹមថុង: ខ្ញុំ?

ដានី: តាសាន គាត់ការនៅ?

គឹមថុង: ការហើយ គាត់ការបានដូចជាមិនបាន២ខែបែកគ្នា កាលហ្នឹងកន្លែងគាត់ការនៅជិតខាងលិចស្តាត ទីបញ្ជាការ កន្លែងផ្ទះគាត់ស្នាក់នៅ ជិតផ្សារដើមគរ ជិតវិទ្យារបស់ឧត្តមសេនីយ៍ លាង ដែង ជាប់គ្នាហ្នឹង ។

ដានី: ពេលបែកភ្នំពេញហើយបានការ?

គឹមថុង: បាទ! បែកភ្នំពេញ ជិតទៅរតនគិរីហើយបានការ ។

ដានី: កាលហ្នឹងប្រពន្ធគាត់ក៏នៅកងពល១៨ដែរ?

គឹមថុង: បាទ! គាត់នៅកងពលកងនារី ។

ដានី: គាត់ប្រធាន?

គឹមថុង: ឈ្មោះយាយខា មុំញនៅក្រោមការគ្រប់គ្រងរបស់យាយវីន ហ្នឹង ។

បូលី: យាយវីន ហ្នឹងមេយាយខា ទៀត?

គឹមថុង: បាទ! មេយាយខា ហើយប្រពន្ធបងធិន បងវ៉ាន់ៗនៅរតនគិរីរាល់ថ្ងៃហ្នឹងក៏នៅក្នុងចង្កោមយាយវីន ហ្នឹង ។ ហើយយាយខា ហ្នឹងមកពីនិរតីដែលខ្ញុំថាមកពីកងគេហៅត-៨ ត-៨ហ្នឹងមកពីតំបន់តាកែវ ។

ដានី: អ៊ីចឹងនារីហ្នឹងជាវរសេនាតូច ឬវរសេនាធំ?

គឹមថុង: វរសេនាតូច ក្រោយមកគេដាក់០៤ ចំណុះឲ្យនេះ៨០១ ។

ដានី: អ៊ីចឹងវរសេនាតូចហ្នឹងវរសេនាតូចឯករាជ្យ?

គឹមថុង: បាទ! វរសេនាតូចឯករាជ្យ មានកាំភ្លើងធំ មានភស្តុភា មានកងនារីហ្នឹង០៤, ០៥ពេទ្យ ហើយ០៦ឡានដឹកជញ្ជូនភស្តុភា ហើយ០៧ហ្នឹងកងគ្រួសារយុទ្ធជនទៅស្នាក់នៅគ្រួសារកម្មាភិបាលគេធ្វើមួយកន្លែងគេហៅ០៧ ហើយ០៣ហ្នឹងកាំភ្លើងធំ ។

ដានី: ហើយអ៊ីពេលដែលទៅដល់ខាងរតនគិរី ទីតាំងអ៊ីនៅណាទៅ?

គឹមថុង: ដីបូងនៅជិតភ្នំស្វាយ ដែលថានៅជិតនេះស្រះយក្សឡោម នេះរតនគិរីមានផ្លូវបែក នៅនេះ នៅកន្លែងបន្ទាយទាហាន ។

ដានី: បន្ទាយរបស់?

គឹមថុង: បន្ទាយរបស់កងទ័ពលន់ នល់ ហើយសុទ្ធតែគ្រាប់ផ្ទុះណែនៗ ។

ដានី: ផ្ទុះច្រើន?

គឹមថុង: របួស ស្លាប់៣-៤នាក់ដែរហ្នឹង ហើយក្រោយមកដាំដំឡូងទាំងអស់ នេះបឹងកន្សែង នេះជារង្វង់មូលមួយ នេះព្រលានយន្តហោះចាស់ នេះស្រះយក្សឡោម នេះផ្លូវទៅបរកែវ នេះកន្លែងទីតាំងកងពល៨០១នៅដីបូង នេះភ្នំស្វាយ នេះបឹងកន្សែង នេះមន្ទីរតំបន់ នេះផ្លូវ ។

ដានី: កាលហ្នឹងនៅរតនគិរីតំបន់ប៉ុន្មាន?

គឹមថុង: ខ្ញុំអត់ដឹងមួយពាន់ប៉ុន្មាន ភ្លេចលេខហើយ ។

ដានី: ពីណាគេប្រធានតំបន់កាលហ្នឹង?

គឹមថុង: អត់ស្គាល់ទេ ខ្ញុំអត់សួរទំនាក់ទំនង ។ នេះភ្នំស្វាយ នេះទីតាំង ក្រោយមកបានមកនៅវើនសៃ នេះបឹងកន្សែង ហើយទ័ពកាំភ្លើងនៅត្រង់នេះ ទ័ពកាំភ្លើងធំដែលខ្ញុំថាហ្នឹង ហើយកងនារីនៅទីនេះ នេះពេទ្យ៣-៥ ។

ដានី: ពេទ្យ៣-៥គ្រាន់ថានៅពេទ្យលោកសង្ឃ?

គឹមថុង: ក្រោយមកចំណុះនៅកងពលហ្នឹង ៣-៥ ។

ដានី: ពេទ្យលោកសង្ឃនៅភ្នំពេញយ៉ាងម៉េចវិញ?

គឹមថុង: នៅដដែល ប៉ុន្តែដកបុគ្គលិក គ្រូពេទ្យមកនៅហ្នឹងដាក់៣-៥ ។

ដានី: ពេលដែលកងពលផ្លាស់មកដល់រតនគិរីហើយ ពេទ្យលោកសង្ឃលែងជា?

គឹមថុង: លែងជារបស់កងពលហើយ មកនៅបុគ្គលិក គ្រូពេទ្យមកហ្នឹង ហើយពេទ្យដែលនៅជំនាញៗមកពីវរៈ៨១, ៨២, ៨៣ ដែលធ្លាប់នៅពេទ្យវរៈ មកនៅពេទ្យហ្នឹង ។

ដានី: អ៊ំពេលហ្នឹងទៅជាអ្នកកាន់តេអូរបស់កងពលតែម្តង?

គឹមថុង: ខ្ញុំនៅកាន់តេអូកងពល ។

ដានី: កងពលក្រុមតេអូហ្នឹងគ្នាច្រើនដែរ?

គឹមថុង: ប្រហែលជាជាង១០នាក់ ។ មានក្រុមទូរលេខ, ក្រុមនិយាយផ្ទាល់ សំរាប់ទាក់ទងទៅតាមវរៈហ្នឹង ទូរលេខក៏ទូរលេខ តាមតេអូក៏តាមតេអូ ។

ដានី: អ៊ំអ្នកគ្រប់គ្រងខាងតេអូហ្នឹង?

គឹមថុង៖ បាទ!

ដានី៖ យើងមានទៅរៀននៅណាដែលអត់?

គឹមថុង៖ អត់ទេ អត់មានរៀនទេ ។

ដានី៖ យើងអនុវត្តន៍ជាក់ស្តែង?

គឹមថុង៖ បាទ! អនុវត្តន៍ជាក់ស្តែង មិនដែលបានទៅរៀនជំនាញទេ ។

ដានី៖ ពេលដែលទៅដល់ខាងរតនគិរីហើយ ពេលហ្នឹងខស្សាហ៍មានប៉ះទង្គិចជាមួយខាងវៀតណាម ឬយ៉ាងម៉េចដែរ?

គឹមថុង៖ ត្រង់ហ្នឹងខ្ញុំអត់ដែលដឹងស៊ីជម្រៅទេ ពីព្រោះមានរបាយការណ៍មកកន្លែងខ្លះស្ងាត់ កន្លែងខ្លះចំហរ ហើយកន្លែងដែលស្ងាត់គឺកន្លែងទូរលេខហ្នឹងឯង ។

ដានី៖ កន្លែងទូរលេខ?

គឹមថុង៖ កន្លែងវៃបក ប៉ុន្តែមានអ្នកបកសារផ្សេង បកសារឥឡូវស្លាប់ហើយឈ្មោះសម្បត្តិ ខ្ញុំអត់ទេ ។

ដានី៖ គេអូរបស់អ៊ីម៉េច? យើងទាក់ទងយ៉ាងម៉េចទៅ?

គឹមថុង៖ ខ្ញុំកាន់កូឡាំង ទាក់ទងទៅសេនាធិការ កន្លែងសុន សេន ។ ទាក់ទងពីសភាពការណ៍កងទ័ពត្រង់ទៅត្រង់មក តែការងារមួយផ្សេងទៀតតាមរយៈទូរលេខ វៃម៉ានីតបកទៅវិញមាន១៥វ៉ាត់កាលហ្នឹង ។

ដានី៖ ហ្នឹងមិនមែនក្រុមខាងគេអូអ្នកធ្វើទេ?

គឹមថុង៖ ក្រុមហ្នឹងដែរ តែមានអ្នកបកសារផ្សេង ។

ដានី៖ ក្រោមការគ្រប់គ្រងរបស់អ៊ី?

គឹមថុង៖ ក្រុមរបស់ខ្ញុំដែរ ។

ដានី៖ អ៊ីចឹងបើមានសភាពការណ៍អីនៅព្រំដែន យើងទូរលេខទៅខាងអគ្គសេនាធិការ?

គឹមថុង៖ បាទ! ទើបតែក្រោយមក កាលហ្នឹងយួនវៃតាមព្រំដែនហើយ វៃនៅតាកែវ វៃនៅក្រចេះ ហើយរតនគិរីដូចជាក្រោយគេ វៃម្តុំអូរយ៉ាដាវ ហើយនិងម្តុំអូរដំបូក ម្តុំភ្នំ ១០២០ កន្លែងច្រមុះស្រួច កន្លែងនេះ វរៈ៨៣នៅម្តុំហ្នឹង ហើយវរៈ៨២នៅមួយជួរនេះ ។

បូលី៖ នេះព្រះវិហារ!

ដានី៖ រតនគិរីនៅកន្ទុយ?

គឹមចុង៖ វារៈ៨១នៅមួយជួរនេះ នេះផ្លូវជាតិលេខ១៩ នេះកន្ទុយនាគគឺ៨៣ ហើយ៨២ព្រំដែនលាវ ។

បូលី៖ នេះ៨៣?

គឹមចុង៖ បាទ! ៨៣នៅមួយជួរនេះ ហើយ៨២មួយជួរនេះ មួយជួរលាវ ផ្លូវទៅលាវ ផ្លូវលេខ៧បុកចេញមកលាវ ហើយ៨១នៅនេះ នេះទីតាំង៨១នៅមួយជួរហ្នឹង ។ ហើយទីបញ្ជាការកងពលនេះ ។

បូលី៖ នេះមណ្ឌលគិរី?

គឹមចុង៖ ខ្ញុំមើលទន្លេសេសាន ។

បូលី៖ នេះវាអត់មានទន្លេ ។

គឹមចុង៖ នេះទន្លេ នៅមួយជួរនេះទីតាំងកងពល ។

បូលី៖ នេះវិញ? នេះព្រំប្រទល់ខេត្ត នេះទន្លេសេសាន នៅខាងណាទន្លេ?

គឹមចុង៖ នៅទល់មុខអូរឡៃ គេហៅអូរឡៃៗ ។

ដានី៖ តាសុន សេន គាត់ខស្សរាប់ចុះទៅដែលអត់ទេ?

គឹមចុង៖ ទៅ ។

ដានី៖ គាត់ទៅដែរ?

គឹមចុង៖ ទៅ កាលហ្នឹងខ្ញុំមកនៅធ្វើការនៅ ភាគច្រើនខ្ញុំអត់សូវនៅកន្លែងទេ ពីព្រោះខ្ញុំគេចាត់ទុកជាមនុស្សម្នាក់ដែលធ្វើការស្អាត ដូចជាខាងជាង គេឲ្យធ្វើជញ្ជាំងសាលារៀន ។ គេចូលចិត្តឲ្យមកព្រៃ អត់សូវខ្លាចព្រៃ ភាគច្រើនអត់សូវនៅកន្លែងទេ ។

ដានី៖ ចុះប្រពន្ធតា០៥គាត់ធ្វើអីវិញ?

គឹមចុង៖ គាត់ជាមនុស្សធម្មតា ។

ដានី៖ គាត់អត់មានគ្រប់គ្រងអីដូចយាយវីន ទេ?

គឹមចុង៖ ក្រោយមកគាត់គ្រប់គ្រងពេទ្យហ្នឹង ពេទ្យ៣-៥ ប៉ុន្តែមិនជាស្នូលទេ គ្រាន់តែនៅក្នុងគណៈគេហ្នឹង ។

ដានី៖ ហើយគាត់ការតាំងពីឆ្នាំណាដែលតា០៥?

គឹមចុង៖ គាត់ការតាំងពីសង្គមចាស់ម៉្លេះ គាត់នោះ ។

ដានី៖ ការមុនតាសាន ទៀត?

គឹមចុង៖ បាទ! គាត់ការពីដើម ស្រុកកំណើតគាត់នៅស្រុកឈូក ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអីទៅតា០៥?

គីមថុង: យាយណូន ។

ដានី: ឥឡូវគាត់នៅដែរ?

គីមថុង: ស្លាប់ ។

ដានី: គាត់ស្លាប់ហើយ?

គីមថុង: ស្លាប់ជាមួយគ្នា ។

បូលី: ស្លាប់ជាមួយប្ដី?

គីមថុង: បាទ!

បូលី: តាម៉ុក កប់ជាមួយគ្នា ។

គីមថុង: បាទ! លឺថាមួយរណ្ដៅជាមួយគ្នា ចេះតែលឺតៗ លឺថាកាយហើយទម្លាក់គាត់ចូលរណ្ដៅ

ដានី: កូនចៅអីអត់ទេ?

គីមថុង: អត់ទេ តែយាយណូន ហើយនិង០៥, ០៦ ។

ដានី: យាយវីន អត់អីទេ?

គីមថុង: យាយវីន នៅរាល់ថ្ងៃតា៎ ។

ដានី: អុំពេលដែលមានការផ្លាស់ប្ដូរកងពល អុំថាតាសាន ទៅមណ្ឌលគិរី?

គីមថុង: បាទ!

ដានី: មានការរៀបរយ ដោះដូរអីយ៉ាងម៉េចវិញ?

គីមថុង: សាន ទៅកាន់កងពល៩២០ ហើយដកចេញពី៨០១ភាគច្រើន ហើយក្រោយមកបាន កែវ សារឿន មកនៅក្នុងគណៈកងពល៨០១ហ្នឹង តែកែវ សារឿន មានបញ្ហារឿង ខ្ញុំមិនដឹងក្រោយមកបានលឺរឿងស្រីញី ខ្ញុំហ្នឹងហើយអ្នកយកសំបុត្រទៅដាក់នៅសេនាធិការ ។

ដានី: យកសំបុត្រគាត់ហ្នឹង?

គីមថុង: សំបុត្ររបស់០៥ ទៅម៉ូតូ២គ្រឿង ដល់ឡប់មកវិញនីរសារបស់តាឡឺៗ នៅដេកពេទ្យ កាលគាត់ទៅរៀន ដល់ឡប់មកវិញសំបុត្រខុសនាមពីខ្ញុំទៅ៣នាក់ ដល់ឡប់មកវិញគ្នា ៤នាក់លើសម៉ូតូ១គ្រឿង អីចឹងម៉ូតូ៣មក ខាងភូមិភាគឧត្ដរឃាត់ខ្ញុំនៅភ្នំស្រី ភ្នំប្រុស ខ្ញុំរករឿងខ្លាំងដែរ មកប្រុងដកកាំភ្លើងខ្ញុំ ខ្ញុំថាច្បាប់កាំភ្លើងមានតែបញ្ជាការខ្ញុំទេអ្នកបំពាក់ ឲ្យខ្ញុំ អ្នកផ្សេង អង្គភាពផ្សេងមកដក លើកលែងតែខ្ញុំមានកំហុស ទាក់ទងនឹងក្បត់ជាតិ បើនៅតែចចេសដកខ្ញុំបាញ់ហើយ ហើយឈ្លបកាន់សុទ្ធតែសេកាសេ ឃើញទំនងដែលឲ្យ ទៅ ។ ឥឡូវខ្ញុំសុំជួបមេមិត្តឯង ជួបទៅខ្ញុំនិយាយហេតុផលច្បាស់គេយល់ ខ្ញុំមិនមែន

ខ្លាំងសត្រូវទេ ខ្ញុំជានីរសារបស់ព្រំដែន ទាក់ទងមកសេនាធិការ ថារឿងអីៗខ្ញុំអត់ដឹង ខ្ញុំដឹងតែនាំសំបុត្រទៅដល់ ។ ហើយចេញពីហ្នឹងមកជាប់នៅល្បាងទៀត កន្លែងកងពលគេព្រលប់ៗ ភូមិភាគខត្តរចង់ចាប់កាំភ្លើង កងទ័ពនៅព្រំដែនកាំភ្លើងស្អាតៗ សុទ្ធតែអាការបត់ ចង់ដកខ្ញុំថាអត់ឲ្យដកទេ ម៉េចបានអត់ដកមិត្តឯងមកចូលក្នុងតំបន់ខ្ញុំ ខ្ញុំវង្វេងតាំហើយខ្ញុំអ្នកស្រុកកំពង់ចាមហ្នឹងដែរ ខ្ញុំមិនដឹង តែខ្ញុំនឹកស្មានថាផ្លូវមកស្ទឹងត្រង់ មកហាន់ជ័យ ទៅវង្វេងចូលត្រង់កន្លែងកងទ័ពគេល្បាង ។

បូលី៖ ពេលយើងធ្វើដំណើរតាមផ្លូវអីចឹងមានសំបុត្រស្នាមអនុញ្ញាតទេអ៊ំ?

គីមថុង៖ មាន ឲ្យមកផ្លូវការអីចឹងគេសេនាធិការបោះត្រាប៉ុណ្ណាណើមក ហើយបញ្ជាក់ច្បាស់លាស់នៅតែចាប់ ឆ្ងល់ដល់ហើយ ដូចជាអំណាចតាមកន្លែង ហើយមកខ្ញុំសំរេចចិត្តថាបាញ់កាលហ្នឹង ខ្ញុំថាបើមិត្តឯងមិនឲ្យខ្ញុំទៅ ដកកាំភ្លើងខ្ញុំ ខ្ញុំបាញ់ហើយ បើបាញ់ខ្ញុំបាញ់ងាប់ទាំងអស់អត់គខ្ញុំបានមួយគ្រាប់មុនទេ ។

ដានី៖ ម៉េចអីចឹង?

គីមថុង៖ ខ្ញុំសំលុតអីចឹង មិនដឹងឈ្លប មិនដឹងកងទ័ព សេការសេ ហើយការ៉ាបីនអត់ខ្សែផង ហើយខ្ញុំធ្លាប់នៅសមរភូមិរាប់ឆ្នាំ ខ្ញុំខ្លាចអី សំលុតអីចឹងបានឲ្យទៅ ជួបមេវា ។

ដានី៖ អីចឹងរឿងរបស់តាកែវ សារឿន អ៊ំជាអ្នករត់សំបុត្ររបស់០៥យកទៅ?

គីមថុង៖ បាទ! ទៅ យកសំបុត្រទៅរាយការណ៍ទៅសេនាធិការ ។

បូលី៖ ដឹងខ្លឹមសារក្នុងសំបុត្រទេ?

គីមថុង៖ ខ្ញុំអត់ដឹង បិទជិត អត់ហ៊ានមើល ។

ដានី៖ តែសង្ស័យថាយ៉ាងម៉េច?

គីមថុង៖ ខ្ញុំអត់ដឹងរឿងថាយ៉ាងណាទេ គ្រាន់តែឲ្យរត់សំបុត្រ ក្រោយមកបែកការណ៍រឿងគេចាប់គាត់ បាន០៥និយាយរឿង ហើយរឿងអ្នកគ្នាឯងដែលនៅមន្ទីរជាមួយគ្នា និយាយរឿងបេះៗ ទាក់ទងរឿងស្រីញី ។

បូលី៖ ស្រីញីហ្នឹងយ៉ាងម៉េចអ៊ំ?

គីមថុង៖ សីលធម៌ ខូចជាមួយនារី ខូចសីលធម៌ជាមួយនារី ។

ដានី៖ នារីនៅក្នុងអគ្គភាព?

គីមថុង៖ នៅក្នុងអគ្គភាពកងនារីរបស់យាយខា ហ្នឹង ក្រោយមកយាយខា អត់នៅហ្នឹងទេ គាត់ការជាមួយតាភាព ទៅនៅភ្នំពេញវិញហើយ នៅយាយរីៗប្រធាន យាយរី, យាយរឿន ប្រធានវរៈហ្នឹង ។

ដានី៖ អ៊ីចឹងយាយខា ឆ្នាំណាដែលគាត់ការហើយគាត់ទៅវិញ?

គីមថុង៖ គាត់ការនៅភ្នំពេញ ការមុនខ្ញុំចេញពីភ្នំពេញមក ។

ដានី៖ អ៊ីចឹងគាត់អត់បានទៅរតនគិរីទេ?

គីមថុង៖ អត់ទេ ។

ដានី៖ យាយខា?

គីមថុង៖ យាយខា អត់បានទៅទេ ទៅតែយាយរី, យាយរឿនហ្នឹង ។

ដានី៖ អ៊ីចឹងយាយខា ហ្នឹងនៅភ្នំពេញទេអ៊ីចឹង?

គីមថុង៖ បាទ! ពេលដែលកងទ័ពចេញទៅនៅរតនគិរីគាត់អត់បានទៅទេ ។

ដានី៖ កាលហ្នឹងតាសារឿន គាត់និយាយថាម៉េច ដល់ពេលគាត់និយាយប្រាប់ទូទៅ?

គីមថុង៖ គាត់អត់ដែលនិយាយផ្ទាល់ប្រាប់ខ្ញុំទេ អ្នកដែលនៅផ្ទាល់ៗក្រោយមកបានធ្លាយរឿងចាប់សមាសភាព បានធ្លាយៗក៏អត់សូវចាប់អារម្មណ៍ចង់ដឹង ចង់លឺដែរ ។

ដានី៖ កាលហ្នឹងអ៊ីមានអារម្មណ៍យ៉ាងម៉េចដែលពេលដែលគេចាប់? ដូចថាសមាសភាពវាមានពលដាលចាប់ច្រើនថែមទៀត?

គីមថុង៖ ខ្ញុំដូចអត់មានអារម្មណ៍អី ប្រើពាក្យមួយថាក្បាលអ្នកណា សក់អ្នកហ្នឹង អ៊ីចឹងអត់ចង់ដឹងរឿងច្រើន និយាយរួមអត់ចង់ដឹងរឿងគេអ្នកធំៗច្រើន ។

ដានី៖ កាលហ្នឹងមានផ្លាស់ប្តូរឋានៈដូចជាគណៈកងពល, គណៈវរសេនាធំអី?

គីមថុង៖ ដក កែវ សារឿន ហ្នឹងហើយបានចេញមកតាឡី ហើយស៊ុង មួយទៀត ។ ស៊ុង ហ្នឹងមកនៅលក្ខណៈជាសេនាធិការទេ មកគ្រប់គ្រងពួកខ្ញុំ មករស់នៅហ្នឹង ហើយកាលហ្នឹងមានតែ០៥ ហើយនិងតាឡី តែកាលហ្នឹងកងពលដូចអត់មានចាត់តាំង៣ទេ មានតែមូលមានតែប្រធាននយោបាយ និងយោធាហ្នឹងតែ២ ។ ។

ដានី៖ ចុះតាធិន ទៅណាវិញ?

គីមថុង៖ តាធិន នៅដដែល ក្រោយមកបានគាត់មកនៅ ។ ដូចជាតាឡី មួយទៀត តាធិន មួយទៀត នៅកន្ទែងកងពល ។ ជំនាន់ខ្ញុំការតាឡីហ្នឹងហើយ ។

ដានី៖ ដូចថាខាងគណៈវរសេនាធំមានផ្លាស់ប្តូរទៀតពេល?

គីមថុង៖ មានឡើង ខ្ញុំអត់ចាំអស់ទេ ដូចជាហ៊ិន ដកពី៨២ដែរទៅ៩២០ តែក្រោយមកស្លាប់ហើយមួយទៀតឈ្មោះពីដើមសន ក៏ទៅហ្នឹងដែរ ។ ហើយតាជុំ នៅ៨២ ។

ដានី៖ តាជុំ ក្រោយមកគាត់វរៈ៨២?

គីមចុង:	៨២ ទៅនៅរតនគិរីតាជុំហ្នឹងឯង នៅក្នុងវរៈ៨២ជាមួយតាវ៉ែន ក្រោយមកគាត់ទៅនៅកងណាទេតាជុំ ខ្ញុំអត់ចាំដែរ ហើយបានបងវ៉ែន ដកមកកន្លែងសេនាធិការ ។

ដានី:	មកភ្នំពេញវិញ?

គីមចុង:	បាទ! ទៅភ្នំពេញវិញ ដកច្រើនដែលទៅដល់រតនគិរី ។

ដានី:	ឆ្នាំណាដែលដកទៅដូចថាតាសាន គាត់ដកទៅខាងមណ្ឌលគិរីវិញ?

គីមចុង:	តាសាន ដកទៅដូចជាមុនខ្ញុំការ ។

ដានី:	អ៊ឹការឆ្នាំ៧៧?

គីមចុង:	បាទ! ៧៧ ដកមុន ។

ដានី:	ខែប៉ុន្មាន?

គីមចុង:	ខ្ញុំការខែ៣ ។

ដានី:	ខែ៣ ៧៧?

គីមចុង:	បាទ!

ដានី:	ដកទៅមុនយូរទេ?

គីមចុង:	គាត់ទៅមុនហ្នឹង តែមិនដឹងមុនហ្នឹងកំរិតប៉ុន្មានខែៗ មុនខ្ញុំការ ។

ដានី:	ខ្ញុំមើលក្នុងចំលើយសារភាពមួយមានដូចគាត់ឈ្មោះគីម អត់មានទៅខាងហ្នឹងទេ?

គីមចុង:	គីម?

ដានី:	បាទ! ខាងមណ្ឌលគិរី?

គីមចុង:	មានដកចេញពី៨១ឈ្មោះ នួន ទៅច្រើនដែរ ។

បូលី:	មុនពេលដកតាសាន ទៅពីណាគេគ្រប់គ្រងនៅមណ្ឌលគិរី?

គីមចុង:	សួរ កងពល ។

ដានី:	អ៊ឹពេលក្រោយមកដូចឆ្នាំ៧៨ មានការដូចថាច្របូកច្របល់ ការចាប់ច្រើនតាំងពីកងទ័ព តាំងពីខាងតំបន់?

គីមចុង:	ចាប់ ។

ដានី:	ច្រើនមានការផ្លាស់ប្តូរ ក្រោយមកខាងភូមិភាគ ខាងកងទ័ពគ្រប់គ្រងតែមួយ ឬយ៉ាងម៉េច មានការបែងចែក?

គីមចុង:	កងទ័ពដូចគ្រប់គ្រងតែមួយទេ តែក្រោយមកមានរង្គោះរង្គើល ចាប់នៅភូមិភាគ ចាប់នៅតំបន់ នៅរតនគិរី ក្រោយមកលីនៅជិតយួនចូល ថាមាន០៥ ទៅជាសមាជិកគ្រប់គ្រងដែរ ។

ដានី៖ គ្រប់គ្រងខាង?

គឹមថុង៖ នៅជាមួយភូមិភាគ ហើយកាលហ្នឹងខ្ញុំមកនៅកន្លែងបាងឡុងនេះ ។

ដានី៖ មកនៅបាងឡុងវិញ?

គឹមថុង៖ ខ្ញុំមកគ្រប់គ្រងកន្លែងសន្តិសុខរបស់កងពល៨០១ហ្នឹង នៅជាមួយសែ ខ្វាក់ភ្នែក ខ្ញុំការ ហើយបានប្រហែលជា១ខែ ។

ដានី៖ អីចឹងអ៊ំចេញពីតេអូរមកនៅ?

គឹមថុង៖ ចេញពីតេអូរក្រោយពីខ្ញុំការហើយ ។

ដានី៖ ចេញពីតេអូរមកខាងសន្តិសុខវិញ?

គឹមថុង៖ បាទ! ហ្នឹង០៥ អត់មានហៅខ្ញុំទៅប្រាប់ទេ ហ្នឹងក្រោយពីគេដើរសួរប្រវត្តិរូបអ្នកដែលនៅកងទ័ព គេដើរសួរហើយក្រោយមកខ្ញុំការហើយឲ្យខ្ញុំទៅនៅ ខ្ញុំទៅស្មានហ្នឹងជិះម៉ូតូទៅ

ដានី៖ អ៊ំទៅទទួលគ្រប់គ្រងនៅហ្នឹងឬយ៉ាងម៉េច?

គឹមថុង៖ មុនដំបូងតាឆេង គ្រប់គ្រងនៅកន្លែងម្តុំនេះ ។

ដានី៖ បឹងកន្សែងហ្នឹង?

គឹមថុង៖ ដំបូងនៅនេះ ។

បូលី៖ ហៅមន្ទីរសន្តិសុខបឹងកន្សែង?

គឹមថុង៖ បាទ! មុនដំបូងនៅហ្នឹង ខ្ញុំទៅដល់នៅហ្នឹង ។

ដានី៖ ជិតភ្នំស្វាយ?

គឹមថុង៖ បាទ! នៅរោងឡានហ្នឹងឃើញទៅដល់ដេក ហើយតាឆេង គ្រប់គ្រងនៅហ្នឹង ឃើញកងទ័ពប្រហែលជា៨-១០នាក់នៅហ្នឹងគេចាត់ទុកពួកសមាសភាព ឃើញអង្គុយមើលតាឆេង ឃើញអង្គុយគេសួរនាំរឿងសកម្មភាព ខ្ញុំទៅបានមួយអាទិត្យ ឃើញសែ ហ្នឹងមក សែ ហ្នឹងគេមកគេរៀបចំជាប្រធាន មកគេចាត់តែងលើខ្ញុំ ។

បូលី៖ មុនដំបូងឆេង ប្រធាន?

គឹមថុង៖ បាទ! ឆេង ។

បូលី៖ បន្ទាប់ពីឆេង មកពីណា?

គឹមថុង៖ មូលហេតុដែលដកតាឆេង មកដោយសារ តាសាន ហើយនិងតាឆេង ហ្នឹងស្រឡាញ់គ្នាដូចជាមិត្តភក្តិមួយជិតស្និត ដល់ពេលសាន ទៅនៅ៩២០ ហៅតាឆេង ទៅកាន់ភស្តុភានៅកងពល៩២០ ។ ដល់តាឆេង ទៅខ្ញុំអត់ទាន់នេះទេ សែ មកនៅនេះហើយបានតាឆេង ទៅ ។ សែ មកគេនៅជាប្រធាននៅហ្នឹង ។

ដានី:	អ៊ឹអនុ?

គីមថុង:	បាទ! ហើយមានម្នាក់ទៀតឈ្មោះ ទឹម ពីដើមអ្នកបើកឡានទៅជាមួយតាឆេង ហ្នឹងទៅហ្នឹងដែរ តែសមត្ថភាពគាត់ខាងផ្នែកអក្សរសាស្ត្រ ចំណេះដឹងមិនសូវជាអ្នកចេះដឹងទេ ជាសមាជិកទៅ ហើយខ្ញុំនៅបានប្រហែលជា ដូចជាមិនយូរទេ ត្រូវរើកន្លែងមកនៅទន្ទឹមនេះ ។

ដានី:	ទន្ទឹមអីគេវិញ?

គីមថុង:	ទន្ទឹងបឹងកន្សែង ក្រោយមន្ទីរពេទ្យ ពេលដែលខ្ញុំរើមកហ្នឹងដែលឃើញចាប់មនុស្សមកច្រើន ។

ដានី:	ចាប់ពីណាមកវិញទៅ?

គីមថុង:	ចាប់តាមកងទ័ព តាមវរសេនាធំឃើញបញ្ជូនមក ពិសេសអ្នកដែលពាក់ព័ន្ធនឹងឈ្មោះ ឡាយ សារីម, ឈ្មោះ ទាញ ដែលនៅកងពល១១ចាស់ ។

ដានី:	បាទ! យល់ហើយ ជាមួយតាសោម ជាមួយតាទាញ!

គីមថុង:	បាទ! លឺដំណឹងថាព័ត៌មានសោម ក្បត់ហើយសេអ៊ីអា ។

ដានី:	ចូលជាមួយទុំ ហ្នឹង?

គីមថុង:	ជាមួយទុំ ទាក់ទងជាមួយភូមិភាគឈូមទេ ពិសេសគឺជាមួយសោម ទាក់ទងជាមួយមន្ទីរពេទ្យច្រើន។ ឡាយ សារីម ដែលមានឈ្មោះ ឡាយ សារីម ហើយខ្ញុំឃើញមកអ្នកខ្លះខ្ញុំស្គាល់ ដូចជាពេទ្យមួយឈ្មោះដំៗ រាល់ថ្ងៃ សួររកខ្ញុំទល់រាល់ថ្ងៃ ហើយខ្ញុំស្គាល់តាំងពីនៅភ្នំពេញ គាត់ជាពេទ្យមួយនៅវរៈ៨៣ ហើយគេចាប់គាត់ ។

ដានី:	ចាប់មកដល់ណាទៅ?

គីមថុង:	ចាប់មកដាក់នៅហ្នឹង ឥឡូវគាត់រួច រស់រាន្តមានជីវិតនៅទល់សព្វថ្ងៃ ។

ដានី:	នៅណាទៅ?

គីមថុង:	ថានៅបុស្សខ្នុរ ធ្វើពេទ្យ ។

ដានី:	ចំការលើវិញ ។

គីមថុង:	បាទ! ថាសួររកខ្ញុំ ។ ខ្ញុំមក ខ្ញុំសួរថា ដំ ឯងរឿងអី ចងខ្សែទូរស័ព្ទ ។

ដានី:	កាលហ្នឹងមានបញ្ជូនមកភ្នំពេញច្រើនដែរ?

គីមថុង:	មកពីភ្នំពេញអត់មានទេ ។

ដានី:	អត់ទេ បញ្ជូនពីបឹងកន្សែង ឧបមាថាចាប់អ្នកទោសមកដល់បឹងកន្សែងហើយបញ្ជូនអ្នកទោសមកភ្នំពេញ?

គឹមថុង៖ ដូចមិនមានទីកន្លែងខ្ញុំ អត់មានទេនៅហ្នឹង អត់មានសោះ មានតែគេបញ្ជូនត្រង់ៗ ឧបមាថាអ្នកដែល ដូចជា ឡាយ សារីម ហ្នឹងគេបញ្ជូនត្រង់ៗតែម្តង ។

ដានី៖ ឲ្យក្រុមអ៊ំទៅនេះហ្នឹងបញ្ជូនទៅ?

គឹមថុង៖ អត់ទេ មានអ្នកផ្សេងទៀត ខ្ញុំអត់ដឹងទេ ដល់ក្រោយមកគេថា ឡាយ សារីម គេចាប់ហើយ មានបញ្ញាជនម្នាក់ឈ្មោះ អ៊ី សុគន្ធារី គាត់ជានិស្សិតរៀននៅភូមិន្ទភ្នំពេញពីដើម គាត់ជានិស្សិតសាលាច្បាប់ ហើយគាត់ជាប្រធាននិស្សិត បំផុសចលនានិស្សិត គាត់នៅស្រុកត្រាំកក់ គាត់ស្រឡាញ់ខ្ញុំណាស់ ។ ហើយមានសាស្ត្រាចារ្យម្នាក់ឈ្មោះ ស្បោង រុន គាត់បង្រៀនខាងម៉ាតេម៉ាទិច(គណិត) គាត់ស្រឡាញ់ខ្ញុំណាស់២នាក់ហ្នឹង ថ្ងៃដែលគេបញ្ជូនគាត់ទៅ ខ្ញុំជិះម៉ូតូតាមក្រោយឡានគាត់ ហើយខ្ញុំឃើញទឹកមុខគាត់ស្លូត ក្រោយមកបានខ្ញុំដឹងថាគេចាប់គាត់ ។

បូលី៖ គេចាប់គាត់មូលហេតុអី?

គឹមថុង៖ ប្រហែលជាមានចំលើយពីភ្នំពេញតាមខ្ញុំគិត ដោយសារអីចឹងហើយ មូលហេតុដែលខ្ញុំប៉ាន់ប្រមាណអីចឹងដោយសារខ្ញុំនៅកន្លែងនេះ ខ្ញុំដឹងពីរបៀបគេដកហូតមនុស្ស គេអាចមានចំលើយ ។

បូលី៖ គេធ្វើយ៉ាងម៉េច អ៊ំអាចរៀបរាប់ដំណើរហ្នឹងបន្តិចបានទេ? នៅពេលគេចង់ចាប់មនុស្សម្នាក់ បញ្ជាពីណា? អ្នកណាគេមានសិទ្ធិបញ្ជាឲ្យចាប់?

គឹមថុង៖ ខ្ញុំនៅកន្លែងហ្នឹងគ្រាន់តែដឹងថា គេប្រាប់មក គេថាមានឡានកន្លែងកងពលដឹកមក នេះ៥នាក់ហើយសួរចំលើយទៅ ធ្វើអីៗ តែប៉ុណ្ណឹង ។

ដានី៖ គេមានទំរង់សំនួរសំរាប់ឲ្យយើងសួរ?

គឹមថុង៖ អត់ ទី១សួរមូលហេតុអីបានគេយកអ្នកឯងមក ហើយជូនកាលគ្នាឆ្លើយត្រង់ដែរ ដោយសារខ្ញុំហូបដំឡូង គាស់ដំឡូងហូបក្បត់សមូលហភាព ហើយសរសេរក្នុងសៀវភៅទៅដល់ពេលរាយការណ៍ទៅ០៥ កាលហ្នឹងសែ អត់សូវទៅប៉ុន្មានទេដោយសារខ្ញុំធ្លាប់នៅមន្ទីរ០៥ហ្នឹងខ្ញុំច្រើនចេញចូលរាយការណ៍ផ្ទាល់ៗ ហើយសែ ជាមនុស្សម្នាក់នៅកង៨១ គេយកមកមិនសូវរាយការណ៍មិនសូវក្បោះក្បាយទេ ។ ទៅដល់ខ្ញុំតែងតែរាយការណ៍គាត់ថា សួរទៅរឿងគាស់ដំឡូង កាប់ចេកហូប ហើយគ្រុនឈឺមេកងដើរគាត់ថាពុត ។ ដល់ក្រោយមកប្រហែលជាខែវស្សា ខ្ញុំនៅនេះឃើញសកម្មភាពចាប់បញ្ជូនមនុស្សទៅភ្នំពេញ ហើយសកម្មភាពចំលើយ ហើយចំលើយភាគច្រើនគឺនៅកន្លែងកងពល នៅកប់នៅហ្នឹងដល់ហើយគេជ្រើសរើសហើយ ឧបមាថាចំលើយឆ្លើយដាក់អូននេះទៅ គេយកមកពួកខ្ញុំ

សួរទៅ សួរអត់មានអីឲ្យធ្វើការធម្មតា តែនៅកន្លែង មានកន្លែងឲ្យដេក ហើយអ្នកណាដែលមើលទៅរត់រួនអីប្រយ័ត្នដាក់ខ្នោះ គេធ្វើដែកកងជើង ខ្ញុំអត់មានពាក់ព័ន្ធនឹងហ្នឹងទេ នៅកន្លែងហ្នឹងខ្ញុំដឹងតែហៅមកសួរ សួរហើយធ្វើឯកសារាយការណ៍ទៅកងពល ។

ដានី: ចុះបើអ្នកហ្នឹងយើងរកឃើញថាអ្នកហ្នឹង គាត់ជាខ្មែរក្បត់មែន គាត់ក្បត់មែន?

គឹមថុង: ហ្នឹងមានចំលើយ ដល់ក្រោយមកមានគេប្រជុំម្នាក់មកពីភ្នំពេញ ហើយគេថាគេនៅជាមួយតាណាត មកគេមានបច្ចេកទេសសួរ ខ្ញុំអង្គុយមើល ។ ឥឡូវគ្រូមួយ គ្រូស៊ុនៗនៅវៃអង្គុលីលេខធ្វើឯកសារជាមួយខ្ញុំ ពីដើមខ្ញុំសរសេរតែដៃទេ ខ្ញុំសរសេរដាក់ក្រដាសកាកែ តែដោយសារគ្រូស៊ុន ហ្នឹងគាត់ចេះវៃអង្គុលីលេខ ហៅមកធ្វើឯកសារ ។

ដានី: កាលនៅរតនគីរី?

គឹមថុង: បាទ! នៅកន្លែងហ្នឹង ។

ដានី: ឥឡូវគាត់នៅទេ?

គឹមថុង: នៅតា៎ គ្រូស៊ុន គ្រាន់តែគាត់បុកម៉ូតូរផ្លេងអត់ចងចាំនេះប៉ុន្មាន តែការពិតគាត់និយាយរួមគាត់ដក គេចឲ្យផុតពីរឿងហ្នឹង ។ ខ្ញុំថាស៊ុន ការពិតនៅតែការពិតហ្នឹង ទោះបីយើងទៅនៅកន្លែងណាក៏ការពិតដែរ ជៀសអត់ផុតទេ ។

ដានី: កាលហ្នឹងតាសុន សេន គាត់ខស្សរាហ៍ចុះមកទេ ដែលចុងក្រោយ?

គឹមថុង: ខ្ញុំដឹងព័ត៌មាន ជួបសុន សេន ផ្ទាល់នៅពេលដែលគេចាប់ពួកហ្វូរ៉ូ ចាប់ប្រហែលជាង ១០០នាក់ មកដាក់កន្លែងខ្ញុំ ហើយពេលហ្នឹងខ្មែរក្រហមមានរបបទៅជួបគ្រួសារ១០ថ្ងៃទៅជួបម្តង ខ្ញុំទៅថ្ងៃដែលគេអនុញ្ញាតឲ្យទៅហ្នឹងខ្ញុំទៅ ទៅហៅខ្ញុំទៅជួប សួររឿងហ្វូរ៉ូ គាត់ថាមិត្តឯងដាក់កន្លែងពួកហ្នឹង ចង់ប្ត? ខ្ញុំថាអត់ តិចរត់អស់ មិនដឹងធ្វើម៉េចដេកនៅលើគ្រែហ្នឹងទៅ ខ្ញុំមានអីចង មានខ្សែណាចង ថាអីចឹង ។ ស្អែកឡើងឃើញដឹកច្រវ៉ាក់ទៅទៅដល់ឲ្យដាក់ច្រវ៉ាក់តាមជើង ហ្វូរ៉ូ ។

ដានី: ហើយគេបញ្ជូនមកភ្នំពេញទាំងអស់?

គឹមថុង: អត់ទេ ការពិតសម្លាប់ចោលទាំងអស់ ហ្វូរ៉ូជាង១០០នាក់ ។

ដានី: មានកន្លែងសម្លាប់នៅជិតហ្នឹងដែរ? ជិតបឹងកន្សែង?

គឹមថុង: មានតា៎ ថ្ងៃសម្លាប់ពួកហ្វូរ៉ូហ្នឹង ពួកអ្នកសម្លាប់ ខ្ញុំទៅមើល ខ្ញុំនៅដេកកន្លែងទៅមើល ពួកហ្នឹងរកវៃខ្ញុំ ច្រលំស្មានថាគេដឹកអ្នកទៅវៃចោល អ៊ូ! អាក្រក់ ខ្ញុំអត់ដែលឃើញគេសម្លាប់មនុស្ស ។

បូលី: សម្លាប់នឹងអីអ៊ី? កាំភ្លើងឬក៏?

គីមថុង៖ អ្នកដែលឃើញមុនគេ ខ្ញុំឃើញគេសម្លាប់មនុស្សមុនគេ សែ ហ្នឹងហើយ វៃនឹងដំបង។

ដានី៖ គេយកដំបងវៃ?

គីមថុង៖ ខ្ញុំឃើញស្ទុតតែម្តង នៅពេលដែលខ្ញុំស្ទុតហ្នឹងហើយ ខ្មែរក្រហមមានរបបតិទាន ខ្ញុំអត់ដាច់ខាតជាមួយខ្លាំង។

ដានី៖ ស្ម័យតិទានហ្នឹង?

គីមថុង៖ បាទ! តិទាន គេតិទានថាឃើញមុខស្លេក ញ័រសាច់ ហើយខ្ញុំចេះតែទទួល ព្រោះមើលទៅប្រៀបបាននឹងជីវិតមនុស្ស ដែលខំចិញ្ចឹមតាំងពីទឹកដោះម្តាយ១-២ដំណក់ ហើយទៅសម្លាប់មនុស្ស។

ដានី៖ ស្ម័យតិទានហ្នឹងដូចក្នុងគ្នាយើង ដូចអ៊ីជាមួយសែ គាត់តិទាន?

គីមថុង៖ បាទ! តិទានខ្ញុំធ្ងន់ៗរហូតខ្ញុំជាមុខសញ្ញាដែលគេប្រុងនឹងចាប់ ដោយសារខ្ញុំអត់ដាច់ខាតតាមរយៈសែ ហើយតាមរយៈ ម៉ុន ហ្នឹងប្រធានគ្រប់គ្រង ក្រោយមកប្រធានគ្រប់គ្រងនៅលើខ្ញុំទៀតនៅបឹងកន្សែង។

ដានី៖ អីចឹងគាត់ធំជាងសែ ទៀត?

គីមថុង៖ បាទ! ធំជាងសែ មកគ្រប់គ្រងហ្នឹង ប៉ុន្តែដោយសារអី ដោយសារ០៥គាត់អត់ជឿគាត់ថាមនុស្សខ្ញុំគាត់ប្រើទៅណាអត់ដែលប៉ះពាល់ជាមួយប្រជាពលរដ្ឋក៏អត់ដែរ គាត់ទុកចិត្ត រាយការណ៍អាក្រក់ពីខ្ញុំ សូម្បីតែខ្ញុំលើកឧទាហរណ៍មួយ កាលហ្នឹងគេឲ្យខ្ញុំចាំកន្លែងនៅបាងឡុង នៅបឹងកន្សែង ហើយគេធ្វើលើកទំនប់មួយប្រហែលជា២០ម៉ែត្រ ហើយគេដាំបាយលាយដំឡូងមី ហើយកំណត់ឲ្យវែកមួយថ្ងៃ១០០វែក ម្នាក់ ហើយបាយមានតែ១ចានប៉ុណ្ណោះទេ ហើយសម្ភារធាងត្រាវ ហើយខ្ញុំគេដួសបាយស្ងោយកមកឲ្យហូបដើម្បីសំរេច១០០អំវែកហ្នឹងខ្ញុំយកបាយស្ងោខ្ញុំរហូតរាល់ថ្ងៃ ខ្ញុំថាខ្ញុំអត់ហូបទេ ខ្ញុំហូបលាយជាមួយគ្នា បាយលាយដំឡូងៗជាមួយគ្នា មើលទៅមានមនោសញ្ចេតនាជាមួយអ្នកធ្វើការ ហើយខ្ញុំក៏វែកដែរ ព្រោះមួយអំវែកៗឡើងទួលខ្លាំងដែរ បន្តិចប៉ុន្មានៗនេះ ហើយខ្ញុំអត់ហូប ហើយសែ គេនៅដឹកនាំកំលាំងមួយចំនួននៅធ្វើស្រែនៅវៀងសែ រវៃបាក់ជើង។

ដានី៖ គាត់កាចដែរ?

គីមថុង៖ មនុស្សសែ ពិបាកនិយាយដែរ ជាចរិតរបស់គាត់ ចរិតមនុស្សរាងអំនួតតិចតួច ព័ត៌មានអីខ្លះដូនកាលអាចបំប៉ោងអីចឹងដែរ ហើយដល់ក្រោយមកអ្នកដែលនៅជាមួយ សែ យប់ឡើងគេធ្វើខ្ទមដាក់ប្រវ៉ាក់ ធ្វើការពលកម្ម ដល់ក្រោយមកប្រហែលជាមានការតាម

ដានខ្ញុំស្អិត ម៉ុន ហ្នឹង តាមដានដោយសារអី ដោយសារខ្ញុំការប្រពន្ធហើយខ្ញុំដឹកក្រែមួយ អ្នកនៅម្តុំហ្នឹងចេះដាង ខ្ញុំឲ្យធ្វើក្រែពីផ្ទះខ្ញុំដឹកឲ្យប្រពន្ធខ្ញុំ ។ តិទានប្រពន្ធខ្ញុំ គេថាខ្ញុំកម្មសិទ្ធិក្រាស់ ហើយមួយទៀតសែ ហ្នឹងគេតាមដានខ្ញុំដូចជាសម្ងរដាក់ប៊ីចេងច្រើន បើមិនដាក់ស៊ីសុទ្ធតែផាងគ្រាវខ្ញុំនិយាយអីចឹង ។ ខ្ញុំនិយាយក្នុងពេលហូបបាយ ខ្ញុំថាមើលយើងសុទ្ធតែត្រីអាំង តែគ្នាពលកម្មដាក់ប៊ីចេងឲ្យឆ្ងាញ់តិចទៅ ដល់ពេលប្រជុំតិទានហ្នឹងហើយដែលតិទានថាខ្ញុំស៊ុមកាលំជាមួយខ្មាំង អត់ដាច់ខាតជាមួយខ្មាំងនៅពេលដែលគេវ៉ៃយកមនុស្សទៅសម្លាប់ ខ្ញុំអត់ទៅបៀតទេ ។ ខ្ញុំធ្លាប់ផ្តល់បទសម្ភាសន៍ឲ្យចៅក្រមស៊ើបអង្កេត គាត់មកនៅកន្លែងហ្នឹង គាត់សួរខ្ញុំ មានមេធាវីមួយជនជាតិអី ប្រហែលជាបង់ក្លាដេស អ៎!មិនមែនទេ នៅនរវេស គាត់សួរថាជាថ្ងៃសំខាន់ ខ្ញុំនិយាយថាថ្ងៃដែលខ្ញុំរំភើបអារម្មណ៍ខ្ញុំឃើញគេវ៉ៃមនុស្សសម្លាប់ គាត់សួរអាហ្នឹងខ្ញុំ បានខ្ញុំបកស្រាយឲ្យគាត់ ។ តែសម្ភាសន៍ចុងក្រោយ គាត់មិនឲ្យខ្ញុំវែកអាហ្នឹង វែកឲ្យស្រឡះកុំឲ្យមើលទៅច្រឡំ ខ្ញុំថាមិនមែនទេប្រហែលជាស្តាប់ខ្ញុំច្រលំ ។ ខ្ញុំនៅក្នុងវង្វង់គេតាមដានហ្នឹង អីចឹងហើយបានជា សែហ្នឹងគាត់ត្រឡប់មកនៅគ្រប់គ្រងហ្នឹងវិញ ឲ្យមនុស្សមួយចំនួនទៅនៅជាមួយខ្ញុំធ្វើស្រែនៅភូមិគង ជិតលំជរ ទៅធ្វើហ្នឹងខ្ញុំអត់មានអី ខ្ញុំឲ្យដេកធម្មតា មានអ្នកឃ្វាលក្របី មានអ្នកស្ទូងស្រូវ ហើយមានអ្នកដកសំណាប ហើយយប់ឡើង ០៥នេះហៅខ្ញុំទៅប្រាប់ថាចេក ដំឡូងនៅភូមិលំជរប្រគល់ឲ្យខ្ញុំ ។ ហើយកំណត់កាលហ្នឹងគេឲ្យស្ទូង១២នាក់មួយហិចតា ហើយខ្ញុំថាដើម្បីសំរេចមួយហិចតាបានទាល់តែមនុស្សមានកំលាំង ពីព្រោះ១ហិចតាយើងស្ទូង២០-៣០នាក់ អីចឹងខ្ញុំហៅរៀបចំមេក្រុម ខ្ញុំហៅមក ឥឡូវកងពលប្រាប់ថាដំឡូង ហើយនិងចេក ពោត នៅភូមិលំជរ និយាយរួមមួយបរិវេណហ្នឹង កាលហ្នឹងវៀតណាមវ៉ៃតាមព្រំដែនហើយ ម្តុំភូមិសំ ខ្ញុំថាឥឡូវដើម្បីមានកំលាំង ទាល់តែនាំគ្នាទៅកាប់ចេកមកបន្ទុំមក ហើយដំឡូងឲ្យទៅដឹក ឲ្យតែហូបកើត ដាំបាយៗដាក់អង្ករតាមរបបហើយដំឡូងថ្ងៃស្ងោរហូបទៅ ពីព្រោះវាមានកំលាំង ហើយគេមានអង្ករក្សកាន់កាំភ្លើងយាម ។

ដានី: កាលហ្នឹងសន្តិសុខគ្នាប៉ុន្មាននាក់ទៅ?

គីមថុង: មានអ្នកនៅកាន់កាំភ្លើងដូចជា ខ្ញុំភ្លេចដែរ ប្រហែលជាមួយក្រុម តាមពេលចេញធ្វើការតែសំរាប់មកខ្ញុំតែ៣នាក់ តែនៅជាមួយសែ ទៅ៥-៦នាក់ មានចុងភៅ ។ ហើយពេលថ្ងៃឃើញដើររើសខ្ចង ខ្ញុំលឺគេនិយាយបើនៅវ៉ុងសែ ជំនាន់សែ ត្រូវហើយ តែខ្ញុំអត់ទេពីព្រោះខ្ញុំដេកនៅកណ្តាលវាលអត់មានជញ្ជាំងទេ បើពួកហ្នឹងមកសម្លាប់មិនងាប់ ហើយខ្ញុំ

មានអ្នកណាការពារ យកពួកហ្នឹងហើយការពារខ្ញុំ អីចឹងទាល់ឲ្យវាស៊ីឆ្អែត។ ឯងធ្វើអី ថារើសខ្ចង ឃើញខ្ញុំញ៉័រដៃ ភ័យ ឯងរើសធ្វើអី ថារើសស្ងោរហូប ម៉េចមិនរើសដាក់ឆ្នាំង ស្ងោរមួយឆ្នាំងឲ្យពួកនៅដកសំណាបស៊ីផង ស្ងោរមួយឆ្នាំងជនជាតិ រើសស៊ីទៅ។ បើពួកកងការពាររករឿងប្រាប់ថាអញឲ្យស្ងោរ ហើយហូបទៅ ម៉ោងប្រហែល១-២ដកសំណាបហើយអស់ យប់ឡើងត្រីរស់ប៉ុនៗនេះនៅតាមទ្វារទឹកស្លុះម៉ោ ម៉ោង១-២ដាស់ខ្ញុំថាបងបានត្រី ម៉េចមិនស្ងោរហូប បានអីហូប ដំឡូងស្ងោរទៅ ស៊ីឯង ស្អែកឡើងធ្វើការទៀត រាល់ថ្ងៃជាប្រចាំ អីចឹងសាច់ឈាមវាទៅដូចមនុស្សធម្មតា ហ្នឹងចោទទី១ស៊ុមក្រលំចិញ្ចឹមពួកសមាសភាព។ ដឹងទេ នៅពេលវៀតណាមវ៉ៃធ្លាយចូលមកដល់ភូមិគកាលហ្នឹង០៩ទេបញ្ញាឲ្យតាស៊ិន បំពាក់អាវុធអ្នកដែលនៅជាមួយខ្ញុំ បំពាក់អាវុធទាំងអស់ បើពួកហ្នឹងស្អប់ខ្ញុំ បាញ់ខ្ញុំចោលតាំងពីយប់ហ្នឹងម្ល៉េះ យប់ឡើងដេកព័ទ្ធជុំវិញខ្ញុំកាំភ្លើងរកដូងឲ្យខ្ញុំហូបទៀត ដាំបាយឲ្យខ្ញុំហូបទៀត រហូតដល់អ្នកខ្លះខ្ញុំការប្រពន្ធឲ្យទៀត ឈ្មោះមុតៗ នៅនោះឃើញខ្ញុំសុទ្ធតែលុតជង្គង់ កុំបានបងឯងខ្ញុំអត់រស់ ដោយសារមានអ្នកខ្លះគេស្អប់ មានអ្នកគេស្រឡាញ់ ខ្ញុំគិតថានៅកន្លែងហ្នឹងមានគេស្រឡាញ់ច្រើនដាង ដោយសារអំពើល្អរបស់ខ្ញុំ ចាត់ទុកថាជាអំពើមានមនុស្សធម៌ខ្លះៗ ជួយមនុស្សគ្នាឯង។

ដានី: អ៊ឹខាងអគ្គសេនាធិការខស្សាហ៍ចុះទៅដែរ? ក្រៅពីសុន សេន?

គឹមថុង: ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅបាងលុង និងវ៉ឺនសៃ ឆ្ងាយពីគ្នា ដីរាប់គីឡូ។

ដានី: តែសុន សេន គាត់ធ្លាប់ឃើញពេលដែលហ្ស៎?

គឹមថុង: ប្រហែលជាទៅញឹកញាប់ខ្ញុំគិត។

ដានី: ចុះដូចជាស៊ូ ម៉េត, មាស មុត គាត់ធ្លាប់ទៅដែរ?

គឹមថុង: ខ្ញុំអត់ដឹងទេ ស៊ូ ម៉េត កាលហ្នឹងពីព្រោះគាត់នៅកាន់កន្លែងយន្តហោះ ប្រហែលជាគាត់អាចទៅ នៅពេលដែលគេធ្វើព្រលានយន្តហោះ ខ្ញុំកាលហ្នឹងខ្ញុំចេញមកហើយ មិនសូវដឹងលឺច្រើន។

ដានី: មាស មុត អត់ទេ?

គឹមថុង: មុត ដូចអត់ដឹងទេ ក្រោយមកបានខ្ញុំស្គាល់។

ដានី: ស្គាល់នៅណា?

គឹមថុង: ស្គាល់នៅពេលដែលខ្ញុំនៅកន្លែងប៉ុល ពត ខ្ញុំនៅផ្ទាល់ ហើយគេទៅរៀនស្គាល់តាមុតៗពេលហ្នឹងឯង ក្រោយមកបានខ្ញុំទៅនៅជាមួយប៉ុល ពត ផ្ទាល់ ឆ្នាំ១៩៨០ខ្ញុំចេញពីមុំបីកាលហ្នឹងគេជ្រើសរើសមនុស្សមានចេះអក្សរទៅនៅកន្លែងហ្នឹង។

ដានី: កន្លែងសន្តិសុខបឹងកន្សែង សមាសភាពទាំងអស់គឺជាកងទ័ពទេ មិនមែនប្រជាជន?

គឹមចុង: កងទ័ពភាគច្រើន ហើយក្រោយមកនៅពេលដែលវៀតណាមកំពុងវ៉ៃព្រំដែន ឃើញមានមកពីប្រជាពលរដ្ឋខ្លះ ពិសេសសហជីពកម្មករ ហេតុអីបានសហជីពកម្មករគេចាប់ ដោយសារឈ្មោះទុំៗ ទុំ នៅត្រង់នេះមន្ទីរគាត់ នៅក្រោមជិតភ្នំស្វាយគេចាប់គាត់ហ្នឹង បានឆ្លាយមានមនុស្សមកនៅកន្លែងខ្ញុំ មានប្រហែលជា ខ្លះចាប់ទាំងគ្រួសារមកជាង១០នាក់ ប៉ុណ្ណឹង ក្រៅពីហ្នឹងតែកងទ័ពៗ

ដានី: ពេលដែលខាងវៀតណាមគេវ៉ៃចូលមក វ៉ៃចូលឆ្នាំណា? ដូចថាយកបានរតនគិរី?

គឹមចុង: វ៉ៃចូលមកគេបំពាក់អាវុធឲ្យខ្ញុំ ពួកខ្ញុំនៅនេះ គេហៅលំជរហ្នឹង បំពាក់អាវុធហើយគ្រាប់ផ្លោងចូលដល់ហើយ ខ្ញុំជម្លៀសចេញ ខ្ញុំដើរកាត់សំដៅទៅ មែនទែនដើរទៅមុំលំផាត់ ខ្ញុំដើរមួយយប់មួយថ្ងៃ មួយយប់ទល់ភ្លឺ ទៅដេកភូមិជ្រៃ ភូមិសាមុត ដេកឃើញដើមស្វាធំៗណាស់ ដើរតាមផ្លូវម៉ោង១២ខ្ញុំទៅដល់លំផាត់ រថក្រោះយួនទៅដល់ភ្នំកូនសេក បាញ់ផាំងៗប្រហែលមួយម៉ោងក្រោយមកដល់មាត់ទន្លេសែពក ខ្ញុំជិះទូកឆ្លងទៅត្រើយម្ខាងស្លាប់ច្រើនដែលតាមមើលៗ

ដានី: កាលមុនរំដោះ នួន ជា គាត់ធ្លាប់ទៅដល់ហ្នឹងដែលអត់?

គឹមចុង: ខ្ញុំអត់ដឹងៗ

ដានី: អត់ដែលដឹង?

គឹមចុង: បាទ!

ដានី: ដែលដឹងថាគាត់ធ្វើជាគណៈភូមិភាគអី នៅខាងភូមិភាគឥសាន?

គឹមចុង: ខ្ញុំអត់ដឹងទេៗ

ដានី: គ្រាន់តែអ៊ំដឹងយ៉ាងម៉េច លឺថាតា០៥គាត់ជាគណៈភូមិភាគមួយដែរ?

គឹមចុង: កាលហ្នឹងខ្ញុំដឹងតាមរយៈខ្ញុំទៅហ្នឹងទេ ខ្ញុំនាំកំលាំងទៅធ្វើស្រែនៅភូមិគង ថាតា០៥ឥឡូវនៅក្នុងគណៈភូមិភាគ ដឹងតាមរយៈហ្នឹងៗ

ដានី: អត់មានលឺនិយាយថា នួន ជា ក្រោយមកគាត់ទៅធ្វើលេខាភូមិភាគ?

គឹមចុង: ខ្ញុំអត់ដឹងទេ ព្រោះកាលហ្នឹងអត់សូវបានចូលទៅសិក្ខាសាលា ទៅរៀន យូរៗគេហៅទៅម្តង ខ្ញុំនៅវក់វីនៅហ្នឹងៗ

ដានី: ដែលលឺឈ្មោះតាធាត់ ទេ?

| | |
|---|---|
| គឹមចុង៖ | ធាត់ លី ពីដើមគាត់នៅមណ្ឌលគិរី ខ្ញុំស្គាល់គាត់ គាត់ទៅរៀនកន្លែងខ្ញុំថា តែខ្ញុំអត់ស្គាល់ទេលីតែឈ្មោះដូចយក្សអីចឹង ដល់ពេលគាត់ទៅរៀនកន្លែងមន្ទីរ ប៉ុល ពត មួយក្រោយនៅពេលតស៊ូជាមួយរដ្ឋកម្ពុជាព្រំដែន មានមន្ទីររបស់ប៉ុល ពត មួយនៅខេត្តត្រាង ។ |
| បូលី៖ | កោះកុង? |
| ដានី៖ | នេះកោះកុង? |
| គឹមចុង៖ | មិនមែនទេ នេះគាត់នៅគេហៅតំបន់ក្រុចកសេះ នេះមួយដូរនេះ ។ |
| បូលី៖ | គេហៅអីគេ? |
| គឹមចុង៖ | គេហៅក-១៨ ហើយភាសាថៃថារយហាវៃ ទិញដីគេ១០៥វៃ ។ |
| ដានី៖ | យើងទិញដីគេតែម្តង? |
| គឹមចុង៖ | បាទ! ទិញដី ទិញចំការកៅស៊ូគេនៅហ្នឹង ។ |
| ដានី៖ | ទិញទៅឥឡូវដីហ្នឹងយ៉ាងម៉េចវិញហើយ? |
| គឹមចុង៖ | ខ្ញុំអត់ដឹងទេ ។ |
| ដានី៖ | គេយកវិញឬបានមកយើង? |
| គឹមចុង៖ | ហ្នឹងនៅជិតទីប្រជុំជនខេត្តត្រាងនៅហ្នឹង ។ |
| បូលី៖ | ក្នុងដីថៃតែម្តង? |
| គឹមចុង៖ | បាទ! ក្នុងដីថៃ ។ |
| ដានី៖ | ចំងាយប៉ុន្មានគីឡូពីព្រំដែន? |
| គឹមចុង៖ | ឆ្ងាយដែរ កន្លែងហ្នឹងហើយជាកន្លែងមានកិច្ចព្រមព្រៀងប៉ារីសនៅហ្នឹងឯង ។ |
| ដានី៖ | កិច្ចព្រមព្រៀងប៉ារីសឆ្នាំ? |
| គឹមចុង៖ | ៩៣ហ្នឹង ។ |
| ដានី៖ | ៩១? |
| គឹមចុង៖ | ៩១ ថ្ងៃ២៣ តុលា ។ |
| ដានី៖ | កាលហ្នឹងអ៊ំបានជួបតាធាត់ នៅហ្នឹងដែរ? |
| គឹមចុង៖ | បាទ! ជួបនៅកន្លែងហ្នឹង ហើយកន្លែងហ្នឹងជាកន្លែងដែលប៉ុល ពត ធ្វើកន្លែងហ៊ុតហ៊ឺនកម្មាភិបាល ដែលមានសង្គ្រាមនៅតាមព្រំដែន ហើយជំនាន់តាម៉ុក ដាច់ជើងនៅហ្នឹង ។ |
| ដានី៖ | តាធាត់ សព្វថ្ងៃគាត់នៅដែរ? |
| គឹមចុង៖ | ស្លាប់ហើយអី? |
| ដានី៖ | ខ្ញុំអត់ដឹងដែរលីតែឈ្មោះ ។ |

គឹមថុង៖ តាធាត់ សួរតាតេរិច ។

ដានី៖ តាណា?

គឹមថុង៖ តេរិច នេះនៅពេល ហ្នឹងអគ្គភាពជាមួយគាត់ ។

ដានី៖ តាតេរិច?

គឹមថុង៖ បាទ! សុទ្ធតែខ្មែរស្រឡាយគាត់ ។

ដានី៖ តេរិច នៅភូមិពេល?

គឹមថុង៖ បាទ!

ដានី៖ ឃុំត្រពាំងប្រាសាទដែរ?

គឹមថុង៖ ស្រុកត្រពាំងប្រាសាទ ឃុំផ្អាវ ។

ដានី៖ អ៊ីចឹងខ្ញុំចង់ហួសទៅ ពេលដែលយួនចូលមកឆ្នាំ៧៩ យ៉ាងម៉េចទៀតទៅ? ពេលយួនចូលមកអ៊ីចាប់ផ្ដើមជម្លៀសបន្តៗ?

គឹមថុង៖ ពេលយួនចូលមកខ្ញុំនៅក្រវល់នៅហ្នឹង ខ្ញុំដឹកនាំកងទ័ពគេហៅកងសមាសភាព ខ្ញុំនៅតែម្ដុំទេ នៅម្ដុំបាងលុង ជុំវិញបាងលុង ភាគច្រើនខ្ញុំនៅហៅអូរកន្សែង ខាងក្រោមហៅភ្នំកាច់ចង្កេះ ខ្ញុំនៅចន្លោះហ្នឹង ដល់ក្រោយមក ខែ២ឬខែ៣ ០៩ទៅនៅបោះតាំងនៅក្នុងទឹកដីមណ្ឌលគិរីហើយ ហៅខ្ញុំទៅរៀន ហើយគាត់សួរនាំហាក់ដូចជាមានមនោសញ្ចេតនាជាមួយខ្ញុំ សួរនាំអ្នកដែលនៅជាមួយខ្ញុំកាន់អាវុធ ។ ខ្ញុំថាពីដើមអត់អីទេ ដល់ក្រោយពីយើងបែកបាក់មានអ្នកខ្លះចង់សេរីដែរ ចង់សងសឹក ហើយកាន់កាំភ្លើង ដល់ហើយគាត់គិតថាបើអ៊ីចឹងអនាគតអាចសងសឹកយើងមែនទេ ខ្ញុំថាអាចដែរ ព្រោះសំរាប់ខ្ញុំគេអត់គុំទេ តែសំរាប់អ្នកផ្សេងទៀតដែលគេធ្វើអំពើអាក្រក់លើគាត់ គេគុំ អ៊ីចឹងវាជាមនិយាយរួមអ្នកដឹកនាំគេនៅក្នុងចំណោមហ្នឹង ខ្ញុំបែកចេញពីសែ អស់ហើយ នៅម្ដុំៗទៅ ។ គាត់ថាឯងមកនៅវរៈ១២មក វរៈ១២ហ្នឹងរបស់តាបុល ហើយខ្ញុំមកកាន់អនុសេនាធំមួយនៅវរៈ១២ ។

ដានី៖ វរសេនាតូច?

គឹមថុង៖ ខ្ញុំមកកាន់អនុ អនុប្រធានវរសេនាធំមួយ បញ្ជាការខ្ញុំតាសៅ នៅផ្ទះខាងត្បូង ។

ដានី៖ បញ្ជាការអនុសេនាធំតាសៅ?

គឹមថុង៖ បាទ! តែវរៈរបស់តាបុល ។

ដានី៖ ហ្នឹងក្នុងវរសេនាធំប៉ែតប៉ុន្មាន?

គីមថុនៈ ៨១ ។ ហើយខ្ញុំមកកាន់ហ្នឹងមក ចាប់ពីហ្នឹងមកខ្ញុំមកនៅកៀកនឹងស្ទឹងត្រែង មកធ្វើផ្លូវ ដើម្បីឆ្លង ឆ្លងទន្លេមកគ្គមកទិសខាងលិច ហើយខ្ញុំមករៀបចំផ្លូវ ។

ដានីៈ ឆ្នាំណាហ្នឹង? ៧៩ដដែលឬចូលដាច់ហើយ?

គីមថុនៈ ចុង៧៩ ។

ដានីៈ ប្រហែលខែប៉ុន្មាន?

គីមថុនៈ ខែវស្សា ខ្ញុំចាំអត់ច្បាស់ដែរ ។

បូលីៈ អីចឹងបានន័យថាចុង៧៩ហើយ ខ្មែរក្រហមនៅគ្រប់គ្រងតំបន់នេះនៅឡើយ?

គីមថុនៈ នៅរាយបាយ នៅជាដុំៗអន្តភាព ពីព្រោះគេចនឹងការវាតត្បាតរបស់កងទ័ពវៀតណាម

ដានីៈ វៀតណាមគេកាន់កាប់កន្លែងទីក្រុងបាងលុង?

គីមថុនៈ ដូចរាស់អីចឹង មួយខែ្ស១០០ម៉ែត្រៗ ហើយខ្ញុំគ្រប់គ្រងអ្នកនៅជាមួយខ្ញុំ ដូចជា៣០-៤០នាក់ តែខ្ញុំបំបែកឲ្យនៅស្រាល ហើយគាស់ក្តួចហូប ស្រូវលាក់ទុក ។

បូលីៈ លាក់យ៉ាងម៉េច?

គីមថុនៈ លាក់លើចុងឈើ ធ្វើធ្នើរហើយយោងខ្សែទៅលុបដានទៅ បើទុកនៅក្រោមដីវាកើចគ្មានសល់ទេ អំបិលកប់ ពាងរបស់ជនជាតិហ្នឹងញាបដាក់ក្អមកុំឲ្យជ្រាប អនាគតទៅទឹកជ្រាបចូល តែទឹកហ្នឹងមករំងាស់ធ្វើអំបិលដដែល ក្នុងមួយនាក់អំបិលមួយកញ្ចប់អត់ឲ្យហូបទេ សំរាប់បែកពីគេ អង្ករមួយទៃហ្នឹងអត់ឲ្យហូបដែរ សំរាប់ពេលខ្វនឯងឈឺ ។

បូលីៈ អង្ករមួយអីគេ?

ដានីៈ មួយទៃ ។

គីមថុនៈ អង្ករមួយទៃ ដេរក្រណាត់ហ្នឹង ស្ពាយនៅហ្នឹងខ្លួន ។

ដានីៈ គេធ្វើមូល គេញាត់អង្ករឲ្យមូលហើយ គេចាប់ច្រកឲ្យពេញ ។

គីមថុនៈ លើកលែងអ្នកឈឺឲ្យហូបបបរអង្ករ គ្នាទៅអត់រួចទេឲ្យហូបបបរក្តួច ទៅមិនរួចទេ ហើយខ្ញុំហូបជាមួយគេ ជាមួយឯង មានរបបហើយអំបិលសៀតនៅចង្កេះ ខ្ចប់នៅចង្កេះហ្នឹង ។

ដានីៈ ប៉ុណ្ណា?

គីមថុនៈ អំបិលខ្ចប់ល្មមដាក់ចង្កេះបានប៉ុណ្ណឹង អំបិលម៉ត់ ហើយនៅពេលបែកពីគេ កងទ័ពវៀតណាមវ៉ៃបែកឃ្លាតពីគេអំបិលហ្នឹងឯង ហើយដាំបាយដីកដីដាំទៅ ។

ដានីៈ កុំឲ្យហុយផ្សែង?

គីមថុនៈ ដីកដីដាំ គឺដាំនឹងដីតែម្តង យកក្រមាទៅកប់ដី លាងអង្ករដាក់ដីដុតភ្លើងពីលើ ។

ដានីៈ ឆ្អិនដែរ?

គឹមចុង៖ ឆ្អិន តែយូរហើយការភ្លើងបាញ់សត្វធ្វើជាអាហារទៅ ទំរាំបានហើយដាក់សញ្ញា ។ ឧបមាថាខ្ញុំនៅអីចឹងមានដើមឈើមួយ ដូចជាគ្រឿងចាស់អីចឹង បើបែកពីគេមកនៅកៀនហ្នឹងទៅហើយដាក់សញ្ញាទៅ ធម្មតាមែកឈើយើងកាច់ទៅស្ទឹកវានៅក្រោម បើដាក់បញ្ឈរមានន័យថាយើងនៅឃ្លាតប្រហែលជា២០០ម៉ែត្រ បើដាក់ចុះក្រោមមានន័យថាយើងនៅឆ្ងាយហើយរង់ចាំ នាំគ្នានៅក្រវែលហ្នឹងតិចឃើញ គឺថាមួយអាទិត្យត្រូវមកមើលសញ្ញាហ្នឹងគ្រប់គ្នា ក្រែងលោមានអ្នកណាបែក អីចឹងខ្ញុំអត់បែកទេកំលាំងខ្ញុំហ្នឹង គ្រប់គ្រងបាន ទោះបីវ៉ៃខ្វាត់ខ្វាយម៉េចខ្ញុំអត់បែកគ្នា មានសញ្ញាអីចឹង ។

ដានី៖ យើងប្រជុំអីចឹងរួចស្រេចមុននឹង ។

គឹមចុង៖ បាទ! ណែនាំអីចឹង បើមិនអីចឹងអត់រស់ទេ បែកវង្វេងពេញព្រៃ ។

បូលី៖ ហើយអង្ករដាក់ចុងឈើហ្នឹង?

គឹមចុង៖ អង្ករ ស្រូវធ្វើត្បាញដូចកន្ត្រោររបស់ជនជាតិ ប្រហែល១០០គីឡូ តែក្រោយមកស្វាហែក ប្រហែលជាអស់២០-៣០ភាគរយ តែនៅ ។

បូលី៖ ដាក់នៅក្រោមខ្លាចដីរជាន់?

គឹមចុង៖ បាទ! ដីរជាន់ ហើយបុកអត់លំបាកទេ ជីកដីបុកក្នុងដីអត់មានធ្វើត្បាលទេ កាប់ដើមឈើហើយបុកទៅ ហើយអុំទៅ ។ មានជនជាតិនៅជាមួយខ្ញុំចេះត្បាញចង្អេរ ត្បាញទៅហើយដំឡូងពេលខ្លះគេចិតហាល ហើយគេស្ពាយទៅ តែខ្ញុំអត់ចិតទេខ្ញុំបុក ។

ដានី៖ ដំឡូងយើងដាំហ្នឹង ឬដំឡូងព្រៃ?

គឹមចុង៖ ដំឡូងចំការ ក្រោយ៧៩តាមសហករណ៍ដាំ គាស់ដំឡូងហ្នឹងយកមកហូប ហើយខ្ញុំខុសគេខ្ញុំបុកឲ្យទៅជាម្សៅ ហើយមុននឹងចំអិនលាយវាឲ្យសើមហើយយកទៅដាក់ចំហុយឆ្អិនដូចនំប៉័ង ហើយហូបទៅ ហើយស្ពាយបានច្រើន ក្នុងម្នាក់ស្ពាយបានកន្លះខែ កាផាល់របស់ជនជាតិហ្នឹង ញុកឲ្យណែនទៅហូបអាហ្នឹង ។

បូលី៖ ដេកពួនយប់ព្រលប់ម៉េចទៅ?

គឹមចុង៖ ខែប្រាំងអស់លំបាកទេ យប់ត្រង់ណាដេកត្រង់ហ្នឹង កាលហ្នឹងកងទ័ពយួនវាតត្បាតខ្លាំងពេក ឧបមាថាព្រលប់ៗខ្ញុំនៅត្រង់ហ្នឹង ម៉ោង៧-៨ខ្ញុំឲ្យស្រាយអង្រឹងចល័តចេញប្រហែល២០០ម៉ែត្រ ទៅទាំងយប់តែម្តង ទៅសំងំដេកនៅហ្នឹង ព្រឹកឡើងដាំបាយហើយលុបកន្លែងចេញ ដើរលាក់ដាន ចុះកងទ័ពវៀតណាម១០០ម៉ែត្រមួយខ្សែៗ រាស់តែម្តង ។

ដានី៖ ចូលមកច្រើន?

គឹមជុង: ៤កងពលរតនគិរី ។

បូលី: រតនគិរីតែឯង៤កងពល?

គឹមជុង: បាទ! ៤កងពល ពួកខ្ញុំនាំគ្នាដើរ ឆ្នាំងស្ពាយកាំភ្លើងទង្គិចលឺសូរក្រូកៗ អ្ហ៎! មកដល់ហើយ គឺបមើលទៅឃើញមួយខ្សែ ។

បូលី: ម៉េចបានអ៊ីដឹងថាមាន៤កងពល វៀតណាម?

គឹមជុង: ហ្នឹងការផ្សាយតាមវិទ្យុ តាមវិទ្យុរបស់ខ្មែរក្រហម កាលហ្នឹងខ្ញុំមានវិទ្យុស្តាប់ដែរ រាគត្បាតបោសសំអាតកំលាំងខ្មែរក្រហមស្លាប់អស់ច្រើន តែសំរាប់អ្នកនៅជាមួយខ្ញុំស្លាប់តិចបំផុត ខ្ញុំលាក់ ។

បូលី: ម៉េចក៏មិនចុះចូលជាមួយវៀតណាម រត់មកក្នុងវិញមក?

គឹមជុង: ដូចជាទឹកនិងប្រេង មានគំនិតថាជាតិមួយ ថាខ្លួនឯងថាមានគំនិតជាតិ ស្នេហាជាតិហើយ វៀតណាមចូលមកមិនមែនចូលមកជួយកម្ពុជា គឺឈ្លានពានតែម្តង ច្បាស់ថាឈ្លានពាន ហើយកំណត់ខ្លួនឯងថាឈ្លានពានអីចឹងតែម្តង ព្រោះការរៀបចំនៅក្នុងរដ្ឋអំណាចភូមិឃុំ វៀតណាមទាំងអស់ អីចឹងមានន័យថាមិនមែនមកជួយទេ ជួយផ្សេង ខ្ញុំនិយាយទៅវាប៉ះកន្លែងខ្លះ មានចំណុចសើបដែរ អីចឹងខ្ញុំមិនព្យាយាមធ្វើអត្ថាធិប្បាយឲ្យវែងឆ្ងាយទេ កន្លែងហ្នឹង តែកំណត់ខ្លួនឯងថាឈ្លានពាន ។ ខ្ញុំយកឧទាហរណ៍តែមួយ ក្នុងឋានៈយើងជាមិត្តជិតខាងហេតុអីមកវាយកព្រំដែន វាមានសង្គ្រាមនៅព្រំដែន ដោយសារអីមិនមែនរឿងរបបកម្ពុជាប្រជាធិបតេយ្យមួយទេ ក្រោយមកខ្ញុំមើលឯកសារផ្សេងៗ មិនមែនមករករឿងកម្ពុជាប្រជាធិបតេយ្យទេ វាមានរឿងកន្លែងខ្លះវាពិបាកនិយាយដែរ ។

បូលី: ខ្ញុំសុំយោបល់អ៊ំកន្លែងហ្នឹងមួយ សុំកាត់បន្តិច កន្លែងហ្នឹងយើងចាត់ទុកថាជាការពិភាក្សាដែលមិនកត់ត្រា បានន័យថាខ្ញុំមិនយកទៅប្រើ រហូតដល់ពេលបច្ចុប្បន្នអ៊ំគិតថានៅតែជាការឈ្លានពាន ឬមិនមែនទេ?

គឹមជុង: ខ្ញុំនៅរក្សាគំនិតហ្នឹងដដែល ហេតុផលកន្លែងខ្លះខ្ញុំឃើញ ពីមុនខ្ញុំអត់ឃើញទេ ពីមុនខ្ញុំអត់ឃើញទេ តែឥឡូវខ្ញុំឃើញ ឃើញអី? តែអូនឯងថតទៅចូលក្នុងរឿង ខ្ញុំឃើញខ្ញុំនិយាយពិត ខ្ញុំនិយាយការពិតនៅពេលដែលទស្សនៈរបស់ខ្ញុំ ខ្ញុំឃើញ ខ្ញុំមើលទៅរាល់ថ្ងៃគណបក្សនយោបាយមើលតែអាហ្នឹងដឹងហើយ ហេតុអីបាននាំឲ្យគណបក្សសង្គ្រោះជាតិឡើងសំលេង? ហេតុអីបានគណបក្សប្រជាជនធ្លាក់ចុះ? ខ្ញុំនៅនេះខ្ញុំអត់ទេ រហូតដល់ចៅហ្វាយស្រុកចាស់គាត់ថា នៅពេលដែលគេរាប់សន្លឹកឆ្នោតគេចាត់តាំងខ្ញុំឲ្យតាមដាន

សន្លឹកឆ្នោត ខ្ញុំថាបងឯងចាំមើលគណបក្សប្រជាជនមិនមែន៩២ទៀតទេ ប្រហែលជាអាចចុះនៅក្នុងកំរិត៧០ ។ មិនដែលទេឯងចេះតែទាយ ថាឲ្យខ្ញុំអីចឹង ។

ដានី: ពូវ៉ាន់ កុសល ហ្នឹង?

គីមថុង: បាទ! ដល់ពេលប្រកាសលទ្ធផលបណ្ដោះអាសន្ន ខ្ញុំថាវិភាគត្រូវ បានក្រោយមកគាត់សួរថា ហេតុអីបានលោកឯងវិភាគអីចឹង? ខ្ញុំថាទី១ខ្ញុំមើលសភាពការណ៍ជាក់ស្ដែងជាក់ស្ដែងអី គណបក្សសម រង្ស៊ី សម្ព័ន្ធជាមួយសិទ្ធិមនុស្ស ហើយអាពីរហ្នឹងប្រឆាំងកាលណាមាន២ឡើងកំលាំង ពីមុនដៃគូមានតែម្នាក់ទេ មួយទល់មួយ ឥឡូវពីរទល់មួយមានន័យថាមានកំលាំង ។ ទី២ទំនាស់នៅក្នុងសង្គម ទំនាស់អី? មន្ត្រីរាជការទំនាស់ជាមួយអ្នកមានអំណាចធំៗ ។ ទី៣ ទំនាស់កសិករ ជាមួយអ្នកមានលុយ ឃើញទេមួយរយៈមុនបោះឆ្នោតរឿងដី ដល់រឿងដីមិនទំនាស់ ហើយក្នុងសង្គមមន្ត្រីរាជការប្រាក់ខែតិច តូចចៅគេចេះតែមានទៅ ខ្ញុំនិយាយក្រៅផ្លូវការទេ គំនិតរបស់ខ្ញុំ ។

ដានី: ជាយោបល់ ។

បូលី: ខ្ញុំថាគំនិតអ៊ំជ្រៅណាស់ អ៊ំប្រើភាសា២ ទី១ទំនាស់មន្ត្រីរាជការនិងអ្នកមានអំណាច, ទំនាស់កសិករជាមួយអ្នកមានលុយ ភាសា២ហ្នឹងជ្រៅមែនទែន ។

គីមថុង: ទំនាស់មួយទៀតទំនាស់ជាមួយអ្នកលក់ដូរ ទំនាស់ជាមួយពីណា? ប៉ូលីស ប៉េអឹម អូនឯងឃើញអត់នៅភ្នំពេញ ឃើញ ។ ខ្ញុំឧទាហរណ៍តូចមួយទេ រវាងអ្នកមានអំណាចនិងអ្នកអត់អំណាច ឥឡូវអូនឯងសង្កេតមើលភ្លើងស្តុបមួយៗ គំនូសអង្កន់ៗក្រហមឃើញឡានខ.ម និងឡានន.ប ដែលទៅឈប់កន្លែងកំរិតហ្នឹងទេ នៅក្នុងនេះ ហ្នឹងហើយដែលអ្នកមានអំណាចមិនគោរពច្បាប់ ហ្នឹងហើយដែលនាំ ។ តែទី២ ប្រវត្តិសាស្ត្ររបស់អាមេរិកដែលជាប់ប្រធានាធិបតីបានមកស្រុកខ្មែរទេ អត់មានទេ លើកទី២ហើយដែលបារ៉ាក់អូបាមាមកបន្ទាប់ពីខេនណាឌី អីចឹងអត់? អូនឯងប្រហែលជាដឹងប្រវត្តិសាស្ត្រជាងខ្ញុំ ។

បូលី: មិនទេ ។

គីមថុង: បារ៉ាក់អូបាមាមកភ្នំពេញ មកធ្វើអី មកលើកទឹកចិត្តសម រង្ស៊ី និង កឹម សុខា អីចឹងបានមើលការឃោសនា នៅពេលឃោសនាបោះឆ្នោត ។ ទី៣ សយ សុភាព ទាយខុសទាយខុសអី? ខុសត្រង់ថាបើសម រង្ស៊ី ចូលស្រុកគាត់កោក្បាល ពីព្រោះសម រង្ស៊ីនៅក្នុងប្រព័ន្ធតុលាការ តែចាប់សម រង្ស៊ី បានអត់ អត់ចាប់បានទេ ដោយសារបារ៉ាក់អូបាមាមកមុន មិនអីចឹង ។ រឿងអីផ្សេងៗចំហរ សំងាត់ខ្ញុំអត់ដឹងទេ គ្រាន់តែ

ចរចារទេ្វភាគី ហ្នឹងជារូបភាពមួយដែលខ្ញុំវិភាគ រឿងនយោបាយនឹងប្រែប្រួល ។ ហើយ ប៉ុល ពត ផ្ដាំគាត់ថាខ្ពស់បំផុតប្រាំអាណត្តិ រាជរដ្ឋាភិបាលដែលរៀបចំឡើងបន្ទាប់ពី រដ្ឋាភិបាលអ៊ុនតាក់ គាត់ថាខ្ពស់បំផុត៥អាណត្តិ បានគាត់វែកញែកដូចខ្ញុំនិយាយម៉ិញ អីចឹង ។

បូលី៖ ចង់និយាយថាបន្ទាប់ពីប្រាំអាណត្តិហើយ ។

គឹមឋុង៖ ចាប់ពីអាណត្តិទី១ ដល់អាណត្តិទី៥នឹងប្រែប្រួលស្ថានការណ៍នយោបាយ ឥឡូវប្រែប្រួល មិនអីចឹង អាណត្តិទី៥ប្រែប្រួល ប្រែប្រួលអី? ពីមុនអាមេរិកប្រើកូន៣ អត់កំលាំង សម្ព័ន្ធជាមួយគណបក្សប្រជាជនបន្តិចរលាយ ក្រោយមកសម រង្ស៊ីប្រឆាំង តែសម្ព័ន្ធ ជាមួយកឹម សុខា ហើយធ្វើបាន អីចឹងវានឹងប្រែប្រួល ។ ទំនាស់ផ្ទៃក្នុងជាតិ ទំនាស់ផ្ទៃ ក្នុងសង្គម ហើយខ្ញុំមើលឃើញហ្នឹង ខ្ញុំប្រាប់កូនខ្ញុំ វាថាហែរគណបក្ស ហែរទៅពុកមាន យាត់អី កុំឲ្យតែពុកប្រាប់ថាឯងកុំហែរគណបក្សសមរង្ស៊ី, គណបក្សប្រជាជន តែពេល ឯងទៅបន្ទប់១ម៉ែត្រ ទៅគូសសន្លឹកឆ្នោតស្រេចតែឯង មិនអីចឹង ខ្ញុំអត់ហាមយាត់ រឿងកូន ។ ខ្ញុំប្រាប់ថាកូនឯងធ្វើនយោបាយសួរពុកសិន ថាត្រូវធ្វើយ៉ាងម៉េច ខ្ញុំថាយក ល្អកុំដើរមុខគេ ដើរក្រោយគេ អ្នកដែលដើរទូលគ្រែឈើដើរមុខគេ ហើយបើគាត់ ស្មោមុតបន្ទា បើយើងក្រោយគេ ហើយយើងធ្វើនយោបាយដើរក្រោយគេ អ្នកណាចាញ់កុំទៅជាមួយគេ អ្នកឈ្នះទៅជាមួយគេ គំនិតខ្ញុំរាល់ថ្ងៃខ្ញុំគិតអីចឹង ។

បូលី៖ ខ្ញុំសុំបើកrecordវិញ សុំបន្ត ។

គឹមឋុង៖ បើកចុះ សុំឲ្យការនិយាយរបស់ខ្ញុំចាត់ទុកជាការសន្ទនាលេងមួយ ។

បូលី៖ អត់យកជាប្រើការទេ ។

គឹមឋុង៖ ជាការគិតរបស់ខ្ញុំម្នាក់ឯងទេ ខ្ញុំភ្លាប់បញ្ហាច្រើនយ៉ាង ។

បូលី៖ សុំបើកវិញ បន្តមកនេះវិញ ប៉ុន្មានខែដែលរត់នៅក្នុងព្រៃ?

គឹមឋុង៖ ខ្ញុំនៅប្រហែលជា៥ខែ គិតទៅចាប់ពីថ្ងៃ៧ មករា ខ្ញុំឆ្លងទន្លេខែ៨ ខ្ញុំឆ្លងទន្លេមេគង្គ ហើយខ្ញុំបានសរសេរប្រវត្តិរបស់ខ្ញុំ ខ្ញុំសរសេរបណ្ដើរអង្គុយបាយបណ្ដើរ ខ្ញុំសរសេរខ្ញុំ ដាក់flash ទុកឲ្យកូនខ្ញុំមើល ។ ខ្ញុំឆ្លងម៉ោង៨យប់ ឆ្លងគ្រាន់តែចេញផុតពីច្រាំងបាន ប្រហែល១០០ម៉ែត្រព្យុះមកពីប ខ្ញុំឆ្លងកាត់កោះស្រឡាយ កោះព្រាលហ្នឹង ស៊ីងត្រែង ត្រូវខ្យល់ អ្នកណាអ្នកចម្លងខ្ញុំ ទាហានរដ្ឋកម្ពុជាហ្នឹង ។

បូលី៖ អាហ៎!

គឹមឋុង៖ បាទ! អ្នកចម្លងខ្ញុំ ។

បូលី៖ ទៅអីចឹងវិញ?

គឹមថុង៖ ខ្ញុំសួរថា អូនឯងស្ដាប់ភាសាខ្ញុំបានអត់? ថាបាន ។ ខ្មែរឬយួន? ថាខ្មែរ អីចឹងខ្មែរនិងខ្មែរមានអីឈ្លោះគ្នា ។ តែរាល់ថ្ងៃអ្នកណាជាអ្នកគ្រប់គ្រងអូនឯង? ថាវៀតណាម ។ ឯណាបន្ទាយ? នោះនៅនោះ អីចឹងខ្មែរឲ្យវៀតណាមគ្រប់គ្រង ។ អីចឹងបងឯងទៅណា? ខ្ញុំត្រូវការឆ្លងទៅត្រើយម្ខាង ហើយអូនឯងដឹងថាអូនឯងចង់រស់ទេ ថាចង់ ចុះខ្ញុំបែកម៉ែ បែកឪ ខ្ញុំរត់ទៅរកម៉ែឪខ្ញុំកុំឲ្យខ្ញុំរស់ម៉េច អូនឯងសម្លាប់ខ្ញុំក៏បានដែរខ្ញុំនៅកណ្ដាប់ដៃអូនឯង កាំភ្លើងខ្ញុំមានគ្រាប់ដែរ តែខ្ញុំអត់បាញ់អូនឯងទេ បើអូនឯងសម្លាប់ខ្ញុំបាញ់មក ។ ហ៊ឺ! អត់ទេ ខ្មែរនិងខ្មែរអត់ឈ្លោះគ្នា ថាអីចឹងជួយចម្លងខ្ញុំ ចម្លងដល់ត្រើយ ខ្ញុំមានអាហ្នឹងឡើងទៅដល់លើគោកខ្ញុំប្រជុំទៅជាមួយខ្ញុំ២០នាក់ ។ សុទ្ធតែអ្នកដែលនៅបឹងកន្សែងជាមួយខ្ញុំ កំលាំងហ្នឹងនៅជាមួយខ្ញុំឡើងមកខ្ញុំប្រជុំថា ខ្ញុំអត់ស្គាល់គោលដៅទេ តែយើងមានត្រីវិស័យមួយ គេប្រាប់ថាទៅដើងប៉ះភ្នំដងរែកហើយអីចឹងយើងទៅ គេប្រាប់លេខត្រីវិស័យឲ្យដើរចំណុចប៉ុន្មានៗ ដើរតាមហ្នឹង ។ មុននឹងលឺមាត់គោ មាន់រងាវអីទៅស៊ើបមើល មានវៀតណាម មានយួនអត់ ស៊ើបមើលបើថាអត់ទេបេញមកវិញចូលភូមិទៅ សុំអង្ករគាត់ ប្រាប់ថាខ្ញុំកងទ័ពរំដោះ កងទ័ពអាពត? ថាបាទចុះពួកមកប្ដូនគេ ខ្ញុំអត់ដឹងទេ មិនមែនពួកខ្ញុំទេ ។ មានពួកអាព័តខ្មៅ នៅម្តុំស្រុកថាឡាបរិវ៉ាត់ទៅប្ដូន ថាមិនមែនពួកខ្ញុំទេ ពួកខ្ញុំចង់ហូបអីខ្ញុំសុំ ហើយមករស់រហូតដល់ខ្ញុំឡើងភ្នំដងរែក ។

បូលី៖ អ៊ំឆ្លងពីណាទៅណា? ពីទីរួមខេត្តស្ទឹងត្រែងទៅថាឡាបរិវ៉ាត់?

គឹមថុង៖ អត់ទេ ខ្ញុំឆ្លងម្តុំភូមិនេះ ភូមិកោះសំពាយ ។

ដានី៖ ក្របេះវិញ?

បូលី៖ កោះសំពាយនៅខាងសៀមបូក?

គឹមថុង៖ ក្របេះអីទេខាងក្រោម កោះសំពាយនៅខាងក្រោមទីរួមខេត្តស្ទឹងត្រែងបន្តិច ។

បូលី៖ សៀមបូក?

គឹមថុង៖ សៀមបូកត្រើយម្ខាង ទល់មុខសៀមបូកវានៅខាងក្រោមថាឡាបរិវ៉ាត់ ។

បូលី៖ សៀមបូកទល់មុខថាឡាបរិវ៉ាត់?

គឹមថុង៖ ខាងក្រោម ។

ដានី៖ ខាងកោះកន្ទុយគោ?

គឹមថុង៖ នេះជាទន្លេមេគង្គ នេះត្រើយខ្ញុំឆ្លងនេះ ។

បូលី: ខាងស៊ីងត្រែងមែន?

គឹមថុង: ខាងស៊ីងត្រែង នេះសៀមបូកនៅនេះ នេះហៅថាឡាបរិវ៉ាត់ ខ្ញុំនៅហ្នឹង ខ្ញុំឆ្លងនៅហ្នឹង ។

បូលី: អ៊ំឆ្លងទៅថាឡាបរិវ៉ាត់?

គឹមថុង: ខ្ញុំឆ្លងទៅត្រើយថាឡាបរិវ៉ាត់ ។

បូលី: នេះថាឡាបរិវ៉ាត់?

គឹមថុង: នេះខ្ញុំឆ្លងមួយជួរនេះ ខ្ញុំឆ្លងមកដល់នេះ បានខ្ញុំដើរកាត់មកចេះ ដើរមកកន្លែងមុំ៣ ។

បូលី: នេះមុំ៣?

គឹមថុង: បាទ! ដើរមកនេះ នៅនេះ ។

បូលី: ឆ្លងទន្លេយើងប្រើរយៈពេលប៉ុន្មាន?

គឹមថុង: ឆ្លងមួយយប់ទល់ភ្លឺ ពីព្រោះខែវស្សា ខែវស្សាទឹកហូរហើយចែវទូកឡើងទឹកហូរ ហើយចន្លោះបន្ទាយយួន បន្ទាយយួននៅកោះសន្ទាយ ខ្ញុំឆ្លងជិតហ្នឹង ដល់ពេលវង្វេងទូកខ្យល់ព្យុះវង្វេងខ្ញុំកេះដែកកេះ ហើយទាហានខ្មែរហ្នឹងគាត់ថាបងឯងកុំកេះដែកកេះ បើកេះង៉ាប់ហើយខ្ញុំ អាមារិនវ៉ានេះក្បែរហ្នឹងមកវ៉ៃង៉ាប់ទាំងអស់គ្នា ខ្ញុំថាខ្ញុំរស់ម្នាក់ឯងអត់កើតទេ ខ្ញុំត្រូវរស់ជាមួយមិត្តភក្តិខ្ញុំ ។ កេះទៅបានក្អែកបន្ទោរប្រៀកៗចេះតែចែវកាត់រកគ្នាមកជួបគ្នាបុកច្រាំង ជិតភ្លឺដល់ច្រាំងម៉ោង៤ ឡើងទៅភ្លឺប្រជុំគ្នាថាយើងកុំចោលគ្នា បើឈឺនៅមើលគ្នាទាល់តែជា លើកលែងតែស្លាប់ បើអ្នកអត់ស្លាប់ អ្នកអត់ឈឺ ចេះតែដឹកដៃទៅរហូតដល់គោលដៅ ។

បូលី: ឆ្លងមួយយប់ពេញប៉ុន្មានទូក?

គឹមថុង: ឆ្លងទៅជាមួយខ្ញុំ៣ទូក មួយទូកគ្នា៦នាក់ ។

បូលី: ហើយអ្នកដែលកងទ័ពខាងរដ្ឋកម្ពុជាចម្លងអ៊ំហ្នឹង ប៉ុន្មាននាក់?

គឹមថុង: ទូកមួយ២នាក់ៗ កាំភ្លើងនៅហ្នឹង ។

បូលី: ៦នាក់អីចឹង?

គឹមថុង: បាទ! គាត់៦នាក់ ហើយគាត់ដាក់សំណាញ់ ដល់ពេលគាត់ឡប់មកវិញភ្លឺគាត់ដើរបង់សំណាញ់ កងទ័ពវៀតណាមមកថាគាត់អ្នកឈ្លបភូមិ ហើយលាគាត់ គាត់ថាទៅឲ្យបានសុខសប្បាយ ខ្មែរមានមនោសញ្ចេតនាអីចឹង ។ គាត់ឡប់ទៅគាត់ថាបង់ត្រី ពីព្រោះបើប្រៀបធៀបគាត់ត្រូវចុះទៅចេះបានដល់ភូមិកោះសំពាយហ្នឹង ។

បូលី: ហើយយើងដើរៗម៉េច? ដើរសរសៀលតាមព្រំដែនរហូត ឬយ៉ាងម៉េច?

គឹមថុង: អត់សរសៀលទេគាត់តែម្តង កាត់សំដៅទៅព្រំដែន ។

ដានីៈ កាត់ពីត្រឹមណាទៅត្រឹមណា?

គឹមថុង: កាត់ពីនេះទៅ សំដៅទៅមុំ៣ ។ នេះមុំ៣កាត់សំដៅមកបេះ ហើយមានកងទ័ពគេនៅចាំស្កាត់ ចាំស្កាត់កំលាំងដែលឆ្លងពីខាងកើតទន្លេ ។

បូលីៈ កងទ័ពពីណា?

គឹមថុង: កងទ័ពដែលមកនៅព្រំដែន កងទ័ព៨០១មួយចំនួយ តា០៥ឆ្លងទៅមុនគេ ឆ្លងមុំខាងលើសំបូរ ។

បូលីៈ កោះរងាវ?

គឹមថុង: កោះរងាវ គាត់ឆ្លងមុំហ្នឹង គាត់ដើរទៅដល់មុនគេបានទូរលេខ បានទាក់ទងកំលាំងឲ្យទៅមុនគេ ខ្ញុំទៅជួបគ្រួសារខ្ញុំនៅហ្នឹង ។

ដានីៈ បែកគ្នាអីចឹង?

គឹមថុង: បាទ! បែកគ្នាតាំងពី៧៩ ខ្ញុំមកជួបប្រពន្ធខ្ញុំនៅមុំ៣ គាត់នៅដឹកជញ្ជូន ។

បូលីៈ ចំណាយពេលប៉ុន្មានចាប់ពីឆ្លងដល់ថាឡាបរិវ៉ាត់រហូតដល់មុំ៣?

គឹមថុង: ខ្ញុំចំណាយពេលពេលប្រហែល១អាទិត្យ ខ្ញុំដេកនៅក្នុងព្រៃ ជួបកងទ័ពវៀតណាមខ្ញុំអត់បាញ់គេច ។ ជួបនៅមុំត្រាង ដងផ្ចិត ជួបខ្ញុំគេច ហ្នឹងខ្ញុំបានជួបកំលាំងដែលចាំស្ទាក់ហ្នឹង ហើយគេនាំផ្លូវបានលឿន បើឲ្យខ្ញុំទៅមកតែគ្នាខ្ញុំមិនដឹងអង្កាលដល់ទេជួប ។ រាល់ថ្ងៃនៅប្រធានភូមិទួលតាសេក ។

បូលីៈ អ្នកនាំផ្លូវ?

គឹមថុង: បាទ! អ្នកនាំផ្លូវ គាត់នៅចាំគ្នាមួយក្រុម ខ្ញុំជួបកំលាំងនៅភូមិអន្លង់ជ្រៃ ជួបគាត់ ។

បូលីៈ ក្នុងខេត្តអីគេ?

គឹមថុង: អន្លង់ជ្រៃដូចនៅក្នុងខេត្តព្រះវិហារហ្នឹង ស្រុកសៀមបូក ។

បូលីៈ សៀមបូក ស្ទឹងត្រែងទេអ៎ំ សៀមបូកនៅខាងទន្លេទេ ។

គឹមថុង: មកនៅអន្លង់ជ្រៃខ្ញុំអត់ដឹងថា ។

បូលីៈ មានតែឆែប ព្រះវិហារ?

គឹមថុង: បាទ! នៅរង្ហង់ហ្នឹង នៅខាងត្បូងឆែប នៅភូមិអន្លង់ជ្រៃ ។

ដានីៈ ខាងកំពង់ស្រឡៅ?

គឹមថុង: បាទ! នៅខាងក្រោយ អន្លង់ជ្រៃដូចជានៅក្នុងខេត្តស្ទឹងត្រែងនៅឡើយទេតាមខ្ញុំមើល ។

បូលីៈ អន្លង់ជ្រៃ ព្រះរំកិល?

គឹមថុង: ព្រះរំកិលខ្ញុំអត់ទៅទេ មកអន្លង់ជ្រៃ មកមុំចំការលើ ។

ដានី: ហួសថាឡាបរិវ៉ាត់អី?

គឹមថុង: ខាងក្រោយថាឡាបរិវ៉ាត់ ។

បូលី: អីចឹងបានន័យថាអ្នកដែលចាំទៅយកអឹំ ទៅយកតាំងពីស្ទឹងត្រែងមកម្ល៉េះ?

គឹមថុង: នៅស្នាក់ហ្នឹង គេនៅដើរ ។

ដានី: តែយើងឆ្លងទន្លេមកម្ខាង?

គឹមថុង: ឆ្លងទន្លេមកម្ខាងតែគេធ្វើការជាមួយប្រជាពលរដ្ឋ ស្នាក់នៅតាមភូមិ ការពារក្រែងលោពួកខ្ញុំចូលទៅរកស្បៀង ក្រុមហ្នឹងហើយ គេស្នាក់បើឃើញកងទ័ពសួរទៅមកពីខាងកើតទន្លេ ឲ្យផ្ដល់ព័ត៌មានទៅពួកគាត់ ។ ចេះទេសកាលអីខ្ញុំចូលទៅជួបនៅភូមិហ្នឹង អន្លង់ជ្រៃដល់គេអត់ទុកចិត្ត គេត្រៀមនៅតាមចំការស្រូវហ្នឹង ហើយមកឃើញគេស្លៀកខោអាវខៀវៗហើយ កងទ័ពចិនឲ្យ ខោអាវចិនឲ្យ ហើយមានពីដុង ស្ពាយកាំភ្លើងគ្រាប់ណែនៗបានគេនាំឡើងមកហ្នឹង ។ ខ្ញុំឡើងនៅកន្លែងគេហៅដូវរូង មានរូងថ្មមួយឡើងទៅលើហើយកាលហ្នឹងកងទ័ពនៅខាងលើ គេកំពុងតែរៀបចំកំលាំងចុះមកវ៉ៃទីតាំងវៀតណាមនៅត្រពាំងគល់ ហើយខ្ញុំឆ្លងប្រហែលម៉ោង៨ ឡើង២ម៉ោងបានដល់លើភ្នំ ។

ដានី: ឡើងចំណុចណាអឹំអាចចង្អុលបានទេ?

គឹមថុង: ទាល់តែមានផែនទីហាសិបពាន់បានចង្អុលច្បាស់ ។

បូលី: អាចអញ្ជើញទៅផែនទីនោះបន្តិចបានទេ អាធំ?

គឹមថុង: អត់ទេ មានផែនទីមួយទៀត ផែនទីលំអិត ផែនទីយោធាខ្នាតពីរយហាសិប ។

ដានី: យើងអត់មាន? នៅនេះអត់មាន?

គឹមថុង: អត់មានទេ ។

បូលី: អានោះអាចជួយបានច្រើន អានេះតូចពេក ។

គឹមថុង: បានតើ! អានេះមុំ៣ ព្រំប្រទល់ នេះកន្លែងម្តុំពេទ្យអ៊ូងខ្ញុំហៅពេទ្យអ៊ូងភូមិថៃ ។

ដានី: ចុះគ-៧ នៅម្តុំណា?

គឹមថុង: គ-៧ នៅនេះទេ នេះ ។

ដានី: ពេទ្យកាលជិតនាំហ្នឹងទៅដល់១០០១ មានពេទ្យមួយដែលពេទ្យគ-៧?

គឹមថុង: គ-៧ មិនមែនទេ ។

ដានី: នៅខាងក្នុងនេះវិញ?

គឹមថុង: នេះគ-៧ នៅមួយជួរនេះទេ នេះផ្សារព្រះវិហារ នេះសំរោង នេះអន្លង់វែង នេះគ-៧ នៅមួយជួរនេះ ។

បូលីៈ ព្រះប្រឡាយនេះ?

គឹមថុនៈ បាទ! ព្រះប្រឡាយ គ-៧ ។

បូលីៈ អ៊ំជាំស្វាម៉ុំណា?

គឹមថុនៈ ហ្នឹងមួយជួរជាំស្វា ស៊ឹងចាន់ ថៃហៅថាហួរចាន់ៗហ្នឹង មួយជួរហ្នឹងគ-៧ នៅហួសព្រះប្រឡាយ ច្រកព្រះប្រឡាយ ។

បូលីៈ ឥឡូវច្រកហ្នឹងនៅសល់នៅឡើយ? ច្រកព្រះប្រឡាយ?

គឹមថុនៈ នៅ ។

បូលីៈ បើយើងទៅ ទៅដល់ទេ?

គឹមថុនៈ ដល់ ។

បូលីៈ មានផ្លូវឡានទៅ?

គឹមថុនៈ ឡើងទៅឆ្ងាយជាងមួយគីឡូ ឡើងផ្លូវច្រក ។

បូលីៈ បើឡានទៅដល់ត្រឹមណា?

គឹមថុនៈ ឡើងដល់ព្រំដែន ។

បូលីៈ ឡាន?

គឹមថុនៈ ឡានដល់ទំនប់ដាច់ ហួសទំនប់ដាច់ ឡើងយូរដែរ ។

បូលីៈ ហ្នឹងគេហៅជាំស្វា? ច្រកជាំស្វា?

គឹមថុនៈ មិនមែនជាំស្វាទេ ច្រកព្រះប្រឡាយ ទៅពីច្រកព្រះប្រឡាយបានដល់ជាំស្វា ស៊ឹងហួយចាន់, គ-៧ ។

បូលីៈ អីចឹងទាល់តែឆ្លងពីព្រះប្រឡាយទៅទៀតបានទៅដល់ជាំស្វា?

គឹមថុនៈ គ-៧ ជាទឹកដីរបស់ថៃ ជិរំ ។

បូលីៈ ពីព្រោះតាមខ្ញុំដឹងថា តាម៉ុក ដាច់ជើងនៅកន្លែងជាំស្វាហ្នឹងឯង?

គឹមថុនៈ អត់ទេ ដាច់ជើងនៅព្រះប្រឡាយ ។

បូលីៈ ផ្លូវចុះព្រះប្រឡាយ?

គឹមថុនៈ បាទ! ដាច់នៅព្រះប្រឡាយ ។

ដានីៈ អីចឹងពេលដែលអ៊ំឡើងមកដល់កន្លែងម៉ុំ៣ ១០០១ ខែប៉ុន្មាន ឆ្នាំណាទៅ?

គឹមថុនៈ ប្រហែលជាខែ៨ ខែកក្កដាខ្ញុំមកដល់ហ្នឹង ហើយខ្ញុំនៅប្រហែលជា១ខែ បានគេជ្រើសរើសមនុស្ស ខ្ញុំមកដល់នេះ ជិះឡានមួយយប់ទល់ភ្លឺ ។

បូលីៈ តាមថៃ?

គឹម ចុង៖ បាទ! គាត់តាមខេត្តហ្នឹង ចេញពីនេះមក ។

បូលី៖ ស៊ីសាកេត?

គឹម ចុង៖ បាទ! ស៊ីសាកេត មកកាត់សុរិន្ទ ដល់ស្រះកែវ, ជិនបូរី ខេត្តត្រាតដល់ ព័ត៌មានគេថា ទៅចិន គេថាទៅរៀននៅចិន ។

បូលី៖ ជ្រើសរើសយកទៅរៀននៅចិន ។

គឹម ចុង៖ បាទ! ប៉ុន្តែ ចេះតែលឺតៗទេ តែអ្នកដែលប្រាប់ខ្ញុំមិនមែនទេ ទៅជួយធ្វើការងារនៅកន្លែង៨៧ ទៅដល់ខ្ញុំនៅហ្នឹង ។

បូលី៖ ខ្ញុំសុំសួរនេះបន្តិច រយៈពេល១ខែដែលអ៊ំនៅ ហេតុអីបានជាខាងខ្មែរក្រហមជ្រើសរើសយកកន្លែងធ្វើជាតំបន់ប្រមូលផ្តុំធំ បន្ទាប់ពីដួលរលំ?

គឹម ចុង៖ តាមពិតមិនមែនជាកន្លែងមួយ តាមពិតនៅតាមព្រំដែនរហូត សំឡូត តែកន្លែងនេះ សុន សេន មកដល់កន្លែងនេះមុនគេ ។ សុន សេន ចេញពីភូមិភាគឧត្តរមកនៅហ្នឹង មកនៅជាមួយតាម៉ុក ខ្ញុំមកឃើញមន្ទីរគេ ខ្ញុំដើរកាត់ទៅលេងគ្រួសារខ្ញុំ ។

បូលី៖ ហៅ១០០១ហ្នឹង?

គឹម ចុង៖ បាទ! ១០០១ ជាកន្លែងដែលមានផ្ទុកឃ្លាំងធំដែរ ហេតុអីបាននៅហ្នឹង? ព្រោះកងទ័ពភាគច្រើននៅម្តុំនេះ ម្តុំភូមិភាគឧត្តរ នៅផ្គត់ផ្គង់ហ្នឹង ហើយកងទ័ពទាំងអស់ត្រូវឡើងមកហ្នឹង ។

បូលី៖ ការជ្រើសរើសដោយសារកងទ័ពនៅម្តុំនេះ?

គឹម ចុង៖ ខ្ញុំមិនដឹងមូលហេតុអីបានគេជ្រើសរើសមកត្រង់ហ្នឹងទេ ប្រហែលជាមានសន្តិសុខគេយ៉ាងម៉េចខ្ញុំអត់ដឹងដែរ ឬមួយក៏ខាងថៃ ភាគីថៃគេកំណត់មកនៅកន្លែងហ្នឹង ឬយ៉ាងណាខ្ញុំអត់ដឹងទេ ដោយសារកងទ័ពនៅនេះច្រើនខ្ញុំមើល ភាគច្រើនកងទ័ពផ្តុំៗនៅហ្នឹងហើយជាកងពលកំលាំងធំ ៨០១នៅទាំងមូលនៅនេះ ។ មណ្ឌលគិរីនៅទាំងមូល ៤១៧នៅភូមិភាគឧត្តរនៅទាំងមូល អីចឹងកំលាំងផ្តុំជាងគេ ។

បូលី៖ បុកមកនេះ?

គឹម ចុង៖ បុកមកនេះសំរាប់ផ្គត់ផ្គង់ ។

ដានី៖ តាម៉ុកគាត់មកហ្នឹងមុនដែរ?

គឹម ចុង៖ មួយជួរអស់នេះរាយប៉ាយកំលាំងអត់មូល កំលាំងមូលតែប៉ៃលិនមួយទេ ។

បូលី៖ ប៉ៃលិនបានមូល?

គឹមថុង៖ មានមូលតែប៉ៃលិនមួយទេ ហើយក្រៅពីហ្នឹងនៅនេះទាំងអស់ នៅតាកែវ ភ្នំវល្លិ៍ នៅនេះ រាយបាយទេ ទើបមានមូលដ្ឋានដែលនាំឲ្យមានទាំងអស់មានឡើង ។

បូលី៖ មូលដ្ឋានប៉ៃលិន?

គឹមថុង៖ បាទ! មូលដ្ឋានប៉ៃលិនតែអត់វីងប៉ុងអីប៉ុន្មានទេ អ្នកនេះដែលនាំឲ្យវីងពីហ្នឹងទៅ ។

បូលី៖ ពង្រីង១០០១, ១០០២, ១០០៣?

គឹមថុង៖ ដើមកំណើតដំបូងហ្នឹងឯង បានមកទំនាក់ទំនងនៅប៉ៃលិន នៅម៉ាឡៃ នៅសំឡូតៗជា កន្លែងមួយរបស់តាទិត, ស៊ូ មេត ហើយតាសាន មកពីនីរតី មកពីខាងផ្នែកនេះ ក្រោយមកបានពង្រីករៀបចំដូចជាឃ្លាំងនៅ ឃ្លាំងខ្មែរក្រហមមួយនៅគេហៅតែវ៉ាន់ៗ តំបន់តែវ៉ាន់ ។

បូលី៖ ខាងណាវិញ?

គឹមថុង៖ នៅដ-២៥ នៅគេហៅម៉ុំនេះ ខ្ញុំភ្លេចហើយម៉ុំនៅថៃ ។

ដានី៖ ដ-២៥ នៅខាងម៉ាឡៃ?

គឹមថុង៖ ប៉ាក់តុង ។

បូលី៖ នៅម៉ុំណាវិញ បើខាងខ្មែរយើងវិញម៉ាឡៃ? នេះម៉ាឡៃ, សំពៅលូន, ភ្នំព្រឹក, កំរៀង?

គឹមថុង៖ នៅមួយជួរនេះ ។

ដានី៖ នៅកន្លែងហ្នឹង កន្លែងរបស់អៀង សារី?

គឹមថុង៖ បាទ!

ដានី៖ នៅម៉ាឡៃ ដ-២៥ ។

គឹមថុង៖ ឃ្លាំងធំជាងគេ ចេញពីហ្នឹងមកនេះ ។

បូលី៖ ឃ្លាំងធំជាងគេ គេហៅអីគេ?

គឹមថុង៖ នៅគេហៅតែវ៉ាន់ ថៃវាហៅតែវ៉ាន់ៗ អៀង សារី មួយជួរហ្នឹង ។

បូលី៖ នេះឃ្លាំងមួយ?

គឹមថុង៖ ធំហើយ គ្រាប់រំសេវមកនេះ ផ្គត់ផ្គង់អានេះ ឡានចេញពីហ្នឹងមកអីៗដឹកពួកខ្ញុំចេញពី ហ្នឹងមក ។

បូលី៖ ទាំងគ្រាប់ ទាំងសម្ភារៈ ទាំងម្ហូបអាហារ នៅហ្នឹងទាំងអស់?

គឹមថុង៖ បាទ! នៅហ្នឹងទាំងអស់ ។

បូលី៖ ឃ្លាំងធំមួយ?

គឹម ចុង: ចេញពីបាន់កកមកហ្នឹង ។ ក្រោយមកមាននេះមួយទៀតគេហៅក-១ ហៅភីអូនៅជិតខេត្តត្រាតមានឃ្លាំងមួយធំដែរ មានរថក្រោះ ក្រោយមកថៃយកអស់ ។

បូលី: ហ្នឹងឃ្លាំងហ្នឹងមួយ?

គឹម ចុង: ហ្នឹងធំ ផ្គត់ផ្គង់សមរភូមិក្នុងៗហ្នឹង ហ្នឹងដែលជិតក-១៨ ។

បូលី: ឃ្លាំងធំមួយទៀតជិតក-១៨ គេហៅអីគេឃ្លាំងធំហ្នឹង?

គឹម ចុង: គេហៅឃ្លាំងក-១ ទេមិនមែនទេ ខ្ញុំភ្លេចច្រើន កាលខ្ញុំនៅជានាយទាហានអ៊ុនគាត់ ខ្ញុំជិះឡានតាមហ្នឹង ។

បូលី: នៅនេះលឺសូរថាមានឃ្លាំងធំមួយដែរ ១០០៣?

គឹម ចុង: បាទ! ១០០៣ ជាកន្លែងមួយដែរ ។

បូលី: ចអីគេ? ច-១៧?

គឹម ចុង: ច-៧ហ្នឹងហើយនេះៗ ។

បូលី: ឃ្លាំងធំនេះច-៧?

គឹម ចុង: ឈ្មោះខ្មែរហៅច-៧ ។

បូលី: នៅ១០០៣លឺសូរថាមានឃ្លាំងធំមួយដែរ របស់តាម៉ុក សំរាប់ផ្គត់ផ្គង់មួយទីតាំង១០០៣?

គឹម ចុង: ហ្នឹងតាម៉ុក គ្រប់គ្រង ។ នេះសុន សេន ។ នេះតាម៉ុក ។

ដានី: ដែលអ៊ំមកដល់ដំបូងខែប៉ុន្មាន? ខែ៨ ឆ្នាំ៧៩?

គឹម ចុង: បាទ!

ដានី: ពេលមកដល់អ៊ំឃើញពីណាមុនគេនៅហ្នឹង?

គឹម ចុង: ខ្ញុំឃើញមេទ័ព ឃើញជួបដំបូងតាឆន ។ តាឆន ប្អូនថ្លៃសុន សេន នៅ៨០២ ។

ដានី: ឥឡូវគាត់នៅម៉ាឡៃ?

គឹម ចុង: លើកកំលាំងទៅរៃត្រពាំងគល់ហ្នឹងខ្ញុំជួបតាឆន ហ្នឹងមុនគេ តាឆន ឲ្យមីខ្ញុំមួយឡាំង ។ ទើបនឹងមក? បាទ ទើបនឹងមក ឲ្យមីមួយឡាំងហើយនាំគ្នាហូបនៅហ្នឹង ។

ដានី: អ៊ំបានឃើញសុន សេន គាត់នៅហ្នឹងអត់?

គឹម ចុង: សុន សេន ខ្ញុំអត់ជួបទេ ខ្ញុំជួបមុននឹងខ្ញុំមកនេះ ពេលហ្នឹងគេហាត់យោធា ហើយគេហាត់ហាត់នៅកន្លែងខ្ញុំ ហើយគ្រូបង្រៀនអ្នកមកពីចិន ។

បូលី: ជនជាតិចិន ឬខ្មែរ?

គឹមថុង: អត់ទេ ខ្មែរយើងកាលពាឆ្នាំគេរើសទៅរៀនចំរាញ់ប្រេងកាត រៀនធ្វើភ្លើង រៀនខាងរថក្រោះ រៀនខាងកាំភ្លើងធំ ហើយមកគេបង្អាត់អាហ្នឹង ដល់ពេលឆ្នាំ៧៩ចិនគេបង្រៀនខាងយោធា មកបង្រៀនហើយសុន សេន គេមកមើលអាហ្នឹង គេមកអង្គុយមើល លូនក្រាបអីហ្នឹង ។

បូលីៈ នៅ១០០១នេះមានដូចថាគេភូមិ-ឃុំ ផ្ទះសំបែងអីត្រឹមត្រូវ?

គឹមថុង: គេដំរំ ដំរំរស់នៅក្នុងទឹកដីថៃខ្លះ ក្នុងដីយើងខ្លះ តែឃ្លាំងនៅក្នុង គេហៅភូមិពេទ្យអ៊ូង១ ។

ដានីៈ ពេទ្យអ៊ូងឈ្មោះភាសាថៃ?

គឹមថុង: បាទ! ភូមិពេទ្យអ៊ូង ។

បូលីៈ ដំរំអីគេ១០០១?

គឹមថុង: ហៅ១០០១ហ្នឹងតែម្តង ។

ដានីៈ ១០០១ម៉េចបានគេជ្រើសរើសយកឈ្មោះ១០០១?

គឹមថុង: ខ្ញុំអត់ដឹងទេ ពីព្រោះខ្មែរក្រហមដាទំលាប់របស់គាត់ច្រើនតែដាក់លេខ ។

បូលីៈ កំពស់ភ្នំឬយ៉ាងម៉េច?

គឹមថុង: មិនដឹងទេ ភ្នំមុំហ្នឹងតែ២០០ទេកំពស់ ។

បូលីៈ អត់ដល់១គីឡូ?

គឹមថុង: បាទ!

បូលីៈ ដំរំយើងនៅជារបៀបម៉េច? ជាខ្ទមតូចៗឬតង់?

គឹមថុង: ប្រក់កៅស៊ូតង់ អាកៅស៊ូផ្លាស្ទិកហ្នឹងក្តោចង់ដាប់ ។

ដានីៈ អ៊ំថាមកជួបប្រពន្ធអ៊ំ ដូចថាប្រជាជនមកនៅច្រើនអត់?

គឹមថុង: នៅច្រើន មកពីភូមិភាគឧត្តរផង គ្រួសារកងទ័ពផង ប្រជាពលរដ្ឋមកពីតាធាត់ផង មកពីរតនគិរីផង នៅពេញហ្នឹង ។

បូលីៈ ប្រហែលប៉ុន្មាន?

គឹមថុង: មនុស្សច្រើនពាន់មិនធម្មតា នៅពេញហ្នឹងទាំងអស់ ព្រលឹមឡើងផ្សែងដូចស្អីអីចឹង ខ្ញុំគ្រាន់តែដើរកាត់ទេ កន្លែងខ្ញុំនៅជាប់មាត់ទន្លេល្ពៅ ទីតាំងខ្ញុំនៅអនុសេនាធំខ្ញុំហ្នឹង ។

ដានីៈ ប្រជាជនមកពីខាងឧត្តរមកនៅហ្នឹងដែរ?

គឹមថុង: បាទ! មកដែរ ។

ដានីៈ អ្នកគ្រប់គ្រងប្រជាជនពីណាគេ?

គឹមថុង: កាលហ្នឹងដូចតាអាន អ្នកនៅឧត្តរ តែលឺតែមុខទេអត់ដែលឃើញ ។

ដានីៈ អត់ដែលឃើញ?

គីមថុនៈ អត់ៗ

បូលីៈ ទន្លេល្ពៅហ្នឹងប៉ុណ្ណាអ៊ំ?

គីមថុនៈ តូច អូរហ្នឹងៗ

បូលីៈ គ្រាន់តែអូរតូចមួយតា៎?

គីមថុនៈ គ្រាន់តែហូរទៅ ហៅទន្លេល្ពៅ ទៅក្រោមទៀតគេហៅអូរៗ

បូលីៈ ទទឹងប៉ុន្មានម៉ែត្រ?

គីមថុនៈ ទៅក្រោមធំ ឧស្សាហ៍ឆ្លងកាត់ដែរប៉ុនព្រែកសង្កែដែរ ប៉ុណ្ណឹងទៅក្រោមៗ

ដានីៈ ប្រហែល៥ម៉ែត្រ?

គីមថុនៈ មិនមែន៥ទេ ១០-២០អីទៅ ទៅទឹកនៅខាងលើហៅក្បាលអូរល្ពៅ ដល់ទៅក្រោមគេហៅទន្លេល្ពៅដែរ ទៅក្រោមទៀតគេហៅអូរអីទៀតខ្ញុំភ្លេចទៅៗ

ដានីៈ កាត់ស្រុកអីខ្លះទៅ?

គីមថុនៈ អត់កាត់ទេ ជាព្រំដែនតែម្តង ព្រំដែនលាវ-ខ្មែរ ខាងកើតភូមិខ្ទីម ខាងជីលាវៗ

ដានីៈ ម្តុំណាទៅទន្លេល្ពៅ?

គីមថុនៈ មួយដួរហ្នឹងៗ

បូលីៈ វាហូរពីណាមក?

គីមថុនៈ ហូរពីលើភ្នំទៅ ពីប្រែក១០០១ធ្លាក់ទៅៗ

បូលីៈ ហូរពីលើភ្នំទៅ?

គីមថុនៈ បាទ! ហូរទម្លាក់ពីប្រែក១០០១ហ្នឹងទៅៗ

បូលីៈ ប្រភពពីណាមក?

គីមថុនៈ ប្រភពទឹកពីហ្នឹងទៅ ទន្លេល្ពៅៗ

បូលីៈ ចេញពីភ្នំទៅ?

គីមថុនៈ ចេញពីភ្នំទៅៗ

បូលីៈ មិនមែនចេញពីទន្លេសេសាន ទន្លេសេកុង?

គីមថុនៈ អាហ្នឹងធ្លាក់ទៅទន្លេមេគង្គៗ

បូលីៈ ប្រែកនេះនៅសល់ដល់រាល់ថ្ងៃទេ ប្រែក១០០១?

គីមថុនៈ ខ្ញុំអត់ដឹងទេ តែលឺថាមានកងទ័ពយើងទៅនៅហ្នឹងៗ

បូលីៈ មានកងទ័ពៗ

គឹមថុង៖	ខាងកងពលលេខ៩ ។
ដានី៖	កងពលលេខ៩របស់ពីណាគេ?
គឹមថុង៖	អតីតខ្មែរក្រហមដែរ នៅហ្នឹង មេកងពលអត់ដឹងទេ បើសេនាធិការផ្ទះនៅខាងលិច ។
ដានី៖	ពីណាគេ?
គឹមថុង៖	ជិន គេត ។
បូលី៖	មានអីចង់បន្ថែមរឿង១០០១ឲ្យច្បាស់ ។
ដានី៖	អ៊ីពេលហ្នឹងកងពល១០០១មានតែពាកងពលហ្នឹងទេ?
គឹមថុង៖	មានកងពលច្រើនណាស់ចេញពីហ្នឹង ។
បូលី៖	មាន៨០១, ៩២០ ។
គឹមថុង៖	៨០២ ហើយកងពលតាធាត់ ១០៧, ១០៥ ។ ១០៧នៅមណ្ឌលគិរី, ១០៥នៅរតនគិរី ។
ដានី៖	អីចឹងមកដល់ហ្នឹងមានបង្កើតកងពល៨០២មួយទៀត?
គឹមថុង៖	បាទ! មាន៨០២ ហើយមាន៤១៧ ។
ដានី៖	មាន៨០១, ៨០២, ៤១៧?
គឹមថុង៖	បាទ! ៤១៧ ។
ដានី៖	មានតែពាហ្នឹងទេ?
គឹមថុង៖	ហើយមានវរសេនាធំឯករាជ្យ១០៧របស់តាធាត់ នៅមណ្ឌលគិរី ហើយ១០៥របស់ ។
ដានី៖	របស់តាអន ស៊ី?
គឹមថុង៖	មិនមែនទេ មិនមែនអន ស៊ី ។ អន ស៊ីនៅ១០៧ហ្នឹង ។
ដានី៖	តាវៀង , តាសារុន?
គឹមថុង៖	ហ្នឹង១០៧ ហើយនៅនេះរបស់១០៥របស់តាថាន ស្លាប់ហើយ ១០៥ហ្នឹង ។
ដានី៖	៩២០នៅហ្នឹងដែរ?
គឹមថុង៖	៩២០នៅហ្នឹងដែរ ។
ដានី៖	អីចឹងបានន័យថាមាន៨០១, ៩២០, ១០៧, ៤១៧?
គឹមថុង៖	១០៧, ៤១៧, ១០៥ ។
បូលី៖	៨០២មួយទៀត?
ដានី៖	៨០២ បង្កើតនៅពេលហ្នឹងដែរ?
គឹមថុង៖	បាទ! ៨០២ បង្កើតក្រោយមក តាឆន, ផ្ទះគាត់ហ្នឹង ។

ដានី៖ ផ្ទះតាឆន?

គឹមចុង៖ បាទ! ផ្ទះតាឆន ។

បូលី៖ នេះ?

គឹមចុង៖ បាទ! ហ្នឹង ផ្ទះតាឆន ។ ឥឡូវគាត់នៅតាំ ។

ដានី៖ អីចឹង៨០១ក្រែងតា០៥ នៅគ្រប់គ្រង?

គឹមចុង៖ គ្រប់គ្រងរួមដូចជាមេកងពលធំមួយ ។

ដានី៖ តាអ៊ុង វ៉ែន?

គឹមចុង៖ អ៊ុង វ៉ែន ដូចជានៅវរសេនាធំមួយឯករាជ្យ ខ្ញុំភ្លេចដែរ ។

ដានី៖ មិនមែន៨០២ទេ?

គឹមចុង៖ ខ្ញុំបាត់ប្រវត្តិរូបហើយ ខ្ញុំចេញមកខ្ញុំនៅបានតែប៉ុន្មាន ខ្ញុំចេញមក ការរៀបចំរចនាសម្ព័ន្ធកងទ័ពអីក្រោយ ខ្ញុំចេញមកនៅនេះ ។

ដានី៖ ១០៧ មាន?

គឹមចុង៖ តាធាត់, តាសារុន, តាវិច ។ ព្រោះខ្ញុំមកនៅនេះខ្ញុំដឹងតាមរយៈរៀបចំឯកសារ ។

ដានី៖ តាវិច អីមានប្រសាសន៍ម៉ិញនៅភូមិកណ្ដាលហ្នឹង?

គឹមចុង៖ បាទ?

ដានី៖ តេ វិច ហ្នឹង?

គឹមចុង៖ នៅពេល ឃុំផ្លាវ ។

ដានី៖ តាវិច ហ្នឹងគាត់នៅជាមួយ?

គឹមចុង៖ នៅជាមួយតាធាត់, តាសារុន, តាអន ស៊ី ក្រុមគាត់ ។

ដានី៖ ចុះតាឆន ឥឡូវគាត់នៅ?

គឹមចុង៖ តាឆន នៅ៨២ ខាងកងពលលេខ៨២ ។

ដានី៖ សព្វថ្ងៃគាត់នៅរស់?

គឹមចុង៖ កាលមុនគាត់មកនេះ លឺថាមកៗ តែខ្ញុំអត់ដែលជួបមុខគាត់ ។

ដានី៖ តែគាត់ទៅនៅម៉ាឡៃ?

គឹមចុង៖ មិនដឹងថានៅណាឥឡូវ មិនដឹងគាត់នៅណា ខ្ញុំអត់ដែលបានជួបគាត់ទេ ផ្ទះគាត់មានដើមបេងមួយធំណាស់ នៅនោះ ។

បូលី៖ អ៊ំនៅ១០០១បានតែមួយខែទេ?

គឹមចុង៖ បាទ! ហើយខ្ញុំមកនៅនេះរហូត រហូតមានកិច្ចព្រមព្រៀងប៉ារីស ។

បូលីៈ អត់ដូរទៅណា?

គីមថុងៈ អត់ដូរ ក្រោយពីមានកិច្ចព្រមព្រៀងប៉ារីសខ្ញុំមកនៅប៉ៃលិន ខ្ញុំនៅជាប្រធានខាងភាគីកម្ពុជាប្រជាធិបតេយ្យ ។

បូលីៈ កាលពីអ៊ំមកនៅនេះដំបូងគេប្រាប់ថាបញ្ជូនទៅចិន ដើម្បីរៀនសូត្រ?

គីមថុងៈ បាទ! រៀន អាហ្នឹងមិនមែនគេប្រាប់ផ្លូវការទេ តៗគ្នា ។

បូលីៈ លឺសូរ?

គីមថុងៈ បាទ! លឺតៗគ្នា មិនដឹងប្រធានអង្គភាព ឬអ្នកណាទេ ថាពួកនេះពួកទៅចិន ហើយពួកខ្ញុំមានដឹងអី ។

ដានីៈ អ៊ំកាលពីដំបូង កាលពី១០០១ គេជ្រើសរើសដំបូង គេមានប្រាប់ថាជ្រើសរើសយ៉ាងម៉េច? ជ្រើសរើសប៉ុន្មាននាក់?

គីមថុងៈ អត់ទេ គេថាជ្រើសរើសយកអ្នកដែលមានចាប់ពីថ្នាក់ទី៣ ឲ្យតែចេះសរសេរអក្សរស្អាតគួរសមគេយកហើយ ខ្ញុំស្ម័គ្រចិត្តដាក់ពាក្យ គេមកគេជ្រើសរើសមក ។

បូលីៈ ទាំងអស់ប៉ុន្មាននាក់មកជាមួយអ៊ំ?

គីមថុងៈ ដូចជាជាង២០នាក់មួយឡាន អាឡានកង់៦មួយពេញ ។

ដានីៈ ចាំឈ្មោះអ្នកណាខ្លះដែលមកជាមួយ?

គីមថុងៈ ភ្លេចអស់ហើយ មានស្លាប់ មានរស់ខ្លះ ភាគច្រើននៅនោះ ។

ដានីៈ នៅណាទៅ?

គីមថុងៈ នៅម៉ាឡៃ នៅប៉ៃលិន ភាគច្រើន មកនេះមកតែខ្ញុំមួយទេ មកតែខ្ញុំព្រោះខ្ញុំស្អប់ពួកតាម៉ុក ខ្ញុំមកនេះ ។ នៅពេលដែលខ្ញុំនៅជំរំភូណយខ្ញុំគេចចេញពីតាម៉ុក តាម៉ុក ចុចមីនខ្ញុំបីសងាប់មួងនៅហ្នឹង ដោយសារខ្ញុំអត់ទៅផ្ដិតមេដាយចូលជាមួយរាជរដ្ឋាភិបាលគាំទ្រតាម៉ុក ខ្ញុំមកចូលម្នាក់ឯង ហើយខ្ញុំបានជិះខថមភាគចក្រពីអន្លង់វែងទៅធ្វើបុណ្យ៧មករានៅភូមិភាគ៤នេះ ជិះទៅជាមួយឧត្ដមសេនីយ៍មួយឈ្មោះ អ៊ីង លាងៗ ។

ដានីៈ ជាមួយពីណា?

គីមថុងៈ អ៊ីង លាង ។

ដានីៈ អ៊ំ!

គីមថុងៈ ខ្ញុំទៅនៅហ្នឹង កាលហ្នឹងឯកឧត្ដម ម៉ៅ ទឹម អភិបាលខេត្តឧត្ដរមានជ័យគាត់នៅភូមិភាគជិះជាមួយគាត់ទៅធ្វើបុណ្យ៧ មករា នៅសៀមរាប ។

ដានីៈ កងពលសែបប៉ុន្មានអ៊ីង លាង?

គីមចុង: ៨២ ហើយខ្ញុំមកម្នាក់ឯងតែម្តង ខ្ញុំអត់មានគ្នាមកទេ ខ្ញុំមកពីរនាក់ ម្នាក់នីរសា នៅផ្ទាល់ជាមួយ ខៀវ សំផន ជាប់ផ្ទះខ្ញុំរាល់ថ្ងៃ។ ម្នាក់ហ្នឹងឯងកាលគេវ៉ៃខៀវ សំផន បែកក្បាលគាត់នៅផ្ទាល់បរិយាកាសហ្នឹង។

បូលី: ពីណាគេ?

គីមចុង: សុខ រឿ។

បូលី: សុខ រឿន?

គីមចុង: សុខ រឿ ឈ្មោះគាត់សុខ រឿ។

បូលី: នៅណាឥឡូវ?

គីមចុង: នៅជាប់ផ្ទះខ្ញុំ នៅផ្ទាល់ជាមួយខៀវ សំផន។

ដានី: ពេលដែលគេចូលទៅភ្នំពេញ គេវ៉ៃ?

គីមចុង: វ៉ៃបែកក្បាល គាត់នៅក្នុងបរិយាកាសហ្នឹង។

បូលី: គាត់ឈ្មោះ សុខ រឿ?

គីមចុង: សុខ រឿ ហើយថ្ងៃហ្នឹងខ្ញុំ បើថ្ងៃហ្នឹងទៅក្រោយ ខ្ញុំត្រូវទៅថ្ងៃ២៧ មិនមែនថ្ងៃ២៧ទេ ថ្ងៃ២៧គេវ៉ៃគាត់ ធ្វើបាតុកម្មវ៉ៃផ្ទះគាត់នៅផ្លូវក្បោះហ្នឹង ហើយថ្ងៃ២៨ខ្ញុំត្រូវជិះកងវ៉ាន់ពី ក-១៨ទៅបាងកក ថ្ងៃ២៩ខ្ញុំត្រូវឡើងយន្តហោះទៅ។

ដានី: កាលហ្នឹងគាត់មានផ្ទះមួយនៅកន្លែងផ្លូវក្បោះហ្នឹង?

គីមចុង: បាទ! មានតាំ។

ដានី: ផ្ទះរបស់គាត់ ឬផ្ទះរបស់ខាងខ្មែរក្រហម?

គីមចុង: ជួលគេ ថ្ងៃក្រោយបានទិញមួយទៀតនៅទួលមុខហ្នឹង កន្លែងគេវ៉ៃបាក់បែក។

បូលី: ផ្លូវក្បោះផ្សារអូឬស្សី?

គីមចុង: ខ្ញុំអត់ទាន់ស្គាល់ទេ ទៅភ្នំពេញចង់ឃើញដល់ហើយ។

ដានី: ហ្នឹងទិញម៉េច យើងយកលុយយើងទៅទិញតែម្តង?

គីមចុង: លុយសល់មាគគោក ហើយបាត់លុយច្រើនដែរ បើជំនាន់ខ្ញុំទៅបានច្រើនក្រោយ។

បូលី: បាត់ប៉ុណ្ណា?

គីមចុង: លុយទាំងហិប១ មិនដឹងប៉ុន្មានខ្ញុំអត់ដឹងដែរ។

បូលី: ដុល្លា?

គីមចុង: បាទ! ជាលុយដុល្លា លុយចិន។

បូលី: លុយចិន?

គីមថុនៈ លុយដុល្លាតែលុយដុល្លារបស់អាមេរិក តែជំនួយរបស់ចិន សល់តាំងពីសម័យសង្គ្រាម ។ ថ្ងៃខ្ញុំទៅ ត្រូវដើងខ្ញុំទៅបានច្រើន លុយ ពីព្រោះកាលហ្នឹងគេរៀបចំឲ្យក្នុងចំណោមហ្នឹង មាន២-៣នាក់ កាលសម័យអ៊ុនតាក់ ។

បូលីៈ ទៅជាមួយពូណុប សុជាតិអត់ទេ?

គីមថុនៈ បាទ?

បូលីៈ ណុប សុជាតិ, យឹម ដាន់ណា, តាបាវ?

គីមថុនៈ តាបាវ កាន់នៅនេះ, ដាន់ណា ហៅអិលអូរ ។

បូលីៈ គាត់ទៅភ្នំពេញដែរពេលហ្នឹង ឃើញរូបថតគាត់ថតនៅមុខវាំង?

គីមថុនៈ ទៅភ្នំពេញទៅលេងទេ ការពិតកន្លែងគាត់ប្រចាំនៅសៀមរាប កន្លែងអិលអូរនៅសៀមរាបទេ ជានាយទាហានប្រចាំនៅតាមភាគីមួយៗ ៤ភាគី តែរបាយការណ៍រាយការណ៍មកប៉ៃលិននៅកន្លែងខ្ញុំ ។

ដានីៈ អ៊ីខ្ញុំចង់បកទៅនេះ ចាំតិចទៀតទៅខាងក្រោយ ។ អីចឹងពេលដែលអ៊ំមកកន្លែងកោះកុងមកកន្លែងមន្ទីរក-១៨ កាលហ្នឹងយើងចេញពីហ្នឹងមកដល់កន្លែងក-១៨ កាលហ្នឹងយើងមានក្រុមយើងគ្នាប៉ុន្មាននាក់ទៅ?

គីមថុនៈ យកគ្រប់កន្លែង សំឡូតក៏យក យកមនុស្សប្រហែលជាជាង១០០នាក់ទៅនៅកន្លែងហ្នឹងទៅរៀបចំជាក្រុមជំនួយការរបស់៨៧ ។

ដានីៈ ៨៧ហ្នឹងឈ្មោះមន្ទីរ?

គីមថុនៈ ៨៧ជាឈ្មោះមន្ទីររបស់ប៉ុល ពត ក្រោយសម័យ៧៩ហើយ ។

បូលីៈ នៅក្នុងដីថៃ?

គីមថុនៈ នេះគាត់នៅក្នុងដីថៃ តែនៅចំរិ ខាងភ្នំ ។

បូលីៈ ប៉ុន្មានគីឡូពីដីខ្មែរទៅ?

គីមថុនៈ ដីប្រហែលមួយគីឡូជាង ។

បូលីៈ មួយគីឡូដីទេ?

គីមថុនៈ បាទ! ភ្នំអីចឹងខ្ញុំនៅចំរិ វិទ្យុនៅហ្នឹង ដើមកំណើតវិទ្យុ ។

ដានីៈ ប៉ុស្តិ៍វិទ្យុអីហ្នឹង?

គីមថុនៈ បាទ!

បូលីៈ គេហៅមន្ទីរ៨៧?

គីមថុនៈ អត់៨៧ទេ កាលហ្នឹងដាក់ឈ្មោះអន្លុភាព១៣១ ។

បូលីៈ តែអ៊ឹថា៨៧មិញស្អីគេអាហ្នឹង?

គឹមចុនៈ នៅក្នុងហ្នឹងជាមន្ទីររបស់៨៧ ។

ដានីៈ តែមន្ទីរ៨៧វាមានមន្ទីរតូចៗតាមហ្នឹងទៀត ។

គឹមចុនៈ មានក្រុមជំនួយការតូចៗ ជំនួយការខាងការបរទេស, ជំនួយការខាងសង្គមកិច្ច, ជំនួយការខាងយោធា, ជំនួយការខាងនយោបាយ មានលេខរបស់គេ ។

ដានីៈ តែអ៊ឹមានប្រសាសន៍មិញថាមន្ទីរ៣១មិញជា ។

គឹមចុនៈ ១៣១ ក្រោយមករៀបចំអង្គភាពហ្នឹងដាក់ឈ្មោះ១៣១ ។

បូលីៈ ដូរទៅវិញ?

គឹមចុនៈ បាទ! លេខ១៣១ ។

បូលីៈ លែងហៅ៨៧ហើយ?

គឹមចុនៈ លែងហើយ ហៅ១៣១ មន្ទីរ១៣១ ។

ដានីៈ ឆ្នាំណាដែលគេប្តូរផ្លាស់? មុនដំបូងពី៧៩មកមន្ទីរ៨៧?

គឹមចុនៈ បាទ! មន្ទីរ៨៧ខ្លាយមកតាមភ្នំដងរែក តាមភ្នំក្រវាញ ក៏រត់តាមសំឡូត មកតាមពាមតាយ ហើយសំងំហ្នឹង បានរៀបចំអង្គភាព១៣១ដែលមានជំនួយការ ។

ដានីៈ ឆ្នាំណាហ្នឹង?

គឹមចុនៈ ដូចជាឆ្នាំ៨១ ហើយខ្ញុំនៅអង្គភាព២១ ។

ដានីៈ ចំណុះឲ្យមន្ទីរ១៣១?

គឹមចុនៈ បាទ! ២១ហ្នឹងទទួលខាងផ្នែកកងទ័ព កងទ័ពមានទទួលខាងផ្នែកប្រយុទ្ធ ខាងផ្នែកក្តាប់កំលាំងខ្មាំង ខាងផ្នែកខាងការបរទេស ដូចខាងបរទេសទាក់ទងនឹងអាវុធ ហ្នឹងខ្ញុំនៅផ្នែកហ្នឹង ហើយខ្ញុំទទួលមួយផ្នែក ។

បូលីៈ ផ្នែកអីគេផ្នែកអ៊ឹ?

គឹមចុនៈ ខ្ញុំនៅខាង ឥឡូវគេហៅដីបេ ។

ដានីៈ ដីបេ ខាងស៊ើបការណ៍?

គឹមចុនៈ បាទ! ខាងស៊ើបការណ៍ ។

បូលីៈ សរសេរម៉េចដីបេ?

គឹមចុនៈ ដីបេជាភាសារបស់បារាំងពីដើម ។

បូលីៈ សរសេរយ៉ាងម៉េច?

ដានីៈ ដីបេពាក្យពេញថាម៉េច?

គីមថុន៖ ភាសាបារាំងក្មេច ការពិតគេសរសេរបេះ ដីបេ ។

បូលី៖ ដីបេហ្នឹងគឺអង្គភាពស៊ើបអង្កេត?

គីមថុន៖ បាទ! អង្គភាពស៊ើបអង្កេត ដូចជាប៉ុល ពត ថាម្ដងខ្ញុំចាំដែរ ជាភាសាបារាំង ហើយខ្ញុំនៅខាងផ្នែកហ្នឹង បន្ដមកទៀតគេហៅផ្នែក៣១ ទទួលខាងប្រជាជនមានចំនួនប៉ុន្មានហើយគាំទ្រអ្នកណាខ្លះ ហ្នឹងខាងផ្នែកចំនួនប្រជាជន ។

បូលី៖ ស្ថិតិនិយាយទៅ?

គីមថុន៖ បាទ! បន្ទាប់មកទៀតមានផ្នែក៤១ ទទួលខាងសង្គមកិច្ច ។

បូលី៖ អីខ្លះទៅសង្គមកិច្ចហ្នឹង?

គីមថុន៖ សង្គមកិច្ចទាក់ទងដល់ពេទ្យ ទាក់ទងសុខភាពហ្នឹងផ្នែក៤១ បន្ទាប់ពីហ្នឹងមានផ្នែក៥១ទៀត អង្គភាព១៣១រៀបចំផ្នែកល្អិតៗទៀត ។

ដានី៖ ៥១ហ្នឹងខាងផ្នែកអីគេ?

គីមថុន៖ ៥១ខាងផ្នែកសេដ្ឋកិច្ច ដូចជាការគេពាណិជ្ជកម្ម ដូចជាស្រូវ អង្ករ ខាងកសិកម្មខាងផ្នែកហ្នឹង ។ ផ្នែកមួយទៀត៦១ ហ្នឹងទទួលខាងសរសេរសៀវភៅអប់រំ ផ្នែកហ្នឹងដែលសរសេរសៀវភៅខ្មែរក្រហមរៀនត្រឹមថ្នាក់ទី១រហូតដល់ទី៥ ។

បូលី៖ មានត្រឹមទី៥ទេអី?

គីមថុន៖ បាទ! ទី៥ បានក្រោយមក កាំង ហ្កេកអ៊ាវ គាត់សរសេរសៀវភៅមួយទៀតគណិតវិទ្យាខ្ពស់ៗ គាត់ដាក់ក្នុងហ្នឹងដែរ ។ ក្រោយពី កាំង ហ្កេកអ៊ាវ មកនៅនេះ គាត់មកនៅជាមួយពួកខ្ញុំ គ្រួសារខ្ញុំដាំបាយឲ្យហូបរាល់ថ្ងៃ ។

ដានី៖ មានត្រឹម៦១ហ្នឹងទេ?

គីមថុន៖ បាទ! ៦១ហើយបាន៧១ ទទួលខាងផ្នែកបរទេស គ្រប់ទ្វីបអាមេរិក អាហ្វ្រិក អូស្រ្តាលី ។

ដានី៖ ការបរទេស ការទូត?

គីមថុន៖ បាទ! ខាងផ្នែកការទូត ហ្នឹងមានប៉ុណ្ណឹងអ្នកជំនួយការប៉ុល ពត ។

ដានី៖ នេះមន្ទីរតូចៗវាមាន៥មន្ទីរ ហើយបូកជាមួយដីបេមួយទៀត?

គីមថុន៖ ដីបេនៅក្នុង២១ ។

ដានី៖ ដីបេនៅក្នុង២១ ឬ៣១?

គីមថុន៖ ២១ មានផ្នែកវាតូចៗទៀត ។ ២១មានផ្នែកផ្ញើសំណង់សមរភូមិ ។

ដានី៖ ចុះវិទ្យុក្នុងណា?

គឹមចុង: វិទ្យុអត់មាននៅក្នុងណា ទាំងអស់គ្នាហ្នឹងហើយដំណឹងផ្សាយវិទ្យុគឺក្រុម១៣១អ្នកបញ្ចេញទៅ។ វិទ្យុមាន២ មួយនៅប៉េកាំង មួយនៅក្នុងស្រុក ហើយសំរាប់ដំណឹងពួកខ្ញុំនេះភាគច្រើនដំណឹងសមរភូមិទេ ធ្វើតាមសារទូរលេខទៅប៉េកាំង។

ដានី: វិទ្យុក្រោមផ្នែកនេះផ្ទាល់ អត់មានក្រោមផ្នែកតូចទេ?

គឹមចុង: ប្រហែលជាក្រោយរំលាយបក្សកុំមុយនីស្ត។

ដានី: នៅក្រោមតែមួយទេ?

គឹមចុង: ក្រោម១៣១ តែបញ្ជាផ្ទាល់របស់ប៉ុល ពត។

ដានី: ដំបូងខ្ញុំចង់ដឹងថានៅក្នុងមន្ទីរ៨៧ ឬ១៣១ហ្នឹង ពីណាខ្លះនៅក្នុងមន្ទីរហ្នឹងដូចជាមេធំៗ?

គឹមចុង: ឃើញខៀវ សំផន គាត់នៅក្នុងហ្នឹងដែរ, នួន ជា អត់នៅទេ នួន ជា គាត់នៅសំឡូត មានអីគាត់មកប្រជុំគ្នានៅកន្លែងហ្នឹង។ អៀង សារី គាត់នៅកន្លែងម៉ាឡៃ តាម៉ុក នៅកន្លែងនេះ។

បូលី: ១០០៣?

គឹមចុង: ហើយសុន សេន នៅនេះ។

បូលី: ១០០១។

គឹមចុង: ថ្ងៃណាគេជួបគ្នាគេជិះឡានមកជួបគ្នានៅនេះ។

ដានី: នេះមានតែប៉ុល ពត ហើយនិងខៀវ សំផន?

គឹមចុង: បាទ! ពីព្រោះខៀវ សំផន គាត់ត្រូវការចេញចូលខាងការងារទូត។

ដានី: ពីណាគេប្រធានមន្ទីរនេះ?

គឹមចុង: ឈ្មោះ ដែន ឥឡូវនេះនៅប៉េកាំង អត់មកទេ។

ដានី: ឈប់មក?

គឹមចុង: គាត់ឈប់មក។

ដានី: គាត់ឈ្មោះដែន?

គឹមចុង: បាទ! គាត់ទៀយណាយគាត់ម៉េចគាត់នៅ ពីដំបូងគាត់ទៅនៅបកភាសាបង្រៀនអ្នកដែលនិយាយវិទ្យុប៉េកាំងភាសាខ្មែរ។

ដានី: ដែន ប្រពន្ធគាត់ឈ្មោះអីទៅ?

គឹមចុង: ខ្ញុំភ្លេចឈ្មោះប្រពន្ធ ហើយកាំង ហ្គេកអាវ ក៏ទៅនៅប៉េកាំងទៅបង្រៀនភាសាខ្មែរហ្នឹងដែរទិសដៅ តែក្រោយមានកិច្ចព្រមព្រៀងប៉ារីសមកកុំឲ្យបែក ឡប់មកវិញ។

ដានី: អីចឹងឈ្មោះដែន គាត់ធ្វើប្រធាននៅហ្នឹងរហូតដល់ឆ្នាំណា?

គឹមថុង៖ ប្រធាន ផែន ក្រោយមកដូចគេបោះឆ្នោត ពីព្រោះនៅមន្ទីរ១៣១ រចនាសម្ព័ន្ធតាមការបោះឆ្នោត ក្នុងមួយឆ្នាំគេធ្វើសន្និបាតម្ដង សន្និបាតគេបោះឆ្នោតជ្រើសរើសប្រធាន ដល់ពេលគាត់គឺងរឹងពេកគេបោះឆ្នោតទំលាក់គាត់ បានកើតជាគាត់មកនៅប៉េកាំង ។

ដានី៖ ពីណាឡើងជំនួសគាត់?

គឹមថុង៖ ក្រោយមកដូចមានអ្នកមកពីមណ្ឌលគិរីនេះឈ្មោះសាន សាង ឥឡូវនៅសំឡូត ។

ដានី៖ ឈ្មោះតាសាង?

គឹមថុង៖ បាទ! សាន សាង គេបោះឆ្នោតជ្រើសរើសគាត់ឲ្យកាន់ ។

ដានី៖ ត្រកូលគាត់ឈ្មោះ "សាន" ហើយគាត់ឈ្មោះ "សាង" ។

គឹមថុង៖ សាង ហើយសាន ហ្នឹងជនជាតិទេ តែស្លាប់អស់ហើយពួកហ្នឹង ។

ដានី៖ តែសាង ហ្នឹងនៅរស់ឥឡូវ?

គឹមថុង៖ លឺដំណឹងថានៅរស់ទេ ។

ដានី៖ សាន ឬក៏សាង?

គឹមថុង៖ សាន ផង, សាង ផង ។

ដានី៖ មនុស្សម្នាក់តែឈ្មោះ២?

គឹមថុង៖ ២ មនុស្ស២នាក់ អក្សរ"ស" ដូចគ្នា ។

បូលី៖ មនុស្ស២នាក់ ឈ្មោះ២ផ្សេងគ្នា ។

ដានី៖ ឈ្មោះសាងមួយ ។

គឹមថុង៖ អក្សរ"ៗ" តែប្រកប "ន" និង"ង" មួយ ។

ដានី៖ ឈ្មោះ សាន មួយ, ឈ្មោះ សាង មួយ?

គឹមថុង៖ បាទ!

ដានី៖ ២នាក់ហ្នឹងសព្វថ្ងៃនៅសំឡូត?

គឹមថុង៖ លឺព័ត៌មានថានៅនៅសំឡូត សាង ទេ ។

ដានី៖ សាង នៅសំឡូត?

គឹមថុង៖ បាទ! សាន ទៅមណ្ឌលគិរី ឡប់ទៅនៅមណ្ឌលគិរីវិញ ហ្នឹងកាលជ្រើសរើសបោះឆ្នោត

ដានី៖ តែពីរនាក់ហ្នឹងគាត់ជនជាតិទាំង២?

គឹមថុង៖ នេះជាមនុស្សកំពង់ស្ពឺ សាង ។

ដានី៖ អ្នកកំពង់ស្ពឺ ។

គឹមថុង៖ ហើយបោះឆ្នោតជ្រើសរើស ជាប់ចេះតែដឹកនាំទៅ ។

ដានីៈ សាន គាត់ជនជាតិត្រឡប់ទៅ?

គីមថុងៈ មណ្ឌលគិរី ហ្នឹងក្រោយឆ្នាំ៧៩ហើយខ្ញុំមកនៅត្រង់ហ្នឹង នៅអគ្គភាពហ្នឹងរហូតមានកិច្ចព្រមព្រៀងប៉ារីស ។

ដានីៈ អ៊ីផ្នែកតូចៗដូចជា២១ ពីណាគ្រប់គ្រង?

បូលីៈ ប្រធានអគ្គភាព២១?

គីមថុងៈ កាលរៀបចំដំបូង ឥឡូវគាត់អភិបាលរងក្រុងប៉ៃលិន ឈ្មោះ នួន ប៊ុន្នោ ។

បូលីៈ ម៉ី ម៉ាក់?

គីមថុងៈ បាទ! ម៉ី ម៉ាក់ គាត់ជាអតីតអ្នកបញ្ជាយន្តហោះនៅពោធិ៍ចិនតុងជាមួយ ស៊ូ ម៉េត ហ្នឹង ហើយ គាត់ចេះអង់គ្លេស ។

បូលីៈ អ៊ីចឹង ម៉ី ម៉ាក់ គាត់ប្រធានអគ្គភាព២១?

គីមថុងៈ បាទ! ២១ហ្នឹង ។

បូលីៈ នួន ប៊ុន្នោ?

ដានីៈ ឈ្មោះគាត់២អ៊ីចឹង?

គីមថុងៈ នួន ប៊ុន្នោ នៅពេលដែលគាត់នៅជាមន្ត្រីអ៊ុនតាក់ គាត់ទៅប្រចាំនៅភ្នំពេញ ការពិតឈ្មោះខ្ញុំត្រូវទៅនៅភ្នំពេញ ដោយសារក្រោយពីមានព្រឹត្តិការណ៍វ៉ៃ ខៀវ សំផន បែកក្បាលទៅ មានការចរចារគ្នាធំភាគច្រើននៅប៉ៃលិន អ៊ីចឹងឲ្យខ្ញុំនៅតំណាង ។ កាលហ្នឹងខ្មែរក្រហមរៀបចំមន្ត្រីតែ៣នាក់ទេ ខ្ញុំមួយ, មួយទៀតឈ្មោះ ហ៊ាង ហើយមួយទៀតឈ្មោះខាន់ ឥឡូវ ខាន់ ស្លាប់ហើយ ហ៊ាង នៅ ។ តែ៣នាក់ហ្នឹងទេ ខ្ញុំទទួលមួយផ្នែក កាលហ្នឹងនៅអ៊ុនតាក់ នៅក្រោយពេលចូលជាមួយរាជរដ្ឋាភិបាល ខ្ញុំទទួលមួយផ្នែកនេះ ហើយ ហ៊ាង ទទួលនៅខាងនេះភ្នំពេញ ហើយខាន់ ទទួលខាងនេះ ខ្ញុំខាងនេះ ច្រើនជាងគេ ។

បូលីៈ បែកជា៣អ៊ីចឹងតែម្ដង?

គីមថុងៈ បាទ! ហ្នឹងរៀបចំផែនការនៅពេលគ្រប់គ្រងក្នុងរដ្ឋាភិបាលចំរុះ ។ ចំរុះអីចំរុះច្រើនភាគី ច្រើនបក្ស ។

ដានីៈ នួន មនោ គាត់គ្រប់គ្រងនៅ២១ គ្រប់គ្រងរហូត?

គីមថុងៈ ២១ហ្នឹង ក្រោយមកបានសង្គ្រាមវៀតណាមវ៉ៃតាមព្រំប្រទល់ ធ្លាក់ចុះអស់ហើយ មួយចំនួនមកនៅដីថៃ ភាគច្រើនមកនៅជំរំ តែជំរំមួយចំនួនខ្មែរក្រហមគ្រប់គ្រងផ្ទាល់ មានតែខាវអ៊ីដាងទេដែលពួកUNគ្រប់គ្រងផ្ទាល់ ដូចថ-៧ សំឡូតហ្នឹងខ្មែរយើងគ្រប់គ្រងទេ

ប៉ុន្តែទទួលអំណោយពីUNដែរ ដល់ហើយបែកគ្នាទៅ ខ្ញុំត្រូវបានជ្រើសរើស នេះខ្ញុំមកនៅនេះ នៅភ្នំពេញហ្នឹង ដល់ក្រោយមកគេត្រូវបានជ្រើសរើសខ្ញុំមកធ្វើអ្នកទទួលខុសត្រូវធ្វើទស្សនាវដ្តីកងទ័ព កម្ពុជាប្រជាធិបតេយ្យ មានដែលឃើញទេ?

បូលី៖ អត់ដែលឃើញសោះ អឺមានសល់ទេ?

គីមថុង៖ បើរកនៅយូនេស្កូប្រហែលនៅឃើញ ។

បូលី៖ នៅយូនេស្កូអ៊ី?

គីមថុង៖ បាទ! ចាប់ពីលេខទី៧ទៅអក្សរខ្ញុំហើយ ។

បូលី៖ អក្សរដៃតែម្តង?

គីមថុង៖ អក្សរខ្ញុំសរសេរឆ្លាក់ដៃ ចាប់ពីលេខទី៧-៣១អក្សរខ្ញុំហើយ ។

ដានី៖ បោះពុម្ពឆ្នាំណាចាប់ផ្តើម?

គីមថុង៖ ចាប់ផ្តើមដូចជា៧៦-៧៧ ។

ដានី៖ ប៉ែតអី?

គីមថុង៖ ៨៦-៨៧ខ្ញុំមកកាន់ទស្សនាវដ្តី ។

បូលី៖ ចំនងជើងធំឈ្មោះអីទស្សនាវដ្តីហ្នឹង?

គីមថុង៖ ទស្សនាវដ្តី "កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ" អក្សរខាងលើ ។

ដានី៖ ទស្សនាវដ្តី "កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ"?

គីមថុង៖ បាទ! សួររកយូនេស្កូមាន ឬទៅស្រាវជ្រាវនៅបេសកម្មទូត ទឹកដៃខ្ញុំមានច្រើនណាស់នៅជំនាន់ក្រោយ ។

ដានី៖ អឺកាលហ្នឹងដាក់ឈ្មោះ ជិន សំអាត?

គីមថុង៖ អត់ទេ ខ្ញុំដាក់ឈ្មោះ ជិន គីមថុន ។

បូលី៖ ប៉ុន្មានទំព័រមួយលេខ?

គីមថុង៖ មួយលេខដូចជា កំរាស់នេះដែរ ក្រាស់ជាងនេះ នេះប្រហែលប៉ុណ្ណឹង ។

ដានី៖ ១០ទំព័រ?

គីមថុង៖ មិនមែនទេលើស មានទំព័រ បទវិចារណ៍កថា បទអត្ថាធិប្បាយ ហើយក្រៅពីហ្នឹងរឿងសមរភូមិ ។

បូលី៖ របស់ពីណា បទអត្ថាធិប្បាយ?

គីមថុង៖ ភាគច្រើនសរសេរបទអត្ថាធិប្បាយ ផ្សាយវិទ្យុភាសារបស់ប៉ុល ពត ។ បទវិចារណ៍កថា បទអត្ថាធិប្បាយ ជួនកាលវិទ្យុគេកាន់ផ្សេង ប្រពន្ធសុន សេន អ្នកចងក្រងអាហ្នឹង បើ

ផ្ញើរពីខ្មែរទៅមានតែប៉ុល ពត ទេ ។ គាត់ហៅមកធ្វើពួកខ្ញុំអ្នកកត់ ហើយយកមកសរសេរទៅយកឲ្យគាត់អ្នកកែ កែហើយបានវិទ្យុលេខផ្ញើរទៅវិទ្យុប៉េកាំង ។

បូលីៈ បានន័យថាប៉ុល ពត គាត់ធ្វើជានិពន្ធនាយកខ្លួនឯងតែម្តង?

គឹមថុងៈ បាទ!

បូលីៈ ព្រោះគាត់អ្នកពិនិត្យផ្ទៀងផ្ទាត់មុននឹងផ្សាយ?

គឹមថុងៈ បាទ! មុននឹងផ្សាយ ។

បូលីៈ ឬមានអ្នកពិនិត្យបន្ទាប់ពីគាត់ទៀត?

គឹមថុងៈ អត់ទេ បើថាអត្ថបទធំៗគឺគាត់តែម្តង អ្នកមើលហើយគាត់អ្នកនិយាយ ក្នុង១ព្រឹកគាត់សរសេរ៤-៥ ។

បូលីៈ ១ព្រឹក?

គឹមថុងៈ ចាប់ពីម៉ោង៦ដល់ម៉ោង១១ សរសេរ៥អត្ថបទ ។

បូលីៈ គាត់សរសេរខ្លួនឯង ឬហៅគេសរសេរ?

គឹមថុងៈ អត់ទេ និយាយអីចឹងអត់មានច្រលំឃ្លាទេ ។

បូលីៈ ហើយអ៊ំអ្នកកត់ទៅ?

គឹមថុងៈ បាទ! កត់ទៅ ជួនកាលគាត់និយាយៗដល់ជិតម៉ោង១១ គាត់ប្រាប់ថាអាហ្នឹងយកទៅដាក់ចំណុចពីព្រឹក ។

បូលីៈ បានន័យថាម៉េចអ៊ំ ចំណុចពីព្រឹក?

គឹមថុងៈ ចង់និយាយថា គំនិតមួយដែលគាត់និយាយនៅពេលអត្ថបទមួយ គាត់ឲ្យធ្វើ៣អត្ថបទហើយ ប៉ុន្តែអត្ថបទទី៣ ឧបមាថាបទវិចារណ៍កថាទី៣ មានភាសាមួយដែលពាក់ព័ន្ធនឹងបទវិចារណ៍កថាលើកទី១ យកអាហ្នឹងទៅដាក់អានោះ ។

បូលីៈ ទៅបញ្ចូលគ្នា?

គឹមថុងៈ បាទ! ទៅបញ្ចូលគ្នា ។

ដានីៈ យើងអ្នកកត់ហ្នឹងមានគ្នាច្រើន មិនមែនតែម្នាក់ទេ?

គឹមថុងៈ មាន៣-៤នាក់ ។

ដានីៈ មាន៣-៤នាក់ចាំកត់ហើយយកមកផ្ទៀងផ្ទាត់គ្នា?

គឹមថុងៈ បាទ! ពីព្រោះទំលាប់គាត់ធ្វើការ ព្រលឹមឡើងជួបជំនួយការហើយ ជំនួយការកាលហ្នឹងខ្ញុំមកនៅនេះហើយ ខ្ញុំលែងនៅជំរំហើយ គេលើកខ្ញុំឲ្យមកនៅធ្វើទស្សនាវដ្តី ព្រលឹមឡើងទៅអានសារ សារទូរលេខដែលគ្រប់សមរភូមិ ទៅអានសារឲ្យគាត់ស្តាប់ ។ គាត់ស្តាប់ទៅ

ហើយគាត់ណែនាំហើយ គាត់ថាសារនេះត្រូវឆ្លើយចេះ ហើយគាត់និយាយឲ្យឆ្លើយយើងកត់ទៅ ហើយទៅដល់ឲ្យទូរលេខផ្សាយទៅសមរភូមិ ហើយសារទូលេខនេះត្រូវឆ្លើយចេះ គាត់ណែនាំហើយគាត់យកទៅឲ្យអ្នកទូរលេខគេបក ។ ធ្វើអីចឹងរៀងរាល់ព្រឹក ហើយក្នុងមួយព្រឹកៗ ឥឡូវរឿងអីមួយ ឧបមារឿងខ្ញុំនិយាយលើកឧទាហរណ៍ ការបោះឆ្នោតនៅក្នុងរដ្ឋាភិបាល ឥឡូវត្រូវវ៉ៃជ្រុងអី យកមកភ្ជាប់ហើយសរសេរអាហ្នឹងទៅ ។

ដានីៈ អីចឹងដូចជាសារទូលេខយើងគ្រាន់តែអានឲ្យស្ដាប់ គាត់ឲ្យយោបល់តែម្ដង ឬមានទីប្រឹក្សាអីឲ្យយោបល់ទៅគាត់សិន?

គឹមចុងៈ ពួកខ្ញុំហ្នឹងហើយគាត់ឲ្យយោបល់ ហើយកត់ បើអត្ថបទធំៗធ្វើហើយយកឲ្យគាត់មើល ។

បូលីៈ អត់មានអ្នកផ្សេងដែលឲ្យយោបល់កែគាត់ទេ?

គឹមចុងៈ អត់ទេ ។

បូលីៈ ដូចថាគាត់និយាយមក ធម្មតាមនុស្សវាមិនអត់ខ្វះទេ តែងតែមានចន្លោះ តើមានដែលកែគាត់ទេ?

គឹមចុងៈ ជួនកាលអាចដែរ ជួនកាលកន្លែងហ្នឹងអត់អីចឹងទេអ៊ំ ទំលាប់ខ្ញុំហៅអ៊ំៗ អត់អីចឹងទេអ៊ំកន្លែងខ្ញុំស្គាល់ចេះ អីចឹងស្គាល់ទៅតាមហ្នឹង ។

បូលីៈ គាត់ស្ដាប់ដែរ?

គឹមចុងៈ មិនមែនរឿងមិនស្ដាប់ទេ គាត់មានហេតុផល ខ្ញុំនិយាយមិនសរសើរអីទេ គាត់ណែនាំខ្ញុំ ខ្ញុំថាទៅណាក៏ដោយ ត្រូវមើលគេ មើលច្រើនជាងនិយាយ ទៅកន្លែងដែលយើងអត់ស្គាល់ ហើយឡប់មកវិញធ្វើ បើមិនធ្វើតាមគេក៏កត់ទុកនៅក្នុងខួរក្បាល នៅពេលណាមួយសភាពការណ៍វាបញ្ជាក់ពីកន្លែងដែលយើងឃើញ ។ កាលហ្នឹងខ្ញុំចេញពីនេះមកខ្ញុំមកត្រង់នេះ មកធ្វើការនៅហ្នឹង គាត់ប្រាប់ខ្ញុំថាជិះកាត់ស្រុកគេ កុំដេក មើលទិដ្ឋភាពស្រុកគេ គេធ្វើអីខ្លះ ដល់ពេលខ្ញុំឡប់ទៅវិញ គាត់សួរថាទៅមួយអាទិត្យហ្នឹងចាប់អារម្មណ៍អី? សួរអីចឹង ខ្ញុំថាចាប់អារម្មណ៍កន្លែងគេចិញ្ចឹមកង្កែបគ្របត្រឡោក ហ្នឹងហើយជាវិជ្ជាដែលនាំឲ្យមិត្តគិត មិត្តដឹង ដោយសារអីដោយសារអត់ដេក គាត់ថាអីចឹង ។ ពីព្រោះមិនដែលអ្នកណាចិញ្ចឹមកង្កែបគ្របត្រឡោក ។ ត្រឡោកមួយកង្កែបមួយ ថៃគេចិញ្ចឹមនៅវាលស្រែ ដល់ពេលចាប់បើកត្រឡោកមកចាប់ៗ ហ្នឹងគាត់ណែនាំអីចឹង ។ ហើយរាល់ពេលដែលខ្ញុំចុះទៅសរមភូមិក៏អីចឹងដែរ គាត់ច្រើនណែនាំទៅប្រាប់ ព្រោះខ្ញុំច្រើននាំពាក្យពីគាត់ទៅប្រាប់សមរភូមិ ដូចជាចុងក្រោយនេះខ្ញុំទទួលផ្នែក ។ កាលហ្នឹងដូចជាអត់ទាន់មាន

កិច្ចព្រមព្រៀងប៉ារីសទេ វៃផង ចរចារផង។ មានដែលលីទេបាញ់កាំភ្លើងធំខ្មែរក្រហម ឆេះក្រុងបាត់ដំបង។

ដានី: លី ខ្ញុំលឺដំណឹងហ្នឹង លឺបាញ់។

គឹមថុង: បាញ់១៣០ ខ្ញុំនៅខាងលិចហ្នឹង ដឹកគ្រាប់ បាញ់១៣០ៗយកពីសំឡូត ទៅថ្មៃធ្វើគួរ កំប្រុក បាញ់ កាលហ្នឹងនាយកន ប្អូនសុន សេន គាត់នៅទទួលមួយផ្នែកហ្នឹង។ ហើយខ្ញុំនាំពាក្យពីហ្នឹងទៅប្រាប់គាត់ យប់ឡើងខ្ញុំមកជួបគាត់ គាត់ណែនាំថាឥឡូវត្រូវវៃបេះ ទៅប្រាប់គេ គូសដែនទីវៃជ្រុងបេះៗ ទិសដៅរបស់ទាហាន គាត់និយាយភាសារខ្លាំង ខ្លាំងមកម៉េច ទិសដៅម៉េច ឥឡូវវៃបេះ ជ្រុងបេះ កាត់បេះ។

ដានី: ប៉ុល ពត គាត់មានប្រសាសន៍ពីរឿង យុទ្ធសាស្រ្តវៃរបស់កងទ័ព?

គឹមថុង: បាទ! យុទ្ធសាស្រ្តវៃតែម្តង បញ្ហាគូស មកដល់ឲ្យខ្ញុំគូសហើយ ខ្លាំងនៅណា ពួកយើងនៅណា ហើយវៃរបៀបម៉េច។

បូលី: ត្រូវទេ ដល់ពេលធ្វើតាមគាត់ទៅ ជោគជ័យទេ?

គឹមថុង: ៩០ភាគរយជោគជ័យ បរាជ័យដែលមិនធ្វើតាមគាត់។

ដានី: អ៊ំពេលដែលគាត់នៅហ្នឹង ពេលប្រជុំខៀវ សំផន ពេលប្រជុំគាត់នៅក្បែរ?

គឹមថុង: គាត់មមាញឹកណាស់ គាត់នៅម្តុំនេះ គាត់មានកន្លែងមួយទៀតសំរាប់តែគាត់។

បូលី: ខៀវ សំផន?

គឹមថុង: បាទ! ពីព្រោះនៅពេលហ្នឹងការទូតមមាញឹកណាស់ ហើយកាលហ្នឹងគ្មានកុំព្យូទ័រទេ មានម៉ាស៊ីនមួយហៅIBM អាហ្នឹងវៃទៅមូលប៉ុន្នេះ វៃភ្លើងដែរ វៃទៅអក្សររត់វិលខ្វាល់អ៊ីចឹង មានតែអាហ្នឹងទេ ហើយកុំព្យូទ័រទាល់តែទៅប្រជុំនៅប៉ារីសបានមានគេទំនើប គាត់មានស្គាល់គេ។ ហើយ ខៀវ សំផន នៅនេះ គាត់ចេញចូលៗខាងការងារទូត មមាញឹកណាស់ មានអ្នកជំនួយការគាត់ទៀត ដូចជាបញ្ញាជន ម៉ក់ បេង, ដូចជា កោ ប៊ុនហេង

បូលី: ចាន់ យូរ៉ាន់ ដែរ?

គឹមថុង: ចាន់ យូរ៉ាន់ ជាថ្នាក់មួយដែលខៀវ សំផន គាត់អត់សូវប្រើ គាត់ជាអ្នកពិភាក្សា គាត់ជាមនុស្សការទូតដើងចាស់ មានអីគាត់ពិភាក្សា ហើយដូចជា អ៊ិន សុភាព ហ្នឹងបញ្ញាជន ហើយទេព ខុនណាល់។

បូលី: នៅជាមួយ ខៀវ សំផន?

គឹមថុង: បាទ! នៅហ្នឹង។

ដានី: អត់នៅជាមួយ ប៉ុល ពត ទេ?

គឹមថុង: អត់ទេ នៅៗពេលដែលបេសកម្មទូតដែលកម្ពុជាប្រជាធិបតេយ្យកាលហ្នឹងនៅមានអាសនៈនៅអង្គការសហប្រជាជាតិ គាត់មានបេសកម្មទូត ដូចជានៅញូយក, នៅចិន នៅកូរ៉េ នៅទ្វីបអាហ្វ្រិក មកដូចចៅហ្វាយស្រុកសំឡូត ផល ហ្នឹងពីដើមនៅសេនេកាល់ ហើយ ម៉ក់ បេន ហ្នឹងពីដើមនៅបេសកម្មទូតនៅយូហ្គោស្លាវី ។

បូលី: ចុះទេព ខុនណាល់?

គឹមថុង: ទេព ខុនណាស់ នៅញូយក នៅជាមួយប្អូនគាជូន ដឿន ។

បូលី: ជួន មុំ?

គឹមថុង: មិនមែនទេ ។

ដានី: ជួន ប្រសិទ្ធ?

គឹមថុង: ជួន ប្រសិទ្ធ ។

ដានី: ឡុង នរិន គាត់នៅហ្នឹងដែរ?

គឹមថុង: ឡុង ណារិន ។

ដានី: សួង ស៊ីគឿន?

គឹមថុង: នៅបារាំង ឆកប្រង៉ាល់នៅចំបក់ដែរ ។

បូលី: សួង ស៊ីគឿន ។

គឹមថុង: ប្រពន្ធបារាំង?

បូលី: បាទ! នីរង់ពេជ្រ ។

គឹមថុង: បាទ!

ដានី: តែគាត់នៅក្នុងមន្ទីរហ្នឹងដែលអត់?

គឹមថុង: នៅក្នុង តែគាត់នៅបរទេសភាគច្រើន បានមានបងសុគន្ធ ហោម សុគន្ធ ហើយមានឈ្មោះមួយទៀតគានេះ ពេជ្រ ប៊ុនរ៉េត ស្លាប់ហើយ ។

ដានី: គាត់ធ្វើទូតនៅថៃ គាត់ធ្លាប់នៅថៃ?

គឹមថុង: កាលរត់ តាម៉ុក ដេញចាប់ប៉ុល ពត រត់ជាមួយខ្ញុំ រត់ជាមួយគ្នា ក្រាបគ្រាប់ផ្លោង តាម៉ុក ជាមួយខ្ញុំ ហើយជាមួយតាគង់, តាគង់ ហ្នឹងខ្ញុំអត់ស្គាល់ទេ ក្រោយមកបានសួរគាត់ថាគាត់នៅចំបក់ ។

ដានី: គង់ ស៊ីគឿន?

គឹមថុង: ថ្ងៃមុនខ្ញុំឃើញឯកសារមួយនិយាយពីរឿងគង់ ស៊ីគឿន ។

បូលី: សៀវភៅគាត់សរសេរទើបតែបោះពុម្ព?

គឹមថុង: ហើយ កោ ប៊ុនហេង, អ៊ុម សុភាព ហើយនិង ម៉ុន១ ។

ដានី: ចុះ គាត ឈុន នៅក្នុងហ្នឹងដែលអត់?

គឹមថុង: គាត ឈុន?

ដានី: បាទ!

គឹមថុង: ខ្ញុំអត់ដឹងទេ ដល់ក្រោយមកបានលឺ លឺកន្លងមកសម័យការទូត ដូចជា គាត ឈុន នៅជាមួយហើយមាន ហោ ណាំហុង អីមានឈ្មោះដែរ តែក្រោយមកគាត់ត្រូវជាមួយរដ្ឋកម្ពុជា ។ ហោ ណាំហុង អីហ្នឹង ហ្នឹងខ្ញុំដឹងតិចតួច ។

ដានី: អាំពេលដែលក្នុងមន្ទីរហ្នឹងមិញអាំជាក្រុមបញ្ញាជននៅជាមួយទៀវ សំផនទេ?

គឹមថុង: បាទ!

ដានី: ពេលដែលប៉ុល ពត គាត់ធ្វើការជាមួយខាងផ្នែកអី?

គឹមថុង: ពួកខ្ញុំជំនួយការមួយចំនួនតូចទេ បោះពុម្ពឯកសារ នៅជាមួយខ្ញុំមានតែប៉ុន្មាននាក់ទេ ។

ដានី: បើតាមអាំចាំពីណាខ្លះ ក្រៅពីអាំ?

គឹមថុង: នៅរាល់ថ្ងៃនៅរស់ឈ្មោះ ហ៊ាង មួយនៅម៉ាឡៃ នៅគីឡូ១៣ ។

ដានី: ឈ្មោះអី?

គឹមថុង: ហ៊ាង ។

ដានី: ហ៊ាង?

គឹមថុង: បាទ! ហើយឈ្មោះ ហេង នៅស្រុកវាលវែង ហ្នឹងអ្នកបោះពុម្ពឯកសារ ។

ដានី: ឈ្មោះ ហ៊ាង នៅគីឡូ១៣ ប្រពន្ធគាត់ឈ្មោះអីទៅ?

គឹមថុង: ឈ្មោះ រ៉ាត់ តែចាស់ៗអស់ហើយ ស្រករៗខ្ញុំ ។

ដានី: ហើយឈ្មោះហេង នៅស្រុកសំឡូត?

គឹមថុង: នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ដានី: ប្រពន្ធគាត់ឈ្មោះអីគេ?

គឹមថុង: ខ្ញុំភ្លេចឈ្មោះ បែកគ្នាយូរ ។

ដានី: នៅខាងឃុំអីទៅ?

គឹមថុង: នៅវាលវែង នៅប្រម៉ោយ ទីតាំងនៅប្រម៉ោយ ។

បូលី: អាំស្គាល់អាំ ហួត យ៉ង់?

គឹមថុង: ហួត យ៉ន់ បងប្អូនគ្រួសារខ្ញុំ ត្រូវជាសាច់ថ្លៃ។ អ្នកនៅជាមួយខ្ញុំចុងក្រោយមាន នួន មនោ ហ្នឹងមួយ ហើយមួយទៀតនៅនេះ នៅមុំភ្នំព្រឹក ឈ្មោះ វិន ហ្នឹងខាងគេយកព័ត៌មាន ហើយមួយទៀតឈ្មោះ សេដ្ឋា ក៏នៅមួយជួរហ្នឹងដែរ។

ដានី: កន្លែងនេះពេលដែលយើងទៅមន្ទីរដំបូង នៅកន្លែងហ្នឹង?

គឹមថុង: បាទ!

ដានី: តែមន្ទីរហ្នឹងដូចថាចល័តចុះ ចល័តឡើងមុំៗជួរហ្នឹងដែរ ឬអត់ទេ?

គឹមថុង: បាទ! នៅក្បែរហ្នឹង។

ដានី: មិនមែននៅមុំហ្នឹងជាប់រហូតទេ?

គឹមថុង: ដូនកាលគាត់ទៅសំរាន្តនៅកន្លែងខៀវ សំផន នៅ។ សួររឿ ដឹងកន្លែងដែលខ្ញុំថានៅជាប់នឹងគាត់ដឹង ព្រោះកាលហ្នឹងគាត់ចេញចូលប៉ារីស គាត់ជនជាតិទេ ជនជាតិទំពួន។

ដានី: សុខ រឿ ជនជាតិទំពួន។

គឹមថុង: តែសំរាប់ខ្ញុំចេះជាងគាត់ ខ្ញុំអត់ស្គាល់ទូអេវ៉ៃទេ តែរឿ ហ្នឹងស្គាល់ទូអេវ៉ៃនៅប្រទេសបារាំង។

បូលី: មន្ទីរដែលប៉ុល ពត ធ្វើការ ដែលស្នាក់នៅ ខៀវ សំផន ស្នាក់នៅ ធ្វើការសង់ពីអី?

គឹមថុង: ស័ង្កសី។

បូលី: ប៉ុនៗណា?

គឹមថុង: ធំៗ សាលារៀនដាក់មនុស្ស១០០នាក់ជាង។

បូលី: ប៉ុនអគារហ្នឹងទាំងមូលទេមើលទៅ?

គឹមថុង: ធំជាងហ្នឹង កន្លែងសាលារៀនមានកន្លែងដេកចងអង្រឹង រោងបាយ ហំណាស់។

បូលី: តែនៅក្នុងដីថៃ?

គឹមថុង: នៅក្នុងទឹកដីថៃ គេហៅរយហារៃ។

បូលី: ប្រហែលជា១គីឡូម៉ែត្រពីព្រំដែនខ្មែរមក?

គឹមថុង: មិនទេឆ្ងាយ។

បូលី: ប៉ុន្មានគីឡូ?

គឹមថុង: កាំភ្លើង១៣០បាញ់អត់ដល់ទេ។

បូលី: ២០-៣០គីឡូ?

គឹមថុង: កាលហ្នឹងខ្ញុំអត់បានចាំ តែបើមានផែនទីហាសិបពាន់ ឬផែនទីពីររយហាពាន់ខ្ញុំចុចបាន។

ដានី: ក្រុមវិទ្យុខ្ញុំធ្លាប់ជួបពូតារានៅអន្លង់វែង។

គីមថុន: តាភ ណា?

ដានី: តាភ?

គីមថុន: ភ ហ្នឹងសិល្បៈ ច្រៀងកំពុតជើងមួយខាង?

ដានី: បាទ!

គីមថុន: រពើសពេក ដើរបាញ់ក្តាន់ញ៉ែញទៅដាន់មីនដាច់ជើង កាលហ្នឹងខ្ញុំកំពុងបញ្ជាឲ្យវ៉ៃនៅអន្លង់វ៉ាន ខ្ញុំថានេះបាត់ដំបង ខ្ញុំឡប់មកវិញព្រលប់ៗលឺថា ភ ហ្នឹងដាច់ជើង ខ្ញុំសួរថាម៉េចដាច់ជើង ថាបាញ់ក្តាន់ញ៉ែញ រពើសអីចឹងហើយមីនក្រាល ។

ដានី: ខាងសិល្បៈ ខាងវិទ្យុ?

គីមថុន: ហ្នឹងហើយទៅពី១០០១ទៅជាមួយខ្ញុំ ភ ហ្នឹង ហើយនិងអាឆាតៗ ចំណាំដើរតួ ធ្វើអាដួកនៅក្នុងសិ្បៈ ។

ដានី: ហើយមីងៗខ្ញុំភ្លេចឈ្មោះគាត់?

គីមថុន: សុខា ។

ដានី: សុខា បាទ!

គីមថុន: សុខា នៅស្រុកកំពង់លែង គេយកមកក្រោយទេ មកច្រៀងសិល្បៈនៅវិទ្យុ វិទ្យុនៅហ្នឹង វិទ្យុហ្នឹងចល័តច្រើនកន្លែងដែរ ។ ដំបូងដាក់នៅត្រង់នេះ ចេញពីហ្នឹងមកនៅនេះ ។

បូលី: មុនដំបូងម៉ាឡៃ ។

គីមថុន: ចេញពីនេះមកនៅនេះ ។

ដានី: ចេញពីម៉ាឡៃមក ។

គីមថុន: ចេញពីម៉ាឡៃមកដាក់នៅប៉ៃលិន ។

ដានី: តែដំបូងបំផុត?

គីមថុន: នេះ ។

បូលី: នៅកោះកុង ។

គីមថុន: ពេលដែលសង្គ្រាមនៅព្រំដែនក្តៅគគុកមកនៅនេះ នេះគេហៅថ-២៥ ។

ដានី: ថ-២៥ នៅក្នុងដីថៃ ។

គីមថុន: កន្លែងតាវណ្ណ ។

បូលី: នៅក្នុងស្រុកម៉ាឡៃ នៅជាប់ទល់ដែនម៉ាឡៃ?

គីមថុន: អត់ទេ នៅក្នុងខេត្តថៃ ខេត្តប្រាជិនបុរី ។

បូលី: បើយើងគិតពី ។

គឹមថុង: ខ្ញុំយកផែនទីថៃមកមើល ។ ថៃហៅតែភ៉ាន់ ។

ប៉ូលី: អ៊ីចឹងលើកវិទ្យុមកដាក់កន្លែងអៀង សារី វិញ?

គឹមថុង: ចេញពីហ្នឹងមកដាក់នេះ ចេញពីអាហ្នឹងមកចូលប៉ៃលិន ។

ដានី: ប៉ៃលិន ពីណាទៅគ្រាន់អៀង សារី ទៅ?

គឹមថុង: អ៊ី ឈាន ក្រោយរំដោះហើយមកនៅប៉ៃលិន លើកមកដាក់ហ្នឹង ចេញពីប៉ៃលិនមកនៅភ្នំព្រឹក ។

ប៉ូលី: ភ្នំព្រឹកកន្លែងនេះ ។

គឹមថុង: ចេញពីភ្នំព្រឹក ក្បាលទន្សោង អន្លង់វែង ចុងក្រោយនេះ ។

ប៉ូលី: ប៉ុល ពត រើហ្នឹងអស់ហើយ ។

គឹមថុង: បាទ! រឿងភ៉ាវហូរហែនៅហ្នឹងឯង ។

ប៉ូលី: ព្រោះខាងនេះគេចុះចូលអស់ហើយ ។

គឹមថុង: ចុះចូលបណ្ដើរៗហើយ ។

ដានី: បើយើងគិតជាឆ្នាំវិញ មកនៅនេះបានប៉ុន្មានឆ្នាំដែលមកខាងម៉ាឡៃវិញ? អានេះពីឆ្នាំ ៧៩-៨០-៨១ ។

គឹមថុង: ៨២ ។

ដានី: ៨២យើងមកខាងនេះ?

គឹមថុង: នៅប្រហែល១ឆ្នាំ មកដាក់នៅហ្នឹងបានយូរ ។

ប៉ូលី: នៅម៉ាឡៃបានយូរ?

គឹមថុង: អត់ទេ ដាក់នៅដ-២៥បានយូរ មានដើងភ្នំមួយ មន្ទីរពេទ្យដ-២៥ទូទាំងប្រទេស ឈឺធ្ងន់ៗមកហ្នឹង តាជួន ជឿន នៅហ្នឹង ។

ប៉ូលី: អ៊ីចឹងវាទៅជាមជ្ឈមណ្ឌលធំជាងគេនៅកន្លែងអៀង សារី វិញ?

គឹមថុង: ហ្នឹងឯង ហ្នឹងហើយបានកើតមាននេះ មុនដំបូងមានអានេះ មានអានេះមួយ មានអានេះ

ប៉ូលី: ១០០១ និងម៉ាឡៃ?

គឹមថុង: បាទ! មានអានេះៗ ហើយមកមានអានេះ ក្រោយមកមានអានេះ ។

ប៉ូលី: បានកោះកុង?

គឹមថុង: កោះកុង ម៉ុំសំឡូត ។

ប៉ូលី: ដែលបង្កើតហ្នឹងមិនយូរពីគ្នាប៉ុន្មានទេ? ក្នុងឆ្នាំ៧៩ទាំងអស់ទេ?

| | |
|---|---|
| គឹមថុង: | តាមស្ថានការណ៍ដែលវាវិវត្តន៍ កាលណាវាវិវត្តន៍ទៅអាចស្រួលបាន គេបង្កើតទៅ ដូចជាកន្លែងតាម៉ុក ១០០៣ គេនៅហ្នឹងគឺគេនៅហ្នឹង គេពង្រឹង តែនៅក្នុងដីថៃ អនាគតកងទ័ពបេះតែចុះមកមុខមានកំលាំង គ្រួសារកងទ័ពនៅលើចុះមកធ្វើសកម្មភាពនៅខាងក្នុងនេះ ទៅកសាងកំលាំងនៅខាងក្នុង ។ |
| បូលី: | បើយើងនិយាយឲ្យខ្លីទៅ តំបន់ធំៗទាំងអស់បង្កើតឡើងខុសគ្នាប្រហែលជាប៉ុន្មានខែតាមមើល? មិនដល់ឆ្នាំ? |
| គឹមថុង: | ជួនកាលឆ្នាំតែមួយ ។ |
| បូលី: | ៧៩តែមួយ? |
| គឹមថុង: | ៧៩ ឬចន្លោះ៨០-៨១ ។ ៧៩-៨០ ចន្លោះហ្នឹង ។ |
| បូលី: | យើងដឹងថាមានច្រើន តែទីតាំងធំ ទី១គឺ១០០១យើងដឹង ។ |
| គឹមថុង: | នេះប្រភពចេញពីនេះមក ។ |
| បូលី: | ដ-២៥នេះ? |
| គឹមថុង: | បាទ! នៅពេលដែលខ្មែរក្រហមចេញពីភ្នំពេញមកហ្នឹងហើយ ។ |
| បូលី: | ដ-២៥មុន? |
| គឹមថុង: | បាទ! មកទំនាក់ទំនងការទូតជាមួយរដ្ឋាភិបាលថៃ ហើយបានកំលាំងត្រូវចូលមកនេះគឺមកនៅ១០០១ ដើម្បីឲ្យកំលាំងនេះមកត្រូវរៀបចំកន្លែងស្នាក់មួយ ប៉ុន្តែតាម៉ុក ត្រូវមានមួយទៀត ។ |
| បូលី: | គាត់រើមក១០០៣មួយទៀត? |
| គឹមថុង: | ១០០៣ តែគាត់មកនេះ ក្រោយមកគាត់រើកមកនេះ ។ |
| ដានី: | គាត់មកដំបូងមកជាមួយគ្នាទេ? |
| គឹមថុង: | មកទំនៅនេះជាមួយសុន សេន ដល់ពេលទ័ពឡើងមកនេះ មកនេះគាត់ឈូស ដាច់ដើងប្រេកព្រះប្រឡាយ ។ |
| ដានី: | ចុះ១០០២? |
| គឹមថុង: | ១០០២ខ្ញុំអត់ដឹងទេ ។ |
| ដានី: | ប្រេកអានសេះនេះ? |
| គឹមថុង: | អានសេះហ្នឹងក្រោយមកទេ ។ |
| ដានី: | ប៉ុន្តែមិនមែនមកតាមលេខរៀងវាមកពី១០០១ តាម៉ុក មក១០០២? |

គឹម ចុង៖ អត់ទេ ដូនកាលគេបង្កើតក្រោយខ្ញុំអត់ដឹងទេអាហ្នឹង កន្លែងកើតប្រកសំខាន់ៗដូនកាលខ្ញុំអត់ដឹង ។

បូលី៖ ម្តុំត្រាតនេះក្រោយ១០០១ទៅទៀតដែលបង្កើតឡើង?

គឹម ចុង៖ មានអាហ្នឹងហើយ មានអាហ្នឹងតែម្តង គាត់ចុះចេញពីភ្នំពេញគាត់មកទំនៅហ្នឹង ប៉ុល ពត

បូលី៖ ភ្លាមៗតែម្តង?

គឹម ចុង៖ បាទ! មកទំនៅហ្នឹង ចេញពីភ្នំពេញមក គាត់មកដើរតាមភ្នំក្រវ៉ាញ ឃើញប្រជាជនស្លាប់នៅអង្រើង ។

ដានី៖ តែពេលដែលគាត់មកអីចឹង កន្លែងហ្នឹងកន្លែងមន្ទីររបស់គាត់ តែកន្លែងនេះអៀង សារី គាត់មកនៅម្តុំនេះ?

គឹម ចុង៖ បាទ!

ដានី៖ ហើយខាងកងទ័ព ខាងតាសុន សេន គាត់នៅម្តុំនេះ?

គឹម ចុង៖ បាទ! គាត់គ្រប់គ្រងមួយជំនាវនេះ ។

ដានី៖ ប៉ុន្តែពាផ្នែកនេះវាមានលក្ខណៈផ្សេងៗគ្នាមុខងារ ។ អាចថាកន្លែងមន្ទីររបស់នយោបាយរបស់រដ្ឋាភិបាល កន្លែងនេះកន្លែងការបរទេស ដូចកន្លែងស្បៀង កន្លែងសេដ្ឋកិច្ច ។

គឹម ចុង៖ ប្រព័ន្ធគ្រប់គ្រងមិនឯកភាពគ្នាទេ របៀបគ្រប់គ្រង ។

បូលី៖ វាដាន់គ្នាខ្លះ?

គឹម ចុង៖ ទៅតាម បើនេះជាអំណាចមួយៗ កន្លែងនេះកងទ័ពភាគច្រើន នេះជាអំណាចតាម៉ុកមួយៗ នេះជាអៀង សារី មួយ តែ អៀង សារី អត់គ្រប់ដណ្តប់ទៅតាមសមរភូមិទេ គ្រប់ដណ្តប់តែភស្តុភា គ្រប់ដណ្តប់បាន តែជាមួយប៉ៃលិន ហើយនៅនេះសមរភូមិមួយទៀតនៅម្តុំនេះ ហៅសមរភូមិស៊ីសុផុន ខាងជើង ។

ដានី៖ អានេះកន្លែងរដ្ឋបាល?

គឹម ចុង៖ បាទ! កន្លែងពង្រឹងស្មារតី ពង្រឹងនយោបាយនៅនេះ ។

ដានី៖ ប៉ុស្តិ៍វិទ្យុចេញពីនេះមក?

គឹម ចុង៖ ចេញពីនេះមក គេថាមួយជំនាវនេះមកនេះទាំងអស់ ។

ដានី៖ គេត្រូវប្រជុំនៅនេះ?

គឹម ចុង៖ មករៀននៅនេះ ។

បូលី៖ និយាយរួមបើយើងនិយាយឲ្យស្រួលស្តាប់ទៅ នយោបាយ, សេដ្ឋកិច្ច, យោធា?

គឹម ចុង៖ បាទ! កងទ័ព ។

បូលី៖ យើងមិនថានយោបាយសុទ្ធទេ មានយោធាខ្លះដែរ គ្រាន់តែថាដែលធំ ដែលចំបងតួនាទីនយោបាយភាគច្រើន ។

គឹមថុង៖ នេះ ។

បូលី៖ នេះសេដ្ឋកិច្ចភាគច្រើន?

គឹមថុង៖ បាទ! សេដ្ឋកិច្ចទូទាំងសមរភូមិ ។

បូលី៖ ទូទាំងតំបន់កាន់កាប់របស់ខ្មែរក្រហម?

គឹមថុង៖ បាទ!

បូលី៖ កងទ័ពភាគច្រើន ។

ដានី៖ នេះមានកងទ័ព តែកងទ័ពការពារ?

គឹមថុង៖ កងទ័ពខាងនីរតី កងទ័ពពួកតាប៉ុក តាប៉ែត មួយជួរហ្នឹង ។

បូលី៖ ខាងកោះកុង ហើយនិងពោធិ៍សាត់?

គឹមថុង៖ ខាងកោះកុង ។

បូលី៖ និយាយរួមកងទ័ពវាវាយទាំងអស់ហ្នឹង?

គឹមថុង៖ និយាយរួមមួយផ្នែកព្រំដែន ។

បូលី៖ គ្រាន់តែថាតំបន់នេះខៀវ សំផន, បញ្ញាជន គាត់នៅច្រើន គឺកិច្ចការធំគឺទាក់ទងរឿងនយោបាយច្រើន?

គឹមថុង៖ ចេញពីហ្នឹង ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស រហូតមានកិច្ចព្រមព្រៀងប៉ារីស កន្លែងហ្នឹងហើយ ។

ដានី៖ តែទីតាំងមុនដំបូងយើងចេញ៧៩មក វាមានអីចឹង ប៉ុន្តែបន្ទាប់ៗមកមានទីតាំងខ្លះវាត្រូវបានបាត់បង់ ឬត្រូវរំសាយ?

គឹមថុង៖ មានបាត់បង់តែមួយកន្លែងទេ ក្រោយពេលនេះមកគេហៅថាទៅផ្ទះមូល ប៉ុល ពត ចេញពីហ្នឹង ។

បូលី៖ ផ្ទះមូល?

គឹមថុង៖ បាទ! ចេញពីហ្នឹងយកចល័តវិទ្យុទៅដាក់នៅហ្នឹង គេហៅផ្ទះមូល ឆ្លងស្ទឹងមេទឹកមកគេហៅអូរស្វរស្តី ហ្នឹងចល័តទៅនៅហ្នឹង ផ្ទះមូលហ្នឹង គេធ្វើកន្លែងគាត់ស្នាក់នៅជាប់មាត់អូរ តែនៅអត់ទាន់បាន១ឆ្នាំទេ ពួកខ្ញុំទៅកាប់ចំការ ផ្គត់ផ្គង់ជីវិតនៅហ្នឹង ។

បូលី៖ ដីខ្មែរ ឬដីថៃ?

គឹមថុង៖ ដីយើង ។

បូលីៈ ដីខ្មែរ តែវៀតណាមវ៉ៃរុញ?

គឹមចុងៈ វ៉ៃរុញប្រតិបត្តិការវ៉ៃបោសសំអាតព្រំដែន បាននាំឲ្យធ្លាក់កើតអាហ្នឹង ។

បូលីៈ កើតគ្រាត?

គឹមចុងៈ កើតក-១៨ ដោយសារចេញពីអាហ្នឹងហើយមកពីអាហ្នឹង ។ ចេញពីអូរស្វស្តីធ្លាក់ពីអូរស្វស្តីមកនៅហ្នឹង ទិញដីនៅហ្នឹង ។

បូលីៈ ក-១៨ហ្នឹងខុសគ្នាយ៉ាងម៉េច ពី១៣១មន្ទីរ?

គឹមចុងៈ ក-១៨ជាឈ្មោះមួយ កន្លែងមួយ ។

បូលីៈ នៅក្នុង១៣១?

គឹមចុងៈ បាទ! នៅលើ១៣១ គេហៅក-១៨ ។

ដានីៈ របៀបក-១៨ ជាកន្លែងរបស់ប៉ុល ពត គាត់នៅ ។

គឹមចុងៈ បាទ! ហ្នឹងហើយ កន្លែងក-១៨មួយហើយនៅក្នុងក-១៨ហ្នឹង គេរៀបចំអង្គភាពមួយឈ្មោះថា១៣១ ។

បូលីៈ អីចឹងក-១៨ហ្នឹងធំជាង១៣១ទៀត?

គឹមចុងៈ ក-១៨ជាកន្លែងមួយ ។ ឧទាហរណ៍១០០១, ១០០៣ ហើយដ-២៥ តែអានេះក-១៨ជាកន្លែងមួយ ហើយនៅក្នុងហ្នឹងគេរៀបចំ ការពិតរៀបចំតាំងពីអត់ទាន់ធ្លាក់ដល់ក-១៨ ។ ១៣១កើតនៅក្នុងនេះដំបូង ដែលខ្ញុំថាឆ្លងទៅអូរស្វរស្តីហ្នឹងហើយ បានធ្លាក់ពីអូរស្វរស្តីមកក-១៨ ។

ដានីៈ អ៊ីកាលពីជំនាន់៣ឆ្នាំយើងមានមន្ទីរ៨៧០ បើអ៊ីប្រៀបធៀបក-១៨ ហើយនិង៨៧០ដូចគ្នាអត់?

គឹមចុងៈ ដូចតែគ្នា មន្ទីរ៨៧ និង៨៧០ ដូចតែគ្នា ។

បូលីៈ តែ៨៧យើងដូរឈ្មោះ?

គឹមចុងៈ គ្រាន់តែឈ្មោះវាដូរច្រើន ។

ដានីៈ ដូចថាមន្ទីរធំ៨៧០ យើងប្រៀបធៀបមក៨៧ ឬ១៣១ ។

គឹមចុងៈ ១៣១ជាអង្គភាពមួយនៅក្រោមហ្នឹង ។

បូលីៈ អង្គភាពតូចមួយនៅក្រោមក-១៨?

គឹមចុងៈ នៅក្រោមមន្ទីរ៨៧ហ្នឹង ។

បូលីៈ ចុះមន្ទីរ៨៧ ហើយនិងក-១៨ ខុសគ្នាម៉េចពីរហ្នឹង?

គឹមចុង: អត់ខុសគ្នា ក-១៨ជាកន្លែងមួយជម្លៀសចេញពីហ្នឹងមក បង្កើតឈ្មោះមួយទៀតហៅ ក-១៨ ទាន់ហ្នឹងទេ?

ដានី: បើតាមខ្ញុំយល់ដូចអ៊ំមានប្រសាសន៍មិញ មន្ទីរ៨៧ជាមន្ទីរមួយធំ តែក-១៨នេះជាកន្លែងថ្នាក់ដឹកនាំគាត់ស្នាក់នៅ គាត់ធ្វើការ ។

គឹមចុង: ក្រោយពី១៣១ហ្នឹងត្រូវចេញពីព្រំដែន កំលាំងដែលផ្នែកៗខ្ញុំប្រាប់អូនឯងទាំងអស់បែកគ្នា នៅក្នុងជំរំដែលខ្មែរក្រហមគ្រប់គ្រង ហើយក-១៨នេះជាកន្លែងមួយទៅស្នាក់នៅរបស់ប៉ុល ពត រៀបចំពង្រឹងស្មារតីកងទ័ពឲ្យមានកំលាំងឡើងវិញ បានជ្រើសរើសចេញពីនេះ ពួកដែលនៅក្នុងជំរំហ្នឹង យកទៅ១, ២, ៣ ដែលខ្ញុំរាប់មានឈ្មោះ៤-៥នាក់ទៅនៅតិចបំផុត ។

ដានី: ដូចក-១, ក-៣ នៅភ្នំពេញ?

គឹមចុង: អាហ្នឹងខ្ញុំអត់សូវដឹងទេ ។

បូលី: ផ្សេងទៀត ។

ដានី: វាអាចអីចឹង វាអាចសំងាត់ ។

គឹមចុង: បាទ! ជ្រើសរើសទៅនៅហ្នឹងរហូតដល់មានកិច្ចព្រមព្រៀងប៉ារីស មានគ្នាតិចទេកំលាំងធ្វើការ ។

ដានី: អីចឹងមន្ទីរហ្នឹងមានដំណើរការរហូតដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីស ក៏មាននៅកន្លែងហ្នឹងដែរ?

គឹមចុង: ក-១៨ហ្នឹង ។

ដានី: នៅកន្លែងក-១៨?

គឹមចុង: កន្លែងប្រភព ថ្ងៃស៊ីញ៉ៅខ្ញុំទៅជួបគាត់ គាត់ថាជិតដល់ម៉ោងស៊ីញ៉ៅហើយ ស្ពាននេះនៅយប់ គាត់ថាគេនៅយប់កំពុងតែរៀបចំដុសធ្មេញ បន្តិចទៀតគេស៊ីញ៉ៅហើយ ហ្នឹងនៅប៉ារីស ។

បូលី: យើងអាចសំរាកតិចទៅ ចាំក្រោយហូបបាយ អ៊ំគាត់ហត់ហើយ៣-៤ម៉ោង ។

ដានី: បាទ!

បូលី: អ៊ំខ្ញុំអាចសុំអនុញ្ញាតជួបអ៊ំម្តងទៀតបានទេ ។

គឹមចុង: ជួបពេលណា ។

បូលី: ពេលណាដែលអ៊ំអាចអនុញ្ញាតបាន បើសិនបានថ្ងៃហ្នឹងខ្ញុំកាន់តែអរ ព្រោះខ្ញុំមានរឿង ។

ដានី: អាចថាពិសាបាយជាមួយគ្នា ។

បូលី៖ ពិសាបាយជាមួយខ្ញុំសិន ។

គឹមថុង៖ ខ្ញុំត្រូវទៅមើលគេជញ្ជូនស្រូវ ។

បូលី៖ ម៉េចៗខ្ញុំជូនអ៊ំទៅចំការ ដាក់ឡានទៅចំការ ។

គឹមថុង៖ អត់ទេ ខ្ញុំមានគោយន្ត ។

បូលី៖ ចង់ស្គាល់ចំការអ៊ំដែរ ។

ប៊ុនថន៖ ទៅសម្ភាសន៍នៅចំការក៏បាន ។

គឹមថុង៖ ទៅនិយាយនៅចំការក្តៅណាស់ ។

បូលី៖ អត់អីទេ បើសិនអ៊ំអនុញ្ញាតបាន ពួកខ្ញុំសុខចិត្តក្តៅ ព័ត៌មាននេះវាឆ្ងាញ់ណាស់មិនងាយមានទេ ។

ដានី៖ អាចថាចំណាយពេល១ម៉ោងកន្លះ ទៅ២ម៉ោងទៀត ដើម្បីពួកខ្ញុំជ្រើចង់ដឹងកន្លែងនេះ កន្លែងណាទីតាំង ដូចកន្លែងនេះវានៅរយៈពេលណាមួយបាត់បង់ទៅ ហើយវារួមមកវិញ

គឹមថុង៖ ត្រូវហើយ ។

បូលី៖ អ៊ំអាចបានទេ ទៅចំការអ៊ំក៏បាន ។

គឹមថុង៖ គ្មានពេល គ្មានកន្លែងស្រួលទេចំការ ចំការខ្ញុំមិនឆ្ងាយទេ ។

បូលី៖ ឲ្យតែអ៊ំស្រួលខ្លួនឈរក៏បាន អង្គុយក៏បាន ខ្ញុំអត់នេះទេ ។

គឹមថុង៖ ឥឡូវមានអីចង់សួរទៀត បង្ហើយតែម្តងទៅ ។

បូលី៖ ខ្ញុំថាច្រើនណាស់ ខ្ញុំចង់ពិភាក្សារឿងបញ្ហាប្រទាញប្រទង់នៅអន្លង់វែង-ត្រពាំងប្រាសាទនេះ រឿងវាច្រើនដែរ ជម្លោះតាម៉ុក, ប៉ុល ពត ។

ដានី៖ ទាក់ទងពីគោលនយោបាយពីក្រោយមកជុំគ្នានៅនេះ ១០០៣, ក្បាលទន្សោង មានការបែកបាក់គ្នា ដែលអ៊ំមានប្រសាសន៍?

គឹមថុង៖ អត់១០០៣ទេ ក្បាលទន្សោងគឺនៅជាំស្រងាំ នៅក្បាលទន្សោង ។

បូលី៖ ហ្នឹងវាច្រើន មិនអាចពិភាក្សាមួយភ្លែតអស់ទេ ។

គឹមថុង៖ កន្លែងចំរូងចំរាស់គ្នា វាមានកន្លែងខ្លះក៏ស្ងាត់ កន្លែងខ្លះក៏ត្រូវនិយាយ ហើយកន្លែងខ្លះជាចំណុចរសើបមួយ រសើបទាក់ទងជាមួយរដ្ឋាភិបាល ។

ដានី៖ ខ្ញុំយល់ដែរកន្លែងហ្នឹង ។

គឹមថុង៖ កន្លែងហ្នឹងជួនកាលអត់អាចនិយាយទេ ដូចម្តុំភ្នំវល្លិ៍ តែខ្ញុំដឹងដែរ ។

បូលី៖ កន្លែងណាអ៊ំឲ្យខ្ញុំបិទសំលេងខ្ញុំអាចបិទបាន ។

គឹមថុង៖ ដូចជាភ្នំវល្លិ៍អី ជារឿងមួយ ។

ដានី៖ អ៊ីឥឡូវពួកខ្ញុំក៏វិលវល់ក្នុងខួរក្បាល ដូចថាវាច្របូកច្របល់ វាច្រើនពេកទៅ ចង់អានេះតិច ចង់អានោះតិច ទាល់តែយើងសំរាកហូបបាយ ពិសាបាយហើយ យើងចាប់ផ្ដើមទៀតវាស្រឡះបន្តិច ។ ចង់អញ្ជើញអ៊ំពិសាបាយជាមួយ ។

គីមថុង៖ ខ្ញុំចង់យកក្រដាស Chatអ៊ំខ្ញុំគូសប្លង់ឲ្យមើល បង្ហាញពីទិដ្ឋភាពឆាប់យល់ ដល់អ៊ីចឹងជួនកាលលំបាកដែរ មានក្រដាស Chat ខ្ញុំពន្យល់ថាចេញពីភ្នំពេញគាត់មកនៅណា ហើយចេះតែនាំគ្នាហៅ ។

**០២:០២:០៤**

ដានី៖

គីមថុង៖ ៧១ វាមានអាហ្នឹង?

ដានី៖ អ៊ីចឹង៨៧ ។

គីមថុង៖ ជាឈ្មោះដែលគាត់នៅតាំងពីភ្នំពេញ កន្លែង៨៧ ។

ដានី៖ ៨៧០ ?

គីមថុង៖ បាទ! ៨៧០ហ្នឹងក្លាយទៅជាកន្លែង៨៧ ក្រោយមកគេហៅ៨៧ ហើយនៅក្នុងហ្នឹងនៅពេលពួកខ្ញុំមកពីមុំនេះ គ្រប់សមរភូមិបង្កើតជាអង្គភាពមួយហៅថា១៣១ ជាអង្គភាពជំនួយការ ។

បូលី៖ ជំនួយឲ្យ៨៧ហ្នឹង?

គីមថុង៖ បាទ! ជំនួយឲ្យហ្នឹង ។

ដានី៖ ដល់ពេល៣១បង្កើតជាមន្ទីរអង្គភាព៥ទៀត?

គីមថុង៖ បាទ! បំបែកចេញជាក្រុមផ្នែកជំនួយការ ដែលខ្ញុំបានជំរាប ។

ដានី៖ ចុះក-១៨?

គីមថុង៖ ក-១៨ ក្រោយឆ្នាំដូចជា៨៥ឬ៨៦ កងទ័ពវៀតណាមវាតត្បាតចេញពីនេះ ផ្លូវ៥៦ មកដល់អន្លង់វាប ។ មកដល់អន្លង់វាបហ្នឹងកាំភ្លើងធំមកដល់គាត់ជម្លៀសមក មកនៅរយហារហ្នឹង ។

បូលី៖ ក-១៨ហ្នឹង?

គីមថុង៖ ហ្នឹងហើយបានបង្កើតជាឈ្មោះមួយហៅថា ក-១៨ ។

បូលី៖ ឆ្នាំ៨៦ ?

គីមថុង៖ បាទ! កំឡុងឆ្នាំហ្នឹង៨៦-៨៧ ។

បូលី៖ ដែលមានទីតាំងនៅក្នុងដីថៃ?

គីមថុនៈ បាទ! នៅក្នុងដីថៃ មុននឹងកើតក-១៨ហ្នឹង ដោយសារគាត់រើ នេះមើលដែនទី ដោយសាររើពីហ្នឹងមកពេលហ្នឹងអង្គភាព១៣១ត្រូវឡើងទៅនៅលើភ្នំទាំងអស់ នៅលើភ្នំក្រវាញទាំងអស់ ។ ចេញពីហ្នឹងមកនេះឡើងមកនៅជួរនេះ នេះស៊ីងមេទឹក ។

បូលីៈ ស៊ីងស្នួរស្តី?

គីមថុនៈ បាទ! ស៊ីងមេទឹក មានដៃមួយគេហៅអូរស្នួរស្តីទៅនៅម្តុំហ្នឹង នៅក្នុងដីខ្មែរយើងត្រង់ហ្នឹង ដល់ពេលមានការបោសសំអាតនៅព្រំដែន បានខ្ចាតចេញមកនៅត្រង់ហ្នឹង ក-១៨ ។

បូលីៈ មុនដំបូង៨៧នៅក្នុងហ្នឹង?

គីមថុនៈ ៨៧គាត់ចេញពីភ្នំពេញគេចេះតែនាំគ្នាហៅទៅកន្លែង៨៧ៗ ហើយបានប្រមូលពួកខ្ញុំដែលនៅប៉ុន្មានតាំងពីនេះមាន ប៉ៃលិន, ម៉ាឡៃ ហើយមាននៅស៊ីសុផុនខាងជើង ១០០៣, ១០០១មកនៅម្តុំនេះ បង្កើតបានជាអង្គភាពមួយ១៣១ ក្រុមជំនួយការយល់ទេ ។ អីចឹង៨៧ជាឈ្មោះដែលបន្សល់តាំងពីភ្នំពេញមក ៨៧០បន្សល់ពីហ្នឹងគេហៅ៨៧ ។

បូលីៈ ៨៧០ហៅកាត់៨៧?

គីមថុនៈ បាទ! ទៅជាអីចឹង ។

បូលីៈ អីចឹង៨៧វានៅក្នុងដីខ្មែរ?

គីមថុនៈ ក្នុងដីខ្មែរ កាលដំបូងនៅចំរាក់ភ្នំនេះ ចំរាក់ភ្នំក្រវាញបានបង្កើតជាអង្គភាព១៣១ហ្នឹងដែលមានវិទ្យុ ហើយប្រកាសថារំលាយបក្សកុំមុយនីស្តនៅពេលហ្នឹង ។

បូលីៈ អ៎!

គីមថុនៈ រំលាយបក្សកុំមុយនីស្តខ្លួនឯងនៅកន្លែងហ្នឹង ។

បូលីៈ ឆ្នាំប៉ុន្មានរំលាយបក្សកុំមុយនីស្ត?

គីមថុនៈ ដូច៨២ ។

បូលីៈ គេមានប្រកាសពីហេតុផល ថាហេតុអីបានជារំលាយចោល?

គីមថុនៈ មូលហេតុដែលនាំឲ្យរំលាយបក្ស បើនៅកាន់កុំមុយនីស្តតទៅទៀត តស៊ូអត់បានទេ ប្រមូលអ្នកខាងលិចក៏អត់បាន ប្រមូលដូចជាអាមេរិក, អូស្ត្រាលី, ដូចជានៅប្រទេសផ្សេងៗទៀតគេថាយើងនៅសង្គមនិយម អីចឹងឈប់ធ្វើហើយ រំលាយបក្សកុំមុយនីស្តចោលហ្នឹងទៅ ។ គេច្រើននិយាយ ពួកនៅហ្នឹងច្រើននិយាយ តាម៉ុក គាត់ថា ឯងទុកធ្វើអីបក្សចាញ់គេ រំលាយចោលទៅ តាម៉ុក ថាអីចឹង ។ តែហេតុផលគាត់ថា ប៉ុល ពត មានពេលមួយគាត់ថា បើយើងនៅរក្សាសង្គមនិយមតទៅទៀត យើងរើរំដោះប្រទេសអត់បានទេ អីចឹងយើងដាក់ទៅរកទីផ្សារសេរី ។

បូលីៈ ចុះបើរំលាយបក្សកុំមុយនីស្តយើងដឹកនាំតាមបែបអីវិញ?

គឹមថុងៈ រំលាយគឺប្រកាសប្រជុំផ្ទៃក្នុងគាត់ មិនដឹងប្រជុំពេលណាទេ តែខ្ញុំគ្រាន់តែដឹងថាប្រកាសរំលាយនៅកន្លែងហ្នឹង រំលាយបក្សកុំមុយនីស្ត ឈប់ធ្វើកុំមុយនីស្ត ។

បូលីៈ ពេលប្រកាសហ្នឹងមានសមាជិកធំៗមកចូលរួមច្រើនទេ?

គឹមថុងៈ ដូចជាមិនមានអីច្រើន មានតាម៉ុក, សុន សេន, ខៀវ សំផន, នួន ជា សមាជិកគាត់ប៉ុន្មានហ្នឹង ។ មកគឺនៅកន្លែងហ្នឹង ខ្ញុំដឹងនៅកន្លែងហ្នឹង ។

បូលីៈ យើងអត់ដើរតាមគោលការណ៍កុំមុយនីស្ត យើងដើរតាមគោលការណ៍អីវិញទៅ?

គឹមថុងៈ គេហៅថាសេរីពហុបក្ស គាត់ថាគ្មានផ្លូវជ្រើសរើសទេ ហើយផ្អែកលើសភាពការណ៍ទូទាំងសកលលោកវាវិវត្តន៍ទៅអីចឹង ហើយមើលប្រៀបធៀបទៅបក្សកុំមុយនីស្តយួន ប្រៀបធៀបទៅបក្សកុយបា, ប្រៀបទៅបក្សសម្ព័ន្ធវាសាវីកាលហ្នឹង ដែលមានបុកខាងជើង ។ គាត់ថាអត់អាចដើរទៅផ្លូវកុំមុយនីស្តទៀតបានទេ បើដើរទៅផ្លូវកុំមុយនីស្តទៀតគ្មានពីណាគាំទ្រទេ ព្រោះវាមានអំពើ៣ឆ្នាំគាត់ឃើញ ។ ហើយខ្ញុំដឹងរឿងរ៉ាវ៣ឆ្នាំដែលមានតាមកន្លែងមួយៗធ្វើបាបប្រជាពលរដ្ឋ ដឹងជុំគ្នាដែលគេរត់មកឃើញ គាត់សហករណ៍ខ្លះ ខ្ញុំកាលហ្នឹងនៅតែនេះអត់ដឹងរឿងរ៉ាវអីច្បាស់លាស់ អីចឹងហើយបានកន្លែងដែលគាត់ផ្ដើមឲ្យមានពន្ធកកិច្ចព្រមព្រៀងប៉ារីសគឺនៅកន្លែងហ្នឹង ។

បូលីៈ អីចឹងបានន័យថាពេញទសវត្សន៍ឆ្នាំ៨០ ប៉ុល ពត នៅហ្នឹងរហូតឬយ៉ាងម៉េចអ៊ំ?

គឹមថុងៈ បាទ! នៅហ្នឹងរហូតដល់មានកិច្ចព្រមព្រៀង ។

បូលីៈ ៧៩-៩១?

គឹមថុងៈ បាទ! នៅហ្នឹងរហូត ហើយគាត់គ្រាន់តែចល័តមកកន្លែងហ្នឹង ម្ដុំហ្នឹង ដូចខ្ញុំប្រាប់អីចឹងតែជាអចិន្ត្រៃយ៍គាត់នៅនេះ ហើយកន្លែងគាត់រស់នៅរបៀបដូចគាត់ចល័ត ពេលខ្លះគាត់ដើរលេងនៅប៉ាតេយ៉ា គាត់ពាក់ពុកមាត់ ធ្វើពាក់សក់ ពាក់អាវធំធ្វើដូចថៅកែ ដើរលេងទៅ គ្រាន់តែដើរជាមួយគាត់ប្លែក ត្រង់គាត់ទិញក្រូចគាត់មើល ជនជាតិថៃ មើលហ្នឹងមិនមែនជាមនុស្សថៅកែគាត់ទិញនៅហ្នឹង របៀបគាត់លើកដវ៉ាន់គេមកលក់ គាត់ទិញហើយអត់ឲ្យអាប់ទេ ឧបមាថាក្រូចមួយគីឡូ២៥ ទិញ៥-១០គីឡូសល់លុយអត់ឲ្យអាប់ទេ គាត់ថាមិនបាច់អាប់ទេ ពីព្រោះអ្នកហ្នឹងលើកពីគេ គាត់បំណោញតិចតួច ។

បូលីៈ គាត់ចេះភាសាថៃទេ?

គឹមថុងៈ ចេះស្ដាប់បានខ្លះ ។

បូលីៈ គាត់ដែលនិយាយភាសាថៃទេ?

គឹមថុង៖ អត់ទេ ភាសាបារាំងគាត់ចេះ ភាសាអង់គ្លេសគាត់មើលយល់ ព្រោះពីដើមធ្លាប់នៅបារាំង ហើយជំនាន់គាត់រៀន រៀនភាសាបារាំងច្រើនជាង ។

បូលី៖ ពេលគាត់ដើរលេង គាត់ពិសាស្រាទេ?

គឹមថុង៖ អត់ ។

បូលី៖ អត់សោះតែម្តង?

គឹមថុង៖ គាត់ហូបដែល ហូបតិចតួចនៅផ្ទះ នៅកន្លែងគាត់ហូបស្រា គាត់ថាសំរាប់អាយុមនុស្សចាស់ ហូបដើម្បីកំដៅឈាមឲ្យរលាយ ។

បូលី៖ មិនមែនហូបរបៀបយើងហូបច្រើន?

គឹមថុង៖ អត់ទេ ។

បូលី៖ ចុះបារីគាត់ជក់ទេ?

គឹមថុង៖ អត់ហូបទេបារី ។

បូលី៖ អត់សោះតែម្តងបារី?

គឹមថុង៖ បាទ! គាត់អត់ហូបសោះបារី ។

ដានី៖ ម៉ិញខ្ញុំបានអគ្គភាព២១ អឺមានប្រសាសន៍ថាអគ្គភាព២១ នួន មនោ ហៅ ម៉ី ម៉ាក់ ហ្នឹងគាត់គ្រប់គ្រងនៅអគ្គភាព២១?

គឹមថុង៖ ប្រធានផ្នែកហ្នឹង ។

ដានី៖ ផ្នែកអគ្គភាព២១?

គឹមថុង៖ បាទ!

ដានី៖ ប៉ុន្មាននាក់នៅក្នុងអគ្គភាព២១?

គឹមថុង៖ ដូចជាមានគ្នាមិនច្រើនទេ ២១, ២២, ២៣, ២៤ មានតែ២ៗនាក់ទេ ៨នាក់ជាងទេ ប្រហែលជា១០នាក់ ហើយមានផ្នែកធ្វើដំណឹងសមរភូមិ ហើយមានផ្នែកតាមដានឯកសា ដូចខ្ញុំនិយាយពួកស៊ើបអង្កេត ហើយមានឯកសារទាក់ទងដល់ការចាត់តាំងកងទ័ព ហើយស្រាវជ្រាវថាតើកងទ័ពវៀតណាមមកកម្ពុជាមានប៉ុន្មានកងពល? មានប៉ុន្មានវរសេនាធំឯករាជ្យ? ហើយពេលសង្គ្រាមជាមួយកម្ពុជាបាត់កងពលណាខ្លះដែលរលាយឈ្មោះ? បាត់ឈ្មោះតែម្តង ដូចជាកងពលលេខ៩ ឬលេខ៣ទេដែលរលាយនៅប៉ៃលិន ។

ដានី៖ កងពលរបស់ពីណា?

គឹមថុង៖ កងពលវៀតណាម ហើយបានចាត់តាំងដូចជា២៨៦ ឬមិនដឹង ខ្ញុំអត់ចាំ កងពលរបស់ទា បាញ់ កាលហ្នឹងទា បាញ់ កាន់គ្រប់គ្រងនៅម្តុំហ្នឹង ។

ដានី៖ ចុះអន្តភាព៣១?

គីមថុង៖ ១៣១ក្រោយពីអានេះ ក្រោយពីវៀតខ្មៅខ្ចាយព្រំដែនទៅអូរស្វរស្តី គាត់មកនៅក-១៨ ហ្នឹងអត់មានទេ មានតែឈ្មោះ ហើយមនុស្សនៅក្នុងជំរំថ-៧ទាំងអស់ៗ អ្នកទាំងអស់ហ្នឹងហើយដែលក្លាយទៅជាសិល្បៈ រ៉ា ពីមុននៅ៦១ដាច់ដើង អ្នកនិពន្ធសៀវភៅហ្នឹងក្រោយមកគេរៀបចំសិល្បៈៗ

ដានី៖ អីចឹងអន្តភាព៣១ហ្នឹងពេលដែលៗ

គីមថុង៖ ១៣១ៗ

ដានី៖ ១៣១ហ្នឹង តែអ៊ំមានប្រសាសន៍ថា១៣១មានអន្តភាព២១, ៣១ តែ៣១ហ្នឹងយ៉ាងម៉េច?

គីមថុង៖ អស់ហើយ អត់មានកន្លែងធ្វើការទៀតទេ នៅក្នុងជំរំទេៗ

ដានី៖ តែខាងស្ថិតិប្រជាជនអស់ហើយ?

គីមថុង៖ អស់ហើយ បានមកនៅបង្កើតក-១៨ បានជ្រើសរើសមនុស្សគេស្គាល់ថាមានស្នាដៃអាចធ្វើការបាន មនុស្សម្នាក់ធ្វើការបាន២-៣មុខ ហើយចេះរើសៗ រើសមុនដំបូងឈ្មោះហ៊ាង ទៅមុនគេ បន្ទាប់មកឈ្មោះ អ៊ុង ក្រោយមកទៀតបានយកខ្ញុំ ខ្ញុំទៅធ្វើទស្សនាវដ្តីហ្នឹងៗ

ដានី៖ ហ្នឹងនៅអន្តភាពអីគេ?

គីមថុង៖ នៅក-១៨ ចេញពី១៣១ អតីត១៣១អន្តភាពៗ

ដានី៖ ចុះ៤១វិញ?

គីមថុង៖ ៤១ក៏អស់ដែរ ខ្លះមកនៅជាអ្នកកន្លែងកាន់វិទ្យុ អស់ហើយៗ

បូលី៖ មុននឹងអស់ពីណាគេ?

គីមថុង៖ និយាយរួមក្រោយពីចេញពីដើងភ្នំដែលខ្ញុំថា ទៅនៅអូរស្វរស្តី ហើយចេញពីអូរស្វរស្តីអស់នៅតែមនុស្សតែអន្តភាពអត់មានធ្វើការៗ

បូលី៖ បែកខ្ញែកគ្នាអស់?

គីមថុង៖ អត់បែកខ្ញែកនៅជុំ នៅក្នុងជំរំៗ

ដានី៖ តែយើងចាត់ដំបូង ចាត់ជាអន្តភាពដំបូង អ្នកគ្រប់គ្រងដូចជា២១ មាននួន មនោ ដល់ពេល៣១ពីណាគេ?

គីមថុង៖ ៣១ ដែលខ្ញុំនិយាយថាសាង នៅមណ្ឌលគិរី គាត់ជាផ្នែកហ្នឹង ដល់វាបែកខ្ញែកគ្នាអស់រលីងមានតែឈ្មោះទេ ហើយការងារក៏អត់ធ្វើអីដែរៗ

ដានី:	ដល់ពេល៤១?

គឹមថុង:	៤១ក៏ដូចគ្នា ។

ដានី:	ពីណាគេអ្នកគ្រប់គ្រងដំបូង?

គឹមថុង:	៤១រាល់ថ្ងៃដូចជាមួយនៅកាកបាទក្រហមនៅប៉ៃលិន ។

បូលី:	ឈ្មោះអីគេ?

គឹមថុង:	ទៅស្រាវជ្រាវគាត់ដឹងហើយ ឈ្មោះ សែង ពីដើម ។

ដានី:	សែន?

គឹមថុង:	សែង ។

បូលី:	លីសែង?

គឹមថុង:	ស-ែ-ង ។ គាត់ហ្នឹងត្រូវជាក្មួយប្រសាររបស់តាពក ។

ដានី:	ក្មួយប្រសារកែ ពក?

គឹមថុង:	បាទ! កែ ពក ឥឡូវគាត់នៅសាខាងកាកបាទក្រហមកម្ពុជានៅប៉ៃលិន ដូចជានៅខាងមន្ទីរទេសចរណ៍ជាមួយថេន ប្អូនស្ងួ ហុង នៅជាមួយហ្នឹង គាត់ធ្លាប់មកលេងផ្ទះខ្ញុំ ។

ដានី:	ចុះ៥១?

គឹមថុង:	តាសាន ហ្នឹងដែលខ្ញុំថាទៅមណ្ឌលគិរី ។

ដានី:	ហ្នឹងគ្រាន់៣១?

គឹមថុង:	៣១ តាសាង ។

បូលី:	មួយសាន ,មួយសាង?

គឹមថុង:	មួយសាន ។

ដានី:	៣១សាង ដល់ពេល៥១ សាន?

គឹមថុង:	៥១សាន, ៥១ សាង ។

បូលី:	ចុះ៦១?

គឹមថុង:	៦១ឆោម ហើយនិងតាវង់ ពីដើមអតីតគ្រូ ឥឡូវដូចថានៅប៉ៃលិន ។

ដានី:	ទាំងពីរនាក់ សោម ហើយនិងវង់ គាត់នៅប៉ៃលិន?

គឹមថុង:	ឆោម ឥឡូវនៅប៉ៃលិន ហើយគាត់ធ្លាប់បានទៅសម្ភាសន៍នៅសាលាក្តីខ្មែរក្រហម ឆោម ហ្នឹង ។

ដានី:	គាត់បានទៅសម្ភាសន៍នៅសាលាក្តីខ្មែរក្រហម?

គីមថុន: បាទ! គាត់និយាយពីរឿង ដូចខ្ញុំនិយាយប្រវត្តិអង្គភាព ដូចគ្នា ខ្ញុំដឹងពីអ្នកដែលនៅជាមួយគ្នា ។ គាត់មកខ្ញុំសួរទៅ គាត់និយាយរឿងនោម ។

ដានី: ចុះ៧១?

គីមថុន: ៧១កាលហ្នឹងប្រធានគេឈ្មោះវុន ហើយនិងយ៉ាន់ នៅភ្នំព្រឹក វុន នៅភ្នំព្រឹកដែរ ។ វុនក្រោយមកគាត់ទៅនៅប៉ៃកាំង ទៅនៅកន្លែងវិទ្យុ ដល់ពេលគាត់ នេះរូបថតគាត់ ដល់ពេលគាត់មានកិច្ចព្រមព្រៀងប៉ារីសគាត់ឈប់ ។ គាត់អត់មកកាលហ្នឹងដូចគាត់ជាប់រវល់អី នេះខ្ញុំ គាត់មកនៅអ្នកបកប្រែខ្ញុំ ព្រោះខ្ញុំអត់ចេះអង់គ្លេស និយាយតែខ្មែរ ។

ដានី: អ៊ីចឹងលោកពូពេលមន្ទីរទាំងអស់ហ្នឹងថាបែកខ្ចាត់ខ្ចាយ ដល់ពេលចូលទៅក្នុងដីថៃ?

គីមថុន: ក-១៨ហ្នឹងគេជ្រើសរើស ។

ដានី: ក-១៨ អង្គភាពណាខ្លះនៅ អង្គភាពណាខ្លះគេរំសាយចោល?

គីមថុន: មានខ្ញុំ ហើយនួន មនោ អង្គភាព២១ ។

ដានី: អង្គភាព២១នៅដដែល?

គីមថុន: នៅដដែល តែអត់មានអ្នកណាផ្សេងទៅធ្វើអីទៀតទេ មានតែខ្ញុំ ហើយនិងនួន មនោដោយសារខ្ញុំយល់ពីការប្រើប្រាស់ដែនទី ជាលក្ខណៈនយោបាយ ជាលក្ខណៈយោធាខ្ញុំយល់ស្ទាត់ ដែនទីហ្នឹង ។

ដានី: ចុះអ្នកផ្សេងៗគាត់ទៅខាងណាផ្សេងវិញ?

គីមថុន: ក្រោយមកគាត់នៅជំរំ ខ្លះគាត់ជំរំមួយហៅថាសាតថេ ទៅរកស៊ីធម្មតា ឧបមាថាយកខ្ញុំដូចគាត់អស់សង្ឃឹមថាគេមិនប្រើប្រាស់គាត់អីទៀត គាត់នឹងបំបែងខ្លួនគាត់ឲ្យទៅជាប្រជាជនធម្មតា ទៅរកធម្មតាទៅ ព្រោះស្ថានការណ៍មិនអនុគ្រោះឲ្យគាត់កសាង ។

ដានី: ក្រុមជំនួយការរបស់ប៉ុល ពត នៅសល់ប៉ុន្មាននាក់ទៅអ៊ីចឹង?

គីមថុន: នៅតិចបំផុតចំរាញ់យកតែអ្នកដែលអាចធ្វើការបាន ដូចខ្ញុំនិយាយពីខាងដើម ឧបមាថាម្នាក់ធ្វើការបាន២-៣មុខ រ៉ាប់រងធ្វើ ដូចខ្ញុំស្រាវជ្រាវកំលាំងទាហានយួនផង ធ្វើទស្សនាវដ្ដីផង ហើយគ្រប់គ្រងការផ្សាយសារ ទទួលសារផង ច្រើនមុខណាស់ អ៊ីចឹងគេជ្រើសរើស នៅពេលដែលគេសាកល្បងមួយឆ្នាំដែលនៅកន្លែង ដែលខ្ញុំថាចាប់ផ្ដើមកកើត១៣១ហ្នឹង គេដឹងកំរិតមនុស្សហើយ អ៊ីចឹងពេលគេរើស គេរើសទៅអ៊ីចឹង ដកហូតយកអ្នកដែលអាចប្រើប្រាស់បាន ។

ដានី: បែកខ្ញែកហ្នឹងខុងឆ្នាំប៉ែតប៉ុន្មានទៅ?

គីមថុន: ដូចជា៨៥-៨៦ ។

ដានី៖ បានន័យថា៨៥-៨៦តាមព្រំដែនហ្នឹងទាំងអស់ យើងរត់ចូលទៅខាងក្នុងដីថៃទាំងអស់ ឬយ៉ាងម៉េច?

គឹមចុង៖ ខ្លះនៅលើព្រំដែន ដូចជាកងទ័ពនៅជាប់នឹងព្រំដែន ហើយក្រុមគ្រួសារទ័ពភាគច្រើននៅក្នុងដីថៃមិនជ្រៅទេ ដូចនៅសំឡូត ដូចនៅប៉ៃលិន ដូចជា១០០១, ១០០៣ សុទ្ធតែក្នុងដីថៃទាំងអស់។

ដានី៖ អីចឹងចាប់ពី៨៥-៨៦?

គឹមចុង៖ បាទ! នៅក្នុងចន្លោះ៨២-៨៣-៨៤ ចន្លោះហ្នឹងគឺនៅហ្នឹង។

ដានី៖ អ៊ំកាលហ្នឹងអ៊ំមានដឹងព្រឹត្តិការណ៍នៅខាង១០០១ ចាប់ពី៨៥យ៉ាងម៉េចទៀតទៅ?

គឹមចុង៖ ខ្ញុំដាច់តាំងពី៧៩ តាំងពីចេញពីនោះមកខ្ញុំអត់ដឹងទេ អត់ដឹងជាខ្សែសង្វាក់ ពីព្រោះខ្ញុំដឹងតែតាមសារទូរលេខ។

ដានី៖ ដឹងយ៉ាងម៉េច?

គឹមចុង៖ សារទូរលេខដែលទាក់ទងមកកន្លែងហ្នឹង ទាក់ទងមកកន្លែងក-១៨ហ្នឹង ហើយខ្ញុំដឹងកិច្ចការជ្រៅនៅពេលដែលខ្ញុំនៅក-១៨ ដឹងរឿងច្រើន។

ដានី៖ អីចឹងយ៉ាងម៉េចទៅពេលហ្នឹង សភាពការណ៍មុំ៣, ១០០១?

គឹមចុង៖ ដូចជារក្សានៅអីចឹង មុំ៣ក្រោយមកដូចស្ងាត់ ១០០១ដូចជានៅកន្លែងនេះនៅដដែលតែក្រោយមករវើរវាត់ខ្ចាយ រត់អស់រលីងជ្រុងហ្នឹង ដូចជាមកនៅមុំនេះ ១០០៣, ១០០២ គេហៅ១០០១។ នេះនៅមុំ១០០៣, ១០០២ កន្លែងតាម៉ុក នៅ។

ដានី៖ ចុះសុន សេន គាត់ទៅណាវិញទៅ?

គឹមចុង៖ គាត់នៅ១០០១ហ្នឹង មិនមែននៅកន្លែងនេះទេ នេះដំបូងជុំគ្នា ក្រោយមកកងទ័ពវៀតណាមវាយខ្ចាយអស់ហើយ បានមកនៅមួយដួរអស់នេះ ខ្ញុំអត់ដឹងច្បាស់ទេ អត់ដឹងចំណុចហើយខ្ញុំមិនដែលដើរទៅដល់ ១០០៣ក៏ខ្ញុំអត់ស្គាល់ដែរ។

ដានី៖ ពេលដែលយើងមកនៅមន្ទីរក-១៨ហ្នឹង ដូចថាខាងនេះធ្លាប់ទៅប្រជុំជាមួយក-១៨?

គឹមចុង៖ មកទាំងអស់។

ដានី៖ មកទាំងអស់តែព័ត៌មានផ្សេងៗ អ៊ំមានដឹងថាពេលហ្នឹងយ៉ាងម៉េចខ្លះទៅ?

គឹមចុង៖ ព័ត៌មានម៉េច?

ដានី៖ ព័ត៌មានតាមព្រំដែន តាមខាងនេះ ទាក់ទងនឹងកងពល ទាក់ទងពីទីតាំង កងពលណាឈរជើងនៅណា? ទីតាំងរបស់កងពលមួយៗ?

គឹមថុន: ការពិតចាប់ពីត្រឹមនេះមករហូតដល់មកនេះ មកចូលហ្នឹងទាំងអស់ មកចូលក-១៨ ព័ត៌មាន មកចូលកន្លែងតែមួយ ។

បូលី: ដុំនៅហ្នឹង?

គឹមថុន: បាទ! ដុំនៅហ្នឹង ។ ដូចនេះជាសមរភូមិមួយ នេះប៉ៃលិន មកហ្នឹងដែរ ។ នេះជាសមរភូមិមួយទៀតខាងជើងហ្នឹង មុំនី កន ក៏ចូលហ្នឹងដែរ ។ ហើយនេះកងពលរបស់ សូ ហុន នៅមុំនេះក៏ចូលមកហ្នឹងដែរ ហើយនេះមួយជួរ១០០១, ១០០៣ក៏ចូលមកនេះទាំងអស់ដែរ ជាកន្លែងតែមួយ ។

បូលី: ជាកន្លែងបណ្តុំព័ត៌មាន?

គឹមថុន: ដុំនៅហ្នឹងទាំងអស់គ្រប់មុខសញ្ញា ដុំមកហ្នឹងទាំងអស់ ។

បូលី: ទាំងអស់គ្នារាយការណ៍មកនេះ?

គឹមថុន: មកហ្នឹង ចាប់ពីត្រឹមហ្នឹងមករហូតចូលមកហ្នឹងទាំងអស់ ។

បូលី: ត្រូវធ្វើសកម្មភាពយ៉ាងម៉េចៗតបទៅវិញ គឺបញ្ជាចេញពីនេះទៅ?

គឹមថុន: បាទ! បញ្ជាពីហ្នឹងទៅ ។

បូលី: តើប្រធានកាន់កាប់កន្លែងមួយៗមានសិទ្ធិសំរេចវ៉ៃខ្លួនឯងទេ?

គឹមថុន: អត់ទេ លើកគោលការណ៍ច្បាស់ ដូចថាត្រូវរំដោះកន្លែងណាមួយ គេប្រជុំ គេសំរេចគ្នាថាត្រូវរំដោះយកមុំត្រពាំងថ្ម ត្រូវធ្វើសកម្មភាពវ៉ៃរំដោះហ្នឹង ហ្នឹងម្ចាស់ការនៅលើសមរភូមិមួយៗ ចាត់ចែងកំលាំងវ៉ៃ តែជាគោលការណ៍រំដោះអាហ្នឹង មានគោលដៅគេ ។ ដូចជានៅតាមផ្លូវជាតិលេខ១០ នេះក្រែង ឥឡូវថាយកទីប្រជុំជនក្រែងឲ្យបាន អ៊ីឈាន ហ្នឹងហើយជាអ្នកចាត់ចែងយកក្រែង បានមិនបាន ។

បូលី: តាមអ៊ំដឹងក្នុងទសវត្សរ៍ឆ្នាំ៨០ហ្នឹង ខ្មែរក្រហមមានកងពលប៉ុន្មានសរុបទាំងអស់?

គឹមថុន: ដូចជា២៤កងពល ៤វរសេនាធំឯករាជ្យ ខ្ញុំភ្លេចចាំអត់អស់លេខកងពល ។

បូលី: ដល់ជុត៩១មកកងពលទាំងអស់ហ្នឹងនៅរក្សារចនាសម្ព័ន្ធដដែល ឬបែកខ្ញែកខ្លះហើយ?

គឹមថុន: ការពិតក្រោយមានកិច្ចព្រមព្រៀងប៉ារីស ដូចជាកងពលមួយ ដូចជាបាត់ វាគិតថាសន្តិភាពហើយមានអ៊ុនតាក់មកជាអាជ្ញាកណ្តាល តែដល់អ៊ុនតាក់មួយរយៈហ្នឹងទៅ កាលហ្នឹងពហិការខ្មែរក្រហមអត់ចូលរួមធ្វើការបោះឆ្នោត ដោយសារព័ត៌មានមួយចំនួនដែលគាត់ថាមិនអាចទៅចូលរួមបាន ។ អ៊ីចឹងគាត់ចាប់ផ្តើមកាលហ្នឹង ទី១វ៉ៃស្មោង ខ្ញុំមកហ្នឹងនេះខ្ញុំមកក្បាលទន្សោង ។

ដានី: ឆ្នាំណាដែលអ៊ំមកហ្នឹង?

គីមថុង៖ ដូចជា៨៧ ខ្ញុំនៅភ្នំព្រឹក ខ្ញុំនៅហ្នឹងមកសរសេរអត្ថបទមកផ្សាយវិទ្យុនៅក្បាលទន្សោង ១ខែមកម្ដង ដូរគ្នា ដូរអ្នកដែលធ្លាប់នៅក-១៨ប៉ុន្មាននាក់ហ្នឹង ផ្លាស់ប្ដូរគ្នា ។

បូលី៖ អីចឹង៨៧ ប៉ុល ពត គាត់មកក្បាលទន្សោង?

គីមថុង៖ បាទ! គាត់មកនៅក្បាលទន្សោងហើយ ។

ដានី៖ ៨៧ ឬ៩៧?

គីមថុង៖ ៩៧ ។

ដានី៖ អីចឹងខ្ញុំចង់ច្បាស់បន្តិចកន្លែងនេះ ចាំមើលក-១៨នេះ អ៊ំមានប្រសាសន៍មុនថាពេលដែលយើងមានប្រជុំកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ៩១នៅហ្នឹងដដែល?

គីមថុង៖ លែងមានហើយ អស់ហើយ ចេញអស់ហើយ ចាប់ពីកិច្ចព្រមព្រៀងប៉ារីសចូលជាធរមានមក ចប់តែម្ដងកន្លែងហ្នឹង ។

បូលី៖ ថៃលែងឲ្យនៅ?

គីមថុង៖ ថៃគេនៅហ្នឹង ដីនៅជាដី ប្រហែលជាកាលហ្នឹងរាជរដ្ឋាភិបាលថៃគាត់ត្រូវជាមួយខ្មែរក្រហមដែល គាត់នៅរក្សា គាត់អត់ទាន់កាន់កាប់យកទៅណាទេ ។ កាលហ្នឹងប៉ុល ពត នៅមួយជួរនេះ ម្ដុំគេហៅជិតបន្ទាយនងចាន់ ម្ដុំនេះតាដាយ៉ាំទន្ទឹមហ្នឹង គេហៅ ។

ដានី៖ ជប់គគីរ?

គីមថុង៖ មិនមែនទេ ចំការគរ នេះតាដាយ៉ាំនៅមួយជួរហ្នឹង គាត់នៅហ្នឹង ។ ហ្នឹងនៅពេលដែលអ៊ុនគាក់ចូលមកគាត់នៅមួយជួរហ្នឹង ហើយខៀវ សំផន គាត់នៅនេះ ។

បូលី៖ ប៉ៃលិន ។

គីមថុង៖ សុន សេន នៅប៉ៃលិនដែរ នៅជាប់ព្រំនេះ គេហៅនៅបានប្រកាត នៅជិតព្រំដែនដោយឡែកប៉ុល ពត គាត់នៅនេះ នៅជាមួយ កាំង ហ្គេកអ៊ាវ គាត់នៅហ្នឹងជាមន្ទីរមួយ តែអត់មានការងារធ្វើ ។

ដានី៖ កន្លែងហ្នឹងគេហៅមន្ទីរអីគេបើយើងនិយាយចំកាលនោះ?

គីមថុង៖ អត់មានឈ្មោះមន្ទីរទេកាលនោះ ហ្នឹងគេហៅ ចុង១មាត់ ខ្ញុំនៅនេះ ។

ដានី៖ មន្ទីរអីម៉េចខ្ញុំធ្លាប់ កន្លែងហ្នឹងមិនកងពលរបស់ ។

គីមថុង៖ សូ ហុង!

ដានី៖ ឌុល សារឿន គាត់នៅហ្នឹង?

គីមថុង៖ សូ ហុង ។ ឌុល សារឿននៅជាមួយ សូ ហុង កងពល៥១៩ ។

ដានី៖ តែខ្មែរយើងហៅកន្លែងប្រកជប់គគីរ ។

គីមថុង: មិនមែនជប់គគីរទេ ។

បូលី: មិនមែនបឹងត្រកួនទេ?

គីមថុង: មិនមែនទេ បឹងត្រកួនចូលមកក្នុង ។

បូលី: ដីខ្មែរ ឬដីថៃ?

គីមថុង: នៅក្នុងដីខ្មែរ ។

បូលី: ដែលគាត់នៅហ្នឹងអី?

គីមថុង: បាទ!

ដានី: គាត់មកនៅហ្នឹងបានរយៈពេលប៉ុន្មានទៅ?

គីមថុង: ខ្ញុំអត់ចាំដែរ ខ្ញុំនៅនេះដូចដាច់ស្រយ៉ាលពីគ្នា ។

ដានី: អ៊ំអត់នៅនេះទេ?

គីមថុង: ខ្ញុំនៅប៉ៃលិនកំពុងតែប្រឡូកអ៊ុនគាក់ ជំនាន់នោះ ។

ដានី: អ៊ំមានប្រសាសន៍កន្លែងហ្នឹងតិច ដូចយើងបន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសមក រចនាសម្ព័ន្ធ?

គីមថុង: ក្រោយកិច្ចព្រមព្រៀងប៉ារីសចូលជាធរមាន អ្នកដែលដើរតួសំខាន់គឺ ខៀវ សំផន និង សុន សេន ។ អ្នកដើរតួកិច្ចការសន្តិភាពនៅកម្ពុជាដែលមានអ៊ុនគាក់ជាកណ្តាល ៤ភាគី សុន សេន និងខៀវ សំផន ក្រៅពីហ្នឹងមានមន្ត្រីទូតមួយចំនួន ដូចខ្ញុំបានរៀបរាប់ឈ្មោះ ដូចកោ ប៊ុនហេង, អ៊ិន សុភាព ហើយនិងម៉ក់ បេន មករួមនៅភ្នំពេញ ។ ឯ ប៉ុល ពត គាត់នៅហ្នឹង ខ្ញុំភ្លេចគាត់នៅត្រង់ហ្នឹង គាត់នៅជាលក្ខណៈធម្មតាអត់មានសកម្មភាពអីទេ ប៉ុន្តែក្រោយពីមានការវៃគ្នាស្មោងនេះ កំពង់ធំ នេះផ្លូវជាតិលេខ៦ ។ ស្មោងមួយដួរហ្នឹង វៃនៅស្មោងម្តុំក្រយាសង្គ្រាម វៃនៅហ្នឹងខ្ញុំនៅធ្វើការនៅក្បាលទន្សោងជាមួយគាត់ ចប់ពីហ្នឹងនឹងវៃនៅប៉ៃលិន មកវៃមែន ។

បូលី: ឆ្នាំណាអ៊ំ?

គីមថុង: ខ្ញុំអត់ចាំឆ្នាំទេ ។

បូលី: កិច្ចព្រមព្រៀងហើយនៅពេលហ្នឹង?

គីមថុង: មានហើយ មានកិច្ចព្រមព្រៀង មានរដ្ឋាភិបាលហើយហ្នឹង រដ្ឋាភិបាលដែលខ្មែរក្រហមហៅថារដ្ឋាភិបាលក្បាល២ មាននាយករដ្ឋមន្ត្រីទី១, នាយករដ្ឋមន្ត្រីទី២ កាលហ្នឹងនរោត្តម រណឫទ្ធិ គាត់នាយករដ្ឋមន្ត្រីទី១ ហើយសម្តេចនាយកគាត់នាយករដ្ឋមន្ត្រីទី២ ដែលខ្មែរក្រហមក្បាល២ ភ្នែក៣ ជំនាន់ហ្នឹងហើយ ។

ដានី៖ អ៊ំមានប្រសាសន៍ថាពេលហ្នឹងខាងប៉ុល ពត គាត់ចាត់តាំងឲ្យខៀវ សំផន ហើយនិងសុន សេន ជាអ្នកដើរតួ ។

គីមថុង៖ គាត់មិនមែនចាត់តាំងទេ គឺការពិតត្រូវតែគាត់ជាអ្នកដើរតួ ព្រោះគាត់គិតថាគាត់ឈប់ហើយ គាត់ចូលនិវត្តន៍ហើយ ។ គាត់គិតថាបញ្ហាថ្ងៃ២៣ តុលា ១៩៩១ហ្នឹងវាចប់គ្រប់សព្វហើយសង្គ្រាមនៅកម្ពុជា វាចប់ហើយ ប្រជាពលរដ្ឋបានសុខសាន្តដោយគ្មានសង្គ្រាមអីទៀតទេ តែចាប់កំរើកឡើងក្រោយពីមានការវ៉ៃតប់នៅស្មោង ត្រង់ក្រយារសង្គ្រាម ។

បូលី៖ មូលហេតុអីបានដុះហ្នឹង?

គីមថុង៖ ខ្ញុំអត់ដឹង ។

បូលី៖ ខាងណាផ្ដើមមុន?

គីមថុង៖ ខ្ញុំមិនដឹងថាខាងណាផ្ដើមមុន តែមានការវ៉ៃគ្នានៅហ្នឹង ។

បូលី៖ ខាងណាឈ្នះ ខាងណាចាញ់ពេលហ្នឹង?

គីមថុង៖ កាលហ្នឹងមិនដឹងអ្នកចាញ់ អ្នកណាឈ្នះទេ ស្ងប់អាហ្នឹងហើយវ៉ៃខ្ចាត់ខ្ចាយ ពួកវ៉ែននៅអន្លង់វែងដឹងរឿងវ៉ាវ៉ៃនៅស្មោង ក្រោយមកបានគាត់ប៉ាន់ប្រមាណថាវ៉ៃនៅប៉ៃលិនវ៉ៃមែន ។ វ៉ៃប៉ៃលិនៗដកចេញអស់រលីង បានពួកខ្ញុំមកនៅភ្នំព្រឹក ដែលជាដើមចមវិទ្យុមុនដំបូងដាក់នៅភ្នំព្រឹក ក្រោយមកបានយកមកនេះ ។

បូលី៖ ក្បាលទន្សោង?

គីមថុង៖ បាទ! មកដាក់នៅក្បាលទន្សោង ចុងក្រោយគេ ។

បូលី៖ ក្បាលទន្សោងមកនៅប្រហែលឆ្នាំប៉ុន្មានអ៊ំ? កៅប៉ុន្មាន?

គីមថុង៖ ក្បាលទន្សោងដូចជា៩៧-៩៨ ព្រោះខ្ញុំចុះមកធ្វើស្រែហូបខ្លួនឯង ។

បូលី៖ គាត់ស្លាប់ឆ្នាំ៩៨ប៉ុល ពត ឆ្នាំ៩៧ តាម៉ុក ចាប់គាត់កាត់ទោស អីចឹងបានន័យថាគាត់មកមុនហ្នឹងទៀត?

គីមថុង៖ មកមុនហ្នឹងប្រហែលជា១ឆ្នាំទេ ។

ដានី៖ ៩៦?

គីមថុង៖ ហើយផ្ទះគាត់នៅជាកន្លែងរបស់តាម៉ុក ទេ ។ ផ្ទះហ្នឹងអានៅពើយ ហើយផ្ទះពួកខ្ញុំចូលមកមានរបងស៊ីម៉ង់ ចូលតិចមកមានបឹង ។

បូលី៖ ក្បាលទន្សោងហ្នឹង?

គីមថុង៖ បាទ! ហើយផុតពីបឹងហ្នឹងផ្ទះពួកខ្ញុំនៅខាងនេះ ។

បូលី៖ ប៉ុន្មាននាក់?

គឹមចុង: ខ្ញុំនៅជាមួយពួកសិល្បៈផង ៦-៧ផ្ទះ ។

បូលី: ច្រើនអីចឹង?

គឹមចុង: ដាំបន្លែ ដាំស្រូវ ដើម្បីស៊ីនៅហ្នឹង កាលជំនាន់ហ្នឹងខ្ញុំបានស្រូវច្រើនជាងគេ ពីព្រោះព្រឹកខ្ញុំធ្វើដំណើរផ្សាយវិទ្យុ ដល់ថ្ងៃម៉ោង១១ខ្ញុំធ្វើហើយខ្ញុំចុះមកកាប់ចំការនៅក្រោម ខ្ញុំមកជាមួយកូនខ្ញុំដែលថាស្លាប់ មកតែ២នាក់ឪកូន ។

បូលី: ទៅទាំងគ្រួសារអីចឹង?

គឹមចុង: ទៅតែខ្ញុំទេ ដល់ខែប្រមូលផលបានគ្រួសារខ្ញុំនៅកូនតូចៗ គាត់នៅតែលើភ្នំ នៅក្បាលទន្សោងហ្នឹង នៅមុំភូមិ១០៥ ។

បូលី: ពេលអ៊ំទៅនៅក្បាលទន្សោង កូន ចៅ ប្រពន្ធ នៅណា?

គឹមចុង: នៅក្បាលទន្សោង ។

បូលី: ទាំងអស់គ្នា?

គឹមចុង: បាទ! មូលហេតុដែលនាំឲ្យខ្ញុំមកនៅក្បាលទន្សោង ដោយសារសុន សេន រកចាប់ខ្ញុំ ។

បូលី: រឿងអី?

គឹមចុង: ថាខ្ញុំលក់ឡាន រកស៊ីលក់ឡាន ទិញឡានចោររបស់ថៃមកលក់ ហើយខ្ញុំមានលុយណាការពិតគេប្រឡំ ហើយសុន សេន ជាមនុស្សដែលចូលចិត្តទទួលរបាយការណ៍ដែលមានអ្នកអានេបអានើបច្រើន ទៅរាយការណ៍ ស្អប់ខ្ញើមម៉េចៗ ហើយខ្ញុំធ្លាប់តស៊ូមតិជាមួយគាត់ញឹកញាប់កាលខ្ញុំនៅអ៊ុនតាក់ ។ ខ្ញុំតស៊ូមតិកន្លែងខ្លះ រហូតដល់ហៅខ្ញុំមកកសាង ៣ថ្ងៃហៅមកកសាង ឲ្យតែអ្នកណានិយាយរឿងខ្ញុំអីថាមិនល្អហៅមក ឲ្យសំដែងដូចសំដែងអាបាត់អីចឹង ខ្ញុំដាក់ឲ្យគាត់ធ្ងន់ៗដែរ គាត់សួរសំនួរខ្ញុំ មានសំនួរ៣-៤ដងសួរខ្ញុំអាហ្នឹងសួរពីរឿងអត្តចរិតខ្ញុំអីចេះៗ ដល់ហើយខ្ញុំបកស្រាយ អត្តចរិតខ្ញុំសុំបកស្រាយឲ្យច្បាស់ ហើយសំនួរតាមខ្ញុំចាំសួរតែមនុស្សម្នាក់ទេ ខ្ញុំនិយាយអត់បើកនេះ ខ្ញុំឆ្លើយមកនេះឆ្លើយឲ្យច្បាស់តែម្តង សំរាប់អ្នកសួរ ខ្ញុំថាចរិតខ្ញុំ បើសិនថ្នាក់ដឹកនាំណាក៏ដោយ បើធ្វើអត់ស្រួលខ្ញុំអត់គោរពទេ ខ្ញុំអត់ចេះថ្វើមជ្រូក ថ្វើមគោយកទៅថ្វាយរាល់ថ្ងៃទេ បុណ្យសក្តិខ្ញុំមានប៉ុណ្ណាខ្ញុំទទួលប៉ុណ្ណឹង ខ្ញុំអត់ចេះបានដោយសារខ្ញុំយកត្រសក់ទុំមួយ យកពោតស្ងោរ ៤-៥ យកទៅថ្វាយ យកទៅប្រគេន ខ្ញុំអត់ទេ ហើយបានចេះតែមានរអៀសៗគ្នាតាំងពីពេលហ្នឹងមក ។ ពីព្រោះនៅភូមិមួយគេហៅភូមិបឹងព្រលិត នៅប៉ៃលិន នៅក្រោយផ្ទះក្បៀង កន្លែងចំការតាផែង កន្លែងសុន សេននៅហើយ ផ្ទះខ្ញុំនៅហ្នឹង ខេត្តប៉ៃលិន។ គាត់មកគាត់យករបងព័ទ្ធជុំវិញដាក់ខ្សែលួស លួសបន្លា ហើយកាលខ្ញុំនៅប្រធានគេនៅ

ហ្នឹង គេឲ្យរបបឡានអាកាម៉ង់កាមួយ ឡាន Jeep ហើយអ៊ី ឈានប្រុងឲ្យខ្ញុំតួយូតាមួយ បាំងកន្លះ គាត់ថាក្នុងនាមភាគីមួយជិះអាហ្នឹងដូចយ៉ាប់ណាស់ ជិះឡានសន្ត្រាមអ៊ុនគាត់ មើលងាយយើងណាស់ តែសុន សេន អត់ឲ្យខ្ញុំទេ ឲ្យអាកាម៉ង់កាហ្នឹង គាត់យកPajaro ទៅជិះទៅ ហើយទាស់គ្នាតាំងពីលំអៀងៗខ្ញុំ កសាងខ្ញុំទាំងប្តី ទាំងប្រពន្ធ ហើយខ្ញុំអត់សូវ គោរពគាត់ទេ។ នៅពេលដែលបោះរបងខ្ញុំយកកន្ត្រៃកាត់មីន របស់កងទ័ពអង់គ្លេសកាល ហ្នឹងគេទទួលដោះមីន កងទ័ពអ៊ុនតាក់ ខ្ញុំយកកន្ត្រៃហ្នឹងមកកាត់ ហើយដករបងចេញខ្ញុំ យកឡានចូលទៅផ្ទះ ហើយគេរាយការណ៍ថាពីណាកាត់ ហៅខ្ញុំទៅតិះទានខ្លាំងៗណាស់។

បូលី: ថាម៉េចខ្លះទៅអ៊ំ?

គឹមថុង: ថាមិត្តឯងអត់គោរពការចាត់តាំង។ ឲ្យខ្ញុំគោរពយ៉ាងម៉េច ខ្ញុំមិនមែនចោរណា ខ្ញុំនៅក្នុង ភូមិអ៊ំ ហើយខ្ញុំតិះទានមេមន្ទីរឈ្មោះ ខាន់ ដែលខ្ញុំទទួលមួយផ្នែកត្រឹមនេះ ជាមួយខ្ញុំ ៣នាក់ ដែលខ្ញុំថាមានរៀបចំ៣នាក់។ ខ្ញុំថាលោកប្រធានមើលទៅ ពីព្រោះកាលហ្នឹងវា មានការរៀបចំលំអៀង ឈ្មោះ យ៉ុនៗ កាន់ទូរលេខនៅភ្នំពេញហើយប្រពន្ធពោះធំ ហើយវិនៗ ដែលខ្ញុំថារាល់ថ្ងៃនៅភ្នំព្រឹកហ្នឹង គាត់អ្នកអានេបអានើបសុន សេន គាត់ថា ត្រឹមដងទឹកមួយពាង វិន ចេញពីប៉ៃលិនដងទឹកនៅបឹងព្រលិតជិះម៉ូតូមួយម៉ោងមកដងទឹក ឲ្យប្រពន្ធបាន តែសំរាប់យ៉ុន បើសុំអ៊ុនតាក់ជិះយន្តហោះមកអត់បាន សុំកន្លះខែបាន អីចឹងមិនអត់ អីចឹងការដឹកនាំលំអៀងហើយ អគតិហើយ ខ្ញុំអត់គាំទ្រទេ ខឹងខ្ញុំតាំងពី អីចឹងៗរហូត បានដល់បែកមានការវ៉ៃនៅប៉ៃលិន ខ្ញុំមកនៅភ្នំព្រឹក ដែលសុន សេន រក ចាប់ខ្ញុំហ្នឹង ខ្ញុំសរសេរសំបុត្រទៅប៉ុល ពត។ ខ្ញុំសរសេរសំបុត្រមួយខ្លី ខ្ញុំថាបើសិនណា ជាអ៊ំមិនដោះស្រាយទេ ជីវិតនយោបាយរបស់ខ្ញុំសុំបញ្ចប់ជាមួយអ៊ំហើយ ខ្ញុំដើរផ្លូវ ផ្សេងហើយ ខ្ញុំត្រៀមហើយ។ ទិសរបស់ខ្ញុំមានពីរ ទី១ចូលជាមួយរដ្ឋកម្ពុជា ទី២ខ្ញុំទៅ នៅថៃ ហើយបើសិនណាខ្ញុំទៅជាមួយរដ្ឋាភិបាលដែលបោះឆ្នោតឆ្នាំ១៩៩៣ខ្ញុំរស់ ហេតុ អីបានរស់ ខ្ញុំដឹងកន្លែងដូចខ្ញុំនិយាយអីចឹង ហើយកាលហ្នឹងឯកសារនៅរដ្ឋកម្ពុជាប្រហែល ជាមិនបានដឹងអីលំអិតទេ។ សំរាប់តែខ្ញុំចូលទៅជាមួយរាជរដ្ឋាភិបាលខ្ញុំរស់ រស់ដោយខ្ញុំ លក់ព័ត៌មានអីចឹង គេឲ្យខ្ញុំរស់កំរិតណាខ្ញុំអត់ដឹងទេ ខ្ញុំគិតអីចឹងបានគាត់ចារមកវិញរង់ចាំ មួយអាទិត្យ បានយកឡានមកដឹងខ្ញុំនៅនេះ នេះនងព្រៃ ចេញពីហ្នឹង ចេញមកមួយយប់ ភ្លឺបានមកដល់ក្បាលទន្សោង មកមួយយប់ទល់ភ្លឺ យកមកតែ២គ្រួសារទេ។ គ្រួសារខ្ញុំ មួយ កូនប៉ុន្មាននាក់ ហើយឈ្មោះ ស៊ីន អ្នកជិតស្និតនៅជាមួយប៉ុល ពត ហើយ ស៊ីន

ហ្នឹង ។ ឥឡូវមិនដឹងទៅណា បែកគ្នាអស់ មកតែ២គ្រួសារហ្នឹង ហើយ២នាក់ហ្នឹងដែលទំនាស់ជាមួយ សុន សេន ស្រួចតែម្ដង ស្អប់ជាងគេ ។

បូលីៈ អ៊ំ ហើយនិង ស៊ីន?

គីមថុងៈ ហើយនិង ហ៊ីង មួយទៀតនៅគីឡូ១៣ ថា៣នាក់ហ្នឹងគាត់ស្អប់ជាងគេ ។

ដានីៈ ណាខ្លះ អ៊ំ, គ្រួសារស៊ីន ហើយពីណាទៀត?

គីមថុងៈ ស៊ីន, ហ៊ីង ហើយខ្ញុំ ។ អីចឹងបានកាលតាម៉ុក ដេញប៉ុល ពត បើសុន សេន នៅរស់ខ្ញុំងាប់មុនគេ ខ្ញុំចូលទ្រុងដែករបស់តាម៉ុក ផ្សារដាក់ពួកគាសារៀន, ០៦ មុនគេហើយ ។ ជាមួយកែវ គាន់ អធិការស្រុកត្រពាំងប្រាសាទ អីចឹងបានខ្ញុំទាស់ជាមួយសុន សេនមូលហេតុដែលខ្ញុំមិនគោរព ខ្ញុំលឺពាក្យមួយម៉ាត់ដែលខ្ញុំអន់ចិត្ត គាត់ថាកសិករឲ្យចេះប្រើអត់បានទេ និយាយអីចឹងតែម្ដង សុន សេន អ្នកនិយាយ ។ ថាកសិករឲ្យចេះប្រើអត់បានទេ បានខ្ញុំគិតពិចារណាឡើងវិញ ខ្ញុំថាអីចឹង យើងរាល់ថ្ងៃជាឧបករណ៍របស់គេហេតុអីខ្ញុំដើរដល់ទីចុងផុត ខ្ញុំចង់ដឹងថាតើដំណើរទៅមុខទៀតខ្មែរក្រហមវិវត្តន៍ទៅយ៉ាងម៉េច ដើរឲ្យចប់ ដើរឲ្យកាល់ដល់ជញ្ជាំង ហ្នឹងជីវិតដែលខ្ញុំចង់ដឹងមើល ។ ទី២ទាក់ទងសន្តិសុខសំរាប់ផ្ទាល់ខ្លួន សំរាប់ក្រុមគ្រួសារខ្ញុំ ពីព្រោះខ្ញុំហាក់ដូចជាជាប់ប្រឡូកប្រឡាក់ផ្នែកនយោបាយខ្លះ នៅជាមួយមន្ទីរប៉ុល ពត ដូចប្រវត្តិខ្ញុំនិយាយហូរហែរពីដើមមកអីចឹងខ្ញុំគិតពីអនាគតកូនខ្ញុំ ថាអត់ពីខ្ញុំ កូនខ្ញុំទៅយ៉ាងម៉េច? អ្នកណាជាអ្នករង់គ្រោះ? អីចឹងគ្រួសារខ្ញុំ កូនខ្ញុំហ្នឹងជាអ្នករង់គ្រោះ ។ អីចឹងបានតាំងពីសមាហរណកម្មមកខ្ញុំខំធ្វើស្អីក៏ដោយដើម្បីជីវភាព ជីវិតកូនខ្ញុំ រហូតដល់ខ្ញុំកសាងកូនខ្ញុំឲ្យបានរៀនដល់ឧត្ដមសិក្សា ។

បូលីៈ ពេលដែលអ៊ំសរសេរសំបុត្រផ្ញើរទៅប៉ុល ពត ហ្នឹងផ្ញើរតាមណា?

គីមថុងៈ គេមានចេញ-ចូល ។ តាមរយៈគេយកព័ត៌មាន ។ ពួកខ្ញុំនៅភ្នំព្រឹកខ្ញុំសរសេរដំណឹងសរសេរព័ត៌មានអី គេមកយកពីហ្នឹងទៅ ហើយតាមរយៈទូរលេខ តាមរយៈការផ្លាស់ប្ដូរគ្នា វែនគេទៅមុនគេជ្រើសរើសមិនខុសអីពីមុនកើតក-១៨ គេជ្រើសរើសអ្នកចំណាន១ឬគេអាចទុកចិត្តខ្លាំងជាងពួកខ្ញុំ ដែលអាចស្រាលកូនតិច គេយកទៅស្រាលមុន តាមរយៈពួកហ្នឹងខ្ញុំផ្ញើរ ផ្ញើរតាមរយៈឈ្មោះយ៉ាន់ គាត់នៅផ្ទាល់ជាមួយប៉ុល ពត ។ យកទៅដល់ខ្ញុំសរសេរប្រាប់គាត់ថា ខ្ញុំហៅប្រើពាក្យតាខៀវ អ៊ំ១ បើខ្ញុំនៅជាមួយគាត់ប្រហែលជាខ្ញុំបាត់បង់អនាគតហើយ ប្រហែលអាចទាក់ទងដល់អាយុជីវិត ហើយបើអ៊ំអត់យកខ្ញុំ ឬអត់ដោះស្រាយខ្ញុំទេខ្ញុំលាហើយ ។ ខ្ញុំអាចបញ្ចប់ជីវិតនយោបាយរវាងអ៊ំនិងខ្ញុំ ហើយបានគាត់ចារមកវិញ គាត់ថាយល់ស្រប ខ្ញុំឃើញសំបុត្រមកដែរតែចាំមួយអាទិត្យទៀត

ដោះស្រាយ មួយអាទិត្យឃើញមកយកខ្ញុំ មកហ្នឹង មកកំពុងបោកខោអាវដាក់ខោអាវទាំងសើមទៅ ប្រពន្ធខ្ញុំ ។

បូលី: ពេលដែលអ៊ំនៅភ្នំព្រឹកហ្នឹង សុន សេន គាត់នៅហ្នឹងដែរឬយ៉ាងម៉េច?

គីមថុង: គាត់នៅគីឡូ១៣ នៅជាមួយនី កន ។ មេក្រហមខ្ញុំអត់ចូលចិត្តសុន សេន ហើយតាម៉ុកអត់ចូលចិត្តតែម្តងឃើញចរិត ពីព្រោះសុន សេន ជាមនុស្សបញ្ញាជនធំ តែកុំចិត្តទុកដាក់នៅពេលដែលនិយាយអីចឹង ខ្ញុំមើលទេ ចរិតគាត់ជាមនុស្សអភិជនមួយធំដូចជាពូជអំបូរគាត់អ្នកចេះ ហើយមើលស្រាលខ្ញុំក្រ ។ ខ្ញុំឃើញចរិតហ្នឹងមួយ ហ្នឹងហើយបានជាគាត់ខ្ញុំចេះតែសំគាល់ៗ បានជាគាត់កសិករបើឲ្យចេះប្រើអត់បានទេ ហើយអ្នកដឹកនាំក្រៅពីហ្នឹងខ្ញុំអត់ដែលលឺសំលេងអីចឹងទេ គាត់មានតែអប់រំនៅពេលអនាគតទៅ ក្រោយមានការផ្សះផ្សារជាតិយើងរស់នៅក្នុងសង្គមសេរីពហុបក្ស សង្គមដែលពោរពេញទៅដោយបរិយាកាសទំនើបគ្រប់បែបយ៉ាង អីចឹងត្រូវគ្រប់គ្រងខ្លួនយើងឲ្យបាន ។ ទី១ គិតពីរឿងសេដ្ឋកិច្ច ជីវភាពក្រុមគ្រួសារហ្នឹង អីចឹងបានខ្ញុំចេះតែគិតរហូតដល់ខ្ញុំមកចូលនេះ អ៊ីដែលខ្ញុំទទួលបាន ស្អីដែលល្អខ្ញុំយក អាណាដែលអត់ល្អ អត់យក ។ មុនគេចាប់ខៀវ សំផនគាត់មកសំរាន្តហ្នឹង អង្រឹងគាត់ ។

បូលី: អ្នកណា?

គីមថុង: ខៀវ សំផន ។

បូលី: តាខៀវ សំផន?

គីមថុង: បាទ! មុនគេចាប់គាត់ទៅចូលឃុំឃាំង គាត់មកសំរាន្តហ្នឹងប្រហែល២ម៉ោង មានវិទ្យុបារាំងមកសម្ភាសន៍ខ្ញុំនេះ ត្រង់ម៉ូតូ ។ កំពុងសម្ភាសន៍វិទ្យុបារាំងសួរថាអ្នកឯងខ្លាចអត់? ខ្លាចអ្នកណា នេះដេកនៅលើនេះ ខ្ញុំខ្លាចអី គាត់ដូចជាឪពុកខ្ញុំហើយខ្ញុំខ្លាចអី ខ្ញុំអត់មាននិយាយរឿងនយោបាយណា រឿងនយោបាយគាត់អ្នកធ្វើ ខ្ញុំអត់មានធ្វើនយោបាយណាខ្ញុំនៅជាមួយគាត់ បានក្រោយមកដឹងថាគេចាប់គាត់ទៅ ។

បូលី: ខ្ញុំសុំបកទៅកន្លែងក្បាលទន្សោងបន្តិច ពេលប៉ុល ពត ដឹកអ៊ំទៅនៅក្បាលទន្សោង ។ ពេលហ្នឹងកិច្ចការអ៊ំធ្វើអីបន្តទៀត?

គីមថុង: ខ្ញុំសរសេរដំណឹងវិទ្យុដដែល ។

បូលី: បន្តសរសេរដំណឹងទៀត?

គីមថុង: បាទ! សរសេរដំណឹងចាក់ចំរូង ពេលហ្នឹងចាក់ចំរូងហើយ ដាក់មីនថ្មេ នៅម្តុំកន្ទួតចារម្តុំដាំស្រែ សរសេរដំណឹង ហើយមួយផ្នែកទៀតដោះស្រាយជីវភាពខ្លួនឯង គេទិញដី

ប្រជាពលរដ្ឋនៅម្តុំជិតគេហៅស្រះឈូក ។ នេះផ្លូវចូលស្រះឈូក មានផ្លូវមួយមកចេះ ស្រែប៉ុល ពត ហើយហ្នឹង ប្រពន្ធគាត់ធ្វើស្រូវហ្នឹង ។

បូលី: ស្រែគំរូមែន?

គឹមថុង: មិនដឹងស្រែអីទេ ។

ដានី: ម្តុំរោងចក្រអារឈើ?

គឹមថុង: នេះកន្លែងផ្លូវចូលទៅកន្លែងដុតខ្មោចសុន សេន ហើយកប់សពតាម៉ុក ។

ដានី: ហ្នឹងវត្តស្រះឈូក ។

គឹមថុង: បាទ! វត្តស្រះឈូក នេះផ្លូវទៅពីដើងភ្នំ ហើយមានទៅផុតផ្លូវចូលទៅ ។

ដានី: ផ្លូវយើងចាក់ទៅខាង១០៥?

គឹមថុង: មិនមែនទេ ផ្លូវមួយមកចេះ មកនេះឆ្វេងដៃមានផ្លូវលំមួយ គេហៅភ្នំភូមិជើងភ្នំ ហ្នឹងជ្រុងហ្នឹងប្រពន្ធគាត់ធ្វើស្រូវ ដាំស្រូវម្ទេះ ។

បូលី: ប្រពន្ធទី២ហ្នឹង?

គឹមថុង: បាទ! ប្រពន្ធ ទេព ខុនណាល់ រាល់ថ្ងៃ ។

បូលី: ឈ្មោះអីគេ?

គឹមថុង: មាន ។

ដានី: ឈ្មោះពេញ?

គឹមថុង: មិនដឹងស្អី តែខ្ញុំនៅហ្នឹងហៅមានៗ មកនៅនេះខ្ញុំហៅតែយាយ កូនស្រីមួយ អាម៉ុលៗ នៅជាមួយខ្ញុំហៅអាម៉ុលៗ ។ កាលគាត់យកយាយមាន ហ្នឹង ពីដើមជានារីកងចល័តមក ធ្វើស្ពាននៅមេទឹក ។

បូលី: ស្ពាននៅណា?

គឹមថុង: ស្ពានមេទឹក ឆ្លងស្ពានមេទឹកខាងនេះអន្លង់រាប ។

បូលី: កាលដែលនៅអូរស្វាយស្តី?

គឹមថុង: បាទ! ហើយគាត់សរសេរសំបុត្រមកប្រាប់ពួកខ្ញុំថា អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យទាំង អស់សុទ្ធតែមានកូន មានគ្រួសារ ។ គេមានបរិយាកាសកំដរជីវិតក្នុងការតស៊ូ ប៉ុន្តែគាត់ ប្រពន្ធទី១គាត់អត់មានកូន ហើយមានវិបត្តិខួរក្បាលទៀត អីចឹងគាត់សុំយកគ្រួសារក្រែង លោមានកូន ដើម្បីកំដរបរិយាកាសក្នុងការដឹកនាំចលនាតស៊ូរំដោះជាតិ ។

បូលី: គាត់សរសេរអីចឹង?

គឹមថុង: បាទ! គាត់សរសេរអីចឹង ។

បូលី៖ សរសេរជាសំបុត្រ?

គីមថុន៖ ជាក្រដាសសំបុត្រ ។

បូលី៖ សរសេរឲ្យពីណា?

គីមថុន៖ សរសេរឲ្យពួកខ្ញុំដែលនៅក-១៨នេះ គាត់ការនៅកន្លែងនេះ កន្លែងមួយទៀតដែលគាត់ចល័តនៅចុះឡើងៗ គាត់ការនៅហ្នឹង ។

បូលី៖ ខ្ញុំសុំសួរកន្លែងហ្នឹងបន្តិច ម៉េចបានគាត់ត្រូវសរសេរសំបុត្ររឿងហ្នឹងមកប្រាប់អ៊ំវិញ?

គីមថុន៖ អត់មានប្រាប់ខ្ញុំទេ ប្រាប់អ្នកដែលរស់នៅជាមួយគាត់ នៅក្នុងមន្ទីរក-១៨ហ្នឹង ។ គាត់ថាគាត់នឹងយកគ្រួសារមួយទៀតហើយ អីចឹងអស់លោកទាំងអស់ពិចារណាទៅ គាត់និយាយហេតុផលអត់ ហើយគាត់ប្រាប់ថាគាត់យកគ្រួសារមួយទៀត ។

ដានី៖ គាត់និយាយចេញមូលហេតុទេ?

គីមថុន៖ គាត់គិតថាចៀសវាងនូវការរិះគន់ ពីមជ្ឈដ្ឋាននៅក្នុងកន្លែងគាត់ ថាអីម៉េចៗ តាមផ្លូវប្រពៃណី តែគាត់ការត្រឹមត្រូវ គាត់ការមុននឹងខ្ញុំទៅនៅកន្លែងហ្នឹង ។

ដានី៖ មុនការប្រពន្ធគាត់ជាស្អីគេ?

គីមថុន៖ ខ្ញុំថាធ្វើអ្នកមកវៃថ្នធ្វើស្ពានមេទឹក ហើយគាត់ថាឲ្យជ្រើសរើសនារីណាដែលមានចរិតសមរម្យយកមកឲ្យគាត់មើល ។ ដល់ហើយបានគាត់សំរេចចិត្តយក គេរើសដល់២-៣នាក់ ។

បូលី៖ អ្នកណាអ្នករើស?

គីមថុន៖ កងទ័ពគេអ្នកគ្រប់គ្រងកំលាំងនារី គេយកមក២-៣នាក់ ហើយមានម្នាក់ហ្នឹងរាងចាស់តិចដែរ ឥឡូវដូចជាមិនទាន់ទៅណាអ្នកទាំងហ្នឹង ហើយបានយកឈ្មោះមានៗ ហ្នឹងទៅ ។

បូលី៖ ហេតុផលអីបានជាគាត់ជ្រើសរើសយកយាយមាន ហ្នឹង?

គីមថុន៖ មិនដឹងជាគាត់មើលឃើញ គាត់មើលខ្លួនគាត់ គាត់ជ្រើសរើសយក គាត់សួរអី ថាគាត់ចាស់យកបានអីមិនបាន ។ នារីហ្នឹងស្ម័គ្រចិត្តយកគាត់ទៅ នៅធម្មតា ដល់ហើយមានកូនកូនមុនប្រុស តែអាលូត ក្រោយស្រី ។ ខ្ញុំទៅនៅហ្នឹងកូនគាត់កើតហើយពរមកលេងកន្លែងខ្ញុំ ធ្វើការនៅក្នុងដើមកៅស៊ូ ។

បូលី៖ ពេលដែលអ៊ំទៅនៅក្បាលទន្សោង?

គីមថុន៖ អត់ទេ ។

បូលី៖ ពេលនៅនេះ ។

គីមថុន៖ ខ្ញុំនៅក-១៨ហ្នឹង ហើយដាក់ឈ្មោះអាម៉ុលៗ ស្រករៗកូនខ្ញុំ ។

បូលី៖ កើត៨១?

គីមចុង៖	បាទ! លឺព័ត៌មានថារៀនឆ្លាត ។
បូលី៖	ពេលដែលគាត់រៀបការហ្នឹងមានមេធំៗមកចូលរួមទេ?
គីមចុង៖	ខ្ញុំអត់ដឹង មិនដឹងថាគាត់ការមានអ្នកណាខ្លះចូលរួមខ្ញុំអត់ដឹង ។
បូលី៖	អ៊ំអត់បានចូលរួមការគាត់ទេ?
គីមចុង៖	អត់ទេ ។
ដានី៖	អ៊ំអញ្ជើញទៅណាកាលហ្នឹង?
គីមចុង៖	កាលហ្នឹងខ្ញុំនៅធ្វើការកន្លែងក-១៨ ។ ខ្ញុំអត់ទាន់ទៅផងទេកាលហ្នឹង ខ្ញុំនៅកន្លែងជំរំមួយហៅថាជំរំថ-៧ ខ្ញុំអត់ទាន់ទៅទេ ខ្ញុំទៅដឹងថាគាត់មានប្រពន្ធហើយ ហើយខ្ញុំទៅនៅបាន ២-៣ថ្ងៃត្រូវវេនខ្ញុំដាំបាយ ព្រោះដាក់វេនគ្នាដាំបាយឃើញពរកូនហ្នឹងមក ហើយបានមួយឈ្មោះហេង១ ខ្ញុំថានៅពោធិ៍សាត់រាល់ថ្ងៃ នៅវាលវែង ថាហ្នឹងហើយប្រពន្ធអ៊ំ ។ ខ្ញុំអត់ហ៊ានសួរគេផង មកសួរពូបានអ៊ីសួរ ។
បូលី៖	ស្អាតទេ?
គីមចុង៖	គាត់ស្រណុកគួរសមរបស់គាត់ដែរ មាឌអ៊ី សមល្មមគាត់រស់នៅ ពីដើមដីគាត់នៅនេះ តាជុំឡូ ឡូតាមរយៈទេព ខុនណាល់ ។ នៅពេលដល់ជំរំគេធ្វើបុណ្យឲ្យគាត់ ឆ្អឹងគាត់មួយក្រឡូ ខ្ញុំអ្នកកាន់ឆ្អឹងគាត់ ។
បូលី៖	ជំរំណា?
គីមចុង៖	ជំរំភូណយ ។
បូលី៖	ពេលដែលរត់ឡើងភ្នំ៩៨?
គីមចុង៖	បាទ! រត់ភ្នំ គេធ្វើបុណ្យឲ្យគាត់ ហើយមានប្រធានយូអិនប្រុបឈ្មោះអ្នកស្រី ដាន់ណា មិនដឹងជនជាតិអីគាត់ឲ្យធ្វើ គាត់ថាធ្វើបុណ្យតាមប្រពៃណីរបស់ខ្មែរធ្វើទៅគាត់អត់ហាមឃាត់ទេ ទោះបីគាត់មាននិន្នាការនយោបាយក៏ដោយ តែជាមនោសញ្ចេតនាប្រពៃណីរបស់ខ្មែរ ធ្វើបុណ្យក្នុងជំរំទៅ ។ ឃើញធាតុរបស់គាត់មួយក្រឡខ្មៅៗហ្នឹង ហើយថាសគាត់មួយហ្នឹងមានប្រាសដុសធ្មេញមួយ ហើយឡាមកោរពុកមាត់ដែលផ្ទាស់ កោរបានមួងក្រវ៉ាត់ចោល ហើយនិងក្រាស ហើយនិងកាតាបធ្លាយម្ដុំនៅហ្នឹង ។
បូលី៖	ឥឡូវនៅណា? ឆ្អឹង ហើយនិងរបស់របរអស់ហ្នឹង?
គីមចុង៖	មិនដឹងទៅណាមកណា នៅប្រពន្ធគាត់ក៏មិនដឹង គ្រាន់តែដឹងពេលគេរៀបតាំងថត ឈ្មោះជ័យ ជាមួយខ្ញុំអ្នកកាន់ ជ័យ នៅម៉ាឡៃរាល់ថ្ងៃ ។ ស្រណោះគាត់ដែរ ពេលដែលគាត់ស្លាប់ខ្ញុំនៅក្បែរហ្នឹងតាំ ។

បូលី៖ ប៉ុល ពត ស្លាប់?

គីមថុង៖ បាទ! ខ្ញុំនៅក្បែរគាត់ នៅឃ្លាតគ្នាបាំងមួយព្រៃ។

បូលី៖ អ៊ំដឹងថាប៉ុល ពត ស្លាប់ដោយសារអីទេ?

គីមថុង៖ ខ្ញុំអត់ដឹងទេ ក្រោយមកខ្ញុំមើលភ្នំពេញប៉ុស្ដិ៍សរសេរជាភាសាខ្មែរ គេសរសេរថៃមួយ ប្រពន្ធគាត់មួយ ហើយអ្នកណាទៀតទេ ថាតើប៉ុល ពត ស្លាប់ដោយសារថ្នាំពុល ឬក៏ស្លាប់ដោយសារគាំងបេះដូង? នេះជាសំនួរមួយដ៏ធំ ដែលគេអាចចោទសួរ។ តែនៅពេលដែលគាត់ស្លាប់ហើយប្រពន្ធគាត់មកមុជទឹកនៅក្រោយផ្ទះខ្ញុំ កន្លែងខ្ញុំនៅ ក្បៀសខ្លួនកន្លែងទឹកអូរមួយដែលមានអន្លង់ជ្រៅជាងគេ។ គាត់មកខ្ញុំសួរម៉ែអាម៉ុល អ៊ំស្លាប់មែន? ស្លាប់ហើយពូ។ ហើយគាត់ស្លាប់របៀបម៉េច? កាលហ្នឹងគេជម្លៀស ហើយនួននៅរាល់ថ្ងៃនេះ មកប្រាប់គាត់ថាត្រៀមទៅនៅកន្លែងថ្មី ហើយគាត់ថា ទៅនៅកន្លែងថ្មីហ្នឹងគាត់ប្រាប់ប្រពន្ធគាត់ថា ម៉ែអាម៉ុល ឯងលាបសក់អី ខ្ញុំឃើញម៉ែអាម៉ុលឯងដូចនៅសល់កាកថ្នាំលាបសក់ហ្នឹង លាបឲ្យខ្ញុំតិចមកកុំឲ្យប្រជាជនស្គាល់ ពីព្រោះករណីដែលអត់យកឡានមក ខ្ញុំគិតថាដើរទៅកន្លែងថ្មី។

បូលី៖ ប៉ុល ពតនិយាយអីចឹង?

គីមថុង៖ បាទ! ប្រពន្ធគាត់និយាយអីចឹង។ ហើយផ្ទះគាត់មានរានហាលមួយ ទ្រឿងឃ្មោកហ្នឹងគាត់អង្គុយ ហើយជាទំលាបរបស់គាត់ នៅពេលអាកាសធាតុត្រជាក់អីចឹង គាត់ឆាប់ផ្ដាសាយគាត់ចាស់ ម៉ែអាម៉ុលខ្ញុំងងុយដេក ខ្ញុំចង់ទៅដេក គាត់ឲ្យជីកដៃគាត់មកសំរាន្តលើគ្រែ គាត់យកភួយទៅគ្រប គាត់ដើរចេញផុតតិចលឺសូរងឹត លឺអីចឹងបានគាត់ងាកទៅឃើញកន្ត្រៀង គាត់ថាយកដៃទៅមើលថាស្លាប់ហើយ។ គាត់ស្លាប់ប្រហែលម៉ោង៨-៩ យប់ ហើយម៉ោង៨ខ្ញុំដឹងតាមរយៈសែង ដែលខ្ញុំនិយាយថានៅប៉ៃលិន គាត់ប្រធានពួកខ្ញុំហ្នឹង គ្រប់គ្រងកំលាំង គាត់ហៅពួកខ្ញុំមេក្រុមៗទៅប្រជុំ។ ហើយកាលហ្នឹង ខៀវ សំផន ហើយនួន ជា ហើយតា ម៉ុក ប៊ុនហេង នៅជុំគ្នាមួយកន្លែង ក្រោមការគ្រប់គ្រងរបស់ ហែម ង៉ុន ចេញចូលទាក់ទងពួកហ្នឹង។

ដានី៖ ឃីម ង៉ុន?

គីមថុង៖ ហែម ង៉ុន ដែលថាចាប់ដាប់គុកស្លាប់ នៅអន្លង់វែង។ ហើយគាត់ប្រជុំគាត់ថាអ៊ំស្លាប់ហើយ អ៊ំពលិជីវិតហើយ បានទាំងអស់គ្នាស្ងុតតែម្ដង។

បូលី៖ មានអ្នកយំទេពេលហ្នឹង?

គីមថុង៖ បាទ?

បូលី៖ លឺសួរស្លាប់មានអ្នកឃំទេ?

គីមថុង៖ បើមីងៗឃំ ពួកខ្ញុំអត់ទេធម្មតាទប់អារម្មណ៍ គាត់ស្លាប់ទៅចប់ហើយ តែកេរ្តិ៍ឈ្មោះគាត់មានល្អ មានអាក្រក់ៗ ថ្ងៃមុនខ្ញុំបើក Websideមើល websideប៉ុល ពត ហ្នឹងឃើញគាត់សម្ភាសន៍ចុងក្រោយជាមួយនេត ថៃយើៗ ហើយស្រណោះគាត់ដែរ គាត់និយាយទាក់ទងពីជីវិតរបស់គាត់ ទាក់ទងនឹងការងារដែលគាត់បានធ្វើ ហើយអ្នកសារព័ត៌មានគេសួរថា ស្លាប់ពលានទាក់ គាត់ថាការស្លាប់ពលានទាក់គាត់គិតថា វាជាការស្លាប់បាត់បង់ជីវិតមែន ចំពោះប្រជាពលរដ្ឋៗ ស្លាប់ទី១ដោយសារប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញគាត់អត់ធ្លាប់រស់នៅជនបទ គាត់មកទទួលជំងឺគ្រុនចាញ់ រាគមួល គាត់អត់មានផ្ទះសំបែងស្នាក់នៅ ហើយស្បៀងអាហារហូបអត់គ្រប់គ្រាន់ៗ ហើយស្លាប់ទី២ មានការកាប់សម្លាប់មែន តែស្លាប់ដោយសារកំលាំងកម្ពុជាប្រជាធិបតេយ្យបានធ្វើផ្ទាល់ ដោយសារកម្មាភិបាលខាងក្រោមធ្វើផ្ទាល់ៗ ហើយស្លាប់មួយទៀតដោយសារការចោទប្រកាន់ថាជាភ្នាក់ងាររបស់សេអ៊ីអា ជាភ្នាក់ងាររបស់ខ្មែរក្រហម ជាភ្នាក់ងារកាសេបេ ហ្នឹងគាត់ថាសរុបទៅប្រហែលជាមិនមានដល់ចំនួនប៉ុណ្ណឹងទេៗ តែក្នុងនាមគាត់ទទួលខុសត្រូវ ខ្ញុំនិយាយតាមភាសាគាត់សម្ភាសន៍ ក្នុងនាមគាត់ជាអ្នកទទួលខុសត្រូវ គាត់នឹងទទួលខុសត្រូវ ព្រោះកំឡុងពេលហ្នឹងគាត់ជាអ្នកដឹកនាំៗ ហើយបានសួររឿងអី ពីព្រោះប្អូនជីទូតមួយខ្ញុំមួយ រាល់ថ្ងៃប្រពន្ធវានៅស្ថានទូតអូស្រ្តាលី ហ្នឹងអ្នកកាត់តហ្វិល ពីដើមមានខ្សែអាត់ធំរបស់វីដេអូ កាត់តហ្នឹងខ្ញុំមើលអាហ្នឹង ថ្ងៃមុនខ្ញុំបើកwebsideមើលនៅសាលាស្រុកនេះឃើញអាហ្នឹង កន្លែងហ្នឹង ហើយបានលោក ឈឹម ស៊ីវុធ អភិបាលរងគាត់សួរខ្ញុំថាបងឯងស្គាល់? ខ្ញុំថាស្គាល់ៗ ពីណា? ប៉ុល ពត ហើយបានគាត់ស្ដាប់ភាសាគាត់និយាយៗ

ដានី៖ មុនពេលដែលដូចថា អ៊ំផ្លាស់មកនៅក្បាលទន្សោងជាមួយប៉ុល ពត កាលហ្នឹងខៀវ សំផន, នួន ជា គាត់ផ្លាស់មកនៅជិតៗហ្នឹងដែរ?

គីមថុង៖ បាទ! មកៗ

ដានី៖ ពេលហ្នឹងមានបញ្ហាអីកើតឡើង ជាមួយក្រុមគាត់ ហើយជាមួយតាម៉ុក មុនពេលរឿងរ៉ាវហ្នឹងកើតឡើង?

គីមថុង៖ ដូចជាមានការចាក់រុក មានការញុះញង់គ្នា កាលហ្នឹងស្រុកត្រពាំងប្រាសាទ អីចឹងបានខ្ញុំផ្ដើមនិយាយពីព្រឹកមិញ តំបន់ត្រពាំងប្រាសាទ និងតំបន់អន្លង់វែង ជាតំបន់មួយដែលមិនមានទស្សនៈឯកភាពគ្នាៗ តំបន់អន្លង់វែង គេគាំទ្រតាម៉ុក ត្រពាំងប្រាសាទចុង

ក្រោយគេគាំទ្រប៉ុល ពត។ ដោយសារតាសាន ហើយនិងសូ សារឿន គាត់នៅហ្នឹងនៅខាងផ្នែកត្រពាំងប្រាសាទ អីចឹងភាសាអ្នកទាំងពីរហ្នឹងអត់ស៊ីគ្នាទេ អត់សូវស៊ីគ្នាទេ ស៊ីគ្នាតែបញ្ហាជាក់ស្តែងនៃការតស៊ូ។ ពីដើម ពីដែងមកកងពលស៊ីគ្នា តែចុងក្រោយអត់ស៊ីគ្នាទេ ពីព្រោះអន្លង់វែងគេចោទប្រកាន់ថា ប៉ុល ពត ក្បត់គេកាត់ទោស មិនដឹងតុលាការពីណាមក គេថាតុលាការប្រជាជនកាត់ទោសគាត់ ហ្នឹងក៏ខាងនេតថៃយើគាត់សួរដែរ គាត់ថាគេកាត់ទោសលោក លោកយល់យ៉ាងម៉េច? ហ្នឹងរឿងប្រវត្តិសាស្ត្រ។

បូលីៈ មូលហេតុអីដែលនាំឲ្យពីរហ្នឹងទាស់គ្នា? ចំបង?

គឹមថុងៈ មូលហេតុកាលហ្នឹងដូចរៀបចំអង្គភាព១៩។ ១៩ហ្នឹងដណ្តើមប្រជែងគ្នាបោះឆ្នោត បោះឆ្នោតជ្រើសរើស១៩ហ្នឹង ហើយខ្ញុំអត់ដឹងលំអិតទេ អ្នកដែលដឹងលំអិតឈ្មោះនឿន។ មួយនៅភ្នំព្រឹក ហ្នឹងនៅផ្ទាល់ កាលហ្នឹងខ្ញុំរំយាលហើយ រំយាលពីគាត់ហើយ ខ្ញុំដឹងតែរួមរួបទេ តែបញ្ហាលំអិត។ រហូតដល់គេបាញ់សុន សេនខ្ញុំអត់ដឹងទេ ខ្ញុំដឹងពីស្រែខ្ញុំទៅ ខ្ញុំដឹងតាមកូនខ្ញុំអាមួយដែលស្លាប់ទៅ ព្រលឹមឡើងវាបើកវិទ្យុស្តាប់ ហើយខ្ញុំកំពុងបេះសណ្តែក។ ថាគេបាញ់តាសុន សេន ងាប់ហើយ ខ្ញុំថាអ៊ើគេបាញ់មែន បានមួយសន្ទុះគេហៅប្រជុំដឹងរឿងហ្នឹង។

បូលីៈ ពីណាហៅទៅ?

គឹមថុងៈ សែង គេប្រធាននៅហ្នឹង ហៅទៅប្រជុំបាននិយាយរឿងមានការទាស់ទែង ហើយឆ្ងាយច្បាស់នៅពេលដែលសម្តេចនាយក គាត់មកសម្ពោធន៍ផ្លូវពីបន្ទាយស្រី មកអន្លង់វែង។ គាត់ថាចង់ចារកម្មមួយឈ្មោះ០៩ គឺហែម ង៉ុន គាត់ចង្អុល។ ហើយរឿងកប៉ាល់ហោះកាលហ្នឹង និន ពិន អភិបាលរងខេត្តសៀមរាបងាប់មួយ ស្លាប់មួយ។

បូលីៈ ឈ្មោះ?

គឹមថុងៈ ហេង។

បូលីៈ ហែម ប៊ុនហេង។

គឹមថុងៈ បាទ! ហែម ប៊ុនហេង ខ្ញុំនៅក្បាលទន្សោង គាត់ណែនាំអត់ឲ្យធ្វើអីទេ អត់ឲ្យប៉ះពាល់ទេ រហូតដល់សួរ អាឧត្តកចក្រហ្នឹងទំងន់ប៉ុន្មានគាត់សួរទៅថៃ ថាទំងន់ប៉ុន្មានតោន។ ហើយឡានសំរាប់ដឹកអេស្កាវេទ័រ ថៃហៅថេល័រ ដឹកបានប៉ុន្មានតោន ឲ្យដឹកយកមកទុកនៅតំបន់អន្លង់វែងទេ។ ហើយកាលហ្នឹងមានការចរចារ ចង់ផ្សះផ្សារគ្នានៅប្រាសាទព្រះវិហារ មានលំនាំអីចឹង ហើយបានចេញឃើញស្លាប់ ថាស្លាប់ហែម ប៊ុនហេង ហ្នឹងមួយ, និនពិន នៅរស់ យកទៅដាក់គុកកន្លែងកាស៊ីណូរាល់ថ្ងៃនៅភ្នំ២០០ហ្នឹង។ គាត់សោកស្តាយ

គាត់ថាអ្នកទាំងអស់ហ្នឹងជាពន្លកនៃការមានសន្តិភាព សំរាប់រដ្ឋកម្ពុជា និងកំលាំងខ្មែរក្រហមចុងក្រោយគេ ពីព្រោះបើយើងធ្វើអីចឹង មានន័យថាដូចទៅខ្វែងលើឯកសារមួយដែលជាឯកសារផ្លូវការ គាត់និយាយអីចឹង ។ គាត់ថាមិនគួរសោះ អាហ្នឹងមកពីអ្នកខ្លះគេគោរព អ្នកខ្លះគេអត់គោរព គាត់អត់គិតថាពីហេតុផលអាយុជីវិតជាតិនៅកន្លែងហ្នឹងខ្លះ ។ ដូចជារឿងជនបរទេសប៉ុន្មាននាក់គេសម្លាប់នៅបន្ទាយស្រី តេម អ្នកដឹងរឿង ។ អីចឹងរឿងអន្លង់វែងមានរឿងសំងាត់ដែលគេអត់បានទម្លាយច្រើនណាស់ ។

បូលី: ខ្ញុំទៅសម្ភាសន៍ខាងអន្លង់វែង ខ្ញុំបានលឺសួរថាអ្នកដែលបានបាញ់សម្លាប់ ហែម ប៊ុនហេង អ្នកដែលចាប់ពីឡុតបើកយន្តហោះយកមកដាក់គុក ហើយអ្នកដែលបញ្ជាឲ្យសម្លាប់សុន សេន គឺខាងភាគីតាប៉ុល ពត អ៊ឹយល់យ៉ាំងម៉េចដែរ?

គីមថុង: ការពិតគាត់បាននិយាយដែរ គេសួរគាត់ថាហេតុអីបានជាសម្លាប់សុន សេន គាត់ឆ្លើយបើកវេបសាយហ្នឹងក៏ឃើញដែរ មកពីសុន សេន រកសម្លាប់គាត់ ។ គេសួរថាមានភស្តុតាងទេ? គាត់ថាគាត់មានភស្តុតាង គាត់ថាសុន សេន ក្រោយពីមានការវ៉ៃតប់ខ្សៀវសំផន បែកក្បាល សុន សេន បាក់ស្មារតី អត់ចង់ហ៊ានទៅភ្នំពេញ ហើយរបៀបមើលទៅកំលាំងខាងនោះខ្លាំង ខាងកម្ពុជាប្រជាធិបតេយ្យខ្សោយ ហើយមានទំនាក់ទំនងរវាងតាស៊ិន ឈុំ ទៅនៅភ្នំពេញ ហើយដឹងពីស្មោងមកអីចឹងហើយបានគាត់មានឯកសារគាត់ចាប់បានឯកសារសំងាត់មួង-ពីរ តាមរយៈបងប្អូនគាត់មកពីភ្នំពេញ ។ គាត់មានគំនិតចង់សម្លាប់ ។ ហើយគេសួរថាហេតុអីបានសម្លាប់ទាំងអស់? គាត់ថាគាត់បញ្ជាឲ្យសម្លាប់តែសុន សេន ទេ តែអ្នកដែលទៅធ្វើគឺធ្វើលើស រហូតដល់សម្លាប់ប្រពន្ធគាត់កូនគាត់ ប្អូនតាឆន មកសម្លាប់មកនៅវាលនេះ ។ គាត់ថារឿងអ្នកទៅធ្វើ គាត់អត់បញ្ជាឲ្យធ្វើអីចឹងទេ គាត់ថាហ្នឹងក៏គាត់ទទួលខុសត្រូវដែរ ។

បូលី: អ្នកណា អ្នកទៅធ្វើផ្ទាល់?

គីមថុង: មិនងាយរកទេ តែខ្ញុំដឹងមនុស្ស សួរទៅក៏មិនប្រាប់ដែរ ។

បូលី: កងពលណា?

គីមថុង: នៅប៉ៃលិន រាល់ថ្ងៃនៅប៉ៃលិន ជាប្រជាជនធម្មតា នៅម្តុំអូរអំពិល ខាងនេះខ្លាងរាប់មកពីម៉ាក់ហ៊ឺន ចូលតាមកូនដំរី ភូមិមួយហៅភូមិអូរអំពិល ។

ដានី: នៅឃុំតាគង់ ។

គីមថុង: បាទ! ចេញពីដំរីភូណាយមកបែកពីខ្ញុំ ពួកហ្នឹងនៅហ្នឹង ។

ដានី: ម៉ាខ្មែ?

គឹមថុន: នៅម៉ាខ្មែ ជិតខ្ទង់ស្លាប់ ពួកហ្នឹងនៅមុំអស់ហ្នឹង ពួកហ្នឹងដឹងរឿងរ៉ាវច្រើន រហូតដល់សាលាក្តីខ្មែរក្រហមមកសម្ភាសន៍ជាមួយខ្ញុំ អីចឹងខ្ញុំ ថាទៅសម្ភាសន៍អី គេថាពូអើយ រឿងដែលកើតចៀសអត់ផុតទេ ពួងឈើពោះកើតកូន មិនមែនទុកនៅក្នុងពោះបានរហូតទេ វាត្រូវតែកើត ពីព្រោះនៅក្នុងនេះ រដ្ឋអំណាចមួយដែលយើងរស់នៅ អីចឹងគេស្រាវជ្រាវរកទាល់តែឃើញ គេចអត់ផុតទេ ខ្ញុំមានជំនឿខ្លួនឯង។

បូលី: តាមខ្ញុំសួរថា០៥, ០៦ អ្នកដែលដឹកនាំទៅធ្វើផ្ទាល់។

គឹមថុន: តាមពិតអ្នកហ្នឹងឯង តែមិនមែនអ្នក០៥ដែលទៅនេះ កូនចៅ០៥, ០៦ហ្នឹង កូនចៅអ្នកទៅធ្វើ លឺថាផុតអី១ហ្នឹងវាអត់ខុសពី ស្វាយកបាយទៅលាបមាត់ពពែ ហើយចោទថាពពែស៊ីបាយ ដូចគ្នាអីចឹង។ ផុត ហើយស្រាតថារំលោភហើយបាញ់ចោលអីហ្នឹង ហ្នឹងខ្ញុំភ្លាប់ទៅសម្តេចនាយកគាត់ថា ហែម ង៉ុន ជាចារកិច្ចមួយឈ្មោះ០៩។

បូលី: ចារកិច្ចរបស់ពីណា?

គឹមថុន: ចារកិច្ចរបស់សម្តេចនាយកហ្នឹង គាត់ថាគាត់បង្ហាញមុខចារកិច្ចមួយឈ្មោះ០៩ នេះហែម ង៉ុន បានអ្នកអន្លង់វែងថា អ៊ឺ! លំបាកចង់ស្លាប់អាហ្នឹងនៅគិញរបស់ហ៊ុនសែន អីចឹងបានខ្ញុំភ្លាប់រឿងដូចជារឿង គេម ដែលស្លាប់ វាពាក់ព័ន្ធហ្នឹង។ អីចឹងមានន័យថាគេបំបាត់ភាគមួយកន្លែងៗកុំឲ្យវាតពីភាគមួយទៅភាគមួយ បាត់ឯកសារមួយចំនួន។

បូលី: ចុះរឿងដែល ហែម ប៊ុនហេង ចុះមកចរចារជាមួយពីណាគេកាលហ្នឹង? ជាមួយតាម៉ុក ឬជាមួយប៉ុល ពត?

គឹមថុន: ជាមួយស្វ សារឿន ហើយនិង០៥ ហ្នឹងឯង។ ប៉ុល ពត អត់ទេ គេរាយការណ៍មកទេ នៅតាដេវកាលហ្នឹង គេរាយការណ៍មកថាចុះមកចង់ជួបអី ហើយគាត់ណែនាំទៅវិញថា អត់ឲ្យប៉ះពាល់ជីវិតគេទេ តែអ្នកដែលបាញ់តាមខ្ញុំលឺគេនិយាយមិនដូវការទេ តែអាចយកមកពិចារណា អ្នកនៅជាមួយគេម ហ្នឹងឯង។

ដានី: គេម ?

គឹមថុន: គេម ដែលថាស្លាប់នៅថៃ។

ដានី: តាគេម គាត់កាន់កងពលប៉ុន្មាន ៧៨៥?

គឹមថុន: បាទ! ៧៨៥ ។

បូលី: ដែលចូលមកចរចារហ្នឹង ប៉ុល ពត បានដឹងទេដំណឹងហ្នឹង?

គឹមថុន: ដឹង។

បូលី: គាត់យល់ព្រមទេ?

គឹមចុង: គាត់ឲ្យមក ។

បូលី: គាត់អ្នកឲ្យមក?

គឹមចុង: គាត់ថាធ្វើម៉េចកុំឲ្យប៉ះពាល់អាយុជីវិតគេ យន្តហោះអត់ឲ្យដុតទេកាលហ្នឹង ណែនាំច្បាស់ណាស់ គាត់ថាកាលហ្នឹងគាត់មានគំរោងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ដើម្បីបញ្ចប់សង្គ្រាម ដូចរាល់ថ្ងៃវាទៅជាលក្ខណៈមិនឈ្នះ មិនចាញ់ គ្មានអ្នកឈ្នះ គ្មានអ្នកចាញ់ បានសម្តេចនាយកគាត់យកគោលនយោបាយមួយ ឈ្នះ ឈ្នះ ឈ្នះទាំងអស់គ្នា ។ ជាលំនាំដូចគំនិតរបស់ប៉ុល ពត អ៊ីចឹង ។

បូលី: មិនមែនជាគំនិតរបស់តាម៉ុក ទេ?

គឹមចុង: អត់ទេ ។

បូលី: នៅខាងអន្លង់វែងគេថា តាម៉ុក មានបំណងចង់ចរចារជាមួយខាងហ៊ុនស៊ីប៊ិច មិនមែនខាងគណបក្សប្រជាជនទេ អ៊ីចឹងបានជាមានឈានទៅរកការជជែកគ្នា ការទាក់ទងគ្នាជាមួយញ៉ឹក ប៊ុនឆៃ ជាមួយខាងភាគីតាម៉ុក តែភាគីខាង ប៉ុល ពត នេះបានធ្វើឲ្យមានការរាំងស្ទះ ព្រោះអត់ចង់ចូល ។

គឹមចុង: ការពិតវានៅវគ្គធម្មយុត្ត និងវគ្គមហានិកាយ ។ វគ្គធម្មយុត្តទៅរកធម៌ធម្មយុត្តទៅ វគ្គមហានិកាយឆ្ពោះទៅមហានិកាយ ប៉ុន្តែបើយើងយកព័ត៌មានទាំងពីរមកសំយោគអំពីផលប្រយោជន៍ ព័ត៌មានខ្លះលំអៀង ព័ត៌មានខ្លះនៅកណ្តាល ជាព័ត៌មានដែលពិត ព័ត៌មានដែលលំអៀងជាព័ត៌មានដែលលំអៀងម្ខាង នេះជាការវិភាគរបស់ខ្ញុំទេ ។

បូលី: តាមអ៊ំដឹងជាគំនិតផ្តួចផ្តើមរបស់អ្នកណានៅក្នុងការចរចារហ្នឹង?

គឹមចុង: ចរចារជាមួយរដ្ឋាភិបាល?

បូលី: បាទ!

គឹមចុង: ជាគំនិតរបស់ប៉ុល ពត គាត់ចង់សន្តិភាព ។ ពីព្រោះគាត់មើលទៅម៉ាឡៃមួយចំនួនរបេះ ប៉ៃលិនរបេះ នៅមួយកន្ទុបគាត់ថានៅធ្វើអី យូរៗគេនឹងធុញហើយ គាត់និយាយអ៊ីចឹង គាត់ថាគេនឹងធុញ ហើយបើគេធុញគេនឹងមានសកម្មភាពអីមួយហើយ អ៊ីចឹងយើងត្រូវដើម្បីបន្សាបការធុញទ្រាន់សង្គ្រាមរបស់គាត់ តែរកច្រកដែលដើរទៅឲ្យទទួលបានផលប្រយោជន៍ ។ ទី១អាយុជីវិត ទី២ផលប្រយោជន៍ដីធ្លី នាទីតំណែងគាត់ថាគាត់អត់គិតទេ ធ្វើម៉េចឲ្យរួចអាយុជីវិត ពីព្រោះអ្នកណាក៏ថាចូលជាមួយរាជរដ្ឋាភិបាលដឹងតែងាប់ហើយ ព្រោះចូលទៅជាមួយយួន គាត់ថាអ៊ីចឹង គាត់ថាចូលទៅជាមួយយួន ។ ហើយគាត់ថាសំរាប់យួនគាត់ដឹងច្បាស់ណាស់ សំរាប់អ្នកដឹកនាំយួនគាត់ស្គាល់ច្បាស់ លេងតែធម៌ជា

មាដុន គាត់ថាស្គាល់ច្បាស់ ។ ហើយគាត់សួរនេតថៃយើទៀតថា លោកឯងមើលមុខខ្ញុំជាមនុស្សកាចឃោរឃៅអត់ ។

បូលី: ទៅខាងនោះគេលើកហេតុផលចេះ អ៊ំចាំជួយវិភាគខ្ញុំក្រែងលោយើងបានព័ត៌មានដែលវាម៉ត់ចត់ជាងហ្នឹង ។ គេលើកហេតុផលថាខាងភាគីរាជរដ្ឋាភិបាល ជាពិសេសខាងហ៊ុនសុីប៉ិចហ្នឹង ពីព្រោះខាងប៉ៃលិនគេចុះចូលហើយ ខាងកែ ពង្ស នៅឱរ៉ាល់ ភ្នំស្រួចអីចុះចូលតែអ្នកទាំងអស់ហ្នឹងហាក់មានទំនោលទៅរកគណបក្សប្រជាជន ច្រើនជាងគណបក្សហ៊ុនសុីប៉ិច អីចឹងធ្វើឲ្យហ៊ុនសុីប៉ិចដែលនៅក្នុងរដ្ឋាភិបាលចំរុះហ្នឹងវាបាត់បង់លំនឹងកំលាំង អីចឹងដើម្បីឲ្យវាមានលំនឹងកំលាំង ហ៊ុនសុីប៉ិចធ្វើយ៉ាងណាទាមទារខាងអន្លង់វែងនេះ ខាងតាម៉ុកឲ្យទៅខាងខ្លួន ប៉ុន្តែមានលក្ខខណ្ឌមួយមិនមានប៉ុល ពត ។ ពីព្រោះគេចាត់ទុកប៉ុល ពតជាមេប្រល័យពូជសាសន៍ទៅចុះ ភាសាដែលគេប្រើ អីចឹងប្រជាជននៅខាងក្នុងប្រាកដជាមិនទទួលយកបានទេ កាលណាមានប៉ុល ពត ចូលរួម អីចឹងធ្វើម៉េចឲ្យការចុះចូលរបស់អន្លង់វែងនេះអត់មានប៉ុល ពត ។ អីចឹងហើយបានប៉ុល ពត គាត់អាចរាំងស្ទះដំណើរការនៃការចរចារ ។

គឹមថុង: ជាហេតុផលមួយខ្ញុំនៅក្នុងហ្នឹង អីចឹងបានក្រោយមកមានសុីអេសអេស មានដែលលឺទេសុីអេសអេស ដូចជាភាសាអង់គ្លេស កំលាំងខ្មែរសេរី ហេតុអីបានតាម៉ុក ងាកទៅរកហ៊ុនសុីប៉ិច ញឹក ប៊ុនឆៃ ព្រោះញឹក ប៊ុនឆៃ មានប្រវត្តិដើមថ្ងៃ៥-៦ ។ ហើយទី២មួយផ្នែកខាងនេះគឺអត់សូវពេញចិត្តពួកអន្លង់វែងទេ ដែលកាន់ជើងប៉ុល ពត អីចឹងគាត់នៅក្រាញមួយរយៈចូលដំរី គាត់ទាក់ទងជាមួយញឹក ប៊ុនឆៃ ប្រើកំលាំងសុីអេសអេសហ្នឹងហើយ ។ រហូតដល់ថ្ងៃមួយខ្ញុំទៅម៉ាឡៃ ចេញពីដំរីទៅខ្ញុំនាំ ទេព ខុនណាល់ ចេញពីដំរីភូណយបានដោយសារខ្ញុំទេ ខ្ញុំទៅយកទូរស័ព្ទពី សូ ហុង ខ្ញុំជូនមនុស្សម្នាក់ឥឡូវនៅអន្លង់វែងទេ ទៅរកបងប្អូនគេនៅម៉ាឡៃ ហើយខ្ញុំស្គាល់ផ្លូវពីយើងនេះទៅ ពីខេត្តសុីសាកេតទៅដល់ម៉ាឡៃខ្ញុំស្គាល់ ស្គាល់ប្រេក គេឲ្យខ្ញុំជូនទៅអត់ឲ្យលុយកាក់អីទេ ខ្ញុំទៅជួបតាហុង នៅកន្លែងម៉ាឡៃ នៅកន្លែងទទួលសាតាំង បានតាហុង សួរនាំបាន ទេព ខុនណាល់ ដឹងព័ត៌មានពីខ្ញុំ ខ្ញុំឲ្យទូរស័ព្ទហ្នឹងទៅ បានគាត់ចេញរួចទៅដល់ម៉ាឡៃ ។ ដើមហេតុដំបូងខ្ញុំទេ ខ្ញុំមិនមានអំនួតទេ ខ្ញុំទៅហ្នឹងខ្ញុំទិញវចនានុក្រមខ្មែរ-អង់គ្លេសមួយនៅទល់រាល់ថ្ងៃ ខ្ញុំទិញនៅអារញ្ញ ។ ឡប់មកវិញគេឲ្យលុយខ្ញុំប៉ុន្មាន ជិតមួយពាន់បាតដែរ ខ្ញុំយកមកទិញប៉ុន្មានរយបាតនៅអារញ្ញ ហើយគេនិយាយរឿងចលនាសុីអេសអេស ធ្វើសកម្មភាពនៅម៉ាឡៃការពិតកាំភ្លើងរដ្ឋកម្ពុជាខ្មែរក្រហមវើយកបានដេ-៣០អីហ្នឹង ហើយទៅចោទថាវើរដ្ឋាភិ

បាលបានកាំភ្លើង បានរថក្រោះ ហើយខ្ញុំឃើញទាហានមកគរកាំភ្លើងនៅជិតផ្ទះតាជៀម នៅម៉ាឡៃ ខ្ញុំស្នាក់នៅហ្នឹង ។

បូលីៈ តាជៀម?

គីមថុង: បាទ! នៅមុខផ្ទះតាជៀម សួរស្អីតាជៀម ពួកអាហ្នឹងវាឆ្គតចង់បង្ករឿងជាមួយរាជរដ្ឋាភិបាល ឥឡូវគេចាប់យកមកគរកាំភ្លើងនៅហ្នឹង ហើយបានឡប់មកបានខ្ញុំប្រាប់ពួកនៅជំរំ ហើយកាលហ្នឹងពួកតាម៉ុក តាមរយៈហែម ង៉ុន ធ្វើសកម្មភាពខ្លាំងណាស់ នៅជំរំពិសេសពួកខ្ញុំ ពីព្រោះពួកខ្ញុំកាលហ្នឹងមានអាងហើយ ។ ទី១អាងយូអ៊ិន ហើយពួកខ្ញុំចេះអង់គ្លេសច្រើនគ្នាដែរ ទៅទំនាក់ទំនងធ្វើការ ហើយតាមរយៈហ្នឹងហើយផ្តល់ព័ត៌មានមួយចំនួនទាក់ទងអំពើប្រព្រឹត្តិរបស់ពួកតាម៉ុកហ្នឹង ហើយបានជាគេចាប់ហ៊ុនស៊ីប៉ិចហ្នឹង ហើយគេចូលផ្សះផ្សារជាតិគេអត់ឲ្យមានប៉ុល ពត ត្រូវរបស់គេហើយ គេអត់ឲ្យមាន ពីព្រោះនៅពេលដែលមានប៉ុល ពត រាជរដ្ឋាភិបាលអត់ទទួលទេ បើខៀវ សំផន ទទួល ។ នួន ជា ហើយនៅពេលខៀវ សំផន គាត់រត់ទៅ គាត់រត់ខ្លួនគាត់ ។

បូលីៈ ខៀវ សំផន?

គីមថុង: បាទ! កន្លែងតាម៉ុក យកមកលាក់នៅភ្នំខាងនេះអូរស្វាយ កន្លែងដែលខ្ញុំនិយាយព្រឹកមិញបាញ់ហិបឆ្នោត ខ្ញុំជាមួយទេព ខុនណាល់ ចង់មកទាក់ទងជាមួយ ជុំ ជាតិ ជាមួយអ៊ីង លាង ។ មកទាក់ទងដើម្បីយកជំរំហ្នឹងមកយករៀបចំធ្វើការផ្សះផ្សារជាតិ តាមគោលនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល ។

បូលីៈ នាំពីភូណយមកវិញ?

គីមថុង: បាទ! ចេញពីភូណយមក តែទៅទាក់ទង របៀបរស់នៅយ៉ាងម៉េចៗតាមលំនាំហ្នឹង ។ ដល់ហើយបានព័ត៌មានហ្នឹង ខ្ញុំមកជាមួយ ទេព ខុនណាល់ ហើយគ្មានអ្នកណាដឹងទេ ជិះឡានថៃមកគាត់កេះខ្ញុំ ថានេះកន្លែងអ៊ំ គាត់រត់ចេញគាត់ដើរទៅ គាត់មកខ្ញុំអង្គុយសួរថាពេលអ៊ំឯងរត់ចេញពីចំការដំឡូង បានហើយមិត្តអើយ ឥឡូវទៅជានីរសាររបស់បងនួនហើយ ។ អ៊ំនួន គាត់ដើរអត់រូបគាត់គ្រា បានទៅជួបផ្លូវជាតិថៃ ហើយរឿងហ្នឹងដូចជាខ្ញុំដឹងអត់ច្បាស់គ្រប់គ្រាន់ទេ តែខ្ញុំដឹងកន្លែងគាត់រស់នៅ ពេលតាម៉ុក យកទៅលាក់ ។

បូលីៈ តាម៉ុក យកទៅលាក់របៀបម៉េច ពេលហ្នឹងវៃគ្នា?

គីមថុង: អត់មានវៃគ្នាទេ កាលហ្នឹងជំរំ កាលណាគាត់នៅជំរំពួកខ្ញុំទៅទាក់ទងបាន អីចឹងគាត់យកមួយដាច់ដោយឡែក ប្រៀបបាននឹងយកមនុស្សទៅសំរាប់ជាផលប្រយោជន៍ខាងនយោ

បាយមួយ អាហ្នឹងខ្ញុំគិតទេ។ យកទៅដាក់នៅកន្លែងមានតែថៃទេអ្នកដឹង ហើយគាត់ចេញមក។

បូលីៈ តាមយោបល់អ៊ំ អ៊ំសន្និដ្ឋានយ៉ាងម៉េ ដួចផ្តើមក្នុងការចរចារសន្តិភាពហ្នឹងអាចជាគំនិតរបស់តាម៉ុក, ប៉ុល ពត ឬក៏គំនិតទាំងអស់គ្នា?

គឹមចុងៈ ខ្ញុំគិតថា រួមគ្នាគិត ពីព្រោះតាម៉ុក ចេញ-ចូលៗព្រឹកល្ងាច ទៅកន្លែងក្បាលទន្លោង ខ្ញុំថារួមគ្នាគិត មិនមែនលេចឆ្លោតែតាម៉ុក ហើយក៏មិនមែនលេចឆ្លោតែប៉ុល ពត ម្នាក់ទេ។ ឧបមាថាអ៊ុនគាត់ អ៊ុនគាត់កាលហ្នឹងគ្រប់ភាគីទាំងអស់ត្រូវប្រគល់កាំភ្លើង តែតាម៉ុក អត់ទេ តាម៉ុកលាក់កំភ្លើងរាប់ពាន់ដើម ដែលបន្តកន្ទុយសង្គ្រាមរាល់ថ្ងៃដោយសារ តាម៉ុក កប់ នេះជាការពិត ហើយគាស់គ្រាប់ គាស់រំសេវ។ ហើយពួកខ្ញុំនៅជាការផារអ៊ុនគាត់ គ្រាន់តែចុះពីលើឡាន ពួកអាហ្នឹងខ្ញុំអ៊ុនគាត់ លក់ក្បាលឲ្យអ៊ុនគាត់ មិនបាច់ឲ្យបាយវាស៊ីទេ ពួកខ្ញុំមកស៊ីបាយនៅអន្លង់វែងតាមរយៈស្គាល់គ្នា។ កុំឲ្យបាយវាស៊ី ហើយឡប់ទៅវិញពួកខ្ញុំមានថៃដឹកទៅស្រួល មានអី។ តាម៉ុក គាត់អត់ឲ្យមើលទេកន្លែងគាត់ កន្លែងឲ្យមើលៗ កន្លែងមិនឲ្យមើលៗ អីចឹងមានន័យថាគាត់ត្រៀមយថាហេតុ មិនអីចឹង។ នៅពេលដែលគេរកសន្តិភាព ហេតុអីបានគាត់កប់កាំភ្លើង កប់គ្រាប់។

បូលីៈ ពេលហ្នឹងអ៊ំនាំអ៊ុនគាត់ចូលមក?

គឹមចុងៈ ខ្ញុំអត់នាំទេ ខ្ញុំមកស្រាវជ្រាវរកឃ្លាំងអាវុធ កាលហ្នឹងភាគីមួយៗត្រូវធ្វើបញ្ជីអាវុធ បញ្ជីឃ្លាំង។

បូលីៈ អ្នកណាឲ្យអ៊ំមកស្រាវជ្រាវ?

គឹមចុងៈ កាលហ្នឹងដូចជាភាគីមួយៗត្រូវតែធ្វើបញ្ជី។

បូលីៈ តែអ៊ំហ៊ានចូលមកតំបន់តាម៉ុក កាន់កាប់ហ្នឹង អត់ខ្លាចតាម៉ុក គាត់ថាម៉េចទេ បានហ៊ានចូលមកស្រាវជ្រាវរកកាំភ្លើង?

គឹមចុងៈ អត់ខ្លាចទេ ក្នុងឋានៈជាភាគីមួយ ខ្ញុំនៅកន្លែងហ្នឹងហើយ ខ្ញុំមានខ្លាចអី ហើយមកតាមស្របច្បាប់ខ្ញុំមានធ្វើអី មកសួរនាំថាអ្នកណាជាអ្នកទុកកាំភ្លើងនៅណា។ គ្រាប់មានប៉ុន្មានតោន សួរអីចឹង។

បូលីៈ ដល់ពេលចូលមកដល់តាម៉ុក ថាយ៉ាងម៉េចទៅ? គាត់ឲ្យមើលទេ?

គឹមចុងៈ ខ្ញុំអត់ទេ មានមិត្តភក្តិខ្ញុំ២នាក់គាត់ដែរ ស៊ីនៗដែលខ្ញុំថាហ្នឹង ពួកឯងលក់ក្បាលឲ្យអ៊ុនគាត់ហើយ។ នៅពេលដែលខ្ញុំនៅជាអ៊ុនគាត់ហើយ កាលហ្នឹងគ្រប់ភាគីទាំងអស់ត្រូវនាំអ៊ុនគាត់ទៅមើល គេហៅកន្លែងប្រមូលផ្តុកផងទ័ពបណ្តោះអាសន្ន។ អីចឹងតំណាងភាគី

មួយៗ ចាំបាច់ត្រូវតែនាំទៅមើលកន្លែងជំរំប្រមូលផ្ដុំកងទ័ពបណ្ដោះអាសន្ន ខ្ញុំនាំទៅមើល នៅចំណោងគួយ ទៅជួបតាមុត ស្គាល់ជិតស្និតពេលហ្នឹងហើយ តាមុតៗ កាលហ្នឹងខ្ញុំនាំទៅចំណោងគួយ ជិះយន្ដហោះពីប៉ៃលិនទៅវង្វេងនៅចំណោងគួយហ្នឹង ហើយខ្ញុំនាំទៅមើលលោកតាសើន សាន ហើយទៅមើលជំរំរំចង់ខាងហ៊ុនស៊ីប៊ិច មួយផ្នែកទៀតនៅសៀមរាប កាលហ្នឹងឯកឧត្ដម នៅ សំ គាត់នៅជាអភិបាលខេត្ដៗ ដល់ហើយសុន សេន អត់ឲ្យខ្ញុំមកទេ ឲ្យ ចាន់ ឆាយ នៅប៉ៃលិនរាល់ថ្ងៃហ្នឹងឲ្យទៅ ពីព្រោះ ចាន់ ឆាយ អត់ដឹងរឿងអីជាក់លាក់ច្បាស់លាស់ទេៗ កាលខ្ញុំទៅកន្លែងហ៊ុនស៊ីប៊ិចជួប ទួន ចាយ ខ្ញុំជួបនៅកន្លែងលោកតា សើន សាន កាលហ្នឹង ដៀង ខែ រហូតដល់ពួកអ៊ុនគាត់ហ្នឹងសំលុតខ្ញុំឲ្យបង្ហាញតំបន់មីន ហើយបានតាដៀង ខែ គាត់ថា ក្នុងឋានៈគាត់ជានាយទាហានម្នាក់មិនមានសិទ្ធិសំរេចទេ គាត់សក្ដិ៥ គាត់មានឧត្ដមសេនីយ៍គាត់ជាអ្នកសំរេច ហើយឧត្ដមសេនីយ៍មានបញ្ហាការធំរបស់គាត់ មានអគ្គបញ្ជាការរបស់ភាគីកម្ពុជាប្រជាធិបតេយ្យជាអ្នកសំរេច អីចឹងគាត់អត់អាចសំរេចនៅក្នុងអង្គប្រជុំនេះទេ ហើយនៅក្នុងកម្មវិធីហ្នឹង ខ្ញុំថាជាកម្មវិធីចរចារ ឬក៏ជាកម្មវិធីដើរមើលទីបញ្ជាការរបស់ភាគីមួយៗ បើលោកសួរអីចឹងខុសប្រធានបទហើយ ខ្ញុំអត់ឆ្លើយទេៗ អីចឹងបាននៅពេលដែលការអនុវត្តកិច្ចព្រមព្រៀង ខ្ញុំនៅជាមួយអ៊ុនគាក់ខ្ញុំដឹងថា ការពិតដាក់មីនទាំងអស់គ្នា តែដល់សួរៗតែកម្ពុជាប្រជាធិបតេយ្យ នេះជាភាពលំអៀងមួយក្នុងការរកសន្ដិភាពនៅកម្ពុជាតាមរយៈអ៊ុនគាក់ នេះជាគំនិតខ្ញុំ ខ្ញុំឃើញជាក់ស្ដែងៗ គាត់ទៅគាត់សួរតែពីរឿង NEDK, mine file យកមក ហើយខ្ញុំសួរថាខាងលោកតាសើន សាន ខាងកាប៉ាស់ហ្នឹងគឺរដ្ឋកម្ពុជា ហើយខាងរណរិទ្ធិយកអត់ ថាយកខាងកម្ពុជាប្រជាធិបតេយ្យយកមុន ខ្ញុំថាអត់ទេយកស្មើរគ្នាព្រោះដាក់មីនទាំងអស់គ្នាៗ ខាងរដ្ឋកម្ពុជាក៏ដាក់, កម្ពុជាប្រជាធិបតេយ្យក៏ដាក់ ៤ភាគីដាក់ទាំងអស់ ហើយយកតែម្នាក់ម៉េចកើត ត្រូវអត់? ជាហេតុផល បានខ្ញុំមើលទិដ្ឋភាពទៅខ្ញុំថា ប្រហែលជាមានលំអៀង លំអៀងទៅរកអីមួយសំរាប់កម្ពុជាប្រជាធិបតេយ្យៗ

បូលីៈ ខ្ញុំចង់បកមកនេះបន្តិច រឿងជម្លោះរវាងប៉ុល ពត និងតាម៉ុកៗ ពេលហ្នឹងតាៗចាស់គាត់ចង់ចូលនិវត្តន៍ ហើយចង់ឲ្យមានអ្នកដឹកនាំបន្តពីហ្នឹងទៅ អីចឹងបានរៀបចំគណកម្មាធិការដូចអ៊ីមានប្រសាសន៍ៗ

គឹមថុងៈ ក-១៩ៗ

បូលីៈ ១៩ ឬ៩៩?

គឹមថុង: ១៩ ។

បូលី: នៅអន្លង់វែងគេថា៩៩ ។

គឹមថុង: ១៩ ។

ដានី: ពេលហ្នឹងបោះឆ្នោតយ៉ាងម៉េច ហើយរើសបានពីណាធ្វើមេ?

គឹមថុង: ដូចជាជាប់លំដាប់ទី១ ០៥ក៏មិនដឹង ០៦ក៏មិនដឹង ហើយហែម ង៉ុន មានឈ្មោះនៅក្នុងហ្នឹង តែលំដាប់ប៉ុន្មានខ្ញុំអត់ដឹងទេ ព្រោះបោះឆ្នោតកាលហ្នឹងមានលក្ខណៈសំងាត់ដែរ មានថ្នាក់ដឹកនាំជាប់គា០៥ ជាប្រធាន ឬ០៦ជាប្រធាន ខ្ញុំអត់ច្បាស់ដែរ ។ ព្រោះខ្ញុំគិតរ៉ក់រីរឿងស្រូវទេកាលហ្នឹង ហើយកាលហ្នឹងចំពេលមានព្រឹត្តិការណ៍មួយបងសានហ្នឹងគាត់ការកូនគាត់នៅស្រះឈូក ហើយមានព្រឹត្តិការណ៍ប៉ិស១ប៉ះទង្គិចគ្នាដោយអាវុធតាំងពីហ្នឹងមក ។

ដានី: ព្រឹត្តិការណ៍យ៉ាងម៉េច?

គឹមថុង: ដូចជាកំលាំងខាងតាហ្នឹងដើរឆ្នែលចុះ ឆ្នែលឡើង របៀបដឹងជាក់គ្នា របៀបដូចត្រីក្រឹមហើយតាំងពីហ្នឹងមកសភាពការណ៍អត់សូវស្រួលរហូត អីចឹងបាននៅក្បាលទន្សោងមានកន្លែងទៅស៊ើបអង្កេត នៅតាមអូរមានចង្ក្រានដាំបាយ ។ អីចឹងបាននៅពេលកំលាំងតាឡើងទៅដេញពួកខ្ញុំនៅក្បាលទន្សោងហ្នឹង ទៅលឿនបំផុត ទៅចំៗគោលដៅ ។

បូលី: កំលាំងតាម៉ុក?

គឹមថុង: បាទ!

បូលី: តែនៅពេលដែលបោះឆ្នោត អ្នកខ្លះដែលមានសិទ្ធិបោះឆ្នោត? ហើយមានចំនួនប៉ុន្មាននាក់?

គឹមថុង: ខ្ញុំអត់ដឹងថាប៉ុន្មានទេ តាមដឹងដូចជាធ្វើការនៅមុំមន្ទីរបង្អែករាល់ថ្ងៃ ។

បូលី: អូ៎! បោះហ្នឹងទេ?

គឹមថុង: បាទ! បោះហ្នឹង ។

បូលី: មិនមែនបោះនៅក្បាលទន្សោងទេ?

គឹមថុង: អត់ទេ បោះនៅហ្នឹង បោះនៅអន្លង់វែង បោះនៅមន្ទីរពេទ្យហ្នឹង ហើយក្រោយមកបានដឹងគេរៀបចំ១៩ ។

បូលី: រៀបចេញទេ?

គឹមថុង: ១៩ហ្នឹងជាក្បាលម៉ាស៊ីនសំរាប់បន្តវេនដឹកនាំដើម្បីរំដោះជាតិតទៅមុខទៀត ក្នុងហ្នឹងមានថ្នាក់បញ្ញាជនមួយចំនួនដែលនៅក្បាលទន្សោង ថ្ងៃក្រោយមកអាចប្រើប្រាស់កំលាំងហ្នឹង

ពីព្រោះអ្នកអស់ហ្នឹងដឹងពីកិច្ចការផ្ទៃរទូត ដឹងស្អីៗ ។ បើសំរាប់សូ សារឿន មិនដឹងអី គាត់ ដឹងតែតេធ្វើមេទៅ មិនចេះដឹងអីធំដុំដឹងតែច្បាំង កិច្ចការផ្ទៃរអីធំដុំប្រហែលជាមិនអាច យល់ច្បាស់លាស់ទេ ។

បូលី: ពេលដែលជាប់០៥, ០៦ តាម៉ុក គាត់យកព្រមទេ?

គឹមថុង: ខ្ញុំអត់ដឹងថាយ៉ាងណាទេ តែចាប់ពីហ្នឹងមកមានប្រទូសប្រគ្រាសគ្នា ដូចជាមិនមានទស្សនៈ មួយឯកភាពគ្នា រហូតមានការបែកបាក់គ្នា ។

បូលី: ពេលដែលផ្ទុះអាវុធរវាងក្រុមតាម៉ុក និងក្រុមប៉ុល ពត យ៉ាងម៉េចទៅពេលហ្នឹង? វ៉ៃ ច្បាំងគ្នា?

គឹមថុង: បាញ់គ្នា បាញ់នៅខាងកើតចំការស្វាយរបស់តាម៉ុក ហ្នឹង ជិតកន្លែងវិទ្យុ ។

បូលី: ប៉ុន្មានថ្ងៃ?

គឹមថុង: មួយយប់ មួយថ្ងៃដែរ ។

បូលី: មួយយប់ មួយថ្ងៃ?

គឹមថុង: មួយយប់ហើយព្រឹកឡើងប្រហែលជាម៉ោង៩-១០ ហ្នឹងខាងអន្លង់វែងគាត់មានកំលាំង ខ្លាំង ហើយកំលាំងអន្តរាគមន៍របស់តាសារឿន ហើយកំលាំងរបស់តាជុំ មកអត់ទាន់ទេ ហើយគេវ៉ៃនៅម្តុំ១០៥ជិតក្បាលទន្សោងហ្នឹង ហើយថយ នាំគ្នាសែង ប៉ុល ពត ដើរ កាត់ភ្នំ ។

បូលី: កាត់ពីណាមកណា?

គឹមថុង: ពីក្បាលទន្សោងមកកើត មកក្រោក ។

បូលី: ពីក្បាលទន្សោងមក!

គឹមថុង: ដើរពីនេះមក ។

បូលី: ដើរមកកើតនេះ ។

គឹមថុង: មកអស់ត្រឹមនេះ ។

បូលី: ហើយមកទៀតត្រឹមណាទៅ?

គឹមថុង: មកទៀតចំអូរស្វាយ ចុះតាមហ្នឹងមក ។

បូលី: ចុះមកណា?

គឹមថុង: ចុះពីលើភ្នំហ្នឹងមក តាជុំទៅជាមួយតាម៉ុក អស់ហើយ ។ ជុំ ហើយអ្នកនាំកំលាំងតាម៉ុក ដើរទៅ ពួកខ្ញុំចុះមកព្រលប់ៗ ហើយពួកខ្ញុំមក ។

បូលី: អីចឹងតាជុំ ទៅចូលដៃជាមួយតាម៉ុក វិញ?

គីមថុន: បាទ! មុនដំបូងនៅជាមួយ ប៉ុល ពត ។ បាត់គាដុំ មួយយប់ ព្រឹកឡើងឃើញនាំទ័ពតាម៉ុក ឡើងទៅអូរស្វាយ ពួកខ្ញុំចុះមកមុន បាននាំនួន ជា, នាំតាប៉ែន, តាដួន ជឿន នាំពួកបញ្ញាជនមួយចំនួន ។

ដានី: ហើយពេលណាបានចាប់បាន ប៉ុល ពត?

គីមថុន: ចាប់ពេលហ្នឹង ។

ដានី: ចាប់នៅម្តុំណា?

គីមថុន: ចាប់នៅមិនដឹងត្រង់ណាទេ ដូចវាលភ្នំអីមួយ ២-៣ថ្ងៃក្រោយមកបានចាប់បាន គាត់គេចទៅនៅក្បែរៗហ្នឹងគាត់សំងំ ហើយគេព័ទ្ធចាប់ ហើយសែងចុះមក យកមកដល់ដីកទៅនៅលើភ្នំ ដាក់កន្លែងគាត់ស្លាប់ហ្នឹង មិនដឹងជាដាក់ខ្នោះឬអត់ខ្ញុំអត់ដឹងដែរ តែខ្ញុំឃើញគេសម្ភាសន៍ថាគេទោសហ្នឹងមានដៃជាប់ខ្នោះ ប៉ុន្មានខែ តែសំរាប់ប៉ុល ពត បង់កក្រមាខៀវ-ស ពាក់អាវដៃខ្លីពណ៌សទៀត ។ ខ្ញុំតាំងពីហ្នឹងដាច់អត់មានអី ។

បូលី: អ៊ំនៅណាពេលហ្នឹង?

គីមថុន: គេយកមកដាក់នៅភូមិឃ្លាំងកណ្តាល កន្លែងពួកខ្ញុំអត់ហ៊ានដើរកាត់តាមផ្លូវទេ ដើរកាត់តែព្រៃទេ ខ្លាចគេចាប់ ទៅស្ទួងត្រីនៅអូរជីក ល្ងាចឡើងកាប់នុយ កូនស្រីខ្ញុំនៅផ្ទះកាប់នុយជន្ទេន កាប់មកទុក ខ្ញុំមកពីព្រៃបានត្រីមកស្ងោរហូបជាមួយកូន ចៅ ។ ព្រលឹមឡើងដាំបាយខ្ចប់មួយកញ្ចប់ទៅសំងំ និយាយរួមប្រុសៗចេញអស់ ។

បូលី: ពេលដែលគេបាញ់គ្នាអ៊ំនៅណា?

គីមថុន: បាទ?

បូលី: ពេលដែលប៉ុល ពត ហើយនិងតាម៉ុក បាញ់គ្នានៅណា?

គីមថុន: ខ្ញុំនៅកន្លែងបាញ់ហ្នឹង ។

បូលី: ក្បាលទន្សោង?

គីមថុន: បាទ! នៅកន្លែងបាញ់គ្នា ។

បូលី: អ៊ំមានឃើញព្រឹត្តិការណ៍ដាក់ស្តែងនឹងភ្នែកហ្នឹងទេ?

គីមថុន: ខ្ញុំបាញ់នឹងគេដែរហ្នឹង ។

បូលី: អ៊ំកាន់កាំភ្លើងដែរ?

គីមថុន: បាទ! គេឲ្យកាន់កាំភ្លើងទៅទប់នៅកន្លែងហ្នឹង ហើយមាន១២លីមួយដើម ឈ្មោះសែនៗឥឡូវស្លាប់ហើយ កាន់១២លីបាញ់លើក្បាលពួកខ្ញុំហ្នឹង ហើយបានព្រឹកឡើងខាងតាម៉ុកយកស្គុតកង់កៅស៊ូទៅបាញ់អា១៤ល្បើកពេងយាម ពេលហ្នឹងពួកខ្ញុំថយ ងាប់អត់រស់ទេ

ហើយពេលយប់គេបាញ់កាំភ្លើងដែលគេកប់ដី គេច្នៃ ចុចរំសេវឡផ្ទុះធ្លាក់ទៅដូចកាំភ្លើងធំអីចឹង ទៅហ្នឹង១-២គ្រាប់ទៅ ហើយអ្នកដែលនៅជាមួយខ្ញុំមានហ៊ីង១ ដែលខ្ញុំថានឹងតាវង់នៅភ្នំព្រឹក ហើយនៅជាមួយគ្នា ដាំបាយ បេះតែគិតថាដល់ពេលហើយយើង ទីចុងបំផុតដូចមើលរឿងភាគអីចឹង វៃតែគ្នាឯង។ ហើយកាលហ្នឹងតាម៉ុក ប្រើពាក្យស្លោកថា ខ្មែរមិនវៃខ្មែរ ខ្មែរមិនបង្ហូរឈាមខ្មែរ ការពិតជាពាក្យស្លោកដែលចេញពីក្បាលទន្សោង ឈ្មោះ រូន អូ សរសេរភាគស្លោក “ខ្មែរមិនវៃខ្មែរ ខ្មែរមិនបង្ហូរឈាមខ្មែរ” ដល់ពេលតាម៉ុកយកមកប្រើ ថាគាត់សរសេរ “ខ្មែរមិនវៃខ្មែរ ខ្មែរមិនបង្ហូរឈាមខ្មែរ” ។

បូលីៈ ពាក្យហ្នឹងពាក្យរបស់ប៉ុល ពត ទេអីចឹង?

គីមថុងៈ បាទ! ការពិតពាក្យស្លោកចេញពីក្បាលទន្សោង ដល់ក្រោយពីពួកខ្ញុំត្រូវគេចោទប្រកាន់អីចឹងទៅ អ្នកណាក៏អាពត។ ពួកខ្ញុំដើរតាមផ្លូវអត់បាន និយាយរួមអ្នកដែលនៅក្រោម១ ដូចអ្នកបើកឡានដើរដះទឹកដាក់ក្បាល សាច ហ្នឹងបេះតែខ្លាចគេ ហើយដើរទៅគេមើលពួកអាក្បត់ បេះតែដេកគិតថា ខ្ញុំមកចាក់ចំរូង គេឲ្យមកចាក់ចំរូងអត់មានកាំភ្លើងទេនៅអំពិល ដាំស្រែ ។

បូលីៈ ឆ្នាំណាចាក់ចំរូង?

គីមថុងៈ មុនសមាហរណកម្មតិច ឲ្យពួកខ្ញុំនៅភូមិកណ្ដាលហ្នឹងទៅចាក់ចំរូង ការពារមូលដ្ឋានរបស់គេហ្នឹង នៅស្រអែម ទាហាននៅស្រអែម ហើយអត់មានអីមានតែកាំបិតបន្ទុះមួយ កាប់ឬស្សីបិទចំរូង ។

ដានីៈ នៅខាងស្រអែមជិតដល់ប្រាសាទព្រះវិហារ?

គីមថុងៈ បាទ! ម្តុំភូមិប្រមី សុទ្ធតែពួកខ្ញុំនៅចាក់ចំរូងហ្នឹង ហ្នឹងចុងក្រោយសម័យតាម៉ុកហើយ ដល់ក្រោយមកអាសៀប១ មួយឥឡូវជាប់គុកហើយ បាញ់ធ្មើឃាតគេ ចោទប្រកាន់រឿងសម្លាប់មនុស្ស រកបាញ់ខ្ញុំចោលទៀត។ កាលហ្នឹងខ្មែរក្រហមប្រើវិធីសាស្ត្រមួយយកថ្នាំពុលទៅចាក់ដាក់ទឹកត្រពាំង កុំឲ្យទាហានមកដឹកទឹកត្រពាំងហ្នឹង អត់មានទឹកឡប់ទៅវិញហើយ វិធីសាស្ត្រគេការពារមូលដ្ឋាន យើងចាក់ចំរូង ហើយទឹកតាមត្រពាំងមួយ១ យកថ្នាំពុល ដបកំប៉ុង១ប៉ុណ្ណេះយកទៅចាក់សសំពោងពេញទឹក ហើយថ្នាំអង់គ្រីនចាក់ទោស ហើយចាក់ទៅត្រីពុលងាប់។ ពួកខ្ញុំមកដឹកទឹកអូរ អីចឹងវិធីសាស្ត្រការពារមូលដ្ឋានក្រោយមកឲ្យខ្ញុំទៅចាក់ចំរូងនៅជប់ពុន ផ្លូវទៅរំចេក ពីរដងហើយខ្ញុំ។ ទីចុងបំផុតរដ្ឋកម្ពុជាមកដល់ទំនប់ដាច់ ម្នាក់នេះនៅក្បែរខ្ញុំ ដែលខ្ញុំថានៅជាមួយ ខៀវ សំផន។

ដានីៈ គាត់ឈ្មោះ សុខ រឿ?

គឹម ចុង: បាទ! សុខ រឿ ។

ដានី: ផ្ទះគាត់?

គឹម ចុង: បាទ! ផ្ទះគាត់ ។

ដានី: ចង់ជួបគាត់ដែរ ។

គឹម ចុង: មានអីជួបទៅ ។

ដានី: អ៊ំពេលដែលយើងទៅចាក់អ៊ីចឹង យើងបានឃើញប្រាសាទព្រះវិហារដែរ?

គឹម ចុង: អត់ឃើញទេ បានតែដើរតាមជើង ។

ដានី: តាមជើង?

គឹម ចុង: ជើងប្រាសាទព្រះវិហារ ខ្ញុំដើរតាមផ្លូវមួយកៀន គេហៅក-១ ខ្ញុំដើរទៅដល់ហ្នឹង កាលហ្នឹងគេឲ្យមកចាក់ចំរូងនៅមន្ទីរ ។

ដានី: ដើរតាមជើងប្រាសាទក្រោមៗ?

គឹម ចុង: បាទ! គេយកឡានទៅគេចូលនៅហ្នឹង ហើយបានគេរៀងមកនេះ ឡានពួកតាម៉ុក ។

ដានី: ហើយកាលហ្នឹងស្ថានភាពនៅហ្នឹងយ៉ាងម៉េចដែរ? នៅខាងប្រាសាទព្រះវិហារ មានកងទ័ព ដូចឥឡូវ?

គឹម ចុង: អត់មាននៅលើហ្នឹងទេ នៅក្រោមៗទេ ។

ដានី: មានក្រោម?

គឹម ចុង: បាទ!

ដានី: កងទ័ពណាខ្លះនៅខាងក្រោម?

គឹម ចុង: កងទ័ពខ្ញុំអត់ដឹងច្បាស់ទេកាលហ្នឹងនោះ ពីព្រោះខ្ញុំនៅក្បាលទន្សោង កន្លែងមួយដែលនៅខាងលើ ក្រោមៗខ្ញុំអត់សូវបានចុះមកទេ ហើយក្រោយពីមានព្រឹត្តិការណ៍គេចាប់តាម៉ុក ចាប់ប៉ុល ពត ទៅជាកំលាំងមិនដឹងថាអ្នកណាជាអ្នកណា អ្នកណានៅខាងតា អ្នកណានៅខាងមិនតា ទើបក្រោយមកមានគេគេចខ្លួន ដូចជា ជា កែវ, អ៊ីង លាង គាត់ទៅចូលជាមួយរាជរដ្ឋាភិបាលនៅគូលែន តាំងពីហ្នឹងមកចាប់ផ្តើមរស្គោះរស្គើហើយតំបន់អន្លង់វែង ហើយអ្នកមានអំណាចដូចជា ហែម ង៉ុន, តេម, ញ៉ន, នួន នៅ ពួកក្រុមគាត់ហ្នឹងហើយ ពួកខ្ញុំឃើញគាត់ដូចខ្លាអ៊ីចឹង ខ្លាចតែម្តង និយាយរួមលែងហ៊ានមើលមុខគេដល់រាល់ថ្ងៃ គេនៅជាភូមិភាគមកជួបខ្ញុំ ជួនខ្ញុំអត់សួរទេ ខ្ញុំអត់ហ៊ាននិយាយ ។ មានអ្នកខ្លះគេនិយាយទៅ សួរខ្ញុំទៅខ្ញុំនិយាយធម្មតា ខ្ញុំថាអ៊ីចឹងឯងអត់ខឹងខ្ញុំទេ ខ្ញុំថាហួសពេលហើយ រាល់ថ្ងៃយើងនៅជ្រកក្រោមរដ្ឋធម្មនុញ្ញរបស់រដ្ឋមួយ អ៊ីចឹងរឿងគំនុំគំគួនមិនអាចដំណើរការទៅ

បានទេ ឥឡូវធ្វើម៉េចឲ្យតែមានស្រូវស៊ី កូនបានរៀន មានឱកាសទៅលេងផ្ទះ មានឱកាសរកស៊ី រកលុយសំរាប់ក្រុមគ្រួសារបានហើយ រឿងអីៗផ្សេងមានគេអ្នកធ្វើហើយ សុំបញ្ចប់ ។

ដានី: តែកាលពូដើរតាមជើងប្រាសាទ ភូមិត-១ កាលហ្នឹងមានទាហានថៃក្បែរហ្នឹងដែរ?

គឹមថុង: អត់មានទេ ។

ដានី: ចុះទាហានខ្មែរក្រហមកាលហ្នឹងឈរម្តុំណាទៅ?

គឹមថុង: នៅក្រោមទេ អត់មានទេ មាននៅសាំតែ ខាងកើតប្រាសាទ គេហៅដាំតែហ្នឹង នៅដាំតែហ្នឹងមាន ។

ដានី: ដាំតែហ្នឹងទាហានខ្មែរក្រហមនៅហ្នឹង?

គឹមថុង: មានហ៊ុនស៊ីប៉ិចនៅហ្នឹង មានលោកហុនៗ បន្ទាយនៅខាងកើតនេះបន្តិច ។

ដានី: ឈ្មោះអីគេ?

គឹមថុង: ឈ្មោះហុន គេហៅខ្វាញ ហ្នឹងហើយពួកលោកហុន ហ្នឹងដែលក្រោយពីពួកខ្ញុំទៅនៅជំរំដែលរ៉ៃជាមួយរាជរដ្ឋាភិបាលចុងក្រោយនៅអន្លង់វែង យក៣៧ទៅបាញ់ ពួកលោកហុនហ្នឹងឯង ដែលនិយាយម៉ិញ និយាយបន្សុីគ្នាជាមួយហ៊ុនស៊ីប៉ិច ។ កាលហ្នឹងយន្តហោះរាជរដ្ឋាភិបាលមកចុះនៅកន្លែងកាស៊ីណូរាល់ថ្ងៃហ្នឹង ។

ដានី: កាស៊ីណូ?

គឹមថុង: កាស៊ីណូដាំស្រង៉ែរាល់ថ្ងៃហ្នឹង ។

ដានី: តែកាលពីមុនមក កាលជំនាន់កោដាង កាលហ្នឹងផ្ទះក្រហមមានអីចឹងដែរ?

គឹមថុង: អត់មានទេ ។

ដានី: អត់មានផ្ទះក្រហមទេ?

គឹមថុង: អត់មាន ខ្ញុំឡើងទៅដល់ជំបូងខ្ញុំដើរ ខ្ញុំឡើងម៉ោង១១ ម៉ោង៤បានខ្ញុំឡើងដល់ ខ្ញុំទៅជាគ្រួសារតែម្តងទៅជាមួយកូនខ្ញុំ ឡើងទៅកប៉ាល់ទម្លាក់ធ្លាក់នៅប្រាសាទទី១ ហ្នឹងដូចជាខាងត្រពាំងប្រាសាទចូលជាមួយរាជរដ្ឋាភិបាលអស់ហើយ សមាហរណកម្ម ហើយខ្ញុំទៅលេងនៅហ្នឹងគេទើបតែចាប់ផ្តើមត្រួសត្រាយផ្លូវអត់ធំទៅស្រអែម ទៅប្រាសាទព្រះវិហារអត់ទាន់ទេ ទៅតាមផ្លូវរទេះ ផ្លូវខ្មែរក្រហមជីកគ្រាប់ទៅប្រាសាទព្រះវិហារមុនទៅតាមហ្នឹង ហើយខ្ញុំទៅលេងដេកមួយយប់ ព្រឹកឡើងបានខ្ញុំមកវិញ ដើរថ្មើរជើងតែម្តង ម៉ោង១១ឡើងទៅ ម៉ោង៤បានដល់ ។

ដានី: ឆ្នាំណាដែលឡើងទៅ?

គឹម ចុង៖ ខ្ញុំទៅដូចជា៩៩ ហើយផ្លូវខ្មៅមួយពីផ្ទះក្រហមហ្នឹងអត់ទាន់មានទេ ។

ដា នី៖ អត់ទាន់មាន ចុះកាលហ្នឹងកងទ័ពខាងខ្មែរក្រហមមានទៅឈរជើងក្បែរៗ ?

គឹម ចុង៖ អត់ទេ មានតែកងទ័ពរបស់រដ្ឋកម្ពុជាហ្នឹងហើយ ។

ដា នី៖ នៅម្តុំណា ?

គឹម ចុង៖ នៅលើប្រាសាទហ្នឹង ត្រង់ស្រះទឹកគេហៅប្រាសាទទី២ហ្នឹង កន្លែងជំរំគេនៅត្រង់ហ្នឹង ហើយមួយកន្លែងទៀតវត្តកែវសុក្កាគិរីស្វារហ្នឹង ខ្ញុំឡើងទៅចំហ្នឹង ។

ដា នី៖ តែខាងថៃអត់ឃើញមានទេ ?

គឹម ចុង៖ អត់មានឃើញទេ តែឃើញតូបលក់ឥវ៉ាន់នៅហ្នឹងពេលខ្ញុំទៅដល់ ឃើញនៅហ្នឹង ។

ដា នី៖ នៅកន្លែងណា ?

គឹម ចុង៖ នៅលើប្រាសាទហ្នឹង ហើយកាលហ្នឹងដូចជា ជា សុផារ៉ា គាត់ទៅគ្រប់គ្រងមួយជំនាន់ហ្នឹងខ្ញុំឃើញទិញអូសខ្សែភ្លើងឡើងទៅប្រាសាទ មានអំពូលភ្លើង តែខ្ញុំទៅអត់មានភ្លើងទេ ខ្ញុំទៅងងឹតឈឹង ។

ដា នី៖ កាលជំនាន់ហ្នឹងកងពលណាខ្លះដែលឈរជើងម្តុំប្រាសាទព្រះវិហារ ?

គឹម ចុង៖ ហ្នឹងទាល់តែសួរផ្ទះនេះមួយ គាត់អភិបាលរងចាស់គាត់ចូលនិវត្តន៍ហើយ ។

ដា នី៖ គាត់ឈ្មោះអីទៅ ?

គឹម ចុង៖ សៅ ថាន ។ គាត់អ្នកដឹងកងណាៗនៅប្រាសាទព្រះវិហារ អាកាំភ្លើង៨៥មួយដើមដែលនៅប្រាសាទហ្នឹង គាត់ហ្នឹងហើយអ្នកដឹងរឿងរ៉ាវ ។

ដា នី៖ គាត់ឈ្មោះ សៅ ថាន អតីត ?

គឹម ចុង៖ អតីតមន្ត្រីទើបតែចូលនិវត្តន៍១-២ឆ្នាំ ។

ដា នី៖ រង នៅជិតផ្ទះ ?

គឹម ចុង៖ នេះផ្ទះគាត់ធំ ហើយមួយទៀតសួរ វណ្ណ កុសល អភិបាលស្រុកចាស់ ។ វណ្ណ កុសល អភិបាលស្រុកចាស់ទើបតែចូលនិវត្តន៍ឆ្នាំហ្នឹង ។

ដា នី៖ គាត់ខាងអីដែលកាលមុន ?

គឹម ចុង៖ គាត់នៅកងពលដែល ក្រោយមកគាត់ជាអភិបាលស្រុកត្រពាំងប្រាសាទពីឆ្នាំ២០០៥-២០១២ គាត់ចូលនិវត្តន៍ ហើយម្តុំប្រាសាទព្រះវិហារកងណាៗនៅម្តុំហ្នឹងគាត់ដឹងខ្ទិចទាំងអស់ ខ្ញុំដឹងក្រោយទេ ពីព្រោះខ្ញុំតាំងពីឡើងដល់ភ្នំដងរែកខ្ញុំទៅនៅនោះ កន្លែងហ្នឹង ។

ដា នី៖ សៅ ថាន ហ្នឹងគាត់កងពលដែរ ?

គឹម ចុង៖ នៅជាមួយបងសយ ។

ដានី៖ នៅកន្លែងពលជាមួយតាហឿន?

គីមធុន៖ បាទ! ជាមួយតាហឿន។

បូលី៖ ត្រូវប្រមូលស្រូវ ខូចស្រូវ?

គីមធុន៖ មានកៅស៊ូមួយដុំគ្រប់។

ដានី៖ អំពេលអ៊ុនគាត់ដំបូងដែលយើងកិច្ចព្រមព្រៀងហើយ យើងមានតំណាងភាគីមួយៗទៅធ្វើការជាមួយអ៊ុនគាត់។ មានភាគីខាងកម្ពុជាប្រជាធិបតេយ្យ ខាងរដ្ឋកម្ពុជា ខាងលោកតាស៊ើន សាន, ហ៊ុនស៊ីប៉ិចចូលទៅទាំងអស់។ កាលហ្នឹងអ្នកឯកភាពជ្រើសរើសតំណាងខាងកម្ពុជាប្រជាធិបតេយ្យចូលទៅធ្វើការជាមួយអ៊ុនគាត់ អ្នកណាជាអ្នកជ្រើសរើសឲ្យទៅ? ហើយជ្រើសរើសប៉ុន្មានទៅទៅធ្វើការជាមួយអ៊ុនគាត់?

គីមធុន៖ ការពិតមានការប្រជុំគ្នាគាត់ចាស់ៗហ្នឹង ជាមួយខៀវ សំផន, នួន ជា, សុន សេន, ប៉ុល ពត រើសចេញពីពួកខ្ញុំ រើសចេញពីក្រុមនៅក-១៨ហ្នឹង រើសចេញទៅនៅផ្ទាល់ៗហ្នឹង។ ខ្ញុំការពិតនៅអ៊ុនគាត់ខ្ញុំនៅលើវ៉ូ២ ហើយនួន មនោ គាត់នៅលើវ៉ូ១ ហើយនៅជាមួយ ទេព ខុនណាល់ហ្នឹង។ លើវ៉ូ២គឺក្រុមការងារដែលចុះគ្រប់កន្លែងដែលភាគីមួយៗនៅ។ ក្រោយពីមានការវ៉ៃគ្នាបែកក្បាលខៀវ សំផន ទៅប៉ុល ពត លែងជឿ។ ប៉ុល ពត អត់ជឿទេ គាត់ថាការអនុវត្តន៍កិច្ចព្រមព្រៀងប៉ារីសជាល្បែងមួយ សំរាប់ចាប់កម្ពុជាប្រជាធិបតេយ្យ គាត់កំណត់អីចឹង។

ដានី៖ គាត់ថាអីចឹងតែម្តង?

គីមធុន៖ បាទ! ថាអីចឹង។ ហើយគាត់ថានេះជាសំដីរបស់គាត់ គាត់ថាអ៊ុនគាត់មកកម្ពុជាមិនមែនមករកសន្តិភាពនៅ កម្ពុជាទេ គេមកកំចាត់កម្ពុជាប្រជាធិបតេយ្យ។

ដានី៖ កាលហ្នឹងប៉ុន្មាននាក់ទៅតាមអីចាំ?

គីមធុន៖ បាទ?

ដានី៖ តំណាងកម្ពុជាប្រជាធិបតេយ្យដែលអ្នកមេៗ?

គីមធុន៖ នៅភ្នំពេញមាន ម៉ាក់ ប៊េន នៅភ្នំពេញ។ ខ្ញុំនៅប៉ៃលិនមានតែខ្ញុំមួយទេ ហើយក្រៅពីហ្នឹងដូចយឹម ដាន់ណា នៅសៀមរាបទេ ហើយមានមន្ត្រីនៅសមរភូមិតាមជួរព្រំដែនយកទៅ។ ដូចព្រឹកម៉ិញក្រុមប្រឹក្សាស្រុកមួយនៅខាងរតនគិរី គាត់នៅទីតាំងអូរយ៉ាដាវកាលនៅអ៊ុនគាត់គាត់ប្រចាំនៅហ្នឹង មានអីរាយការណ៍មកតាមរយៈខ្ញុំនៅប៉ៃលិន។

ដានី៖ ដល់ពេលភាគីកម្ពុជាប្រជាធិបតេយ្យធ្វើពលិកាមិនចូលរួមបោះឆ្នោត ពេលហ្នឹងយើងដកកំលាំងចេញពី។

គឹម ថុង៖ ដកអស់ហើយ ។

ដានី៖ ឆ្នាំណាដែលដកចេញ?

គឹម ថុង៖ ក្រោយបោះឆ្នោត ។

ដានី៖ ក្រោយបោះឆ្នោតបានដកចេញ?

គឹម ថុង៖ បាទ! ដកចេញអស់តែម្តង ។

ដានី៖ តែធ្វើពលិការវាមានមុនបោះឆ្នោត?

គឹម ថុង៖ បាទ! មុន ហើយកំលាំងដែលមកបណ្តើរៗគឺដកចេញអស់ហើយ ។

បូលី៖ កាលហ្នឹងតាខៀវ សំផន ហើយនិងតាសុន សេន គាត់ទៅភ្នំពេញបានតែប៉ុន្មានម៉ោង អត់ទាន់បានសំរាកមួយយប់ផង?

គឹម ថុង៖ ខៀវ សំផន អត់ទាន់បានសំរាក តែបើសុន សេន ទៅមុនៗ ខៀវ សំផន ទៅក្រោយ ទៅថ្ងៃគេបាតុកម្ម ថ្ងៃហ្នឹងខ្ញុំនៅកន្លែងក-១៨ ក្មេងៗទូរលេខមកព្រលឹមឡើងសួរ ថាពួសារថ្ងៃនេះប្រហែលជា១ម៉ឺន ខ្ញុំថាបកបណ្តើរទៅ ពីព្រោះរៀបចំឲ្យខ្ញុំនាំកំលាំងទៅក្រោយ ហើយខ្ញុំថាឥឡូវទទួលបណ្តើរ បកបណ្តើរទៅ មួយសន្ទុះមកប្រាប់ខ្ញុំថាបាតុកម្មពួមួយសន្ទុះទៀតដាច់ទាក់ទង ដល់ដាច់ទាក់ទងអីចឹងបានខ្ញុំថាឥឡូវខំវិម៉ក ជាភាសាខ្មែរក្នុងសារទូរលេខ ហើយអ្នកភ្នំពេញមកថាវិម៉កថាចូលដល់ផ្ទះយើងហើយ បាតុករចូលដល់ផ្ទះយើងហើយដាច់តាំងពីហ្នឹងមក វាលឺគេអូទៅតំឡើងនៅលើផ្ទះហើយវិម៉កខ្មែរមកថាបាតុករចូលដល់ផ្ទះយើងហើយ ។ បានម៉ោង៥កន្ទះខ្ញុំបើកវិទ្យុប៉េកាំងស្តាប់ថាខៀវ សំផន បែកក្បាល ខ្ញុំអត់អស់ចិត្តខ្ញុំទៅទូរទស្សន៍ថៃ ថៃនៅប្រចាំនៅក-១៨ ប្រហែលម៉ោង ១១-១២ ឃើញចូលដល់កន្លែងហ្នឹង ។

ដានី៖ យើងដឹងថារង្គោះរង្គើនៅពេលដែលមានគំនិតថ្មី មានការចង់ផ្លាស់ប្តូរមេដឹកនាំ ចង់ឲ្យមេដឹកនាំក្មេងៗជំនួសចាស់ៗ អីចឹងគំនិតដែលប្រជុំប្រុងមានទំនាស់គ្នា មុនពេលរៀបចំអាហ្នឹង?

គឹម ថុង៖ រៀបចំថាមានអ្នកតំណាងអ្នកដឹកនាំក្រោយ ប្រហែលជាអ្នកខ្លះធ្លាប់នៅជាមួយតាម៉ុក ថាគេមិនទុកចិត្តខ្លួនឯង មិនបានធ្វើអ្នកដឹកនាំនឹងគេ នេះខ្ញុំមើលទេ អីចឹងមានការប្រណែនគ្នា ហើយទី២ ជួនកាលអាចមានអ្នកណាមួយឆ្លៀតឆ្លាលសំរាប់ការបែកបាក់ ។

ដានី៖ ព្រោះកាលហ្នឹងយើង អឹៗនៅជួបជុំគ្នា ។

គឹម ថុង៖ នៅក្បាលទន្សោង ។

ដានី៖ នៅជួបជុំគ្នាទាំងអស់ ហើយតាម៉ុក ដូចថាប្រជុំតាមខ្ញុំដឹងថាឯកភាពគ្នាទាំងអស់ ថាត្រូវជ្រើសរើសមេដឹកនាំថ្មី ឬក៏មានតែតាម៉ុក មួយទេ?

គីមថុង៖ ពេលហ្នឹងខ្ញុំអត់ដែលបានចូលរួមក្នុងការប្រជុំរៀបចំ១៩៩ទេ ខ្ញុំកាលហ្នឹងជារដូវដែលខ្ញុំត្រូវទៅដាំស្រូវនៅក្រោម ហើយខ្ញុំអត់សូវចូលរួមប្រជុំទាក់ទងនឹងការរៀបចំការងារហ្នឹងទេ ដឹងប្រយោលទេ ដឹងដោយប្រយោលទេ តាមរយៈមិត្តភក្តិដែលនៅធ្វើការរួមជាមួយគ្នា គេរៀបចំដំណើរការចេះៗ ហើយមានអ្នកនេះៗជាតំណាងសំរាប់ដឹកនាំពេលក្រោយ ហើយដឹងស៊ីជំរៅខ្ញុំអត់ដឹងទេ ។

ដានី៖ ពេលក្រោយមកមានបញ្ហាដែលសុន សេន គាត់ស្លាប់ ហើយកាលហ្នឹងមានតា០៥ គាត់បើកឡានទៅផ្ទាល់ខ្លួនឯង ក្រោយមកតា០៥ គាត់មាននិយាយ ចេញមកបកស្រាយបញ្ហាហ្នឹងថាយ៉ាងម៉េចៗ?

គីមថុង៖ ដូចជាអត់ទាន់មានចេញមុខ ចេញមាត់អីជាអ្នកនាំអីធំដុំទេ តាមខ្ញុំមើលជំនាន់ហ្នឹង ដូចជាគ្រាន់តែចាប់ផ្តើមរើបឡើង វាដូចជាមិនសូវស៊ីសង្វាក់គ្នា ។

ដានី៖ ដូចថាខាងតាម៉ុក ពេលដែលតាសុន សេន ស្លាប់ទៅ គេចាប់ផ្តើមនេះខ្លាំងមែនទែន ។

គីមថុង៖ រឹខ្លាំង ។

ដានី៖ តែខាងតាប៉ុល ពត, តា០៥, តា០៦ ពេលហ្នឹងយើងចាប់ផ្តើមយ៉ាងម៉េច? ចាប់ផ្តើមជួបជុំគ្នា ។

គីមថុង៖ ដូចអត់មានអី មានគំនិតថារើបកដើម្បីយកតំបន់នេះ តំបន់នោះ ខ្ញុំឃើញដូចជាទៅទាំងព្រមតែម្តង រហូតដល់គេចាប់០៥, ០៦ បានទាំងអស់ទៅដូចចប់ អត់មានរឿងអី ទៅជារឿងអីផ្សេងពីហ្នឹងទៀត ទៅដូចជាពួកខ្ញុំរស់នៅដូចជាចំណាត់ខ្លាំង រស់នៅដូចជាអ្នកទោស ។

ដានី៖ ពីព្រោះបើយើងគិតមើលទៅ ដូចទ័ពខាងតា០៥, ០៦ ក៏កងទ័ពច្រើន ។

គីមថុង៖ នៅត្រពាំងប្រាសាទ ។

ដានី៖ ហើយមួយទៀតខ្ញុំលឺព័ត៌មានមក ធ្លាប់ជួបក្មួយខាងតាប៉ុល ពត មេឃុំនៅខាងត្រពាំងតាវ

គីមថុង៖ អាហា ។

ដានី៖ គាត់ថាពេលហ្នឹងដូចថាតាប៉ុល ពត គាត់អត់ចង់ឲ្យមានសង្គ្រាមរវាងក្រុមគាត់ ហើយនិងតាម៉ុក កើតឡើងទេ គាត់គិតថាគាត់អាចជួបនិយាយជាមួយតាម៉ុក ទាក់ទងបញ្ហាផ្សុំគំនិតគ្នា គាត់គិតថាគាត់អាចនិយាយជាមួយតាម៉ុក បាន ។ គាត់អាចផ្សះផ្សារឲ្យតាម៉ុក

យល់ស្របតាមគាត់ ។ គាត់អត់ចង់ឲ្យក្រុមទាំងពីរហ្នឹងវៃគ្នាទេ ធ្វើឲ្យកំលាំងឈានទៅរកបរាជ័យនៅថ្ងៃក្រោយ បញ្ហាហ្នឹងអីចឹងមែន ឬគ្រាន់តែនិយាយ?

គីមថុង: ការពិតតា គាត់ចាត់ទុកថាជាមនុស្សម្នាក់ដែលគេចាប់គាត់ ចាប់បង្ខំគាត់ឲ្យនិយាយតាមគេ វាអីចឹង ហើយវាស៊ីគ្នានឹងសំដីមេឃុំនៅត្រពាំងតាវនិយាយ ។ សំរាប់គាត់និងតាគាត់អត់មានបញ្ហាទេ តែមានអ្នកផ្សេង គេអត់ឲ្យតាទៅផ្សះផ្សារជាមួយប៉ុល ពត អីចឹង ធ្វើឲ្យពីរនាក់មានគំលាតគ្នា ។ សំដីរបស់មេឃុំហ្នឹងខ្ញុំយល់ស្របមុនហ្នឹង រហូតដល់តាក្រោយមកគាត់ថាអញចាញ់បោកគេ ចាញ់បោកក្មេងៗ ខ្ញុំខ្វល់ ។

បូលី: ចាញ់បោកយ៉ាងម៉េចទៅអ៊ំ?

គីមថុង: ចាញ់បោកក្មេងៗ ចង់និយាយថាតា មក មិនមែនគាត់មកចូលរដ្ឋាភិបាលទេ គេចាប់គាត់ឲ្យរដ្ឋាភិបាលហ្នឹង ត្រូវទេ?

បូលី: បាទ!

គីមថុង: អ្នកណាអ្នកចាប់គាត់? សំនួរហ្នឹងមួយសួរថាអ្នកណា អ្នកណាដឹងកន្លែងគាត់ ។ អូនឯងអត់ស្គាល់កន្លែងតានៅផង ទៅចាប់បានអត់ ។ មានតែខ្ញុំទេអ្នករត់បាយចេញ-ចូលព្រឹកល្ងាចសំរាប់តា ខ្ញុំហ្នឹងហើយអ្នកចាប់គាត់មក យកមកឲ្យ មិនអីចឹង? ត្រូវអីចឹងមែនអត់? ហ្នឹងហើយបានគាត់ថាអញចាញ់បោកក្មេងៗ?

ដានី: ហ្នឹងលឺតាមពីណាដែលគាត់និយាយអីចឹង?

គីមថុង: ខ្ញុំមកដល់ហ្នឹងហើយ ខ្ញុំចេញពីជំរំមកដល់ហ្នឹង ពួកក្រុមហ្នឹងហើយ ពួកអ្នកនៅត្រពាំងប្រាសាទ ហើយអូនឯងសួរអ្នកនៅត្រពាំងប្រាសាទហ្នឹងធ្លាយរឿងហ្នឹងច្រើនដាងនឹងដឹងរឿងហ្នឹងច្រើន ។

បូលី: តាមខ្ញុំសួរអ្នកនៅអន្លង់វែង គេថាតាម៉ុក សុខចិត្តចេញឲ្យគេចាប់តែម្តង ។

គីមថុង: បាទ?

បូលី: តាម៉ុក គាត់សុខចិត្តដើរចេញមកឲ្យគេចាប់ បើមិនអីចឹងទេគេធ្វើបាបកូនចៅគាត់ ។

គីមថុង: ការពិតមិនមែនអីចឹង ។

បូលី: អ្នកនៅអន្លង់វែងនិយាយអីចឹង ។

គីមថុង: អ្នកនៅអន្លង់វែង?

ដានី: បាទ!

គីមថុង: តែអូនឯងយកពាក្យហ្នឹងទៅសួរអ្នកនៅត្រពាំងប្រាសាទ សួរអ្នកមួយចំនួននៅត្រពាំងប្រាសាទចំលើយប្រហាក់ប្រហែលនឹងចំលើយខ្ញុំ ។ ខ្ញុំអត់សន្និដ្ឋានថាចំលើយខ្ញុំជាចំលើយ

ដែលត្រឹមត្រូវទេ តែយកទៅសំយោគជាមួយគ្នានឹងចំលើយអ្នកផ្សេងៗទៀតនៅតំបន់អន្លង់វែង ។

បូលីៈ អីចឹងបានន័យថាតា គាត់មិនចង់ឲ្យគេចាប់គាត់ទេ?

គីមថុងៈ បាទ!

បូលីៈ គាត់លាក់ខ្លួន?

គីមថុងៈ បាទ! គាត់លាក់ខ្លួន ហើយអ្នកណាជាអ្នកលាក់គាត់ ។ យើងគិតថាអ្នកណាជាអ្នកលាក់គាត់ មានតែអ្នកដែលនៅជាមួយគាត់ ហើយអ្នកហ្នឹងមកចូលជាមួយរាជរដ្ឋាភិបាល គាត់មានហេតុផលអីមិននាំតា មកចូល នេះជារឿងមួយដែលខ្ញុំពិចារណា ហើយសួរនៅស្រុកត្រពាំងប្រាសាទនឹងចេញរឿងនេះ នឹងដឹងរឿងនេះ ។ តែអ្នកខ្លះគេអត់និយាយ អ្នកខ្លះគេនិយាយ ឧបមាថាខ្ញុំជាអ្នកយកតា ទៅដាក់នៅកន្លែងនេះ ដូចខ្ញុំឧទាហរណ៍មិញថាអូនឯងដឹងកន្លែងតានៅអត់? ឧបមាថារាជរដ្ឋាភិបាល ទាហានរបស់រាជរដ្ឋាភិបាល ដឹងកន្លែងតាលាក់អត់ កន្លែងតានៅអត់? ហើយសួរព័ត៌មានដែលតាដើរចេញមកចូលជាមួយរាជរដ្ឋាភិបាល តាដឹងតាមរយៈណា បើគាត់នៅកន្លែងមួយដែលគាត់លាក់ខ្លួន នេះជារឿងមួយដែលយើងគួរពិចារណា ។ ព័ត៌មានដែលយើងគួរពិចារណា ថាគាត់នៅកន្លែងមួយដែលគេលាក់ ហេតុអីបានគាត់ដឹងព័ត៌មានពីហ្នឹងមក ដឹងព័ត៌មានរវាងគាត់និងរាជរដ្ឋាភិបាល ។ អីចឹងមានទុយយោមួយ ថាមានរចនាសម្ព័ន្ធសំរាប់ទំនាក់ទំនងគ្នា ទំនាក់ទំនងតាមវិធីណាវាជារឿងមួយទៀត ។

បូលីៈ ខឹម ង៉ុន គាត់នៅណាឥឡូវ?

គីមថុងៈ គាត់ស្លាប់ហើយ ជាប់គុកដែរ ។

បូលីៈ គ្រាន់ជាគិញរបស់សម្តេចហ៊ុនសែន?

គីមថុងៈ បាទ! ហ្នឹងហើយ គិញ០៩ ។

បូលីៈ ម៉េចបានទៅជាប់គុកវិញសមាហរណកម្មហើយ?

គីមថុងៈ ប្រហែលជាមានរឿងអីមួយទៀត ហេតុអីបានធ្វើអីចឹងទៅជាប់គុក ប្រហែលជាមានរឿងអីមួយទៀត ។

បូលីៈ គួរតែបានផលច្រើនជាងជាប់គុក ។

គីមថុងៈ បាទ! ហេតុអីបានជាប់គុក ។

បូលីៈ អីចឹងខ្ញុំគិតថាសុំអរគុណអ៊ំត្រឹមប៉ុណ្ណឹងចុះ ព្រោះបានច្រើន ។

គីមថុងៈ ខ្ញុំខាតពេលច្រើនដែរ ហើយភ្លៀងទឹកស្រូវអស់ហើយ ។

*បូលី៖* *អីចឹងអរគុណអ៊ំច្រើនមែនទែន ៗ*

**ចប់**